# ព្រះ

# ត្រៃបិដកបាលី

និង

សេចក្តីប្រែជាភាសាខ្មែរ

# សុត្តន្តបិដក

## អង្គុត្តរនិកាយ ឯក-ទុកនិបាត

បឋមភាគ

# ៤០

[illegible]

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ព.ស ២៥៤៦

[illegible]

[illegible]

このカンボジア版南伝大蔵経を
カンボジアの仏教徒へ
贈ることができることに感謝します。
これが日本の仏教徒の心です。

It is with a deep sense of gratitude that I present the translation of the complete TRIPITAKA to Cambodian Buddhists on behalf of the Japanese Buddhist community.

# អារម្ភកថា

[illegible]

[illegible]

[illegible]

[illegible]

[illegible]

[illegible]

[illegible] The Rev. Seikyo Mochaku

[illegible] The Rev. Eitsu Sonohara

[illegible]

The Rev. Zendo Matsunaga The Rev. Jitsujo Arima The Rev. Yoshimichi Ito
The Rev. Keiichi Watai The Rev. Gijun Sugitani The Rev. Shincho Shigeta
The Rev. Risho Maeda The Rev. Kyoshi Nakajima Mr. Rokusuke Ei

# សុត្តន្តបិដកេ

## អង្គុត្តរនិកាយស្ស ឯកកនិបាតោ

### បឋមោ ភាគោ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ឯកកនិបាតបាឡិ

(១) ឯវំមេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច ។

(២) នាហំ ភិក្ខវេ អញ្ញំ ឯករូបម្បិ សមនុបស្សាមិ យំ ឯវំ បុរិសស្ស ចិត្តំ បរិយាទាយ តិដ្ឋតិ យថយិទំ ភិក្ខវេ ឥត្ថីរូបំ ឥត្ថីរូបំ ភិក្ខវេ បុរិសស្ស ចិត្តំ បរិយាទាយ តិដ្ឋតីតិ ។

# សុត្តន្តបិដក

## អង្គុត្តរនិកាយ ឯកនិបាត

### បឋមភាគ

សូមនមស្ការ ព្រះដ៏មានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ។

បាលីសំដែងនូវធម៌តែមួយៗជាដើម

(១) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយ ក្នុងទីនោះថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកាព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា

(២) ម្នាលភិក្ខុទាំងឡាយ តថាគតពុំដែលឃើញរូបដទៃ សូម្បីតែមួយ ដែលគ្របសង្កត់ចិត្តបុរសហើយស្ថិតនៅ ដូចរូបស្ត្រីនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ រូបស្ត្រីតែងគ្របសង្កត់ចិត្តបុរស ហើយស្ថិតនៅ ។

(៣) នាហំ ភិក្ខវេ អញ្ញំ ឯកសទ្ទំបិ សមនុបស្សាមិ យំ ឯវំ បុរិសស្ស ចិត្តំ បរិយាទាយ តិដ្ឋតិ យថយិទំ ភិក្ខវេ ឥត្ថិសទ្ទោ ឥត្ថិសទ្ទោ ភិក្ខវេ បុរិសស្ស ចិត្តំ បរិយាទាយ តិដ្ឋតីតិ ។

(៤) នាហំ ភិក្ខវេ អញ្ញំ ឯកគន្ធំបិ សមនុបស្សាមិ យំ ឯវំ បុរិសស្ស ចិត្តំ បរិយាទាយ តិដ្ឋតិ យថយិទំ ភិក្ខវេ ឥត្ថិគន្ធោ ឥត្ថិគន្ធោ ភិក្ខវេ បុរិសស្ស ចិត្តំ បរិយាទាយ តិដ្ឋតីតិ ។

(៥) នាហំ ភិក្ខវេ អញ្ញំ ឯករសំបិ សមនុបស្សាមិ យំ ឯវំ បុរិសស្ស ចិត្តំ បរិយាទាយ តិដ្ឋតិ យថយិទំ ភិក្ខវេ ឥត្ថិរសោ ឥត្ថិរសោ ភិក្ខវេ បុរិសស្ស ចិត្តំ បរិយាទាយ តិដ្ឋតីតិ ។

(៦) នាហំ ភិក្ខវេ អញ្ញំ ឯកផោដ្ឋព្វំបិ សមនុបស្សាមិ យំ ឯវំ បុរិសស្ស ចិត្តំ បរិយាទាយ តិដ្ឋតិ យថយិទំ ភិក្ខវេ ឥត្ថិផោដ្ឋព្វោ ឥត្ថិផោដ្ឋព្វោ ភិក្ខវេ បុរិសស្ស ចិត្តំ បរិយាទាយ តិដ្ឋតីតិ ។



(៣) ម្នាលភិក្ខុទាំងឡាយ តថាគតពិនិត្យមិនឃើញសំឡេងដទៃ សូម្បីតែសំឡេង ១ ដែលគ្របសង្កត់ចិត្តបុរស ហើយស្ថិតនៅ ដូចសំឡេងស្ត្រីនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ សំឡេងស្ត្រីរមែងគ្របសង្កត់ចិត្តបុរសហើយស្ថិតនៅ ។

(៤) ម្នាលភិក្ខុទាំងឡាយ តថាគតពិនិត្យមិនឃើញក្លិនដទៃ សូម្បីតែក្លិន ១ ដែលគ្របសង្កត់ចិត្តបុរស ហើយស្ថិតនៅ ដូចក្លិនស្ត្រីនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ ក្លិនស្ត្រីរមែងគ្របសង្កត់ចិត្តបុរស ហើយស្ថិតនៅ ។

(៥) ម្នាលភិក្ខុទាំងឡាយ តថាគតពិនិត្យមិនឃើញរសដទៃ សូម្បីតែរស ១ ដែលគ្របសង្កត់ចិត្តបុរស ហើយស្ថិតនៅ ដូចរសស្ត្រីនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ រសស្ត្រីរមែងគ្របសង្កត់ចិត្តបុរស ហើយស្ថិតនៅ ។

(៦) ម្នាលភិក្ខុទាំងឡាយ តថាគតពិនិត្យមិនឃើញផ្សព្វដទៃ សូម្បីតែផ្សព្វ ១ ដែលគ្របសង្កត់ចិត្តបុរសហើយស្ថិតនៅ ដូចផ្សព្វស្ត្រីនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ ផ្សព្វស្ត្រីរមែងគ្របសង្កត់ចិត្តបុរសហើយស្ថិតនៅ ។

ឧប្បជ្ជតិ ឧប្បន្នោ វា កាមច្ឆន្ទោ ភិយ្យោភាវាយ វេបុល្លាយ សំវត្តតិ យថយិទំ ភិក្ខវេ សុភនិមិត្តំ សុភនិមិត្តំ ភិក្ខវេ អយោនិសោ មនសិករោតោ អនុប្បន្នោ ចេវ កាមច្ឆន្ទោ ឧប្បជ្ជតិ ឧប្បន្នោ ច កាមច្ឆន្ទោ ភិយ្យោភាវាយ វេបុល្លាយ សំវត្តតីតិ ។

(១៦) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យេន អនុប្បន្នំ វា ថីនមិទ្ធំ ឧប្បជ្ជតិ ឧប្បន្នំ វា ថីនមិទ្ធំ ភិយ្យោភាវាយ វេបុល្លាយ សំវត្តតិ យថយិទំ ភិក្ខវេ អរតិ តន្ទិ វិជម្ភិកា (១) ភត្តសម្មទោ ចេតសោ ច លីនត្តំ លីនចិត្តស្ស ភិក្ខវេ អនុប្បន្នញ្ចេវ ថីនមិទ្ធំ ឧប្បជ្ជតិ ឧប្បន្នញ្ច ថីនមិទ្ធំ ភិយ្យោភាវាយ វេបុល្លាយ សំវត្តតីតិ ។

(១៧) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យេន អនុប្បន្នំ វា ឧទ្ធច្ចកុក្កុច្ចំ

* ម. វិជម្ភិតា ។



ឲ្យកើតឡើងផងក្តី កាមច្ឆន្ទៈដែលកើតឡើងហើយ ឲ្យប្រព្រឹត្តទៅ ដើម្បីសេចក្តីចំរើនជាភិយ្យោភាពក្តី ដូចសុភនិមិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលធ្វើទុកក្នុងចិត្តនូវសុភនិមិត្តដោយឧបាយខុស កាមច្ឆន្ទៈដែលមិនទាន់កើតឡើង ក៏កើតឡើងបានផង កាមច្ឆន្ទៈដែលកើតឡើងហើយ ក៏ប្រព្រឹត្តទៅ ដើម្បីសេចក្តីចំរើនឡើងជាភិយ្យោភាពផង ។

(១៦) ម្នាលភិក្ខុទាំងឡាយ តថាគតពិនិត្យមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលនាំថីនមិទ្ធៈមិនទាន់កើតឡើង ឲ្យកើតឡើងផងក្តី ថីនមិទ្ធៈដែលកើតឡើងហើយ ឲ្យប្រព្រឹត្តទៅ ដើម្បីសេចក្តីចំរើនឡើងជាភិយ្យោភាពក្តី ដូចសេចក្តីអផ្សុក សេចក្តីខ្ជិល ការបិតពត់កាយ សេចក្តីស្រវឹងដោយភត្ត ភាពនៃចិត្តទ្រេតទ្រោតនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលមានចិត្តទ្រេតទ្រោត ថីនមិទ្ធៈ ដែលមិនទាន់កើតឡើង ក៏កើតឡើងបានផង ថីនមិទ្ធៈដែលកើតឡើងហើយ ក៏ប្រព្រឹត្តទៅ ដើម្បីសេចក្តីចំរើនឡើងជាភិយ្យោភាពផង ។

(១៧) ម្នាលភិក្ខុទាំងឡាយ តថាគតពិនិត្យមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលនាំឧទ្ធច្ចកុក្កុច្ចៈមិនទាន់កើតឡើង

ឧប្បជ្ជតិ ឧប្បន្នញ្ច ឧទ្ធច្ចកុក្កុច្ចំ ភិយ្យោភាវាយ វេបុល្លាយ សំវត្តតិ យថយិទំ ភិក្ខវេ ចេតសោ អវូបសមោ អវូបសន្តចិត្តស្ស ភិក្ខវេ អនុប្បន្នញ្ចេវ ឧទ្ធច្ចកុក្កុច្ចំ ឧប្បជ្ជតិ ឧប្បន្នញ្ច ឧទ្ធច្ចកុក្កុច្ចំ ភិយ្យោភាវាយ វេបុល្លាយ សំវត្តតីតិ ។

(១៦) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យេន អនុប្បន្នា វា វិចិកិច្ឆា ឧប្បជ្ជតិ ឧប្បន្នា វា វិចិកិច្ឆា ភិយ្យោភាវាយ វេបុល្លាយ សំវត្តតិ យថយិទំ ភិក្ខវេ អយោនិសោ មនសិការោ អយោនិសោ ភិក្ខវេ មនសិករោតោ អនុប្បន្នា ចេវ វិចិកិច្ឆា ឧប្បជ្ជតិ ឧប្បន្នា ច វិចិកិច្ឆា ភិយ្យោភាវាយ វេបុល្លាយ សំវត្តតីតិ ។

(១៧) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យេន អនុប្បន្នោ វា កាមច្ឆន្ទោ



ឲ្យកើតឡើងបានក្តី ឧទ្ធច្ចកុក្កុច្ចៈដែលកើតឡើងហើយ ឲ្យប្រព្រឹត្តទៅ ដើម្បីសេចក្តីចំរើនឡើងជាភិយ្យោភាពក្តី ដូចចិត្តមិនស្ងប់នេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលមានចិត្តមិនស្ងប់ ឧទ្ធច្ចកុក្កុច្ចៈដែលមិនទាន់កើតឡើង ក៏កើតឡើងបានផង ឧទ្ធច្ចកុក្កុច្ចៈដែលកើតឡើងហើយ ក៏ប្រព្រឹត្តទៅ ដើម្បីសេចក្តីចំរើនឡើងជាភិយ្យោភាពផង ។

(១៦) ម្នាលភិក្ខុទាំងឡាយ តថាគតពិនិត្យមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ១ ដែលនាំនូវវិចិកិច្ឆាមិនទាន់កើតឡើង ឲ្យកើតឡើងបានក្តី វិចិកិច្ឆាដែលកើតឡើងហើយ ឲ្យប្រព្រឹត្តទៅ ដើម្បីសេចក្តីចំរើនឡើងជាភិយ្យោភាពក្តី ដូចការធ្វើទុកក្នុងចិត្តដោយឧបាយខុសនុ៎ះសោះឡើយ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលធ្វើទុកក្នុងចិត្តដោយឧបាយខុស វិចិកិច្ឆាដែលមិនទាន់កើតឡើង ក៏កើតឡើងបានផង វិចិកិច្ឆាដែលកើតឡើងហើយ ក៏ប្រព្រឹត្តទៅ ដើម្បីសេចក្តីចំរើនឡើងជាភិយ្យោភាពផង ។

(១៧) ម្នាលភិក្ខុទាំងឡាយ តថាគតពិនិត្យមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលនាំនូវកាមច្ឆន្ទៈមិនទាន់កើតឡើង

នុប្បជ្ជតិ ឧប្បន្នោ វា កាមច្ឆន្ទោ បហីយតិ យថយិទំ ភិក្ខវេ អសុភនិមិត្តំ អសុភនិមិត្តំ ភិក្ខវេ យោនិសោ មនសិការោតោ អនុប្បន្នោ ចេវ កាមច្ឆន្ទោ នុប្បជ្ជតិ ឧប្បន្នោ ច កាមច្ឆន្ទោ បហីយតីតិ ។

(១៧) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យេន អនុប្បន្នោ វា ព្យាបាទោ នុប្បជ្ជតិ ឧប្បន្នោ វា ព្យាបាទោ បហីយតិ យថយិទំ ភិក្ខវេ មេត្តា ចេតោវិមុត្តិ មេត្តំ ភិក្ខវេ ចេតោវិមុត្តិំ យោនិសោ មនសិការោតោ អនុប្បន្នោ ចេវ ព្យាបាទោ នុប្បជ្ជតិ ឧប្បន្នោ ច ព្យាបាទោ បហីយតីតិ ។

(១៨) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យេន អនុប្បន្នំ វា ថីនមិទ្ធំ នុប្បជ្ជតិ ឧប្បន្នំ វា ថីនមិទ្ធំ បហីយតិ យថយិទំ ភិក្ខវេ អារម្ភធាតុ និក្កមធាតុ បរក្កមធាតុ អារទ្ធវីរិយស្ស ភិក្ខវេ អនុប្បន្នញ្ចេវ ថីនមិទ្ធំ នុប្បជ្ជតិ ឧប្បន្នញ្ច ថីនមិទ្ធំ បហីយតីតិ ។



មិនឲ្យកើតឡើងបានខ្លះ កាមច្ឆន្ទៈដែលកើតឡើងហើយ ក៏ឲ្យសាបសូន្យទៅក្តី ដូចអសុភនិមិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលធ្វើទុកក្នុងចិត្តនូវអសុភនិមិត្តដោយឧបាយប្រាជ្ញ កាមច្ឆន្ទៈដែលមិនទាន់កើតឡើង ក៏មិនកើតឡើងផង កាមច្ឆន្ទៈដែលកើតឡើងហើយ ក៏សាបសូន្យទៅផង ។

(១៧) ម្នាលភិក្ខុទាំងឡាយ តថាគតមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ១ ដែលញុំាងព្យាបាទមិនទាន់កើតឡើង មិនឲ្យកើតឡើងបានខ្លះ ព្យាបាទដែលកើតឡើងហើយ ឲ្យសាបសូន្យទៅក្តី ដូចមេត្តាចេតោវិមុត្តិនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលធ្វើទុកក្នុងចិត្តនូវមេត្តាចេតោវិមុត្តិដោយឧបាយប្រាជ្ញ ព្យាបាទដែលមិនទាន់កើតឡើង ក៏មិនកើតឡើងផង ព្យាបាទដែលកើតឡើងហើយក៏សាបសូន្យទៅផង ។

(១៨) ម្នាលភិក្ខុទាំងឡាយ តថាគតពុំឃើញសភាវៈដទៃ សូម្បីតែសភាវៈ១ ដែលញុំាងថីនមិទ្ធៈ មិនទាន់កើតឡើង មិនឲ្យកើតឡើងបានខ្លះ ថីនមិទ្ធៈដែលកើតឡើងហើយ ឲ្យសាបសូន្យទៅក្តី ដូចអារម្ភធាតុ និក្កមធាតុ បរក្កមធាតុនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលមានព្យាយាមប្រារព្ធហើយ ថីនមិទ្ធៈដែលមិនទាន់កើតឡើង ក៏មិនកើតឡើងផង ថីនមិទ្ធៈដែលកើតឡើងហើយក៏សាបសូន្យទៅផង ។

[៦០] នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យេន អនុប្បន្នំ វា ឧទ្ធច្ចកុក្កុច្ចំ នុប្បជ្ជតិ ឧប្បន្នំ វា ឧទ្ធច្ចកុក្កុច្ចំ បហីយតិ យថយិទំ ភិក្ខវេ ចេតសោ វូបសមោ វូបសន្តចិត្តស្ស ភិក្ខវេ អនុប្បន្នញ្ចេវ ឧទ្ធច្ចកុក្កុច្ចំ នុប្បជ្ជតិ ឧប្បន្នញ្ច ឧទ្ធច្ចកុក្កុច្ចំ បហីយតីតិ ។

[៦១] នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យេន អនុប្បន្នា វា វិចិកិច្ឆា នុប្បជ្ជតិ ឧប្បន្នា វា វិចិកិច្ឆា បហីយតិ យថយិទំ ភិក្ខវេ យោនិសោ មនសិការោ យោនិសោ ភិក្ខវេ មនសិករោតោ អនុប្បន្នា ចេវ វិចិកិច្ឆា នុប្បជ្ជតិ ឧប្បន្នា ច វិចិកិច្ឆា បហីយតីតិ ។

វគ្គោ(១) ទុតិយោ ។

[៦២] នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យំ ឯវំ អភាវិតំ អកម្មនិយំ(២) ហោតិ

១ ឱ. នីវរណប្បហានវគ្គោ ។ ២ អកម្មនិយន្តិ បាឋោ ។



[៦០] ម្នាលភិក្ខុទាំងឡាយ តថាគតរកពិនិត្យមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលនាំនូវឧទ្ធច្ចកុក្កុច្ចៈមិនទាន់កើតឡើង មិនឲ្យកើតឡើងផង នាំឧទ្ធច្ចកុក្កុច្ចៈដែលកើតឡើងហើយ ឲ្យសាបសូន្យទៅ ដូចចេតសោវូបសមៈ (ចិត្តស្ងប់) នេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលមានចិត្តស្ងប់ ឧទ្ធច្ចកុក្កុច្ចៈដែលមិនទាន់កើតឡើង ក៏មិនកើតឡើងផង ឧទ្ធច្ចកុក្កុច្ចៈដែលកើតឡើងហើយ ក៏សាបសូន្យទៅផង ។

[៦១] ម្នាលភិក្ខុទាំងឡាយ តថាគតរកពិនិត្យមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលនាំនូវវិចិកិច្ឆាមិនទាន់កើតឡើង មិនឲ្យកើតឡើងផង នាំវិចិកិច្ឆាដែលកើតឡើងហើយ ឲ្យសាបសូន្យទៅ ដូចការធ្វើទុកក្នុងចិត្តដោយឧបាយត្រូវនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលធ្វើទុកក្នុងចិត្តដោយឧបាយត្រូវ វិចិកិច្ឆាដែលមិនទាន់កើតឡើង ក៏មិនកើតឡើងផង វិចិកិច្ឆាដែលកើតឡើងហើយ ក៏សាបសូន្យទៅផង ។

ចប់វគ្គទី ២ ។

[៦២] ម្នាលភិក្ខុទាំងឡាយ តថាគតរកពិនិត្យមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលបុគ្គលមិនបានចំរើនហើយជាសភាវៈមិនគួរដល់ការងារ ( យកជាការមិនបាន ) ដូចចិត្តនេះសោះឡើយ

យថយិទំ ភិក្ខវេ ចិត្តំ ចិត្តំ ភិក្ខវេ អភាវិតំ អកម្មនិយំ ហោតីតិ ។

(៤៣) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មំបិ សមនុបស្សាមិ យំ ឯវំ ភាវិតំ កម្មនិយំ ហោតិ យថយិទំ ភិក្ខវេ ចិត្តំ ចិត្តំ ភិក្ខវេ ភាវិតំ កម្មនិយំ ហោតីតិ ។

(៤៤) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មំបិ សមនុបស្សាមិ យំ ឯវំ អភាវិតំ មហតោ អនត្ថាយ សំវត្តតិ យថយិទំ ភិក្ខវេ ចិត្តំ ចិត្តំ ភិក្ខវេ អភាវិតំ មហតោ អនត្ថាយ សំវត្តតីតិ ។

(៤៥) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មំបិ សមនុបស្សាមិ យំ ឯវំ ភាវិតំ មហតោ អត្ថាយ សំវត្តតិ យថយិទំ ភិក្ខវេ ចិត្តំ ចិត្តំ ភិក្ខវេ ភាវិតំ មហតោ អត្ថាយ សំវត្តតីតិ ។



ម្នាលភិក្ខុទាំងឡាយ ចិត្តដែលបុគ្គលមិនបានចំរើនហើយ ជាធម្មជាតមិនគួរដល់ការងារទេ ។

(៤៣) ម្នាលភិក្ខុទាំងឡាយ តថាគតរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលបុគ្គលចំរើនហើយ ទើបជាធម្មជាតគួរដល់ការងារ ដូចចិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ ចិត្តដែលបុគ្គលចំរើនហើយ ទើបជាធម្មជាតគួរដល់ការងារ ។

(៤៤) ម្នាលភិក្ខុទាំងឡាយ តថាគតរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលបុគ្គលមិនបានចំរើនហើយ តែងប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍ធំ ដូចចិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ ចិត្តដែលបុគ្គលមិនបានចំរើនហើយ តែងប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍ធំ ។

(៤៥) ម្នាលភិក្ខុទាំងឡាយ តថាគតរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលបុគ្គលបានចំរើនហើយ តែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ធំ ដូចចិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ ចិត្តដែលបុគ្គលបានចំរើនហើយ តែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ធំ ។

(២៦) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យំ ឯវំ អភាវិតំ អបាតុភូតំ មហតោ អនត្ថាយ សំវត្តតិ យថយិទំ ភិក្ខវេ ចិត្តំ ចិត្តំ ភិក្ខវេ អភាវិតំ អបាតុភូតំ មហតោ អនត្ថាយ សំវត្តតីតិ ។

(២៧) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យំ ឯវំ ភាវិតំ បាតុភូតំ មហតោ អត្ថាយ សំវត្តតិ យថយិទំ ភិក្ខវេ ចិត្តំ ចិត្តំ ភិក្ខវេ ភាវិតំ បាតុភូតំ មហតោ អត្ថាយ សំវត្តតីតិ ។

(២៨) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យំ ឯវំ អភាវិតំ អពហុលីកតំ មហតោ អនត្ថាយ សំវត្តតិ យថយិទំ ភិក្ខវេ ចិត្តំ ចិត្តំ ភិក្ខវេ អភាវិតំ អពហុលីកតំ មហតោ អនត្ថាយ សំវត្តតីតិ ។

(២៩) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យំ ឯវំ ភាវិតំ ពហុលីកតំ



(២៦) ម្នាលភិក្ខុទាំងឡាយ តថាគតរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលបុគ្គលមិនបានចំរើន មិនបានឲ្យកើតប្រាកដហើយ តែងប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍យ៉ាងធំ ដូចចិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ ចិត្តដែលបុគ្គលមិនបានចំរើន មិនបានឲ្យកើតប្រាកដហើយ តែងប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍យ៉ាងធំ ។

(២៧) ម្នាលភិក្ខុទាំងឡាយ តថាគតរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលបុគ្គលបានចំរើន បានឲ្យកើតប្រាកដហើយ តែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍យ៉ាងធំ ដូចចិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ ចិត្តដែលបុគ្គលបានចំរើន បានឲ្យកើតប្រាកដហើយ តែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍យ៉ាងធំ ។

(២៨) ម្នាលភិក្ខុទាំងឡាយ តថាគតរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលបុគ្គលមិនបានចំរើន មិនបានធ្វើឲ្យច្រើនហើយ តែងប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍យ៉ាងធំ ដូចចិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ ចិត្តដែលបុគ្គលមិនបានចំរើន មិនបានធ្វើឲ្យច្រើនហើយ តែងប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍យ៉ាងធំ ។

(២៩) ម្នាលភិក្ខុទាំងឡាយ តថាគតរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលបុគ្គលបានចំរើន បានធ្វើឲ្យច្រើនហើយ

មហតោ អត្ថាយ សំវត្តតិ យថយិទំ ភិក្ខវេ ចិត្តំ ចិត្តំ ភិក្ខវេ ភាវិតំ ពហុលីកតំ មហតោ អត្ថាយ សំវត្តតីតិ ។

(៣០) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យំ ឯវំ អភាវិតំ អពហុលីកតំ ទុក្ខាធិវហំ ហោតិ យថយិទំ ភិក្ខវេ ចិត្តំ ចិត្តំ ភិក្ខវេ អភាវិតំ អពហុលីកតំ ទុក្ខាធិវហំ ហោតីតិ ។

(៣១) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យំ ឯវំ ភាវិតំ ពហុលីកតំ សុខាធិវហំ ហោតិ យថយិទំ ភិក្ខវេ ចិត្តំ ចិត្តំ ភិក្ខវេ ភាវិតំ ពហុលីកតំ សុខាធិវហំ ហោតីតិ ។

វគ្គោ (១) តតិយោ ។

១ ឱ. អកម្មនីយវគ្គោ ។



តែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍យ៉ាងធំ ដូចចិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ ចិត្តដែលបុគ្គលបានអប់រំ បានធ្វើឲ្យច្រើនហើយ តែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍យ៉ាងធំ ។

(៣០) ម្នាលភិក្ខុទាំងឡាយ តថាគតមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលបុគ្គលមិនបានអប់រំ មិនបានធ្វើឲ្យច្រើនហើយ តែងនាំមកនូវសេចក្តីទុក្ខក្រៃពេក ដូចចិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ ចិត្តដែលបុគ្គលមិនបានអប់រំ មិនបានធ្វើឲ្យច្រើនហើយ តែងនាំមកនូវសេចក្តីទុក្ខក្រៃពេក ។

(៣១) ម្នាលភិក្ខុទាំងឡាយ តថាគតមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលបុគ្គលបានអប់រំ បានធ្វើឲ្យច្រើនហើយ តែងនាំមកនូវសេចក្តីសុខក្រៃពេក ដូចចិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ ចិត្តដែលបុគ្គលបានអប់រំ បានធ្វើឲ្យច្រើនហើយ តែងនាំមកនូវសេចក្តីសុខក្រៃពេក ។

ចប់ វគ្គទី ៣ ។

(៣២) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យំ ឯវំ អទន្តំ មហតោ អនត្ថាយ សំវត្តតិ យថយិទំ ភិក្ខវេ ចិត្តំ ចិត្តំ ភិក្ខវេ អទន្តំ មហតោ អនត្ថាយ សំវត្តតីតិ ។

(៣៣) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យំ ឯវំ ទន្តំ មហតោ អត្ថាយ សំវត្តតិ យថយិទំ ភិក្ខវេ ចិត្តំ ចិត្តំ ភិក្ខវេ ទន្តំ មហតោ អត្ថាយ សំវត្តតីតិ ។

(៣៤) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យំ ឯវំ អគុត្តំ មហតោ អនត្ថាយ សំវត្តតិ យថយិទំ ភិក្ខវេ ចិត្តំ ចិត្តំ ភិក្ខវេ អគុត្តំ មហតោ អនត្ថាយ សំវត្តតីតិ ។

(៣៥) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យំ ឯវំ គុត្តំ មហតោ អត្ថាយ សំវត្តតិ យថយិទំ ភិក្ខវេ ចិត្តំ ចិត្តំ ភិក្ខវេ គុត្តំ មហតោ អត្ថាយ សំវត្តតីតិ ។



(៣២) ម្នាលភិក្ខុទាំងឡាយ តថាគតពិនិត្យមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលបុគ្គលមិនបានទូន្មានហើយ តែងប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍យ៉ាងធំ ដូចចិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ ចិត្តដែលបុគ្គលមិនបានទូន្មានហើយ តែងប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍យ៉ាងធំ ។

(៣៣) ម្នាលភិក្ខុទាំងឡាយ តថាគតពិនិត្យមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលបុគ្គលទូន្មានហើយ តែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍យ៉ាងធំ ដូចចិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ ចិត្តដែលបុគ្គលទូន្មានហើយ តែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍យ៉ាងធំ ។

(៣៤) ម្នាលភិក្ខុទាំងឡាយ តថាគតពិនិត្យមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលបុគ្គលមិនបានគ្រប់គ្រងហើយ តែងប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍យ៉ាងធំ ដូចចិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ ចិត្តដែលបុគ្គលមិនបានគ្រប់គ្រងហើយ តែងប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍យ៉ាងធំ ។

(៣៥) ម្នាលភិក្ខុទាំងឡាយ តថាគតពិនិត្យមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលបុគ្គលបានគ្រប់គ្រងហើយ តែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍យ៉ាងធំ ដូចចិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ ចិត្តដែលបុគ្គលបានគ្រប់គ្រងហើយ តែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍យ៉ាងធំ ។

(៣៦) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មំបិ សមនុបស្សាមិ យំ ឯវំ អរក្ខិតំ មហតោ អនត្ថាយ សំវត្តតិ យថយិទំ ភិក្ខវេ ចិត្តំ ចិត្តំ ភិក្ខវេ អរក្ខិតំ មហតោ អនត្ថាយ សំវត្តតីតិ ។

(៣៧) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មំបិ សមនុបស្សាមិ យំ ឯវំ រក្ខិតំ មហតោ អត្ថាយ សំវត្តតិ យថយិទំ ភិក្ខវេ ចិត្តំ ចិត្តំ ភិក្ខវេ រក្ខិតំ មហតោ អត្ថាយ សំវត្តតីតិ ។

(៣៨) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មំបិ សមនុបស្សាមិ យំ ឯវំ អសំវុតំ មហតោ អនត្ថាយ សំវត្តតិ យថយិទំ ភិក្ខវេ ចិត្តំ ចិត្តំ ភិក្ខវេ អសំវុតំ មហតោ អនត្ថាយ សំវត្តតីតិ ។

(៣៩) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មំបិ សមនុបស្សាមិ យំ ឯវំ សំវុតំ មហតោ អត្ថាយ សំវត្តតិ យថយិទំ ភិក្ខវេ ចិត្តំ ចិត្តំ ភិក្ខវេ សំវុតំ មហតោ អត្ថាយ សំវត្តតីតិ ។





(៣៦) ម្នាលភិក្ខុទាំងឡាយ តថាគតរកពិនិត្យ មិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ១ ដែលបុគ្គលមិនបានរក្សាហើយ តែងប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍យ៉ាងធំ ដូចចិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ ចិត្តដែលបុគ្គលមិនបានរក្សាហើយ តែងប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍យ៉ាងធំ ។

(៣៧) ម្នាលភិក្ខុទាំងឡាយ តថាគតរកពិនិត្យមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ១ ដែលបុគ្គលបានរក្សាហើយ តែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍យ៉ាងធំ ដូចចិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ ចិត្តដែលបុគ្គលបានរក្សាហើយ តែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍យ៉ាងធំ ។

(៣៨) ម្នាលភិក្ខុទាំងឡាយ តថាគតរកពិនិត្យមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ១ ដែលបុគ្គលមិនបានសង្រួមហើយ តែងប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍យ៉ាងធំ ដូចចិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ ចិត្តដែលបុគ្គលមិនបានសង្រួមហើយ តែងប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍យ៉ាងធំ ។

(៣៩) ម្នាលភិក្ខុទាំងឡាយ តថាគតរកពិនិត្យមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ១ ដែលបុគ្គលបានសង្រួមហើយ តែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍យ៉ាងធំ ដូចចិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ ចិត្តដែលបុគ្គលបានសង្រួមហើយ តែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍យ៉ាងធំ ។

[៤០] នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យំ ឯវំ អទន្តំ អគុត្តំ អរក្ខិតំ អសំវុតំ មហតោ អនត្ថាយ សំវត្តតិ យថយិទំ ភិក្ខវេ ចិត្តំ ចិត្តំ ភិក្ខវេ អទន្តំ អគុត្តំ អរក្ខិតំ អសំវុតំ មហតោ អនត្ថាយ សំវត្តតីតិ ។

[៤១] នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យំ ឯវំ ទន្តំ គុត្តំ រក្ខិតំ សំវុតំ មហតោ អត្ថាយ សំវត្តតិ យថយិទំ ភិក្ខវេ ចិត្តំ ចិត្តំ ភិក្ខវេ ទន្តំ គុត្តំ រក្ខិតំ សំវុតំ មហតោ អត្ថាយ សំវត្តតីតិ ។

វគ្គោ (១) ចតុត្ថោ ។

[៤២] សេយ្យថាបិ ភិក្ខវេ សាលិសូកំ វា យវសូកំ វា មិច្ឆាបណិហិតំ ហត្ថេន វា បាទេន វា អក្កន្តំ ហត្ថំ វា បាទំ វា ភិន្ទិស្សតិ (២) លោហិតំ វា ឧប្បាទេស្សតីតិ នេតំ ឋានំ វិជ្ជតិ

១ ម. អទន្តវគ្គោ ។ ២ ឱ. ភេច្ឆតិ ។



(៤០) ម្នាលភិក្ខុទាំងឡាយ តថាគតរំពៃរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ១ ដែលបុគ្គលមិនបានទូន្មាន មិនបានគ្រប់គ្រង មិនបានរក្សា មិនបានសង្រួមហើយ តែងប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍យ៉ាងធំ ដូចចិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ ចិត្តដែលបុគ្គលមិនបានទូន្មាន មិនបានគ្រប់គ្រង មិនបានរក្សា មិនបានសង្រួមហើយ តែងប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍យ៉ាងធំ ។

(៤១) ម្នាលភិក្ខុទាំងឡាយ តថាគតរំពៃរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ១ ដែលបុគ្គលបានទូន្មាន បានគ្រប់គ្រង បានរក្សា បានសង្រួមហើយ តែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍យ៉ាងធំ ដូចចិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ ចិត្តដែលបុគ្គលបានទូន្មាន បានគ្រប់គ្រង បានរក្សា បានសង្រួមហើយ តែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍យ៉ាងធំ ។

ចប់ វគ្គទី ៤ ។

(៤២) ម្នាលភិក្ខុទាំងឡាយ ចុងកន្ទ្រាំងស្រូវខ្សាយក្តី ចុងកន្ទ្រាំងស្រូវសាលីក្តី ដែលបុគ្គលរៀបចំមិនត្រូវទំនង គឺមិនឲ្យចុងវាឡើងលើ បុគ្គលបង្កិតដោយដៃឬជាន់ដោយជើង ទឹងមុតដៃឬជើង ពិតធ្វើឈាមឲ្យហូរចេញឡើងបាន ហេតុនុ៎ះ មិនមែនមានទេ ហេតុនោះព្រោះ

តំ កិស្ស ហេតុ មិច្ឆាបណិហិតត្តា ភិក្ខវេ សូកស្ស(១) ឯវមេវ ខោ ភិក្ខវេ សោ វត ភិក្ខុ មិច្ឆាបណិហិតេន ចិត្តេន អវិជ្ជំ ភិជ្ជិស្សតិ វិជ្ជំ ឧប្បាទេស្សតិ និព្វានំ សច្ឆិករិស្សតីតិ នេតំ ឋានំ វិជ្ជតិ តំ កិស្ស ហេតុ មិច្ឆាបណិហិតត្តា ភិក្ខវេ ចិត្តស្សាតិ ។

(៤៣) សេយ្យថាបិ ភិក្ខវេ សាលិសូកំ វា យវសូកំ វា សម្មាបណិហិតំ ហត្ថេន វា បាទេន វា អក្កន្តំ ហត្ថំ វា បាទំ វា ភិជ្ជិស្សតិ លោហិតំ វា ឧប្បាទេស្សតីតិ ឋានមេតំ វិជ្ជតិ តំ កិស្ស ហេតុ សម្មាបណិហិតត្តា ភិក្ខវេ សូកស្ស(២) ឯវមេវ ខោ ភិក្ខវេ សោ វត ភិក្ខុ សម្មាបណិហិតេន ចិត្តេន អវិជ្ជំ ភិជ្ជិស្សតិ វិជ្ជំ ឧប្បាទេស្សតិ និព្វានំ សច្ឆិករិស្សតីតិ ឋានមេតំ វិជ្ជតិ តំ កិស្ស ហេតុ សម្មាបណិហិតត្តា ភិក្ខវេ ចិត្តស្សាតិ ។

---

១ - ២ សាលិសូកស្សាតិបិ ។



ហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះចុងគ្រាប់ស្រូវដែលបុគ្គលរៀបចំមិនត្រូវទំនង ដូចម្ដេចមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានចិត្តដំកល់ខុស នឹងទំលាយអវិជ្ជា នឹងធ្វើវិជ្ជាឲ្យកើតឡើង នឹងធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ហេតុនុ៎ះ មិនមែនមានទេ រឿងនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះចិត្តដែលភិក្ខុនោះដំកល់ខុស ដូច្នេះឯង ។

(៤៣) ម្នាលភិក្ខុទាំងឡាយ ចុងគ្រាប់ស្រូវឡាយក្ដី ចុងគ្រាប់ស្រូវសាលីក្ដី ដែលបុគ្គលរៀបចំត្រូវទំនង គឺធ្វើឲ្យមានចុងឡើងលើ បុគ្គលបង្កក់ដោយដៃ ឬជាន់ដោយជើង នឹងមុតដៃ ឬជើង នឹងធ្វើឈាមឲ្យផុសឡើងបាន ហេតុនេះមែនមាន រឿងនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះចុងគ្រាប់ស្រូវបុគ្គលរៀបចំត្រូវទំនង ដូចម្ដេចមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានចិត្តដំកល់ត្រូវ នឹងទំលាយអវិជ្ជា នឹងធ្វើវិជ្ជាឲ្យកើតឡើង នឹងធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ហេតុនេះមែនមាន រឿងនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះចិត្តដែលភិក្ខុនោះដំកល់ត្រូវ ដូច្នេះឯង ។

(៤៦) ឥធាហំ ភិក្ខវេ ឯកច្ចំ បុគ្គលំ បទុដ្ឋចិត្តំ ឯវំ ចេតសា ចេតោ បរិច្ច បជានាមិ ឥមម្ហិ ចេ អយំ សមយេ បុគ្គលោ កាលំ ករេយ្យ យថាភតំ និក្ខិត្តោ ឯវំ និរយេតិ តំ កិស្ស ហេតុ ចិត្តំ ហិស្ស ភិក្ខវេ បទុដ្ឋំ ចេតោបទោសហេតុ បន ភិក្ខវេ ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជន្តីតិ ។

(៤៧) ឥធាហំ ភិក្ខវេ ឯកច្ចំ បុគ្គលំ បសន្នចិត្តំ ឯវំ ចេតសា ចេតោ បរិច្ច បជានាមិ ឥមម្ហិ ចេ អយំ សមយេ បុគ្គលោ កាលំ ករេយ្យ យថាភតំ និក្ខិត្តោ ឯវំ សគ្គេតិ តំ កិស្ស ហេតុ ចិត្តំ ហិស្ស ភិក្ខវេ បសន្នំ ចេតោបសាទហេតុ បន ភិក្ខវេ ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តីតិ ។



(៤៦) ម្នាលភិក្ខុទាំងឡាយ តថាគតកំណត់នូវចិត្ត (របស់បុគ្គល) ដោយចិត្ត (របស់ខ្លួន) គឺដឹងច្បាស់នូវបុគ្គលពួកមួយក្នុងលោកនេះដែលមានចិត្តប្រទូស្តយ៉ាងនេះថា បើបុគ្គលនេះធ្វើនូវមរណកាលក្នុងសម័យនេះ នឹងធ្លាក់ទៅក្នុងនរក ដូចគេចាប់ដាក់ទៅដូច្នោះឯង រឿងនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះថា បុគ្គលនោះមានចិត្តប្រទូស្ត ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត សត្វទាំងឡាយពួកមួយ ក្នុងលោកនេះ ទម្លាយរាងកាយស្លាប់ទៅ តែងទៅកើត ក្នុងអបាយ ទុគ្គតិ វិនិបាត នរក ក៏ព្រោះតែចិត្តប្រទូស្តជាហេតុផង ។

(៤៧) ម្នាលភិក្ខុទាំងឡាយ តថាគតកំណត់នូវចិត្ត (របស់បុគ្គល) ដោយចិត្ត (របស់ខ្លួន) គឺដឹងច្បាស់នូវបុគ្គលពួកមួយ ក្នុងលោកនេះដែលមានចិត្តជ្រះថ្លាយ៉ាងនេះថា បើបុគ្គលនេះធ្វើមរណកាលក្នុងសម័យនេះ នឹងទៅកើតក្នុងស្ថានសួគ៌ ដូចគេនាំទៅដាក់ទុកដូច្នោះឯង រឿងនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត សត្វទាំងឡាយ ពួកមួយ ក្នុងលោកនេះ ទម្លាយរាងកាយស្លាប់ទៅ នឹងទៅកើតក្នុងសុគតិសួគ៌ទេវលោក ក៏ព្រោះតែចិត្តជ្រះថ្លាជាហេតុផង ។

[៤៥] សេយ្យថាបិ ភិក្ខវេ ឧទករហទោ អាវិលោ លុឡិតោ កលលីភូតោ តត្ថ ចក្ខុមា បុរិសោ តីរេ ឋិតោ ន បស្សេយ្យ សិប្បិសម្ពុកម្បិ សក្ខរកឋលម្បិ មច្ឆគុម្ពម្បិ ចរន្តម្បិ តិដ្ឋន្តម្បិ តំ កិស្ស ហេតុ អាវិលត្តា ភិក្ខវេ ឧទកស្ស ឯវមេវ ខោ ភិក្ខវេ សោ វត ភិក្ខុ អាវិលេន ចិត្តេន អត្តត្ថំ វា ញស្សតិ បរត្ថំ វា ញស្សតិ ឧភយត្ថំ វា ញស្សតិ ឧត្តរឹ វា មនុស្សធម្មា អលមរិយញាណទស្សនវិសេសំ សច្ឆិករិស្សតីតិ នេតំ ឋានំ វិជ្ជតិ តំ កិស្ស ហេតុ អាវិលត្តា ភិក្ខវេ ចិត្តស្សាតិ ។

[៤៦] សេយ្យថាបិ ភិក្ខវេ ឧទករហទោ អច្ឆោ វិប្បសន្នោ អនាវិលោ តត្ថ ចក្ខុមា បុរិសោ តីរេ ឋិតោ បស្សេយ្យ សិប្បិសម្ពុកម្បិ សក្ខរកឋលម្បិ មច្ឆគុម្ពម្បិ ចរន្តម្បិ តិដ្ឋន្តម្បិ តំ កិស្ស ហេតុ អនាវិលត្តា ភិក្ខវេ ឧទកស្ស ឯវមេវ ខោ ភិក្ខវេ សោ វត ភិក្ខុ អនាវិលេន ចិត្តេន អត្តត្ថំ វា ញស្សតិ បរត្ថំ វា ញស្សតិ



(៤៥) ម្នាលភិក្ខុទាំងឡាយ អន្លង់ទឹក មានទឹកល្អក់ក្រល់កករជាភក់ បុរសអ្នកមានចក្ខុឈរនៅមាត់អន្លង់នោះ មិនឃើញខ្យងនិងគ្រំ ឬគ្រួសនិងកំបែងក្អម ឬហ្វូងត្រីដែលហែលទៅមក ឬក៏ស្ថិតនៅថ្កានឡើយ ដំណើរនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះទឹកនោះល្អក់ ដូចម្ដេចមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានចិត្តល្អក់ នឹងស្គាល់ប្រយោជន៍របស់ខ្លួនក្ដី ស្គាល់ប្រយោជន៍របស់អ្នកដទៃក្ដី ស្គាល់ប្រយោជន៍ទាំងពីរពួកក្ដី នឹងធ្វើឲ្យជាក់ច្បាស់នូវគុណវិសេសគឺញាណ-ទស្សនៈដ៏ប្រសើរ ក្រៅពីធម៌របស់មនុស្សធម្មតាក្ដី ហេតុនុ៎ះ មិនដែលមានទេ ដំណើរនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះចិត្តនោះ មានចិត្តល្អក់ ក៏ដូច្នោះដែរ ។

(៤៦) ម្នាលភិក្ខុទាំងឡាយ អន្លង់ទឹកមានទឹកថ្លាស្អាតមិនល្អក់ បុរសអ្នកមានចក្ខុ ឈរនៅមាត់អន្លង់នោះ ក៏ឃើញខ្យងនិងគ្រំ ឬគ្រួសនិងកំបែងក្អម ឬហ្វូងត្រី ដែលហែលទៅមកឬក៏ស្ថិតនៅថ្កាន ដំណើរនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះទឹកនោះ មិនល្អក់ ដូចម្ដេចមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានចិត្តមិនល្អក់ នឹងស្គាល់ប្រយោជន៍របស់ខ្លួនក្ដី ស្គាល់ប្រយោជន៍របស់អ្នកដទៃក្ដី

ឧភយត្ថំ វា ញស្សតិ ឧត្តរិ វា មនុស្សធម្មា អលមរិយញាណទស្សនវិសេសំ សច្ឆិករិស្សតីតិ ឋានមេតំ វិជ្ជតិ តំ កិស្ស ហេតុ អនាវិលត្តា ភិក្ខវេ ចិត្តស្សាតិ ។

(៤៨) សេយ្យថាបិ ភិក្ខវេ យានិ កានិចិ រុក្ខជាតានិ ផន្ទនោ(១) តេសំ អគ្គមក្ខាយតិ យទិទំ មុទុតាយ ចេវ កម្មញ្ញតាយ ច ។ ឯវមេវ ខោ អហំ ភិក្ខវេ នាញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យំ ឯវំ ភាវិតំ ពហុលីកតំ មុទុញ្ច ហោតិ កម្មញ្ញញ្ច យថយិទំ ភិក្ខវេ ចិត្តំ ចិត្តំ ភិក្ខវេ ភាវិតំ ពហុលីកតំ មុទុញ្ច ហោតិ កម្មញ្ញញ្ច ហោតីតិ ។

(៤៩) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យំ ឯវំ លហុបរិវត្តំ យថយិទំ ភិក្ខវេ ចិត្តំ យាវញ្ចិទំ ភិក្ខវេ ឧបមាបិ ន សុករា យាវ លហុបរិវត្តំ ចិត្តន្តិ ។

១ ម. ចន្ទនោ ។



ស្គាល់ប្រយោជន៍ទាំងពីរផងក្តី នឹងធ្វើឲ្យជាក់ច្បាស់នូវគុណវិសេសគឺ ញាណទស្សនៈដ៏ប្រសើរ ក្រៃលែងជាងមនុស្សធម៌ក្តី ហេតុនុ៎ះ រមែងមាន ដំណើរនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះចិត្តនោះ មានចិត្តមិនល្អក់ ក៏ដូច្នោះឯង ។

(៤៨) ម្នាលភិក្ខុទាំងឡាយ រុក្ខជាតិទាំងឡាយ ប្រភេទណាមួយ ចន្ទន៍ បណ្ឌិតសរសើរថាប្រសើរជាងរុក្ខជាតិទាំងនោះ ព្រោះដើមចន្ទន៍នេះទន់ផង គួរដល់ការងារផង យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ តថាគតពិនិត្យមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ ជាសភាវៈទន់ផង គួរដល់ការងារផង ដូចចិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ ចិត្តដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនហើយ ជារបស់ទន់ផង គួរដល់ការងារផង ដូច្នេះឯង ។

(៤៩) ម្នាលភិក្ខុទាំងឡាយ តថាគតពិនិត្យមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលកើតឡើងនិងរលត់ទៅរហ័ស ដូចចិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ ចិត្តនេះកើតឡើងនិងរលត់ទៅរហ័សក្រៃពេក មិនងាយនឹងធ្វើឧបមាបានឡើយ ។

(៥០) ម្នាលភិក្ខុទាំងឡាយ ចិត្តនេះមានរស្មីផ្លូយចេញ ប៉ុន្តែចិត្តនោះឯង ត្រូវឧបក្កិលេសទាំងឡាយជាអាគន្តុកៈ ចូលមកធ្វើឲ្យសៅហ្មង ។

(៤៩) បភស្សរមិទំ ភិក្ខវេ ចិត្តំ តញ្ច ខោ អាគន្តុកេហិ ឧបក្កិលេសេហិ ឧបក្កិលិដ្ឋន្តិ ។

(៥០) បភស្សរមិទំ ភិក្ខវេ ចិត្តំ តញ្ច ខោ អាគន្តុកេហិ ឧបក្កិលេសេហិ វិប្បមុត្តន្តិ ។

វគ្គោ (១) បញ្ចមោ ។

(៥១) បភស្សរមិទំ ភិក្ខវេ ចិត្តំ តញ្ច ខោ អាគន្តុកេហិ ឧបក្កិលេសេហិ ឧបក្កិលិដ្ឋំ តំ អស្សុតវា បុថុជ្ជនោ យថាភូតំ នប្បជានាតិ តស្មា អស្សុតវតោ បុថុជ្ជនស្ស ចិត្តភាវនា នត្ថីតិ វទាមីតិ ។

(៥២) បភស្សរមិទំ ភិក្ខវេ ចិត្តំ តញ្ច ខោ អាគន្តុកេហិ ឧបក្កិលេសេហិ វិប្បមុត្តំ តំ សុតវា អរិយសាវកោ យថាភូតំ បជានាតិ តស្មា សុតវតោ អរិយសាវកស្ស ចិត្តភាវនា អត្ថីតិ វទាមីតិ ។

(៥៣) អច្ឆរាសង្ឃាតមត្តម្បិ ចេ ភិក្ខវេ ភិក្ខុ មេត្តាចិត្តំ អាសេវតិ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ អរិត្តជ្ឈានោ វិហរតិ សត្ថុសាសនករោ

១ ម. ស. បណិហិតអច្ឆវគ្គោ ។





(៥០) ម្នាលភិក្ខុទាំងឡាយ កាលចិត្តនេះមានរស្មីផ្សាយចេញ ម្យ៉ាង កាលចិត្តនោះឯងផុតស្រឡះចាកឧបក្កិលេសទាំងឡាយ ដែលជាអាគន្តុកៈ ។

ចប់ វគ្គទី ៥ ។

(៥១) ម្នាលភិក្ខុទាំងឡាយ កាលចិត្តនេះ មានរស្មីផ្សាយចេញ ប៉ុន្តែ កាលចិត្តនោះឯង ត្រូវឧបក្កិលេសទាំងឡាយជាអាគន្តុកៈ ចូលមកសៅហ្មង បុថុជ្ជនអ្នកមិនចេះដឹង រមែងមិនដឹងច្បាស់នូវកាលចិត្តនោះ តាមសេចក្តីពិត ព្រោះហេតុនោះឯង តថាគតពោលថា បុថុជ្ជនអ្នកមិនចេះដឹង មិនមានការចំរើនចិត្តទេ ។

(៥២) ម្នាលភិក្ខុទាំងឡាយ កាលចិត្តនេះមានរស្មីផ្សាយចេញ ម្យ៉ាង កាលចិត្តនោះឯង ផុតស្រឡះចាកឧបក្កិលេសទាំងឡាយ ដែលជាអាគន្តុកៈ អរិយសាវកអ្នកចេះដឹង រមែងដឹងច្បាស់នូវកាលចិត្តនោះ តាមសេចក្តីពិត ព្រោះហេតុនោះឯង តថាគតពោលថា អរិយសាវកអ្នកចេះដឹង រមែងមានការចំរើនចិត្ត ។

(៥៣) ម្នាលភិក្ខុទាំងឡាយ បើភិក្ខុគប្បីសេពនូវមេត្តាចិត្ត សូម្បីមួយ ផ្ទាត់ម្រាមដៃ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ តថាគត ហៅថា មានឈានមិនចាត់ចោល ជាអ្នកធ្វើតាមសាសនាព្រះសាស្តា

ឱវាទប្បដិករោ អមោឃំ រដ្ឋបិណ្ឌំ ភុញ្ជតិ ។ កោ បន វាទោ យេ នំ ពហុលីករោន្តីតិ ។

(៥៤) អច្ឆរាសង្ឃាតមត្តម្បិ ចេ ភិក្ខវេ ភិក្ខុ មេត្តាចិត្តំ ភាវេតិ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ អរិត្តជ្ឈានោ វិហរតិ សត្ថុសាសនករោ ឱវាទប្បដិករោ អមោឃំ រដ្ឋបិណ្ឌំ ភុញ្ជតិ ។ កោ បន វាទោ យេ នំ ពហុលីករោន្តីតិ ។

(៥៥) អច្ឆរាសង្ឃាតមត្តម្បិ ចេ ភិក្ខវេ ភិក្ខុ មេត្តាចិត្តំ មនសិការោតិ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ អរិត្តជ្ឈានោ វិហរតិ សត្ថុសាសនករោ ឱវាទប្បដិករោ អមោឃំ រដ្ឋបិណ្ឌំ ភុញ្ជតិ ។ កោ បន វាទោ យេ នំ ពហុលីករោន្តីតិ ។

(៥៦) យេ កេចិ ភិក្ខវេ ធម្មា អកុសលា អកុសលភាគិយា អកុសលបក្ខិកា សព្វេ តេ មនោបុព្វង្គមា មនោ តេសំ ធម្មានំ បឋមំ ឧប្បជ្ជតិ អន្វទេវ អកុសលា ធម្មាតិ ។



ជាអ្នកធ្វើតាមឱវាទនៃព្រះសាស្តា បរិភោគបិណ្ឌបាតរបស់អ្នកដែន មិនឥតអំពើ ចាំបាច់និយាយថ្វី ដល់ពួកភិក្ខុដែលសន្សំរឿយៗ នូវមេត្តាចិត្តនោះ ។

(៥៤) ម្នាលភិក្ខុទាំងឡាយ ភិក្ខុចំរើននូវមេត្តាចិត្ត សូម្បីមួយផ្ទាត់ម្រាមដៃ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ តថាគតហៅថា មានឈានមិនឃ្លាតលះបង់ ជាអ្នកធ្វើតាមសាសនានៃព្រះសាស្តា ជាអ្នកធ្វើតាមឱវាទនៃព្រះសាស្តា បរិភោគបិណ្ឌបាតរបស់អ្នកដែន មិនឥតអំពើ ចាំបាច់និយាយថ្វី ដល់ពួកភិក្ខុដែលសន្សំរឿយៗ នូវមេត្តាចិត្តនោះ ។

(៥៥) ម្នាលភិក្ខុទាំងឡាយ បើភិក្ខុធ្វើទុកនូវមេត្តាចិត្ត សូម្បីមួយផ្ទាត់ម្រាមដៃ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ តថាគតហៅថា មានឈានមិនឃ្លាតលះបង់ ជាអ្នកធ្វើតាមសាសនានៃព្រះសាស្តា ជាអ្នកធ្វើតាមឱវាទនៃព្រះសាស្តា បរិភោគបិណ្ឌបាតរបស់អ្នកដែន មិនឥតអំពើ ចាំបាច់និយាយថ្វី ដល់ពួកភិក្ខុដែលសន្សំរឿយៗ នូវមេត្តាចិត្តនោះ ។

(៥៦) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយណានីមួយ ជាអកុសល ជាចំណែកខាងអកុសល ជាពួកនៃអកុសល ធម៌ជាអកុសលទាំងអស់នោះ មានចិត្តជាប្រធាន ចិត្តដែលកើតមុនធម៌ទាំងនោះ អកុសលធម៌ទាំងឡាយ ក៏កើតជាមួយគ្នា ។

[៥៨] យេ កេចិ ភិក្ខវេ ធម្មា កុសលា កុសលភាគិយា កុសលបក្ខិកា សព្វេ តេ មនោបុព្វង្គមា មនោ តេសំ ធម្មានំ បឋមំ ឧប្បជ្ជតិ អន្វទេវ កុសលា ធម្មាតិ ។

[៥៩] នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យេន អនុប្បន្នា វា អកុសលា ធម្មា ឧប្បជ្ជន្តិ ឧប្បន្នា វា កុសលា ធម្មា បរិហាយន្តិ យថយិទំ ភិក្ខវេ បមាទោ បមត្តស្ស ភិក្ខវេ អនុប្បន្នា ចេវ អកុសលា ធម្មា ឧប្បជ្ជន្តិ ឧប្បន្នា ច កុសលា ធម្មា បរិហាយន្តីតិ ។

[៦០] នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យេន អនុប្បន្នា វា កុសលា ធម្មា ឧប្បជ្ជន្តិ ឧប្បន្នា វា អកុសលា ធម្មា បរិហាយន្តិ យថយិទំ ភិក្ខវេ អប្បមាទោ អប្បមត្តស្ស ភិក្ខវេ អនុប្បន្នា ចេវ កុសលា ធម្មា ឧប្បជ្ជន្តិ ឧប្បន្នា ច អកុសលា ធម្មា បរិហាយន្តីតិ ។



(៥៨) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយណាមួយ ជាកុសល ជាចំណែកខាងកុសល ជាពួកនៃកុសល ធម៌ជាកុសលទាំងអស់នោះ មានចិត្តជាប្រធាន ចិត្តរមែងកើតមុនធម៌ទាំងនោះ ធម៌ជាកុសលទាំងឡាយ ក៏កើតជាមួយគ្នា ។

(៥៩) ម្នាលភិក្ខុទាំងឡាយ តថាគតមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ១ ដែលធ្វើនូវពួកអកុសលធម៌មិនទាន់កើតឡើង ឲ្យកើតឡើងផងក្តី ពួកកុសលធម៌ដែលកើតឡើងហើយ ឲ្យសាបសូន្យទៅក្តី ដូចសេចក្តីប្រមាទនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលប្រមាទហើយ ពួកអកុសលធម៌ដែលមិនទាន់កើតឡើង ក៏រមែងកើតឡើងផង ពួកកុសលធម៌ដែលកើតឡើងហើយ រមែងសាបសូន្យទៅផង ។

(៦០) ម្នាលភិក្ខុទាំងឡាយ តថាគតមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ១ ដែលធ្វើនូវពួកកុសលធម៌ មិនទាន់កើតឡើង ឲ្យកើតឡើងផងក្តី ពួកអកុសលធម៌ដែលកើតឡើងហើយ ឲ្យសាបសូន្យទៅក្តី ដូចសេចក្តីមិនប្រមាទនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលមិនប្រមាទហើយ ពួកកុសលធម៌ ដែលមិនទាន់កើតឡើង ក៏រមែងកើតឡើងផង ពួកអកុសលធម៌ ដែលកើតឡើងហើយ ក៏រមែងសាបសូន្យទៅផង ។

(៦១) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យេន អនុប្បន្នា វា អកុសលា ធម្មា ឧប្បជ្ជន្តិ ឧប្បន្នា វា កុសលា ធម្មា បរិហាយន្តិ យថយិទំ ភិក្ខវេ កោសជ្ជំ កុសីតស្ស ភិក្ខវេ អនុប្បន្នា ចេវ អកុសលា ធម្មា ឧប្បជ្ជន្តិ ឧប្បន្នា ច កុសលា ធម្មា បរិហាយន្តីតិ ។

វគ្គោ[១] ឆដ្ឋោ ។

(៦២) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យេន អនុប្បន្នា វា កុសលា ធម្មា ឧប្បជ្ជន្តិ ឧប្បន្នា វា អកុសលា ធម្មា បរិហាយន្តិ យថយិទំ ភិក្ខវេ វីរិយារម្ភោ អារទ្ធវីរិយស្ស ភិក្ខវេ អនុប្បន្នា ចេវ កុសលា ធម្មា ឧប្បជ្ជន្តិ ឧប្បន្នា ច អកុសលា ធម្មា បរិហាយន្តីតិ ។

(៦៣) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យេន អនុប្បន្នា វា អកុសលា ធម្មា

១ ឱ. ម. បមាទាទិវគ្គោ ។



(៦១) ម្នាលភិក្ខុទាំងឡាយ តថាគតពិនិត្យមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ១ ដែលញុំាងពួកអកុសលធម៌មិនទាន់កើតឡើង ឲ្យកើតឡើងបានក្តី ពួកកុសលធម៌ដែលកើតឡើងហើយ ឲ្យសាបសូន្យទៅក្តី ដូចសេចក្តីខ្ជិលច្រអូសនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលខ្ជិលច្រអូសហើយ ពួកអកុសលធម៌ ដែលមិនទាន់កើតឡើង ក៏រមែងកើតឡើងបានផង ពួកកុសលធម៌ ដែលកើតឡើងហើយ ក៏រមែងសាបសូន្យទៅផង ។

ចប់ វគ្គទី ៦ ។

(៦២) ម្នាលភិក្ខុទាំងឡាយ តថាគតពិនិត្យមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ១ ដែលញុំាងពួកកុសលធម៌មិនទាន់កើតឡើង ឲ្យកើតឡើងបានក្តី ពួកអកុសលធម៌ដែលកើតឡើងហើយ ឲ្យសាបសូន្យទៅក្តី ដូចការប្រារព្ធព្យាយាមនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលផ្តើមព្យាយាមហើយ ពួកកុសលធម៌ ដែលមិនទាន់កើតឡើង ក៏រមែងកើតឡើងបានផង ពួកអកុសលធម៌ ដែលកើតឡើងហើយ ក៏រមែងសាបសូន្យទៅផង ។

(៦៣) ម្នាលភិក្ខុទាំងឡាយ តថាគតពិនិត្យមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលញុំាងពួកអកុសលធម៌មិនទាន់កើតឡើង

ឧប្បជ្ជន្តិ ឧប្បន្នា វា កុសលា ធម្មា បរិហាយន្តិ យថយិទំ ភិក្ខវេ មិច្ឆាទិដ្ឋិ មិច្ឆាទិដ្ឋិកស្ស ភិក្ខវេ អនុប្បន្នា ចេវ អកុសលា ធម្មា ឧប្បជ្ជន្តិ ឧប្បន្នា ច កុសលា ធម្មា បរិហាយន្តីតិ ។

(៦៤) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យេន អនុប្បន្នា វា កុសលា ធម្មា ឧប្បជ្ជន្តិ ឧប្បន្នា វា អកុសលា ធម្មា បរិហាយន្តិ យថយិទំ ភិក្ខវេ សម្មាទិដ្ឋិ សម្មាទិដ្ឋិកស្ស ភិក្ខវេ អនុប្បន្នា ចេវ កុសលា ធម្មា ឧប្បជ្ជន្តិ ឧប្បន្នា ច អកុសលា ធម្មា បរិហាយន្តីតិ ។

(៦៥) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យេន អនុប្បន្នា វា អកុសលា ធម្មា ឧប្បជ្ជន្តិ ឧប្បន្នា វា កុសលា ធម្មា បរិហាយន្តិ



ឲ្យកើតឡើងផងក្តី ពួកកុសលធម៌ ដែលកើតឡើងហើយ ឲ្យសាបសូន្យទៅក្តី ដូចសេចក្តីយល់ឃើញខុសនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលមានសេចក្តីយល់ឃើញខុស ពួកអកុសលធម៌ ដែលមិនទាន់កើតឡើង ក៏រមែងកើតឡើងផង ពួកកុសលធម៌ដែលកើតឡើងហើយ ក៏រមែងសាបសូន្យទៅផង ។

(៦៤) ម្នាលភិក្ខុទាំងឡាយ តថាគតពុំមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលញុំាងពួកកុសលធម៌មិនទាន់កើតឡើង ឲ្យកើតឡើងផងក្តី ពួកអកុសលធម៌ដែលកើតឡើងហើយ ឲ្យសាបសូន្យទៅក្តី ដូចសេចក្តីយល់ឃើញត្រូវនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលមានសេចក្តីយល់ឃើញត្រូវ ពួកកុសលធម៌ ដែលមិនទាន់កើតឡើង រមែងកើតឡើងផង ពួកអកុសលធម៌ដែលកើតឡើងហើយ ក៏រមែងសាបសូន្យទៅផង ។

(៦៥) ម្នាលភិក្ខុទាំងឡាយ តថាគតពុំមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលញុំាងពួកអកុសលធម៌មិនទាន់កើតឡើង ឲ្យកើតឡើងផងក្តី ពួកកុសលធម៌ដែលកើតឡើងហើយ ឲ្យសាបសូន្យទៅក្តី

យថយិទំ ភិក្ខវេ អសន្តុដ្ឋិតា អសន្តុដ្ឋស្ស ភិក្ខវេ អនុប្បន្នា ចេវ អកុសលា ធម្មា ឧប្បជ្ជន្តិ ឧប្បន្នា ច កុសលា ធម្មា បរិហាយន្តីតិ ។

(៦៦) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យេន អនុប្បន្នា វា កុសលា ធម្មា ឧប្បជ្ជន្តិ ឧប្បន្នា វា អកុសលា ធម្មា បរិហាយន្តិ យថយិទំ ភិក្ខវេ សន្តុដ្ឋិតា សន្តុដ្ឋស្ស ភិក្ខវេ អនុប្បន្នា ចេវ កុសលា ធម្មា ឧប្បជ្ជន្តិ ឧប្បន្នា ច អកុសលា ធម្មា បរិហាយន្តីតិ ។

(៦៧) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យេន អនុប្បន្នា វា អកុសលា ធម្មា ឧប្បជ្ជន្តិ ឧប្បន្នា វា កុសលា ធម្មា បរិហាយន្តិ យថយិទំ ភិក្ខវេ អយោនិសោមនសិការោ អយោនិសោ ភិក្ខវេ មនសិករោតោ អនុប្បន្នា ចេវ អកុសលា ធម្មា ឧប្បជ្ជន្តិ ឧប្បន្នា ច កុសលា ធម្មា បរិហាយន្តីតិ ។



ដូចសេចក្ដីមិនសន្ដោសនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលមិនមានសេចក្ដីសន្ដោស ពួកអកុសលធម៌ ដែលមិនទាន់កើតឡើង ក៏រមែងកើតឡើងបានផង ពួកកុសលធម៌ ដែលកើតឡើងហើយ ក៏រមែងសាបសូន្យទៅផង ។

(៦៦) ម្នាលភិក្ខុទាំងឡាយ តថាគតពុំឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលនាំឲ្យពួកកុសលធម៌មិនទាន់កើតឡើង ឲ្យកើតឡើងបានផង ពួកអកុសលធម៌ ដែលកើតឡើងហើយ ឲ្យសាបសូន្យទៅផង ដូចសេចក្ដីសន្ដោសនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលមានសេចក្ដីសន្ដោស ពួកកុសលធម៌ ដែលមិនទាន់កើតឡើង ក៏រមែងកើតឡើងបានផង ពួកអកុសលធម៌ដែលកើតឡើងហើយ ក៏រមែងសាបសូន្យទៅផង ។

(៦៧) ម្នាលភិក្ខុទាំងឡាយ តថាគតពុំឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលនាំឲ្យពួកអកុសលធម៌មិនទាន់កើតឡើង ឲ្យកើតឡើងបានផង ពួកកុសលធម៌ដែលកើតឡើងហើយ ឲ្យសាបសូន្យទៅផង ដូចការធ្វើទុកក្នុងចិត្តដោយមិនសមនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលធ្វើទុកក្នុងចិត្តដោយមិនសម ពួកអកុសលធម៌ ដែលមិនទាន់កើតឡើង ក៏រមែងកើតឡើងបានផង ពួកកុសលធម៌ ដែលកើតឡើងហើយ ក៏រមែងសាបសូន្យទៅផង ។

(៦៨) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យេន អនុប្បន្នា វា កុសលា ធម្មា ឧប្បជ្ជន្តិ ឧប្បន្នា វា អកុសលា ធម្មា បរិហាយន្តិ យថយិទំ ភិក្ខវេ យោនិសោ មនសិការោ យោនិសោ ភិក្ខវេ មនសិករោតោ អនុប្បន្នា ចេវ កុសលា ធម្មា ឧប្បជ្ជន្តិ ឧប្បន្នា ច អកុសលា ធម្មា បរិហាយន្តីតិ ។

(៦៩) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យេន អនុប្បន្នា វា អកុសលា ធម្មា ឧប្បជ្ជន្តិ ឧប្បន្នា វា កុសលា ធម្មា បរិហាយន្តិ យថយិទំ ភិក្ខវេ អសម្បជញ្ញំ អសម្បជានស្ស ភិក្ខវេ អនុប្បន្នា ចេវ អកុសលា ធម្មា ឧប្បជ្ជន្តិ ឧប្បន្នា ច កុសលា ធម្មា បរិហាយន្តីតិ ។

(៧០) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យេន អនុប្បន្នា វា កុសលា ធម្មា ឧប្បជ្ជន្តិ ឧប្បន្នា វា អកុសលា ធម្មា បរិហាយន្តិ



(៦៨) ម្នាលភិក្ខុទាំងឡាយ តថាគតរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ១ ដែលញ៉ាំងពួកកុសលធម៌មិនទាន់កើតឡើង ឲ្យកើតឡើងបានក្តី ពួកអកុសលធម៌ដែលកើតឡើងហើយ ឲ្យសាបសូន្យទៅក្តី ដូចការធ្វើទុកក្នុងចិត្តត្រូវទំនងនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលធ្វើទុកក្នុងចិត្តត្រូវទំនង ពួកកុសលធម៌ដែលមិនទាន់កើតឡើង ក៏រមែងកើតឡើងបានផង ពួកអកុសលធម៌ ដែលកើតឡើងហើយ ក៏រមែងសាបសូន្យទៅផង ។

(៦៩) ម្នាលភិក្ខុទាំងឡាយ តថាគតរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ១ ដែលញ៉ាំងពួកអកុសលធម៌មិនទាន់កើតឡើង ឲ្យកើតឡើងបានក្តី ពួកកុសលធម៌ដែលកើតឡើងហើយ ឲ្យសាបសូន្យទៅក្តី ដូចអសម្បជញ្ញៈ (សេចក្តីមិនដឹងខ្លួន) នេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលមានអសម្បជញ្ញៈ ពួកអកុសលធម៌ ដែលមិនទាន់កើតឡើង ក៏រមែងកើតឡើងបានផង ពួកកុសលធម៌ ដែលកើតឡើងហើយ ក៏រមែងសាបសូន្យទៅផង ។

(៧០) ម្នាលភិក្ខុទាំងឡាយ តថាគតរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ១ ដែលញ៉ាំងពួកកុសលធម៌ មិនទាន់កើតឡើង ឲ្យកើតឡើងបានក្តី ពួកអកុសលធម៌ ដែលកើតឡើងហើយ ឲ្យសាបសូន្យទៅក្តី

យថយិទំ ភិក្ខវេ អសម្បជញ្ញំ អសម្បជានស្ស ភិក្ខវេ អនុប្បន្នា ចេវ អកុសលា ធម្មា ឧប្បជ្ជន្តិ ឧប្បន្នា ច កុសលា ធម្មា បរិហាយន្តីតិ ។

(៧១) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យេន អនុប្បន្នា វា កុសលា ធម្មា ឧប្បជ្ជន្តិ ឧប្បន្នា វា អកុសលា ធម្មា បរិហាយន្តិ យថយិទំ ភិក្ខវេ អប្បមត្តតា អប្បមត្តស្ស ភិក្ខវេ អនុប្បន្នា ចេវ កុសលា ធម្មា ឧប្បជ្ជន្តិ ឧប្បន្នា ច អកុសលា ធម្មា បរិហាយន្តីតិ ។

វគ្គោ[១] សត្តមោ ។

(៧២) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យេន អនុប្បន្នា វា កុសលា ធម្មា ឧប្បជ្ជន្តិ ឧប្បន្នា វា អកុសលា ធម្មា បរិហាយន្តិ យថយិទំ ភិក្ខវេ កល្យាណមិត្តតា កល្យាណមិត្តស្ស ភិក្ខវេ អនុប្បន្នា ចេវ កុសលា ធម្មា ឧប្បជ្ជន្តិ ឧប្បន្នា ច អកុសលា ធម្មា បរិហាយន្តីតិ ។

១ ម. វីរិយារម្ភាទិវគ្គោ ។



ដូចអសម្បជញ្ញៈ (សេចក្តីមិនដឹងខ្លួន) នេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលមានអសម្បជញ្ញៈ ពួកអកុសលធម៌ ដែលមិនទាន់កើតឡើង រមែងកើតឡើងបានផង ពួកកុសលធម៌ ដែលកើតឡើងហើយ រមែងសាបសូន្យទៅផង ។

(៧១) ម្នាលភិក្ខុទាំងឡាយ តថាគតពុំឃើញសភាវៈដទៃ សូម្បីតែសភាវៈ១ ដែលនាំឲ្យពួកកុសលធម៌ មិនទាន់កើតឡើង ឲ្យកើតឡើងបានក្តី ពួកអកុសលធម៌ ដែលកើតឡើងហើយ ឲ្យសាបសូន្យទៅក្តី ដូចការមានឧបាយចិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលមានឧបាយចិត្ត ពួកកុសលធម៌ ដែលមិនទាន់កើតឡើង ក៏រមែងកើតឡើងបានផង ពួកអកុសលធម៌ ដែលកើតឡើងហើយ ក៏រមែងសាបសូន្យទៅផង ។

ចប់ វគ្គទី ៧ ។

(៧២) ម្នាលភិក្ខុទាំងឡាយ តថាគតពុំឃើញសភាវៈដទៃ សូម្បីតែសភាវៈ១ ដែលនាំឲ្យពួកកុសលធម៌ មិនទាន់កើតឡើង ឲ្យកើតឡើងបានក្តី ពួកអកុសលធម៌ ដែលកើតឡើងហើយ ឲ្យសាបសូន្យទៅក្តី ដូចការមានកល្យាណមិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលមានកល្យាណមិត្ត ពួកកុសលធម៌ ដែលមិនទាន់កើតឡើង ក៏រមែងកើតឡើងបានផង ពួកអកុសលធម៌ ដែលកើតឡើងហើយ រមែងសាបសូន្យទៅផង ។

[៧៣] នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យេន អនុប្បន្នា វា អកុសលា ធម្មា ឧប្បជ្ជន្តិ ឧប្បន្នា វា កុសលា ធម្មា បរិហាយន្តិ យថយិទំ ភិក្ខវេ អនុយោគោ អកុសលានំ ធម្មានំ អននុយោគោ កុសលានំ ធម្មានំ អនុយោគោ ភិក្ខវេ អកុសលានំ ធម្មានំ អននុយោគោ កុសលានំ ធម្មានំ អនុប្បន្នា ចេវ អកុសលា ធម្មា ឧប្បជ្ជន្តិ ឧប្បន្នា ច កុសលា ធម្មា បរិហាយន្តីតិ ។

[៧៤] នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យេន អនុប្បន្នា វា កុសលា ធម្មា ឧប្បជ្ជន្តិ ឧប្បន្នា វា អកុសលា ធម្មា បរិហាយន្តិ យថយិទំ ភិក្ខវេ អនុយោគោ កុសលានំ ធម្មានំ អននុយោគោ អកុសលានំ ធម្មានំ អនុយោគោ ភិក្ខវេ កុសលានំ ធម្មានំ អននុយោគោ អកុសលានំ ធម្មានំ អនុប្បន្នា ចេវ កុសលា ធម្មា ឧប្បជ្ជន្តិ ឧប្បន្នា ច អកុសលា ធម្មា បរិហាយន្តីតិ ។



(៧៣) ម្នាលភិក្ខុទាំងឡាយ តថាគតរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលជាហេតុនាំពួកអកុសលធម៌ មិនទាន់កើតឡើង ឲ្យកើតឡើងបានផង ពួកកុសលធម៌ ដែលកើតឡើងហើយ ឲ្យសាបសូន្យទៅផង ដូចកិរិយាប្រកបរឿយៗ នូវអកុសលធម៌ និងកិរិយាមិនប្រកបរឿយៗ នូវកុសលធម៌នេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ ពួកអកុសលធម៌ ដែលមិនទាន់កើតឡើង ក៏រមែងកើតឡើងបានផង ពួកកុសលធម៌ដែលកើតឡើងហើយ ក៏រមែងសាបសូន្យទៅផង ព្រោះកិរិយាប្រកបរឿយៗ នូវអកុសលធម៌ និងកិរិយាមិនប្រកបរឿយៗនូវកុសលធម៌ ។

(៧៤) ម្នាលភិក្ខុទាំងឡាយ តថាគតរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលជាហេតុនាំពួកកុសលធម៌មិនទាន់កើតឡើង ឲ្យកើតឡើងបានផង ពួកអកុសលធម៌ដែលកើតឡើងហើយ ឲ្យសាបសូន្យទៅផង ដូចកិរិយាប្រកបរឿយៗនូវកុសលធម៌ និងកិរិយាមិនប្រកបរឿយៗនូវអកុសលធម៌នេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ ពួកកុសលធម៌ដែលមិនទាន់កើតឡើង ក៏រមែងកើតឡើងបានផង ពួកអកុសលធម៌ដែលកើតឡើងហើយ ក៏រមែងសាបសូន្យទៅផង ព្រោះកិរិយាប្រកបរឿយៗនូវកុសលធម៌ និងកិរិយាមិនប្រកបរឿយៗនូវអកុសលធម៌ ។

(៧៥) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យេន អនុប្បន្នា វា ពោជ្ឈង្គា នុប្បជ្ជន្តិ ឧប្បន្នា វា ពោជ្ឈង្គា ន ភាវនាបារិបូរឹ គច្ឆន្តិ យថយិទំ ភិក្ខវេ អយោនិសោ មនសិការោ ។ អយោនិសោ ភិក្ខវេ មនសិករោតោ អនុប្បន្នា ចេវ ពោជ្ឈង្គា នុប្បជ្ជន្តិ ឧប្បន្នា ច ពោជ្ឈង្គា ន ភាវនាបារិបូរឹ គច្ឆន្តីតិ ។

(៧៦) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យេន អនុប្បន្នា វា ពោជ្ឈង្គា ឧប្បជ្ជន្តិ ឧប្បន្នា វា ពោជ្ឈង្គា ភាវនាបារិបូរឹ គច្ឆន្តិ យថយិទំ ភិក្ខវេ យោនិសោ មនសិការោ ។ យោនិសោ ភិក្ខវេ មនសិករោតោ អនុប្បន្នា ចេវ ពោជ្ឈង្គា ឧប្បជ្ជន្តិ ឧប្បន្នា ច ពោជ្ឈង្គា ភាវនាបារិបូរឹ គច្ឆន្តីតិ ។



(៧៥) ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ១ ដែលញុំាងពោជ្ឈង្គទាំងឡាយមិនទាន់កើតឡើង មិនឲ្យកើតឡើងបានទេ ពោជ្ឈង្គទាំងឡាយដែលកើតឡើងហើយ ក៏មិនឲ្យដល់នូវការបរិបូណ៌ ដោយភាវនាទេ ដូចការធ្វើទុកក្នុងចិត្តមិនត្រូវទំនងនេះ សោះឡើយ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលធ្វើទុកក្នុងចិត្តមិនត្រូវទំនង ពោជ្ឈង្គទាំងឡាយ ដែលមិនទាន់កើតឡើង ក៏កើតឡើងមិនបានផង ពោជ្ឈង្គទាំងឡាយ ដែលកើតឡើងហើយ ក៏មិនដល់នូវការបរិបូណ៌ ដោយភាវនាផង ។

(៧៦) ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ១ ដែលញុំាងពោជ្ឈង្គទាំងឡាយ មិនទាន់កើតឡើង ឲ្យកើតឡើងបានទេ ពោជ្ឈង្គទាំងឡាយ ដែលកើតឡើងហើយ ឲ្យដល់នូវការបរិបូណ៌ ដោយភាវនាទេ ដូចការធ្វើទុកក្នុងចិត្តត្រូវទំនងនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលធ្វើទុកក្នុងចិត្តត្រូវទំនង ពោជ្ឈង្គទាំងឡាយ ដែលមិនទាន់កើតឡើង ក៏តែងកើតឡើងបានផង ពោជ្ឈង្គទាំងឡាយ ដែលកើតឡើងហើយ ក៏តែងដល់នូវការបរិបូណ៌ ដោយភាវនាផង ។

(៧៧) អប្បមត្តិកា ឯសា ភិក្ខវេ បរិហានិ យទិទំ ញាតិបរិហានិ ឯតំ បដិកិដ្ឋំ ភិក្ខវេ បរិហានីនំ យទិទំ បញ្ញាបរិហានីតិ ។

(៧៨) អប្បមត្តិកា ឯសា ភិក្ខវេ វុឌ្ឍិ យទិទំ ញាតិវុឌ្ឍិ ឯតទគ្គំ ភិក្ខវេ វុឌ្ឍីនំ យទិទំ បញ្ញាវុឌ្ឍិ តស្មាតិហ ភិក្ខវេ ឯវំ សិក្ខិតព្វំ បញ្ញាវុឌ្ឍិយា វឌ្ឍិស្សាមាតិ ឯវំ ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។

(៧៩) អប្បមត្តិកា ឯសា ភិក្ខវេ បរិហានិ យទិទំ ភោគបរិហានិ ឯតំ បដិកិដ្ឋំ ភិក្ខវេ បរិហានីនំ យទិទំ បញ្ញាបរិហានីតិ ។

(៨០) អប្បមត្តិកា ឯសា ភិក្ខវេ វុឌ្ឍិ យទិទំ ភោគវុឌ្ឍិ ឯតទគ្គំ ភិក្ខវេ វុឌ្ឍីនំ យទិទំ បញ្ញាវុឌ្ឍិ តស្មាតិហ ភិក្ខវេ ឯវំ សិក្ខិតព្វំ បញ្ញាវុឌ្ឍិយា វឌ្ឍិស្សាមាតិ ឯវំ ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។



(៧៧) ម្នាលភិក្ខុទាំងឡាយ ការសាបសូន្យខាងញាតិនេះ ជាការសាបសូន្យបន្តិចបន្តួច ម្នាលភិក្ខុទាំងឡាយ ឯការសាបសូន្យខាងបញ្ញានេះ ទើបជាការសាបសូន្យដ៏លាមក ជាងការសាបសូន្យទាំងអស់ ។

(៧៨) ម្នាលភិក្ខុទាំងឡាយ សេចក្តីចំរើនដោយញាតិនេះ ជាសេចក្តីចំរើនបន្តិចបន្តួច ម្នាលភិក្ខុទាំងឡាយ ឯសេចក្តីចំរើនដោយបញ្ញានេះ ទើបជាសេចក្តីចំរើនប្រសើរ ជាងសេចក្តីចំរើនទាំងអស់ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គួរសិក្សាយ៉ាងនេះថា យើងទាំងឡាយនឹងចំរើនដោយបញ្ញាវុឌ្ឍិ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគួរសិក្សាយ៉ាងនេះឯង ។

(៧៩) ម្នាលភិក្ខុទាំងឡាយ ការសាបសូន្យខាងទ្រព្យនេះ ជាការសាបសូន្យបន្តិចបន្តួច ម្នាលភិក្ខុទាំងឡាយ ឯការសាបសូន្យខាងបញ្ញានេះ ទើបជាការសាបសូន្យដ៏លាមក ជាងការសាបសូន្យទាំងអស់ ។

(៨០) ម្នាលភិក្ខុទាំងឡាយ សេចក្តីចំរើនដោយទ្រព្យនេះ ជាសេចក្តីចំរើនបន្តិចបន្តួច ម្នាលភិក្ខុទាំងឡាយ ឯសេចក្តីចំរើនដោយបញ្ញានេះ ទើបជាសេចក្តីចំរើនប្រសើរ ជាងសេចក្តីចំរើនទាំងអស់ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គួរសិក្សាយ៉ាងនេះថា យើងទាំងឡាយនឹងចំរើនដោយបញ្ញាវុឌ្ឍិ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគួរសិក្សាយ៉ាងនេះឯង ។

(៨១) អប្បមត្តិកា ឯសា ភិក្ខវេ បរិហានិ យទិទំ យសោបរិហានិ ឯតំ បដិកិដ្ឋំ ភិក្ខវេ បរិហានីនំ យទិទំ បញ្ញាបរិហានីតិ ។

(៨២) អប្បមត្តិកា ឯសា ភិក្ខវេ វុឌ្ឍិ យទិទំ យសោវុឌ្ឍិ ឯតទគ្គំ ភិក្ខវេ វុឌ្ឍីនំ យទិទំ បញ្ញាវុឌ្ឍិ តស្មាតិហ ភិក្ខវេ ឯវំ សិក្ខិតព្វំ បញ្ញាវុឌ្ឍិយា វឌ្ឍិស្សាមាតិ ឯវំ ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។

វគ្គោ [១] អដ្ឋមោ ។

(៨៣) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យោ ឯវំ មហតោ អនត្ថាយ សំវត្តតិ យថយិទំ ភិក្ខវេ បមាទោ បមាទោ ភិក្ខវេ មហតោ អនត្ថាយ សំវត្តតីតិ ។

(៨៤) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យោ ឯវំ មហតោ អត្ថាយ សំវត្តតិ យថយិទំ ភិក្ខវេ អប្បមាទោ អប្បមាទោ ភិក្ខវេ មហតោ អត្ថាយ សំវត្តតីតិ ។

[១] ម. កល្យាណមិត្តាទិវគ្គោ ។



(៨១) ម្នាលភិក្ខុទាំងឡាយ ការសាបសូន្យបាត់យសនេះ ជាការសាបសូន្យបន្តិចបន្តួចទេ ម្នាលភិក្ខុទាំងឡាយ ឯការសាបសូន្យបាត់បញ្ញានេះ ទើបជាការសាបសូន្យដ៏លាមក ជាងការសាបសូន្យទាំងអស់ ។

(៨២) ម្នាលភិក្ខុទាំងឡាយ សេចក្តីចំរើនដោយយសនេះ ជាសេចក្តីចំរើនបន្តិចបន្តួចទេ ម្នាលភិក្ខុទាំងឡាយ ឯសេចក្តីចំរើនដោយបញ្ញានេះ ទើបជាសេចក្តីចំរើនប្រសើរ ជាងសេចក្តីចំរើនទាំងអស់ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គួរសិក្សាយ៉ាងនេះថា យើងទាំងឡាយ នឹងចំរើនដោយបញ្ញាវុឌ្ឍិ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគួរសិក្សាយ៉ាងនេះឯង ។

ចប់ វគ្គទី ៨ ។

(៨៣) ម្នាលភិក្ខុទាំងឡាយ តថាគតពិនិត្យរកមិនឃើញសភាវៈដទៃសូម្បីតែមួយ ដែលប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍ច្រើន ដូចសេចក្តីប្រមាទនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ មានតែសេចក្តីប្រមាទ ទើបប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍ច្រើន ។

(៨៤) ម្នាលភិក្ខុទាំងឡាយ តថាគតពិនិត្យរកមិនឃើញសភាវៈដទៃសូម្បីតែមួយ ដែលប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ច្រើន ដូចសេចក្តីមិនប្រមាទនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ មានតែសេចក្តីមិនប្រមាទ ទើបប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ច្រើន ។

(៨៥) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យោ ឯវំ មហតោ អនត្ថាយ សំវត្តតិ យថយិទំ ភិក្ខវេ កោសជ្ជំ កោសជ្ជំ ភិក្ខវេ មហតោ អនត្ថាយ សំវត្តតីតិ ។

(៨៦) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យោ ឯវំ មហតោ អត្ថាយ សំវត្តតិ យថយិទំ ភិក្ខវេ វីរិយារម្ភោ វីរិយារម្ភោ ភិក្ខវេ មហតោ អត្ថាយ សំវត្តតីតិ ។

(៨៧) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យោ ឯវំ មហតោ អនត្ថាយ សំវត្តតិ យថយិទំ ភិក្ខវេ មហិច្ឆតា មហិច្ឆតា ភិក្ខវេ មហតោ អនត្ថាយ សំវត្តតីតិ ។

(៨៨) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យោ ឯវំ មហតោ អត្ថាយ សំវត្តតិ យថយិទំ ភិក្ខវេ អប្បិច្ឆតា អប្បិច្ឆតា ភិក្ខវេ មហតោ អត្ថាយ សំវត្តតីតិ ។



(៨៥) ម្នាលភិក្ខុទាំងឡាយ តថាគតមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍ច្រើន ដូចសេចក្តីខ្ជិលច្រអូសនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ ហេតុតែសេចក្តីខ្ជិលច្រអូស ទើបប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍ច្រើន ។

(៨៦) ម្នាលភិក្ខុទាំងឡាយ តថាគតមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ច្រើន ដូចការផ្តើមព្យាយាមនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ មានតែការផ្តើមព្យាយាម ទើបប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ច្រើន ។

(៨៧) ម្នាលភិក្ខុទាំងឡាយ តថាគតមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍ច្រើន ដូចសេចក្តីប្រាថ្នាច្រើននេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ មានតែសេចក្តីប្រាថ្នាច្រើន ទើបប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍ច្រើន ។

(៨៨) ម្នាលភិក្ខុទាំងឡាយ តថាគតមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ច្រើន ដូចសេចក្តីប្រាថ្នាតិចនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ មានតែសេចក្តីប្រាថ្នាតិច ទើបប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ច្រើន ។

[៤៩] នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យោ ឯវំ មហតោ អនត្ថាយ សំវត្តតិ យថយិទំ ភិក្ខវេ អសន្តុដ្ឋិតា អសន្តុដ្ឋិតា ភិក្ខវេ មហតោ អនត្ថាយ សំវត្តតីតិ ។

[៥០] នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យោ ឯវំ មហតោ អត្ថាយ សំវត្តតិ យថយិទំ ភិក្ខវេ សន្តុដ្ឋិតា សន្តុដ្ឋិតា ភិក្ខវេ មហតោ អត្ថាយ សំវត្តតីតិ ។

[៥១] នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យោ ឯវំ មហតោ អនត្ថាយ សំវត្តតិ យថយិទំ ភិក្ខវេ អយោនិសោ មនសិការោ អយោនិសោ មនសិការោ ភិក្ខវេ មហតោ អនត្ថាយ សំវត្តតីតិ ។

[៥២] នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យោ ឯវំ មហតោ អត្ថាយ សំវត្តតិ យថយិទំ ភិក្ខវេ យោនិសោ មនសិការោ យោនិសោ មនសិការោ ភិក្ខវេ មហតោ អត្ថាយ សំវត្តតីតិ ។



[៤៩] ម្នាលភិក្ខុទាំងឡាយ តថាគតមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍ច្រើន ដូចសេចក្តីមិនសន្តោសនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ មានតែសេចក្តីមិនសន្តោស ទើបប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍ច្រើន ។

[៥០] ម្នាលភិក្ខុទាំងឡាយ តថាគតមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ច្រើន ដូចសេចក្តីសន្តោសនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ មានតែសេចក្តីសន្តោស ទើបប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ច្រើន ។

[៥១] ម្នាលភិក្ខុទាំងឡាយ តថាគតមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍ច្រើន ដូចការធ្វើទុកក្នុងចិត្តខុសទំនងនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ មានតែការធ្វើទុកក្នុងចិត្តខុសទំនង ទើបប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍ច្រើន ។

[៥២] ម្នាលភិក្ខុទាំងឡាយ តថាគតមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ច្រើន ដូចការធ្វើទុកក្នុងចិត្តត្រូវទំនងនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ មានតែការធ្វើទុកក្នុងចិត្តត្រូវទំនង ទើបប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ច្រើន ។

[៩៣] នាហំ ភិក្ខវេ អញ្ញំ ឯកធម្មំបិ សមនុបស្សាមិ យោ ឯវំ មហតោ អនត្ថាយ សំវត្តតិ យថយិទំ ភិក្ខវេ អសម្បជញ្ញំ អសម្បជញ្ញំ ភិក្ខវេ មហតោ អនត្ថាយ សំវត្តតីតិ ។

[៩៤] នាហំ ភិក្ខវេ អញ្ញំ ឯកធម្មំបិ សមនុបស្សាមិ យោ ឯវំ មហតោ អត្ថាយ សំវត្តតិ យថយិទំ ភិក្ខវេ សម្បជញ្ញំ សម្បជញ្ញំ ភិក្ខវេ មហតោ អត្ថាយ សំវត្តតីតិ ។

[៩៥] នាហំ ភិក្ខវេ អញ្ញំ ឯកធម្មំបិ សមនុបស្សាមិ យោ ឯវំ មហតោ អនត្ថាយ សំវត្តតិ យថយិទំ ភិក្ខវេ បាបមិត្តតា បាបមិត្តតា ភិក្ខវេ មហតោ អនត្ថាយ សំវត្តតីតិ ។

[៩៦] នាហំ ភិក្ខវេ អញ្ញំ ឯកធម្មំបិ សមនុបស្សាមិ យោ ឯវំ មហតោ អត្ថាយ សំវត្តតិ យថយិទំ ភិក្ខវេ កល្យាណមិត្តតា កល្យាណមិត្តតា ភិក្ខវេ មហតោ អត្ថាយ សំវត្តតីតិ ។



(៩៣) ម្នាលភិក្ខុទាំងឡាយ តថាគតមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍ច្រើន ដូចអសម្បជញ្ញៈ (សេចក្ដីមិនដឹងខ្លួន) នេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ មានតែអសម្បជញ្ញៈ រមែងប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍ច្រើន ។

(៩៤) ម្នាលភិក្ខុទាំងឡាយ តថាគតមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ច្រើន ដូចសម្បជញ្ញៈ (សេចក្ដីដឹងខ្លួន) នេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ មានតែសម្បជញ្ញៈ រមែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ច្រើន ។

(៩៥) ម្នាលភិក្ខុទាំងឡាយ តថាគតមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍ច្រើន ដូចការមានបាបមិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ មានតែការមានបាបមិត្ត រមែងប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍ច្រើន ។

(៩៦) ម្នាលភិក្ខុទាំងឡាយ តថាគតមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ច្រើន ដូចការមានកល្យាណមិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ មានតែការមានកល្យាណមិត្ត រមែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ច្រើន ។

[៩៧] នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យោ ឯវំ មហតោ អនត្ថាយ សំវត្តតិ យថយិទំ ភិក្ខវេ អនុយោគោ អកុសលានំ ធម្មានំ អននុយោគោ កុសលានំ ធម្មានំ អនុយោគោ ភិក្ខវេ អកុសលានំ ធម្មានំ អននុយោគោ កុសលានំ ធម្មានំ មហតោ អនត្ថាយ សំវត្តតីតិ ។

[៩៨] នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យោ ឯវំ មហតោ អត្ថាយ សំវត្តតិ យថយិទំ ភិក្ខវេ អនុយោគោ កុសលានំ ធម្មានំ អននុយោគោ អកុសលានំ ធម្មានំ អនុយោគោ ភិក្ខវេ កុសលានំ ធម្មានំ អននុយោគោ អកុសលានំ ធម្មានំ មហតោ អត្ថាយ សំវត្តតីតិ ។

វគ្គោ(១) នវមោ ។

[៩៩] អជ្ឈត្តិកំ ភិក្ខវេ អង្គន្តិ ករិត្វា នាហំ អញ្ញំ ឯកង្គម្បិ សមនុបស្សាមិ យំ ឯវំ មហតោ អនត្ថាយ សំវត្តតិ យថយិទំ ភិក្ខវេ បមាទោ បមាទោ ភិក្ខវេ មហតោ អនត្ថាយ សំវត្តតីតិ ។

១ ម. បមាទវគ្គោ ។



[៩៧] ម្នាលភិក្ខុទាំងឡាយ តថាគតមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលប្រព្រឹត្តទៅ ដើម្បីឱ្យខូចប្រយោជន៍ច្រើន ដូចកិរិយាប្រកបរឿយ ៗ នូវអកុសលធម៌ នឹងកិរិយាមិនប្រកបរឿយ ៗ នូវកុសលធម៌នេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ មានតែកិរិយាប្រកបរឿយ ៗ នូវអកុសលធម៌ នឹងកិរិយាមិនប្រកបរឿយ ៗ នូវកុសលធម៌ ទើបប្រព្រឹត្តទៅ ដើម្បីឱ្យខូចប្រយោជន៍ច្រើន ។

[៩៨] ម្នាលភិក្ខុទាំងឡាយ តថាគតមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ច្រើន ដូចកិរិយាប្រកបរឿយ ៗ នូវកុសលធម៌ នឹងកិរិយាមិនប្រកបរឿយ ៗ នូវអកុសលធម៌នេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ មានតែកិរិយាប្រកបរឿយ ៗ នូវកុសលធម៌ នឹងកិរិយាមិនប្រកបរឿយ ៗ នូវអកុសលធម៌ ទើបប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ច្រើន ។

ចប់វគ្គទី ៩ ។

[៩៩] ម្នាលភិក្ខុទាំងឡាយ តថាគតមិនឃើញអង្គដទៃ ដែលជាអង្គខាងក្នុង សូម្បីតែអង្គ ១ ដែលប្រព្រឹត្តទៅ ដើម្បីឱ្យខូចប្រយោជន៍ច្រើន ដូចសេចក្តីប្រមាទនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ មានតែសេចក្តីប្រមាទ ទើបប្រព្រឹត្តទៅ ដើម្បីឱ្យខូចប្រយោជន៍ច្រើន ។

(១០០) អជ្ឈត្តិកំ ភិក្ខវេ អង្គន្តិ ករិត្វា នាញ្ញំ ឯកង្គម្បិ សមនុបស្សាមិ យំ ឯវំ មហតោ អត្ថាយ សំវត្តតិ យថយិទំ ភិក្ខវេ អប្បមាទោ អប្បមាទោ ភិក្ខវេ មហតោ អត្ថាយ សំវត្តតីតិ ។

(១០១) អជ្ឈត្តិកំ ភិក្ខវេ អង្គន្តិ ករិត្វា នាញ្ញំ ឯកង្គម្បិ សមនុបស្សាមិ យំ ឯវំ មហតោ អនត្ថាយ សំវត្តតិ យថយិទំ ភិក្ខវេ កោសជ្ជំ កោសជ្ជំ ភិក្ខវេ មហតោ អនត្ថាយ សំវត្តតីតិ ។

(១០២) អជ្ឈត្តិកំ ភិក្ខវេ អង្គន្តិ ករិត្វា នាញ្ញំ ឯកង្គម្បិ សមនុបស្សាមិ យំ ឯវំ មហតោ អត្ថាយ សំវត្តតិ យថយិទំ ភិក្ខវេ វីរិយារម្ភោ វីរិយារម្ភោ ភិក្ខវេ មហតោ អត្ថាយ សំវត្តតីតិ ។

(១០៣) អជ្ឈត្តិកំ ភិក្ខវេ អង្គន្តិ ករិត្វា នាញ្ញំ ឯកង្គម្បិ សមនុបស្សាមិ ។បេ។ មហិច្ឆតា ភិក្ខវេ មហតោ អនត្ថាយ សំវត្តតីតិ ។



(១០០) ម្នាលភិក្ខុទាំងឡាយ តថាគតរកមិនឃើញអង្គដទៃ ដែលជាអជ្ឈត្តិកៈ សូម្បីតែអង្គ ១ ដែលប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ច្រើន ដូចសេចក្តីមិនប្រមាទនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ មានតែសេចក្តីមិនប្រមាទ រមែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ច្រើន ។

(១០១) ម្នាលភិក្ខុទាំងឡាយ តថាគតរកមិនឃើញអង្គដទៃ ដែលជាអជ្ឈត្តិកៈ សូម្បីតែអង្គ ១ ដែលប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍ច្រើន ដូចសេចក្តីខ្ជិលច្រអូសនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ មានតែសេចក្តីខ្ជិលច្រអូស រមែងប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍ច្រើន ។

(១០២) ម្នាលភិក្ខុទាំងឡាយ តថាគតរកមិនឃើញអង្គដទៃ ដែលជាអជ្ឈត្តិកៈ សូម្បីតែអង្គ ១ ដែលប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ច្រើន ដូចការប្រារព្ធព្យាយាមនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ មានតែការប្រារព្ធព្យាយាម រមែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ច្រើន ។

(១០៣) ម្នាលភិក្ខុទាំងឡាយ តថាគតរកមិនឃើញអង្គដទៃ ដែលជាអជ្ឈត្តិកៈ សូម្បីតែអង្គ ១ ។បេ។ ម្នាលភិក្ខុទាំងឡាយ មានតែសេចក្តីប្រាថ្នាច្រើន រមែងប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍ច្រើន ។

(១០៤) អជ្ឈត្តិកំ ភិក្ខវេ អង្គន្តិ ករិត្វា នាញ្ញំ ឯកង្គម្បិ សមនុបស្សាមិ ។ បេ ។ អប្បិច្ឆតា ភិក្ខវេ មហតោ អត្ថាយ សំវត្តតីតិ ។

(១០៥) អជ្ឈត្តិកំ ភិក្ខវេ អង្គន្តិ ករិត្វា នាញ្ញំ ឯកង្គម្បិ សមនុបស្សាមិ ។ បេ ។ អសន្តុដ្ឋិតា ភិក្ខវេ មហតោ អនត្ថាយ សំវត្តតីតិ ។

(១០៦) អជ្ឈត្តិកំ ភិក្ខវេ អង្គន្តិ ករិត្វា នាញ្ញំ ឯកង្គម្បិ សមនុបស្សាមិ ។ បេ ។ សន្តុដ្ឋិតា ភិក្ខវេ មហតោ អត្ថាយ សំវត្តតីតិ ។

(១០៧) អជ្ឈត្តិកំ ភិក្ខវេ អង្គន្តិ ករិត្វា នាញ្ញំ ឯកង្គម្បិ សមនុបស្សាមិ ។ បេ ។ អយោនិសោ មនសិការោ ភិក្ខវេ មហតោ អនត្ថាយ សំវត្តតីតិ ។

(១០៨) អជ្ឈត្តិកំ ភិក្ខវេ អង្គន្តិ ករិត្វា នាញ្ញំ ឯកង្គម្បិ សមនុបស្សាមិ ។ បេ ។ យោនិសោ មនសិការោ ភិក្ខវេ មហតោ អត្ថាយ សំវត្តតីតិ ។



(១០៤) ម្នាលភិក្ខុទាំងឡាយ តថាគតពិចារណាមិនឃើញអង្គដទៃ ដែលជាអង្គខាងក្នុង សូម្បីតែអង្គ ១ សោះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ មានតែសេចក្តីប្រាថ្នាតិច ទើបប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ច្រើន ។

(១០៥) ម្នាលភិក្ខុទាំងឡាយ តថាគតពិចារណាមិនឃើញអង្គដទៃ ដែលជាអង្គខាងក្នុង សូម្បីតែអង្គ ១ សោះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ មានតែសេចក្តីមិនសន្តោស ទើបប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍ច្រើន ។

(១០៦) ម្នាលភិក្ខុទាំងឡាយ តថាគតពិចារណាមិនឃើញអង្គដទៃ ដែលជាអង្គខាងក្នុង សូម្បីតែអង្គ ១ សោះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ មានតែសេចក្តីសន្តោស ទើបប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ច្រើន ។

(១០៧) ម្នាលភិក្ខុទាំងឡាយ តថាគតពិចារណាមិនឃើញអង្គដទៃ ដែលជាអង្គខាងក្នុង សូម្បីតែអង្គ ១ សោះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ មានតែការធ្វើទុកក្នុងចិត្តដោយមិនឧបាយ ទើបប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍ច្រើន ។

(១០៨) ម្នាលភិក្ខុទាំងឡាយ តថាគតពិចារណាមិនឃើញអង្គដទៃ ដែលជាអង្គខាងក្នុង សូម្បីតែអង្គ ១ សោះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ មានតែការធ្វើទុកក្នុងចិត្តដោយឧបាយ ទើបប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ច្រើន ។

(១០៩) អជ្ឈត្តិកំ ភិក្ខវេ អង្គន្តិ ករិត្វា នាញ្ញំ ឯកង្គម្បិ សមនុបស្សាមិ ។បេ។ អសម្បជញ្ញំ ភិក្ខវេ មហតោ អនត្ថាយ សំវត្តតីតិ ។

(១១០) អជ្ឈត្តិកំ ភិក្ខវេ អង្គន្តិ ករិត្វា នាញ្ញំ ឯកង្គម្បិ សមនុបស្សាមិ ។បេ។ សម្បជញ្ញំ ភិក្ខវេ មហតោ អត្ថាយ សំវត្តតីតិ ។

(១១១) ពាហិរំ ភិក្ខវេ អង្គន្តិ ករិត្វា នាញ្ញំ ឯកង្គម្បិ សមនុបស្សាមិ យំ ឯវំ មហតោ អនត្ថាយ សំវត្តតិ យថយិទំ ភិក្ខវេ បាបមិត្តតា បាបមិត្តតា ភិក្ខវេ មហតោ អនត្ថាយ សំវត្តតីតិ ។

(១១២) ពាហិរំ ភិក្ខវេ អង្គន្តិ ករិត្វា នាញ្ញំ ឯកង្គម្បិ សមនុបស្សាមិ យំ ឯវំ មហតោ អត្ថាយ សំវត្តតិ យថយិទំ ភិក្ខវេ កល្យាណមិត្តតា កល្យាណមិត្តតា ភិក្ខវេ មហតោ អត្ថាយ សំវត្តតីតិ ។

(១១៣) អជ្ឈត្តិកំ ភិក្ខវេ អង្គន្តិ ករិត្វា នាញ្ញំ ឯកង្គម្បិ សមនុបស្សាមិ យំ ឯវំ មហតោ



(១០៩) ម្នាលភិក្ខុទាំងឡាយ តថាគតពិនិត្យមិនឃើញអង្គដទៃ ដែលជាអង្គខាងក្នុង សូម្បីតែអង្គ ១ នោះ ។បេ។ ម្នាលភិក្ខុទាំងឡាយ មានតែអសម្បជញ្ញៈ ទើបប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍ច្រើន ។

(១១០) ម្នាលភិក្ខុទាំងឡាយ តថាគតពិនិត្យមិនឃើញអង្គដទៃ ដែលជាអង្គខាងក្នុង សូម្បីតែអង្គ ១ នោះ ។បេ។ ម្នាលភិក្ខុទាំងឡាយ មានតែសម្បជញ្ញៈ ទើបប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ច្រើន ។

(១១១) ម្នាលភិក្ខុទាំងឡាយ តថាគតពិនិត្យមិនឃើញអង្គដទៃ ដែលជាអង្គខាងក្រៅ ដែលប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍ច្រើន ដូចការមានបាបមិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ មានតែការមានបាបមិត្ត ទើបប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍ច្រើន ។

(១១២) ម្នាលភិក្ខុទាំងឡាយ តថាគតពិនិត្យមិនឃើញអង្គដទៃ ដែលជាអង្គខាងក្រៅ ដែលប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ច្រើន ដូចការមានកល្យាណមិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ មានតែការមានកល្យាណមិត្ត ទើបប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ច្រើន ។

(១១៣) ម្នាលភិក្ខុទាំងឡាយ តថាគតពិនិត្យមិនឃើញអង្គដទៃ ដែលជាអង្គខាងក្នុង ដែលប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍ច្រើន

អនត្ថាយ សំវត្តតិ យថយិទំ ភិក្ខវេ អនុយោគោ អកុសលានំ ធម្មានំ អននុយោគោ កុសលានំ ធម្មានំ អនុយោគោ ភិក្ខវេ អកុសលានំ ធម្មានំ អននុយោគោ កុសលានំ ធម្មានំ មហតោ អនត្ថាយ សំវត្តតីតិ ។

(១១៦) អជ្ឈត្តិកំ ភិក្ខវេ អង្គន្តិ ករិត្វា នាហំ ឯកង្គម្បិ សមនុបស្សាមិ យំ ឯវំ មហតោ អត្ថាយ សំវត្តតិ យថយិទំ ភិក្ខវេ អនុយោគោ កុសលានំ ធម្មានំ អននុយោគោ អកុសលានំ ធម្មានំ អនុយោគោ ភិក្ខវេ កុសលានំ ធម្មានំ អននុយោគោ អកុសលានំ ធម្មានំ មហតោ អត្ថាយ សំវត្តតីតិ ។

(១១៧) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យោ ឯវំ សទ្ធម្មស្ស សម្មោសាយ អន្តរធានាយ សំវត្តតិ យថយិទំ ភិក្ខវេ បមាទោ បមាទោ ភិក្ខវេ សទ្ធម្មស្ស សម្មោសាយ អន្តរធានាយ សំវត្តតីតិ ។



ដូចកិរិយាប្រកបរឿយៗ នូវអកុសលធម៌ទាំងឡាយ និងកិរិយាមិនប្រកបរឿយៗ នូវកុសលធម៌ទាំងឡាយនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ មានតែកិរិយាប្រកបរឿយៗ នូវអកុសលធម៌ទាំងឡាយ និងកិរិយាមិនប្រកបរឿយៗ នូវកុសលធម៌ទាំងឡាយ ទើបប្រព្រឹត្តទៅ ដើម្បីខូចប្រយោជន៍ច្រើន ។

(១១៦) ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញអង្គដទៃ ដែលជាអង្គខាងក្នុង សូម្បីតែមួយ ដែលប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ច្រើន ដូចកិរិយាប្រកបរឿយៗ នូវកុសលធម៌ទាំងឡាយ និងកិរិយាមិនប្រកបរឿយៗ នូវអកុសលធម៌ទាំងឡាយនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ មានតែកិរិយាប្រកបរឿយៗ នូវកុសលធម៌ទាំងឡាយ និងកិរិយាមិនប្រកបរឿយៗ នូវអកុសលធម៌ទាំងឡាយ ទើបប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ច្រើន ។

(១១៧) ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈមួយ ដែលប្រព្រឹត្តទៅ ដើម្បីវិនាស ដើម្បីអន្តរធាននៃព្រះសទ្ធម្ម ដូចសេចក្តីប្រមាទនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ មានតែសេចក្តីប្រមាទ ទើបប្រព្រឹត្តទៅ ដើម្បីវិនាស ដើម្បីអន្តរធាននៃព្រះសទ្ធម្ម ។

(១១៦) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យោ ឯវំ សទ្ធម្មស្ស ឋិតិយា អសម្មោសាយ អនន្តរធានាយ សំវត្តតិ យថយិទំ ភិក្ខវេ អប្បមាទោ អប្បមាទោ ភិក្ខវេ សទ្ធម្មស្ស ឋិតិយា អសម្មោសាយ អនន្តរធានាយ សំវត្តតីតិ ។

(១១៧) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យោ ឯវំ សទ្ធម្មស្ស សម្មោសាយ អន្តរធានាយ សំវត្តតិ យថយិទំ ភិក្ខវេ កោសជ្ជំ កោសជ្ជំ ភិក្ខវេ សទ្ធម្មស្ស សម្មោសាយ អន្តរធានាយ សំវត្តតីតិ ។

(១១៨) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យោ ឯវំ សទ្ធម្មស្ស ឋិតិយា អសម្មោសាយ អនន្តរធានាយ សំវត្តតិ យថយិទំ ភិក្ខវេ វីរិយារម្ភោ វីរិយារម្ភោ ភិក្ខវេ សទ្ធម្មស្ស ឋិតិយា អសម្មោសាយ អនន្តរធានាយ សំវត្តតីតិ ។





(១១៦) ម្នាលភិក្ខុទាំងឡាយ តថាគតពិនិត្យមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ១ ដែលប្រព្រឹត្តទៅ ដើម្បីឋិតនៅ មិនវិនាស មិនអន្តរធាននៃព្រះសទ្ធម្ម ដូចសេចក្តីមិនប្រមាទនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ មានតែសេចក្តីមិនប្រមាទ ទើបប្រព្រឹត្តទៅ ដើម្បីឋិតនៅ មិនវិនាស មិនអន្តរធាននៃព្រះសទ្ធម្មឡើយ ។

(១១៧) ម្នាលភិក្ខុទាំងឡាយ តថាគតពិនិត្យមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ១ ដែលប្រព្រឹត្តទៅ ដើម្បីវិនាស ដើម្បីអន្តរធាននៃព្រះសទ្ធម្ម ដូចសេចក្តីខ្ជិលច្រអូសនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ មានតែសេចក្តីខ្ជិលច្រអូស ទើបប្រព្រឹត្តទៅ ដើម្បីវិនាស ដើម្បីអន្តរធាននៃព្រះសទ្ធម្ម ។

(១១៨) ម្នាលភិក្ខុទាំងឡាយ តថាគតពិនិត្យមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ១ ដែលប្រព្រឹត្តទៅ ដើម្បីឋិតនៅ មិនវិនាស មិនអន្តរធាននៃព្រះសទ្ធម្ម ដូចការប្រារព្ធព្យាយាមនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ មានតែការប្រារព្ធព្យាយាម ទើបប្រព្រឹត្តទៅ ដើម្បីឋិតនៅ មិនវិនាស មិនអន្តរធាននៃព្រះសទ្ធម្មឡើយ ។

(១៥៩) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មំបិ សមនុបស្សាមិ ។បេ។ មហិច្ឆតា ភិក្ខវេ សទ្ធម្មស្ស សម្មោសាយ អន្តរធានាយ សំវត្តតិ ។

(១៦០) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មំបិ សមនុបស្សាមិ ។បេ។ អប្បិច្ឆតា ភិក្ខវេ សទ្ធម្មស្ស ឋិតិយា អសម្មោសាយ អនន្តរធានាយ សំវត្តតិ ។

(១៦១) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មំបិ សមនុបស្សាមិ ។បេ។ អសន្តុដ្ឋិតា ភិក្ខវេ សទ្ធម្មស្ស សម្មោសាយ អន្តរធានាយ សំវត្តតិ ។

(១៦២) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មំបិ សមនុបស្សាមិ ។បេ។ សន្តុដ្ឋិតា ភិក្ខវេ សទ្ធម្មស្ស ឋិតិយា អសម្មោសាយ អនន្តរធានាយ សំវត្តតិ ។

(១៦៣) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មំបិ សមនុបស្សាមិ ។បេ។ អយោនិសោ មនសិការោ ភិក្ខវេ សទ្ធម្មស្ស សម្មោសាយ អន្តរធានាយ សំវត្តតិ ។



(១៥៩) ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ១ សោះ ។បេ។ ម្នាលភិក្ខុទាំងឡាយ មានតែសេចក្តីប្រាថ្នាច្រើន រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីវិនាស ដើម្បីអន្តរធាននៃព្រះសទ្ធម្ម ។

(១៦០) ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ១ សោះ ។បេ។ ម្នាលភិក្ខុទាំងឡាយ មានតែសេចក្តីប្រាថ្នាតិច រមែងប្រព្រឹត្តទៅ ដើម្បីឋិតនៅ មិនវិនាស មិនអន្តរធាននៃព្រះសទ្ធម្មឡើយ ។

(១៦១) ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ១ សោះ ។បេ។ ម្នាលភិក្ខុទាំងឡាយ មានតែសេចក្តីមិនសន្តោស រមែងប្រព្រឹត្តទៅ ដើម្បីវិនាស ដើម្បីអន្តរធាននៃព្រះសទ្ធម្ម ។

(១៦២) ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ១ សោះ ។បេ។ ម្នាលភិក្ខុទាំងឡាយ មានតែសេចក្តីសន្តោស រមែងប្រព្រឹត្តទៅ ដើម្បីឋិតនៅ មិនវិនាស មិនអន្តរធាននៃព្រះសទ្ធម្មឡើយ ។

(១៦៣) ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ១ សោះ ។បេ។ ម្នាលភិក្ខុទាំងឡាយ មានតែការធ្វើទុកក្នុងចិត្តខុសទំនង រមែងប្រព្រឹត្តទៅ ដើម្បីវិនាស ដើម្បីអន្តរធាននៃព្រះសទ្ធម្ម

(១៦៤) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ ។បេ។ យោនិសោ មនសិការោ ភិក្ខវេ សទ្ធម្មស្ស ឋិតិយា អសម្មោសាយ អនន្តរធានាយ សំវត្តតិ ។

(១៦៥) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ ។បេ។ អសម្បជញ្ញំ ភិក្ខវេ សទ្ធម្មស្ស សម្មោសាយ អន្តរធានាយ សំវត្តតិ ។

(១៦៦) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ ។បេ។ សម្បជញ្ញំ ភិក្ខវេ សទ្ធម្មស្ស ឋិតិយា អសម្មោសាយ អនន្តរធានាយ សំវត្តតិ ។

(១៦៧) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ ។បេ។ បាបមិត្តតា ភិក្ខវេ សទ្ធម្មស្ស សម្មោសាយ អន្តរធានាយ សំវត្តតិ ។



(១៦៤) ម្នាលភិក្ខុទាំងឡាយ តថាគតមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈមួយ ។បេ។ ម្នាលភិក្ខុទាំងឡាយ ការធ្វើទុកក្នុងចិត្តត្រូវទំនង រមែងប្រព្រឹត្តទៅ ដើម្បីឋិតនៅ មិនវិនាស មិនអន្តរធាននៃព្រះសទ្ធម្មឡើយ ។

(១៦៥) ម្នាលភិក្ខុទាំងឡាយ តថាគតមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈមួយ ។បេ។ ម្នាលភិក្ខុទាំងឡាយ ភាពនៃអសម្បជញ្ញៈ រមែងប្រព្រឹត្តទៅ ដើម្បីវិនាស ដើម្បីអន្តរធាននៃព្រះសទ្ធម្ម ។

(១៦៦) ម្នាលភិក្ខុទាំងឡាយ តថាគតមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈមួយ ។បេ។ ម្នាលភិក្ខុទាំងឡាយ ភាពនៃសម្បជញ្ញៈ រមែងប្រព្រឹត្តទៅ ដើម្បីឋិតនៅ មិនវិនាស មិនអន្តរធាននៃព្រះសទ្ធម្មឡើយ ។

(១៦៧) ម្នាលភិក្ខុទាំងឡាយ តថាគតមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈមួយ ។បេ។ ម្នាលភិក្ខុទាំងឡាយ ភាពនៃការមានបាបមិត្ត រមែងប្រព្រឹត្តទៅ ដើម្បីវិនាស ដើម្បីអន្តរធាននៃព្រះសទ្ធម្ម ។

(១២៨) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ ។បេ។ កល្យាណមិត្តតា ភិក្ខវេ សទ្ធម្មស្ស ឋិតិយា អសម្មោសាយ អនន្តរធានាយ សំវត្តតីតិ ។

(១២៩) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ ។បេ។ អនុយោគោ ភិក្ខវេ អកុសលានំ ធម្មានំ អននុយោគោ កុសលានំ ធម្មានំ សទ្ធម្មស្ស សម្មោសាយ អន្តរធានាយ សំវត្តតីតិ ។

(១៣០) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យោ ឯវំ សទ្ធម្មស្ស ឋិតិយា អសម្មោសាយ អនន្តរធានាយ សំវត្តតិ យថយិទំ ភិក្ខវេ អនុយោគោ កុសលានំ ធម្មានំ អននុយោគោ អកុសលានំ ធម្មានំ អនុយោគោ ភិក្ខវេ កុសលានំ ធម្មានំ អននុយោគោ អកុសលានំ ធម្មានំ សទ្ធម្មស្ស ឋិតិយា អសម្មោសាយ អនន្តរធានាយ សំវត្តតីតិ ។

វគ្គោ ទសមោ ។



(១២៨) ម្នាលភិក្ខុទាំងឡាយ តថាគតមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ១ សោះ ។បេ។ ម្នាលភិក្ខុទាំងឡាយ មានតែការមានកល្យាណមិត្ត រមែងប្រព្រឹត្តទៅ ដើម្បីឋិតនៅ មិនវិនាស មិនអន្តរធាននៃព្រះសទ្ធម្មឡើយ ។

(១២៩) ម្នាលភិក្ខុទាំងឡាយ តថាគតមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ១ សោះ ។បេ។ ម្នាលភិក្ខុទាំងឡាយ មានតែកិរិយាប្រកបរឿយៗ នូវអកុសលធម៌ទាំងឡាយ និងកិរិយាមិនប្រកបរឿយៗ នូវកុសលធម៌ទាំងឡាយ រមែងប្រព្រឹត្តទៅ ដើម្បីវិនាស ដើម្បីអន្តរធាននៃព្រះសទ្ធម្ម ។

(១៣០) ម្នាលភិក្ខុទាំងឡាយ តថាគតមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ១ ដែលប្រព្រឹត្តទៅ ដើម្បីឋិតនៅ មិនវិនាស មិនអន្តរធាននៃព្រះសទ្ធម្ម ដូចកិរិយាប្រកបរឿយៗ នូវកុសលធម៌ទាំងឡាយ និងកិរិយាមិនប្រកបរឿយៗ នូវអកុសលធម៌ទាំងឡាយនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ មានតែកិរិយាប្រកបរឿយៗ នូវកុសលធម៌ទាំងឡាយ និងកិរិយាមិនប្រកបរឿយៗ នូវអកុសលធម៌ទាំងឡាយ រមែងប្រព្រឹត្តទៅ ដើម្បីឋិតនៅ មិនវិនាស មិនអន្តរធាននៃព្រះសទ្ធម្មឡើយ ។

ចប់វគ្គទី ១០ ។

(១៣១) យេ តេ ភិក្ខវេ ភិក្ខូ អធម្មំ ធម្មោតិ ទីបេន្តិ តេ ភិក្ខវេ ភិក្ខូ ពហុជនាហិតាយ បដិបន្នា ពហុជនាសុខាយ ពហុនោ ជនស្ស អនត្ថាយ អហិតាយ ទុក្ខាយ ទេវមនុស្សានំ ពហុញ្ច តេ ភិក្ខវេ ភិក្ខូ អបុញ្ញំ បសវន្តិ តេ ចិមំ សទ្ធម្មំ អន្តរធាបេន្តីតិ ។

(១៣២) យេ តេ ភិក្ខវេ ភិក្ខូ ធម្មំ អធម្មោតិ ទីបេន្តិ ។បេ។ អវិនយំ វិនយោតិ ទីបេន្តិ ។បេ។ វិនយំ អវិនយោតិ ទីបេន្តិ ។បេ។ អភាសិតំ អលបិតំ តថាគតេន ភាសិតំ លបិតំ តថាគតេនាតិ ទីបេន្តិ ។បេ។ ភាសិតំ លបិតំ តថាគតេន អភាសិតំ អលបិតំ តថាគតេនាតិ ទីបេន្តិ ។បេ។ អនាចិណ្ណំ តថាគតេន អាចិណ្ណំ តថាគតេនាតិ ទីបេន្តិ ។បេ។ អាចិណ្ណំ តថាគតេន អនាចិណ្ណំ តថាគតេនាតិ ទីបេន្តិ ។បេ។ អបញ្ញត្តំ តថាគតេន



(១៣១) ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយណា សំដែងនូវសភាពមិនមែនជាធម៌ថាជាធម៌ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះឈ្មោះថាប្រតិបត្តិដើម្បីមិនជាគុណដល់ជនច្រើន ដើម្បីមិនជាសុខដល់ជនច្រើន ដើម្បីមិនជាប្រយោជន៍ដល់ជនច្រើន ដើម្បីមិនជាគុណ ដើម្បីសេចក្តីទុក្ខ ដល់ទេវតានិងមនុស្សទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះ រមែងបាននូវបាបច្រើន មិនតែប៉ុណ្ណោះ ភិក្ខុទាំងនោះឈ្មោះថាធ្វើព្រះសទ្ធម្មនេះឲ្យអន្តរធានទៅ ។

(១៣២) ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយណា សំដែងនូវធម៌ ថាមិនមែនជាធម៌ ។បេ។ សំដែងនូវសភាពមិនមែនវិន័យ ថាជាវិន័យ ។បេ។ សំដែងនូវវិន័យថាមិនមែនជាវិន័យ ។បេ។ សំដែងនូវពាក្យដែលព្រះតថាគត មិនសំដែងមិនពោលទុកទេ ថាជាពាក្យដែលព្រះតថាគត បានសំដែងបានពោលហើយ ។បេ។ សំដែងនូវពាក្យដែលព្រះតថាគត បានសំដែងបានពោលហើយ ថាជាពាក្យដែលព្រះតថាគតមិនសំដែងមិនពោលទេ ។បេ។ សំដែងនូវវត្តដែលព្រះតថាគតមិនសន្សំសោះ ថាជាវត្តដែលព្រះតថាគតបានសន្សំហើយ ។បេ។ សំដែងនូវវត្តដែលព្រះតថាគតបានសន្សំហើយ ថាជាវត្តដែលព្រះតថាគតមិនសន្សំទេ ។បេ។ សំដែងនូវសិក្ខាបទដែលព្រះតថាគតមិនបញ្ញត្តសោះ

បញ្ញត្តំ តថាគតេនាតិ ទីបេន្តិ ។បេ។ បញ្ញត្តំ តថាគតេន អប្បញ្ញត្តំ តថាគតេនាតិ ទីបេន្តិ តេ ភិក្ខវេ ភិក្ខូ ពហុជនាហិតាយ បដិបន្នា ពហុជនា-សុខាយ ពហុនោ ជនស្ស អនត្ថាយ អហិតាយ ទុក្ខាយ ទេវមនុស្សានំ ពហុញ្ច តេ ភិក្ខវេ ភិក្ខូ អបុញ្ញំ បសវន្តិ តេ ចិមំ សទ្ធម្មំ អន្តរធាបេន្តីតិ ។

[១៣៣] យេ តេ ភិក្ខវេ ភិក្ខូ អធម្មំ អធម្មោតិ ទីបេន្តិ តេ ភិក្ខវេ ភិក្ខូ ពហុជនហិ-តាយ បដិបន្នា ពហុជនសុខាយ ពហុនោ ជនស្ស អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ ពហុញ្ច តេ ភិក្ខវេ ភិក្ខូ បុញ្ញំ បសវន្តិ តេ ចិមំ សទ្ធម្មំ ឋបេន្តីតិ ។

[១៣៤] យេ តេ ភិក្ខវេ ភិក្ខូ ធម្មំ ធម្មោតិ ទីបេន្តិ ។បេ។ អវិនយំ អវិនយោតិ ទីបេន្តិ ។បេ។



ថាជាសិក្ខាបទដែលព្រះតថាគតបានបញ្ញត្តហើយ ។បេ។ សំដែងនូវសិក្ខាបទដែលព្រះតថាគតបានបញ្ញត្តហើយ ថាជាសិក្ខាបទដែលព្រះតថាគតមិនបានបញ្ញត្តទេ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយនោះ ឈ្មោះថាប្រតិបត្តិ ដើម្បីមិនជាគុណដល់ជនច្រើន ដើម្បីមិនជាសុខដល់ជនច្រើន ដើម្បីវិនាសប្រយោជន៍ដល់ជនច្រើន ដើម្បីមិនជាគុណ ដើម្បីសេចក្តីទុក្ខដល់ទេវតានិងមនុស្សទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះ រមែងបាននូវបាបច្រើន មិនតែប៉ុណ្ណោះ ភិក្ខុទាំងនោះឈ្មោះថាធ្វើព្រះសទ្ធម្មនេះឲ្យអន្តរធានទៅ ។

(១៣៣) ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយណា សំដែងនូវសភាពមិនមែនជាធម៌ ថាជាសភាពមិនមែនជាធម៌ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះឈ្មោះថា ប្រតិបត្តិដើម្បីជាគុណដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីជាគុណ ដើម្បីសេចក្តីសុខដល់ទេវតានិងមនុស្សទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះ រមែងបាននូវបុណ្យច្រើន មិនតែប៉ុណ្ណោះ ភិក្ខុទាំងនោះ ឈ្មោះថា ធ្វើព្រះសទ្ធម្មនេះឲ្យឋិតនៅ ។

(១៣៤) ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយណា សំដែងធម៌ ថាជាធម៌ ។បេ។ សំដែងនូវសភាពមិនមែនជាវិន័យ ថាមិនមែនជាវិន័យទេ ។បេ។

វិនយំ វិនយោតិ ទីបេន្តិ ។បេ។ អភាសិតំ អលបិតំ តថាគតេន អភាសិតំ អលបិតំ តថាគតេនាតិ ទីបេន្តិ ។បេ។ ភាសិតំ លបិតំ តថាគតេន ភាសិតំ លបិតំ តថាគតេនាតិ ទីបេន្តិ ។បេ។ អនាចិណ្ណំ តថាគតេន អនាចិណ្ណំ តថាគតេនាតិ ទីបេន្តិ ។បេ។ អាចិណ្ណំ តថាគតេន អាចិណ្ណំ តថាគតេនាតិ ទីបេន្តិ ។បេ។ អបញ្ញត្តំ តថាគតេន អបញ្ញត្តំ តថាគតេនាតិ ទីបេន្តិ ។បេ។ បញ្ញត្តំ តថាគតេន បញ្ញត្តំ តថាគតេនាតិ ទីបេន្តិ តេ ភិក្ខវេ ភិក្ខូ ពហុជនហិតាយ បដិបន្នា ពហុជនសុខាយ ពហុនោ ជនស្ស អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ ពហុញ្ច តេ ភិក្ខវេ ភិក្ខូ បុញ្ញំ បសវន្តិ តេ ចិមំ សទ្ធម្មំ ឋបេន្តីតិ ។

វគ្គោ(១)ទុតិយោ ។

១ ម. អធម្មវគ្គោ ។



សំដែងវិន័យថាជាវិន័យ ។បេ។ សំដែងនូវពាក្យដែលព្រះតថាគតមិនសំដែង មិនពោលនោះ ថាជាពាក្យដែលព្រះតថាគតមិនសំដែង មិនពោល ។បេ។ សំដែងនូវពាក្យដែលព្រះតថាគតបានសំដែង បានពោលហើយ ថាជាពាក្យដែលព្រះតថាគត បានសំដែង បានពោល ។បេ។ សំដែងនូវកិច្ច ដែលព្រះតថាគតមិនសន្សំនោះ ថាជាកិច្ចដែលព្រះតថាគតមិនបានសន្សំ ។បេ។ សំដែងនូវកិច្ចដែលព្រះតថាគត បានសន្សំហើយ ថាជាកិច្ចដែលព្រះតថាគតបានសន្សំ ។បេ។ សំដែងនូវសិក្ខាបទ ដែលព្រះតថាគត មិនបញ្ញត្តនោះ ថាជាសិក្ខាបទដែលព្រះតថាគតមិនបញ្ញត្ត ។បេ។ សំដែងនូវសិក្ខាបទ ដែលព្រះតថាគត បានបញ្ញត្តហើយថាជាសិក្ខាបទដែលព្រះតថាគតបានបញ្ញត្តហើយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះ ឈ្មោះថាប្រតិបត្តិ ដើម្បីជាគុណដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីជាគុណ ដើម្បីសេចក្តីសុខដល់ទេវតានិងមនុស្សទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះ តែងបានបុណ្យច្រើន មិនតែប៉ុណ្ណោះ ភិក្ខុទាំងនោះ ឈ្មោះថាធ្វើព្រះសទ្ធម្មនេះឲ្យឋិតនៅ ។

ចប់ វគ្គទី ១១ ។

(១៣៩) យេ តេ ភិក្ខវេ ភិក្ខូ អនាបត្តឹ អាបត្តីតិ ទីបេន្តិ ។បេ។ អាបត្តឹ អនាបត្តីតិ ទីបេន្តិ ។បេ។ លហុកំ អាបត្តឹ គរុកា អាបត្តីតិ ទីបេន្តិ ។បេ។ គរុកំ អាបត្តឹ លហុកា អាបត្តីតិ ទីបេន្តិ ។បេ។ ទុដ្ឋុល្លំ អាបត្តឹ អទុដ្ឋុល្លា អាបត្តីតិ ទីបេន្តិ ។បេ។ អទុដ្ឋុល្លំ អាបត្តឹ ទុដ្ឋុល្លា អាបត្តីតិ ទីបេន្តិ ។បេ។ សាវសេសំ អាបត្តឹ អនវសេសា អាបត្តីតិ ទីបេន្តិ ។បេ។ អនវសេសំ អាបត្តឹ សាវសេសា អាបត្តីតិ ទីបេន្តិ ។បេ។ សប្បដិកម្មំ អាបត្តឹ អប្បដិកម្មា អាបត្តីតិ ទីបេន្តិ ។បេ។ អប្បដិកម្មំ អាបត្តឹ សប្បដិកម្មា អាបត្តីតិ ទីបេន្តិ តេ ភិក្ខវេ ភិក្ខូ ពហុជនាហិតាយ បដិបន្នា ពហុជនាសុខាយ ពហុនោ ជនស្ស អនត្ថាយ អហិតាយ ទុក្ខាយ ទេវមនុស្សានំ ពហុញ្ច តេ ភិក្ខវេ ភិក្ខូ អបុញ្ញំ បសវន្តិ តេ ចិមំ សទ្ធម្មំ អន្តរធាបេន្តីតិ ។



(១៣៩) ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយណា សំដែងនូវអនាបត្តិ ថាជាអាបត្តិ ។បេ។ សំដែងនូវអាបត្តិថាជាអនាបត្តិ ។បេ។ សំដែងនូវលហុកាបត្តិ ថាជាគរុកាបត្តិ ។បេ។ សំដែងនូវគរុកាបត្តិ ថាជាលហុកាបត្តិ ។បេ។ សំដែងនូវទុដ្ឋុល្លាបត្តិ ថាជាអទុដ្ឋុល្លាបត្តិ ។បេ។ សំដែងនូវអទុដ្ឋុល្លាបត្តិ ថាជាទុដ្ឋុល្លាបត្តិ ។បេ។ សំដែងនូវសាវសេសាបត្តិ ថាជាអនវសេសាបត្តិ ។បេ។ សំដែងនូវអនវសេសាបត្តិ ថាជាសាវសេសាបត្តិ ។បេ។ សំដែងនូវសប្បដិកម្មាបត្តិ ថាជាអប្បដិកម្មាបត្តិ ។បេ។ សំដែងនូវអប្បដិកម្មាបត្តិ ថាជាសប្បដិកម្មាបត្តិវិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះ ឈ្មោះថាប្រតិបត្តិដើម្បីមិនជាគុណដល់ជនច្រើន ដើម្បីមិនជាសុខដល់ជនច្រើន ដើម្បីមិនជាប្រយោជន៍ដល់ជនច្រើន ដើម្បីមិនជាគុណ ដើម្បីសេចក្តីទុក្ខ ដល់ទេវតានិងមនុស្សទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះ រមែងបានបាបច្រើន មិនតែប៉ុណ្ណោះ ភិក្ខុទាំងនោះ ឈ្មោះថាធ្វើព្រះសទ្ធម្មនេះឲ្យអន្តរធានទៅ ។

(១៣៦) យេបិ តេ ភិក្ខវេ ភិក្ខូ អនាបត្តឹ អនាបត្តីតិ ទីបេន្តិ តេ ភិក្ខវេ ភិក្ខូ ពហុជនហិតាយ បដិបន្នា ពហុជនសុខាយ ពហុនោ ជនស្ស អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ ពហុញ្ច តេ ភិក្ខវេ ភិក្ខូ បុញ្ញំ បសវន្តិ តេ ចិមំ សទ្ធម្មំ ឋបេន្តីតិ ។

(១៣៧) យេបិ តេ ភិក្ខវេ ភិក្ខូ អាបត្តឹ អាបត្តីតិ ទីបេន្តិ តេ ភិក្ខវេ ភិក្ខូ ពហុជនហិតាយ បដិបន្នា ពហុជនសុខាយ ពហុនោ ជនស្ស អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ ពហុញ្ច តេ ភិក្ខវេ ភិក្ខូ បុញ្ញំ បសវន្តិ តេ ចិមំ សទ្ធម្មំ ឋបេន្តីតិ ។

(១៣៨) យេបិ តេ ភិក្ខវេ ភិក្ខូ លហុកំ អាបត្តឹ លហុកា អាបត្តីតិ ទីបេន្តិ ។បេ។ គរុកំ អាបត្តឹ គរុកា អាបត្តីតិ ទីបេន្តិ ។បេ។ ទុដ្ឋុល្លំ អាបត្តឹ ទុដ្ឋុល្លា អាបត្តីតិ ទីបេន្តិ ។បេ។



(១៣៦) ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុណា សំដែងនូវអនាបត្តិ ថាជាអនាបត្តិ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះ ឈ្មោះថាប្រតិបត្តិដើម្បីជាគុណដល់ជនច្រើន ដើម្បីសេចក្ដីសុខដល់ជនច្រើន ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីជាគុណ ដើម្បីសេចក្ដីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះ រមែងបាននូវបុណ្យច្រើន មិនតែប៉ុណ្ណោះ ភិក្ខុទាំងនោះ ឈ្មោះថាធ្វើព្រះសទ្ធម្មនេះឲ្យឋិតនៅ ។

(១៣៧) ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយណា សំដែងនូវអាបត្តិ ថាជាអាបត្តិ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះ ឈ្មោះថាប្រតិបត្តិ ដើម្បីជាគុណដល់ជនច្រើន ដើម្បីសេចក្ដីសុខដល់ជនច្រើន ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីជាគុណ ដើម្បីសេចក្ដីសុខដល់ទេវតានិងមនុស្សទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះ រមែងបាននូវបុណ្យច្រើន មិនតែប៉ុណ្ណោះ ភិក្ខុទាំងនោះឈ្មោះថាធ្វើព្រះសទ្ធម្មនេះឲ្យឋិតនៅ ។

(១៣៨) ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយណា សំដែងនូវលហុកាបត្តិ ថាជាលហុកាបត្តិ ។បេ។ សំដែងនូវគរុកាបត្តិ ថាជាគរុកាបត្តិ ។បេ។ សំដែងនូវទុដ្ឋុល្លាបត្តិ ថាជាទុដ្ឋុល្លាបត្តិ ។បេ។

អទុដ្ឋុល្លំ អាបត្តឹ អទុដ្ឋុល្លា អាបត្តីតិ ទីបេន្តិ ។ បេ ។ សាវសេសំ អាបត្តឹ សាវសេសា អាបត្តីតិ ទីបេន្តិ ។ បេ ។ អនវសេសំ អាបត្តឹ អនវសេសា អាបត្តីតិ ទីបេន្តិ ។ បេ ។ សប្បដិកម្មំ អាបត្តឹ សប្បដិកម្មា អាបត្តីតិ ទីបេន្តិ ។ បេ ។ អប្បដិកម្មំ អាបត្តឹ អប្បដិកម្មា អាបត្តីតិ ទីបេន្តិ តេ ភិក្ខវេ ភិក្ខូ ពហុជនហិតាយ បដិបន្នា ពហុជនសុខាយ ពហុនោ ជនស្ស អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ ពហុញ្ច តេ ភិក្ខវេ ភិក្ខូ បុញ្ញំ បសវន្តិ តេ ចិមំ សទ្ធម្មំ ឋបេន្តីតិ ។

វគ្គោ[១] ទ្វាទសមោ ។

---

១ ម. អនាបត្តិវគ្គោ ។



សំដែងនូវអទុដ្ឋុល្លាបត្តិ ថាជាអទុដ្ឋុល្លាបត្តិ ។ បេ ។ សំដែងនូវសាវសេសាបត្តិ ថាជាសាវសេសាបត្តិ ។ បេ ។ សំដែងនូវអនវសេសាបត្តិ ថាជាអនវសេសាបត្តិ ។ បេ ។ សំដែងនូវសប្បដិកម្មាបត្តិ ថាជាសប្បដិកម្មាបត្តិ ។ បេ ។ សំដែងនូវអប្បដិកម្មាបត្តិ ថាជាអប្បដិកម្មាបត្តិ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះ ឈ្មោះថាប្រតិបត្តិ ដើម្បីជាគុណដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីជាគុណ ដើម្បីសេចក្តីសុខដល់ទេវតានិងមនុស្សទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះ រមែងបានបុណ្យច្រើន មួយទៀតសោត ភិក្ខុទាំងនោះ ឈ្មោះថាធ្វើព្រះសទ្ធម្មនេះឲ្យឋិតនៅ ។

ចប់ វគ្គទី ១២ ។

## ឯកបុគ្គលបាលិ

(១៣៩) ឯកបុគ្គលោ ភិក្ខវេ លោកេ ឧប្បជ្ជមានោ ឧប្បជ្ជតិ ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ កតមោ ឯកបុគ្គលោ តថាគតោ អរហំ សម្មាសម្ពុទ្ធោ អយំ ខោ ភិក្ខវេ ឯកបុគ្គលោ លោកេ ឧប្បជ្ជមានោ ឧប្បជ្ជតិ ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានន្តិ ។

(១៤០) ឯកបុគ្គលស្ស ភិក្ខវេ បាតុភាវោ ទុល្លភោ លោកស្មឹ កតមស្ស ឯកបុគ្គលស្ស តថាគតស្ស អរហតោ សម្មាសម្ពុទ្ធស្ស ឥមស្ស ខោ ភិក្ខវេ ឯកបុគ្គលស្ស បាតុភាវោ ទុល្លភោ លោកស្មិន្តិ ។

(១៤១) ឯកបុគ្គលោ ភិក្ខវេ លោកេ ឧប្បជ្ជមានោ ឧប្បជ្ជតិ អច្ឆរិយមនុស្សោ កតមោ ឯកបុគ្គលោ

## ឯកបុគ្គលបាលិ

(១៣៩) ម្នាលភិក្ខុទាំងឡាយ បុគ្គលឯក កាលកើតឡើងក្នុងលោក ក៏រមែងកើតឡើង ដើម្បីជាគុណដល់ជនច្រើន ដើម្បីសេចក្ដីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីប្រយោជន៍ ដើម្បីជាគុណ ដើម្បីសេចក្ដីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ បុគ្គលឯក តើនរណា គឺព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ម្នាលភិក្ខុទាំងឡាយ បុគ្គលឯកនេះឯង កាលកើតឡើងក្នុងលោក ក៏រមែងកើតឡើង ដើម្បីជាគុណដល់ជនច្រើន ដើម្បីសេចក្ដីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីប្រយោជន៍ ដើម្បីជាគុណ ដើម្បីសេចក្ដីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ ។

(១៤០) ម្នាលភិក្ខុទាំងឡាយ ការកើតប្រាកដនៃបុគ្គលឯក បានដោយកម្រក្នុងលោក ការកើតប្រាកដនៃបុគ្គលឯក តើនរណា គឺព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ម្នាលភិក្ខុទាំងឡាយ ការកើតប្រាកដនៃបុគ្គលឯកនេះឯង រកបានដោយកម្រក្នុងលោក ។

(១៤១) ម្នាលភិក្ខុទាំងឡាយ បុគ្គលឯក កាលកើតឡើងក្នុងលោក ក៏រមែងកើតឡើងជាមនុស្សអស្ចារ្យ បុគ្គលឯក តើនរណា

តថាគតោ អរហំ សម្មាសម្ពុទ្ធោ អយំ ខោ ភិក្ខវេ ឯកបុគ្គលោ លោកេ ឧប្បជ្ជមានោ ឧប្បជ្ជតិ អច្ឆរិយមនុស្សោតិ ។

(១៤២) ឯកបុគ្គលស្ស ភិក្ខវេ កាលកិរិយា ពហុនោ ជនស្ស អនុតប្បា ហោតិ កតមស្ស ឯកបុគ្គលស្ស តថាគតស្ស អរហតោ សម្មាសម្ពុទ្ធស្ស ឥមស្ស ខោ ភិក្ខវេ ឯកបុគ្គលស្ស កាលកិរិយា ពហុនោ ជនស្ស អនុតប្បា ហោតីតិ ។

(១៤៣) ឯកបុគ្គលោ ភិក្ខវេ លោកេ ឧប្បជ្ជមានោ ឧប្បជ្ជតិ អទុតិយោ អសហាយោ អប្បដិមោ អប្បដិសមោ អប្បដិភាគោ អប្បដិបុគ្គលោ អសមោ អសមសមោ ទ្វិបទានំ អគ្គោ កតមោ ឯកបុគ្គលោ តថាគតោ អរហំ សម្មាសម្ពុទ្ធោ អយំ ខោ ភិក្ខវេ ឯកបុគ្គលោ លោកេ ឧប្បជ្ជមានោ ឧប្បជ្ជតិ អទុតិយោ អសហាយោ អប្បដិមោ អប្បដិសមោ អប្បដិភាគោ អប្បដិបុគ្គលោ អសមោ អសមសមោ ទ្វិបទានំ អគ្គោតិ ។



គឺព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ម្នាលភិក្ខុទាំងឡាយ បុគ្គលឯកនេះឯង កាលកើតឡើងក្នុងលោក គឺកើតឡើងជាមនុស្សអស្ចារ្យ ។

(១៤២) ម្នាលភិក្ខុទាំងឡាយ កាលកិរិយានៃបុគ្គលឯក ជាទីសោកស្តាយនៃជនច្រើន កាលកិរិយានៃបុគ្គលឯក តើដូចម្តេច គឺព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ម្នាលភិក្ខុទាំងឡាយ កាលកិរិយានៃបុគ្គលឯកនេះឯង ជាទីសោកស្តាយនៃជនច្រើន ។

(១៤៣) ម្នាលភិក្ខុទាំងឡាយ បុគ្គលឯក កាលកើតឡើងក្នុងលោក គឺកើតឡើងឥតមានគូ មិនមានសំឡាញ់ មិនមានបុគ្គលមានខ្លួនភាពដូច មិនមានបុគ្គលមានអត្តភាពស្មើ ជាអ្នកដែលរកការតមិន ឥតមានបុគ្គលតបតំហុសបាន មិនមានបុគ្គលប្រៀបផ្ទឹមបាន មិនមានបុគ្គលស្មើ ស្មើតែនឹងបុគ្គលដែលឥតគេស្មើ ប្រសើរបំផុតជាងពួកសត្វមានជើងពីរ បុគ្គលឯក តើដូចម្តេច គឺព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ម្នាលភិក្ខុទាំងឡាយ បុគ្គលឯកនេះឯង កាលកើតឡើងក្នុងលោក គឺកើតឡើងឥតមានគូ មិនមានសំឡាញ់ មិនមានបុគ្គលមានអត្តភាពដូច មិនមានបុគ្គលមានអត្តភាពស្មើ ជាអ្នកដែលរកការតមិន ឥតមានបុគ្គលតបតំហុសបាន មិនមានបុគ្គលប្រៀបផ្ទឹមបាន មិនមានបុគ្គលស្មើ ស្មើតែនឹងបុគ្គលដែលឥតគេស្មើ ប្រសើរបំផុតជាងពួកសត្វមានជើងពីរ ។

(១៦៦) ឯកបុគ្គលស្ស ភិក្ខវេ បាតុភាវា មហតោ ចក្ខុស្ស បាតុភាវោ ហោតិ មហតោ អាលោកស្ស បាតុភាវោ ហោតិ មហតោ ឱភាសស្ស បាតុភាវោ ហោតិ ឆន្នំ អនុត្តរិយានំ បាតុភាវោ ហោតិ ចតុន្នំ បដិ-សម្ភិទានំ សច្ឆិកិរិយា ហោតិ អនេកធាតុបដិវេធោ ហោតិ នានាធាតុបដិវេធោ ហោតិ វិជ្ជាវិមុត្តិផល-សច្ឆិកិរិយា ហោតិ សោតាបត្តិផលសច្ឆិកិរិយា ហោតិ សកទាគាមិផលសច្ឆិកិរិយា ហោតិ អនាគាមិផល-សច្ឆិកិរិយា ហោតិ អរហត្តផលសច្ឆិកិរិយា ហោតិ កតមស្ស ឯកបុគ្គលស្ស តថាគតស្ស អរហតោ សម្មាសម្ពុទ្ធស្ស ឥមស្ស ខោ ភិក្ខវេ ឯកបុគ្គលស្ស បាតុភាវា មហតោ ចក្ខុស្ស បាតុភាវោ ហោតិ មហតោ អាលោកស្ស បាតុភាវោ ហោតិ មហតោ ឱភាសស្ស បាតុភាវោ ហោតិ ឆន្នំ អនុត្តរិយានំ បាតុភាវោ ហោតិ ចតុន្នំ បដិសម្ភិទានំ សច្ឆិកិរិយា ហោតិ អនេកធាតុបដិវេធោ ហោតិ នានាធាតុ-បដិវេធោ ហោតិ វិជ្ជាវិមុត្តិផលសច្ឆិកិរិយា ហោតិ





(១៦៦) ម្នាលភិក្ខុទាំងឡាយ ការកើតប្រាកដនៃបុគ្គលឯក ជាការកើតប្រាកដនៃចក្ខុដ៏ប្រសើរ ជាការកើតប្រាកដនៃពន្លឺដ៏ប្រសើរ ជាការកើតប្រាកដនៃរស្មីដ៏ប្រសើរ ជាការកើតប្រាកដនៃអនុត្តរិយៈ ៦ ប្រការ ជាកិរិយាធ្វើឲ្យជាក់ច្បាស់នូវបដិសម្ភិទា ៤ ប្រការ ជាកិរិយាត្រាស់ដឹងនូវធាតុច្រើនប្រការ ជាកិរិយាត្រាស់ដឹងនូវធាតុផ្សេងៗ ជាកិរិយាធ្វើឲ្យជាក់ច្បាស់នូវវិជ្ជាវិមុត្តិផល ជាកិរិយាធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ជាកិរិយាធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ជាកិរិយាធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ជាកិរិយាធ្វើឲ្យជាក់ច្បាស់នូវអរហត្តផល ការកើតប្រាកដនៃបុគ្គលឯក តើនរណា គឺព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ម្នាលភិក្ខុទាំងឡាយ ការកើតប្រាកដនៃបុគ្គលឯកនេះឯង ជាការកើតប្រាកដនៃចក្ខុដ៏ប្រសើរ ជាការកើតប្រាកដនៃពន្លឺដ៏ប្រសើរ ជាការកើតប្រាកដនៃរស្មីដ៏ប្រសើរ ជាការកើតប្រាកដនៃអនុត្តរិយៈ ៦ ប្រការ ជាកិរិយាធ្វើឲ្យជាក់ច្បាស់នូវបដិសម្ភិទា ៤ ប្រការ ជាកិរិយាត្រាស់ដឹងនូវធាតុច្រើនប្រការ ជាកិរិយាត្រាស់ដឹងនូវធាតុផ្សេងៗ ជាកិរិយាធ្វើឲ្យជាក់ច្បាស់នូវវិជ្ជាវិមុត្តិផល

សោតាបត្តិផលសច្ឆិកិរិយា ហោតិ សកទាគាមិផល-
សច្ឆិកិរិយា ហោតិ អនាគាមិផលសច្ឆិកិរិយា ហោតិ
អរហត្តផលសច្ឆិកិរិយា ហោតីតិ ។

(១៦៨) នាហំ ភិក្ខវេ អញ្ញំ ឯកបុគ្គលម្បិ សមនុ-
បស្សាមិ យោ ឯវំ តថាគតេន អនុត្តរំ ធម្មចក្កំ
បវត្តិតំ សម្មទេវ អនុប្បវត្តេតិ យថយិទំ ភិក្ខវេ
សារីបុត្តោ សារីបុត្តោ ភិក្ខវេ តថាគតេន អនុត្តរំ
ធម្មចក្កំ បវត្តិតំ សម្មទេវ អនុប្បវត្តេតីតិ ។

ពុទ្ធវគ្គោ (១) ។

---

១. ម. ឯកបុគ្គលវគ្គោ តេរសមោ ។



ជាកិរិយាធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ជាកិរិយាធ្វើឲ្យជាក់ច្បាស់
នូវសកទាគាមិផល ជាកិរិយាធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ជាកិរិយា
ធ្វើឲ្យជាក់ច្បាស់នូវអរហត្តផល ។

(១៦៨) ម្នាលភិក្ខុទាំងឡាយ តថាគតមិនពិចារណាឃើញបុគ្គលដទៃ
សូម្បីតែបុគ្គលម្នាក់ ដែលញុំាងធម្មចក្រដ៏ប្រសើរ ដែលតថាគតឲ្យប្រព្រឹត្ត
ទៅហើយ ឲ្យប្រព្រឹត្តទៅតាមដោយប្រពៃ ដូចជាសារីបុត្តនេះសោះ
ម្នាលភិក្ខុទាំងឡាយ មានតែសារីបុត្ត ទើបញុំាងធម្មចក្រដ៏ប្រសើរ
ដែលតថាគតឲ្យប្រព្រឹត្តទៅហើយ ឲ្យប្រព្រឹត្តទៅតាមដោយប្រពៃបាន ។

ចប់ ពុទ្ធវគ្គ ។

[១៦៦] ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ រត្តញ្ញូនំ យទិទំ អញ្ញាកោណ្ឌញ្ញោ ។ មហាបញ្ញានំ យទិទំ សារីបុត្តោ ។ ឥទ្ធិមន្តានំ យទិទំ មហាមោគ្គល្លានោ ។ ធុតវាទានំ(១) យទិទំ មហាកស្សបោ ។ ទិព្វចក្ខុកានំ យទិទំ អនុរុទ្ធោ ។ ឧច្ចាកុលិកានំ យទិទំ ភទ្ទិយោ កាឡិគោធាយបុត្តោ ។ មញ្ជុស្សរានំ យទិទំ លកុណ្ឌកភទ្ទិយោ ។ សីហនាទិកានំ យទិទំ បិណ្ឌោលភារទ្វាជោ ។ ធម្មកថិកានំ យទិទំ បុណ្ណោ មន្តានិបុត្តោ ។ សង្ខិត្តេន ភាសិតស្ស វិត្ថារេន អត្ថំ វិភជន្តានំ យទិទំ មហាកច្ចានោ ។

វគ្គោ បឋមោ ។

[១៦៧] ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ មនោមយំ កាយំ អភិនិម្មិនន្តានំ(២) យទិទំ ចុល្លបន្ថកោ ។ ចេតោវិវដ្ដកុសលានំ យទិទំ ចុល្លបន្ថកោ ។ សញ្ញាវិវដ្ដកុសលានំ(៣) យទិទំ មហាបន្ថកោ ។

---

១. ធុតង្គវាទេត្តិបិ ទិស្សតិ ។ ម. ធុតង្គធរានំ ។ ២ ម. អភិនិម្មិតានំ ។ ៣ ឱ.ម. បញ្ញាវិវដ្ដកុសលានំ ។



(១៦៦) ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុអ្នកដឹងរាត្រី ដែលជាសាវ័ករបស់តថាគត ស្រេចនឹងអញ្ញាកោណ្ឌញ្ញៈ ប្រសើរជាងគេ ។ បណ្តាពួកភិក្ខុអ្នកមានប្រាជ្ញាច្រើន ស្រេចនឹងសារីបុត្ត ។ ពួកភិក្ខុអ្នកមានឫទ្ធិ ស្រេចនឹងមហាមោគ្គល្លាន ។ ពួកភិក្ខុអ្នកពោលពាក្យកំចាត់បង់កិលេស ស្រេចនឹងមហាកស្សបៈ ។ ពួកភិក្ខុអ្នកមានទិព្វចក្ខុ ស្រេចនឹងអនុរុទ្ធ ។ ពួកភិក្ខុអ្នកមានត្រកូលខ្ពស់ ស្រេចនឹងភទ្ទិយកាឡិគោធាយបុត្ត ។ ពួកភិក្ខុអ្នកមានសំឡេងពីរោះ ស្រេចនឹងលកុណ្ឌកភទ្ទិយៈ ។ ពួកភិក្ខុអ្នកបន្លឺសីហនាទ ស្រេចនឹងបិណ្ឌោលភារទ្វាជៈ ។ ពួកភិក្ខុជាធម្មកថិក ស្រេចនឹងបុណ្ណមន្តានីបុត្ត ។ ពួកភិក្ខុអ្នកចែកសេចក្តីធម៌ដែលតថាគតសំដែងដោយសង្ខេបឲ្យពិស្តារបាន ស្រេចនឹងមហាកច្ចានៈ ។

ចប់ វគ្គទី ១ ។

(១៦៧) ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុអ្នកនិម្មិតកាយសម្រេចតាមចិត្តបាន ដែលជាសាវ័ករបស់តថាគត ស្រេចនឹងចុល្លបន្ថកៈ ប្រសើរជាងគេ ។ ពួកភិក្ខុអ្នកឈ្លាសក្នុងការបើកចិត្ត ស្រេចនឹងចុល្លបន្ថកៈ ។ ពួកភិក្ខុអ្នកឈ្លាសក្នុងការបើកប្រាជ្ញា ស្រេចនឹងមហាបន្ថកៈ ។

អរណវិហារីនំ យទិទំ សុភូតិ ។ ទក្ខិណេយ្យានំ យទិទំ សុភូតិ ។ អារញ្ញកានំ យទិទំ រេវតោ ខទិរវនិយោ ។ ឈាយីនំ យទិទំ កង្ខារេវតោ ។ អារទ្ធវីរិយានំ យទិទំ សោណោ កោឡិវិសោ ។ កល្យាណវាក្ករណានំ យទិទំ សោណោ កុដិកណ្ណោ ។ លាភីនំ យទិទំ សីវលិ ។ សទ្ធាធិមុត្តានំ យទិទំ វក្កលិ ។

វគ្គោ ទុតិយោ ។

(១៤៨) ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ សិក្ខាកាមានំ យទិទំ រាហុលោ ។ សទ្ធាបព្វជិតានំ យទិទំ រដ្ឋបាលោ ។ បឋមំ សលាកំ គណ្ហន្តានំ យទិទំ កុណ្ឌធានោ ។ បដិភាណវន្តានំ យទិទំ វង្គីសោ ។ សមន្តបាសាទិកានំ យទិទំ ឧបសេនោ វង្គន្តបុត្តោ ។ សេនាសនបញ្ញាបកានំ យទិទំ ទព្វោ មល្លបុត្តោ ។ ទេវតានំ បិយមនាបានំ យទិទំ បិលិន្ទវច្ឆោ ។ ខិប្បាភិញ្ញានំ យទិទំ ពាហិយោ ទារុចីរិយោ ។ ចិត្តកថិកានំ យទិទំ កុមារកស្សបោ ។ បដិសម្ភិទប្បត្តានំ យទិទំ មហាកោដ្ឋិតោ ។

វគ្គោ តតិយោ ។



ពួកភិក្ខុអ្នកនៅដោយឥតកិលេស ស្រេចតែសុភូតិ ។ ពួកភិក្ខុអ្នកគួរដល់ទក្ខិណាទាន ស្រេចតែសុភូតិ ។ ពួកភិក្ខុអ្នកនៅក្នុងព្រៃ ស្រេចតែរេវតៈខទិរវនិយៈ ។ ពួកភិក្ខុអ្នកបានឈាន ស្រេចតែកង្ខារេវតៈ ។ ពួកភិក្ខុអ្នកមានព្យាយាមប្រារព្ធ ស្រេចតែសោណកោឡិវិសៈ ។ ពួកភិក្ខុអ្នកពោលពាក្យពីរោះ ស្រេចតែសោណកុដិកណ្ណៈ ។ ពួកភិក្ខុអ្នកមានលាភ ស្រេចតែសីវលី ។ ពួកភិក្ខុអ្នកមានសទ្ធាស៊ប់ ស្រេចតែវក្កលិ ។

ចប់ វគ្គ ទី ២ ។

(១៤៨) ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកភិក្ខុអ្នកស្រឡាញ់សិក្សា ដែលជាសាវ័ករបស់តថាគត ស្រេចតែរាហុលប្រសើរជាងគេ ។ ពួកភិក្ខុអ្នកបួសដោយសទ្ធា ស្រេចតែរដ្ឋបាល ។ ពួកភិក្ខុអ្នកចាប់ស្លាកមុនបង្អស់ ស្រេចតែកុណ្ឌធាន ។ ពួកភិក្ខុអ្នកមានបដិភាណ ស្រេចតែវង្គីសៈ ។ ពួកភិក្ខុអ្នកមានសេចក្ដីជ្រះថ្លាគ្រប់គ្រាន់ ស្រេចតែឧបសេនវង្គន្តបុត្ត ។ ពួកភិក្ខុអ្នករៀបចំសេនាសនៈ ស្រេចតែទព្វមល្លបុត្ត ។ ពួកភិក្ខុជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់ទេវតាទាំងឡាយ ស្រេចតែបិលិន្ទវច្ឆៈ ។ ពួកភិក្ខុអ្នកត្រាស់ដឹងរហ័ស ស្រេចតែពាហិយទារុចីរិយៈ ។ ពួកភិក្ខុអ្នកពោលធម៌វិចិត្រ ស្រេចតែកុមារកស្សបៈ ។ ពួកភិក្ខុអ្នកបានបដិសម្ភិទា ស្រេចតែមហាកោដ្ឋិតៈ ។

ចប់ វគ្គ ទី ៣ ។

## ឯតទគ្គបាលិយំ ចតុត្ថោ វគ្គោ

(១៤៩) ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ ពហុស្សុតានំ យទិទំ អានន្ទោ ។ សតិមន្តានំ យទិទំ អានន្ទោ ។ គតិមន្តានំ យទិទំ អានន្ទោ ។ ធិតិមន្តានំ យទិទំ អានន្ទោ ។ ឧបដ្ឋាកានំ យទិទំ អានន្ទោ ។ មហាបរិសានំ យទិទំ ឧរុវេលកស្សបោ ។ កុលប្បសាទកានំ យទិទំ កាឡុទាយី ។ អប្បាពាធានំ យទិទំ ពាក្កុលោ(១) ។ បុព្វេនិវាសំ អនុស្សរន្តានំ យទិទំ សោភិតោ ។ វិនយធរានំ យទិទំ ឧបាលិ ។ ភិក្ខុនោវាទកានំ យទិទំ នន្ទកោ ។ ឥន្ទ្រិយេសុ គុត្តទ្វារានំ យទិទំ នន្ទោ ។ ភិក្ខុឱវាទកានំ យទិទំ មហាកប្បិនោ ។ តេជោធាតុកុសលានំ យទិទំ សាគតោ ។ បដិភានេយ្យកានំ យទិទំ រាធោ ។ លូខចីវរធរានំ យទិទំ មោឃរាជា ។

វគ្គោ ចតុត្ថោ ។

(១៥០) ឯតទគ្គំ ភិក្ខវេ មម សាវិកានំ ភិក្ខុនីនំ រត្តញ្ញូនំ យទិទំ មហាបជាបតី គោតមី ។

១ ម. អប្បាពាធានំ យទិទំ ពាកុលោ ។



## ឯតទគ្គបាលិ វគ្គទី ៤

(១៤៩) ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកភិក្ខុអ្នកចេះដឹងច្រើន ដែលជាសាវករបស់តថាគត ព្រះអានន្ទប្រសើរជាងគេ ។ ពួកភិក្ខុអ្នកមានស្មារតី ព្រះអានន្ទ ។ ពួកភិក្ខុអ្នកមានគតិ ព្រះអានន្ទ ។ ពួកភិក្ខុអ្នកមានព្យាយាម ព្រះអានន្ទ ។ ពួកភិក្ខុជាឧបដ្ឋាក ព្រះអានន្ទដែរ ។ ពួកភិក្ខុអ្នកមានបរិស័ទច្រើន ព្រះឧរុវេលកស្សបៈ ។ ពួកភិក្ខុអ្នកញុំាងត្រកូលឲ្យជ្រះថ្លា ព្រះកាឡុទាយី ។ ពួកភិក្ខុអ្នកគ្មានអាពាធ ព្រះពាក្កុលៈ ។ ពួកភិក្ខុអ្នករឭកឃើញបុព្វេនិវាស ព្រះសោភិតៈ ។ ពួកភិក្ខុអ្នកទ្រទ្រង់វិន័យ ព្រះឧបាលិ ។ ពួកភិក្ខុអ្នកឲ្យឱវាទភិក្ខុនី ព្រះនន្ទកៈ ។ ពួកភិក្ខុអ្នករក្សាទ្វារគឺឥន្ទ្រិយទាំងឡាយ ព្រះនន្ទៈ ។ ពួកភិក្ខុអ្នកឲ្យឱវាទភិក្ខុ ព្រះមហាកប្បិន ។ ពួកភិក្ខុអ្នកឈ្លាសវៃក្នុងតេជោធាតុ ព្រះសាគតៈ ។ ពួកភិក្ខុអ្នកឈ្លាសវៃក្នុងបដិភាណ ព្រះរាធៈ ។ ពួកភិក្ខុអ្នកទ្រទ្រង់ចីវរសៅហ្មង ព្រះមោឃរាជ ។

ចប់ វគ្គទី ៤ ។

(១៥០) ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកភិក្ខុនីអ្នកដឹងរាត្រី ដែលជាសាវិការបស់តថាគត ព្រះនាងមហាបជាបតីគោតមីប្រសើរជាងគេ ។

មហាបញ្ញានំ យទិទំ ខេមា ។ ឥទ្ធិមន្តីនំ(១) យទិទំ ឧប្បលវណ្ណា ។ វិនយធរានំ យទិទំ បដាចារា ។ ធម្មកថិកានំ យទិទំ ធម្មទិន្នា ។ ឈាយីនំ(២) យទិទំ នន្ទា ។ អារទ្ធវីរិយានំ យទិទំ សោណា ។ ទិព្វចក្ខុកានំ យទិទំ សកុលា(៣) ។ ខិប្បាភិញ្ញានំ យទិទំ ភទ្ទា កុណ្ឌលកេសា ។ បុព្វេនិវាសំ អនុស្សរន្តីនំ យទិទំ ភទ្ទា កាបិលានី ។ មហាភិញ្ញប្បត្តានំ យទិទំ ភទ្ទា កច្ចានា ។ លូខចីវរធរានំ យទិទំ កិសាគោតមី ។ សទ្ធាធិមុត្តានំ យទិទំ សិគាលមាតា ។

វគ្គោ បញ្ចមោ ។

[១៥១] ឯតទគ្គំ ភិក្ខវេ មម សាវកានំ ឧបាសកានំ បឋមំ សរណំ គច្ឆន្តានំ យទិទំ តបុស្សភល្លិកា វាណិជា ។ ទាយកានំ យទិទំ សុទត្តោ គហបតិ អនាថបិណ្ឌិកោ ។ ធម្មកថិកានំ យទិទំ ចិត្តោ គហបតិ មច្ឆិកាសណ្ឌិកោ ។

---

១ ស. ឥទ្ធិមន្តានំ ។ ២ ស. ឈាយិនំ ។ ៣ ម. ពកុលា ។



ភិក្ខុនីអ្នកមានប្រាជ្ញាច្រើន ប្រសើរជាងគេ គឺនាងខេមា ។ ភិក្ខុនីអ្នកមានឫទ្ធិ ប្រសើរជាងគេ គឺនាងឧប្បលវណ្ណា ។ ភិក្ខុនីអ្នកទ្រទ្រង់វិន័យ ប្រសើរជាងគេ គឺនាងបដាចារា ។ ភិក្ខុនីជាធម្មកថិក ប្រសើរជាងគេ គឺនាងធម្មទិន្នា ។ ភិក្ខុនីអ្នកមានឈាន ប្រសើរជាងគេ គឺនាងនន្ទា ។ ភិក្ខុនីអ្នកមានព្យាយាមប្រារព្ធ ប្រសើរជាងគេ គឺនាងសោណា ។ ភិក្ខុនីអ្នកមានទិព្វចក្ខុ ប្រសើរជាងគេ គឺនាងសកុលា ។ ភិក្ខុនីបានត្រាស់ដឹងរហ័ស ប្រសើរជាងគេ គឺនាងភទ្ទាកុណ្ឌលកេសា ។ ភិក្ខុនីអ្នករឭកឃើញបុព្វេនិវាស ប្រសើរជាងគេ គឺនាងភទ្ទាកាបិលានី ។ ភិក្ខុនីអ្នកបានអភិញ្ញាធំ ប្រសើរជាងគេ គឺនាងភទ្ទាកច្ចានា ។ ភិក្ខុនីអ្នកទ្រទ្រង់ចីវរសៅហ្មង ប្រសើរជាងគេ គឺនាងកិសាគោតមី ។ ភិក្ខុនីអ្នកមានសទ្ធាស៊ប់ ប្រសើរជាងគេ គឺនាងសិគាលមាតា ។

វគ្គទី ៥ ។

[១៥១] ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកឧបាសកអ្នកដល់សរណៈជាបឋម ដែលជាសាវករបស់តថាគត ប្រសើរជាងគេ គឺតបុស្សពាណិជ និងភល្លិកពាណិជ ។ ពួកឧបាសកជាទាយក (អ្នកឲ្យទាន) ប្រសើរជាងគេ គឺសុទត្តគហបតី ឈ្មោះអនាថបិណ្ឌិកសេដ្ឋី ។ ពួកឧបាសកជាធម្មកថិក ប្រសើរជាងគេ គឺចិត្តគហបតី ដែលនៅក្នុងស្រុកមច្ឆិកាសណ្ឌៈ ។

ចតូហិ សង្គហវត្ថូហិ បរិសំ សង្គណ្ហន្តានំ យទិទំ ហត្ថកោ អាឡវកោ ។ បណីតទាយកានំ យទិទំ មហានាមោ សក្កោ ។ មនាបទាយកានំ យទិទំ ឧគ្គោ គហបតិ វេសាលិកោ ។ សង្ឃុបដ្ឋាកានំ យទិទំ ឧគ្គតោ គហបតិ ។ អវេច្ចប្បសន្នានំ យទិទំ សូរោ អម្ពដ្ឋោ ។ បុគ្គលប្បសន្នានំ យទិទំ ជីវកោ កោមារភច្ចោ ។ វិស្សាសកានំ យទិទំ នកុលបិតា គហបតីតិ ។

វគ្គោ ឆដ្ឋោ ។

[១៩៦] ឯតទគ្គំ ភិក្ខវេ មម សាវិកានំ ឧបាសិកានំ បឋមំ សរណំ គច្ឆន្តីនំ យទិទំ សុជាតា សេនានិធីតា(១) ។ ទាយិកានំ យទិទំ វិសាខា មិគារមាតា ។ ពហុស្សុតានំ យទិទំ ខុជ្ជុត្តរា ។ មេត្តាវិហារីនំ យទិទំ សាមាវតី ។ ឈាយីនំ យទិទំ ឧត្តរា នន្ទមាតា ។ បណីតទាយិកានំ យទិទំ សុប្បវាសា កោលិយធីតា ។ គិលានុបដ្ឋាកីនំ យទិទំ សុប្បិយា ឧបាសិកា ។

១ ម. សេនិយធីតា ។



ពួកឧបាសកអ្នកសង្គ្រោះបរិស័ទឡើយដោយសង្គហវត្ថុ ៤ ប្រការ ស្រេចតែហត្ថកអាឡវកៈ ។ ពួកឧបាសកអ្នកឲ្យរបស់ទានដ៏ឧត្តម ស្រេចតែមហានាមសក្យៈ ។ ពួកឧបាសកអ្នកឲ្យរបស់ជាទីគាប់ចិត្ត ស្រេចតែឧគ្គគហបតី អ្នកនៅក្នុងក្រុងវេសាលី ។ ពួកឧបាសកអ្នកបម្រើសង្ឃ ស្រេចតែឧគ្គតគហបតី ។ ពួកឧបាសកអ្នកជ្រះថ្លាមិនកម្រើក ស្រេចតែសូរអម្ពដ្ឋៈ ។ ពួកឧបាសកអ្នកញុំាងបុគ្គលឲ្យជ្រះថ្លា ស្រេចតែជីវកកោមារភច្ច ។ ពួកឧបាសកអ្នកមានសេចក្ដីស្និទ្ធស្នាល ស្រេចតែនកុលបិតាគហបតី ។

ចប់ វគ្គទី ៦ ។

(១៩៦) ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកឧបាសិកាអ្នកដល់នូវសរណៈជាដំបូង ដែលជាសាវិការបស់តថាគត ស្រេចតែនាងសុជាតា សេនានីធីតា(១) ប្រសើរជាងគេ ។ ពួកឧបាសិកាជាទាយិកា (អ្នកឲ្យទាន) ស្រេចតែនាងវិសាខា មិគារមាតា ។ ពួកឧបាសិកាអ្នកចេះដឹងច្រើន ស្រេចតែនាងខុជ្ជុត្តរា ។ ពួកឧបាសិកាអ្នកនៅដោយមេត្តា ស្រេចតែនាងសាមាវតី ។ ពួកឧបាសិកាអ្នកបានឈាន ស្រេចតែនាងឧត្តរានន្ទមាតា ។ ពួកឧបាសិកាអ្នកឲ្យទានដ៏ប្រណីត ស្រេចតែនាងសុប្បវាសាកោលិយធីតា ។ ពួកឧបាសិកាអ្នកបម្រើភិក្ខុឈឺ ស្រេចតែនាងសុប្បិយាឧបាសិកា ។

១ អដ្ឋកថា ជា សេនិយធីតា ។

អវេច្ចប្បសន្នានំ យទិទំ កាតិយានី ។ វិស្សាសិ-
កានំ យទិទំ នកុលមាតា គហបតានី ។
អនុស្សវប្បសន្នានំ យទិទំ កាឡី ឧបាសិកា
កុររឃរិកា(១) ។

វគ្គោ (២) សត្តមោ ។

១ ម. កាឡី ឧបាសិកា កុលឃរិកា ។ ២ ឱ. ឯតទគ្គវគ្គោ ។



ពួកឧបាសិកាអ្នកជ្រះថ្លាមិនកម្រើក ប្រសើរតែនាងកាតិយានី ។ ពួកឧបាសិកាអ្នកពោលពាក្យគួរឲ្យស្និទ្ធស្នាល ប្រសើរតែនាងនកុលមាតាគហបតានី ។ ពួកឧបាសិកាអ្នកជ្រះថ្លាតាមពាក្យដែលឮគេៗ ថា ប្រសើរតែកាលីឧបាសិកាកុររឃរិកា(១) ។

ចប់វគ្គទី ៧ ។

១. កុររឃរិកា ។

(១៨៣) អដ្ឋានមេតំ ភិក្ខវេ អនវកាសោ យំ ទិដ្ឋិសម្បន្នោ បុគ្គលោ កញ្ចិ សង្ខារំ និច្ចតោ ឧប-គច្ឆេយ្យ នេតំ ឋានំ វិជ្ជតិ ។ ឋានញ្ច ខោ ឯតំ ភិក្ខវេ វិជ្ជតិ យំ បុថុជ្ជនោ កញ្ចិ សង្ខារំ និច្ចតោ ឧបគច្ឆេយ្យ ឋានមេតំ វិជ្ជតីតិ ។

(១៨៤) អដ្ឋានមេតំ ភិក្ខវេ អនវកាសោ យំ ទិដ្ឋិសម្បន្នោ បុគ្គលោ កញ្ចិ សង្ខារំ សុខតោ ឧប-គច្ឆេយ្យ នេតំ ឋានំ វិជ្ជតិ ។ ឋានញ្ច ខោ ឯតំ ភិក្ខវេ វិជ្ជតិ យំ បុថុជ្ជនោ កញ្ចិ សង្ខារំ សុខតោ ឧបគច្ឆេយ្យ ឋានមេតំ វិជ្ជតីតិ ។

(១៨៥) អដ្ឋានមេតំ ភិក្ខវេ អនវកាសោ យំ ទិដ្ឋិ-សម្បន្នោ បុគ្គលោ កញ្ចិ ធម្មំ អត្តតោ ឧបគច្ឆេយ្យ នេតំ ឋានំ វិជ្ជតិ ។ ឋានញ្ច ខោ ឯតំ ភិក្ខវេ វិជ្ជតិ យំ បុថុជ្ជនោ កញ្ចិ ធម្មំ អត្តតោ ឧបគច្ឆេយ្យ ឋានមេតំ វិជ្ជតីតិ ។



(១៨៣) ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលបរិបូណ៌ដោយទិដ្ឋិ គឺសោតាបន្នៈ គប្បីប្រកាន់នូវសង្ខារណាមួយ ថាជាទៀង ដោយហេតុណា ហេតុនុ៎ះមិនមែនជាហេតុ មិនមែនជាបច្ច័យឡើយ គឺជាហេតុនុ៎ះ មិនដែលមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលជាបុថុជ្ជន គប្បីប្រកាន់នូវសង្ខារណាមួយ ថាជារបស់ទៀង ដោយហេតុណា ហេតុនុ៎ះឈ្មោះថាជាហេតុ គឺជាហេតុនោះ តែងមាន ។

(១៨៤) ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលបរិបូណ៌ដោយទិដ្ឋិ គប្បីប្រកាន់នូវសង្ខារណាមួយថាជាសុខ ដោយហេតុណា ហេតុនុ៎ះមិនមែនជាហេតុ មិនមែនជាបច្ច័យ គឺជាហេតុនុ៎ះ មិនដែលមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលជាបុថុជ្ជន គប្បីប្រកាន់នូវសង្ខារណាមួយ ថាជាសុខ ដោយហេតុណា ហេតុនុ៎ះឈ្មោះថាជាហេតុ គឺជាហេតុនុ៎ះ តែងមាន ។

(១៨៥) ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលបរិបូណ៌ដោយទិដ្ឋិ គប្បីប្រកាន់នូវធម៌ណាមួយថាជាខ្លួន ដោយហេតុណា ហេតុនុ៎ះមិនមែនជាហេតុ មិនមែនជាបច្ច័យឡើយ គឺជាហេតុនុ៎ះ មិនដែលមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលជាបុថុជ្ជន គប្បីប្រកាន់នូវធម៌ណាមួយថាជាខ្លួន ដោយហេតុណា ហេតុនុ៎ះឈ្មោះថាជាហេតុ គឺជាហេតុនុ៎ះ តែងមាន ។

(១៧៦) អដ្ឋានមេតំ ភិក្ខវេ អនវកាសោ យំ ទិដ្ឋិសម្បន្នោ បុគ្គលោ មាតរំ ជីវិតា វោរោបេយ្យ នេតំ ឋានំ វិជ្ជតិ ។ ឋានញ្ច ខោ ឯតំ ភិក្ខវេ វិជ្ជតិ យំ បុថុជ្ជនោ មាតរំ ជីវិតា វោរោបេយ្យ ឋានមេតំ វិជ្ជតីតិ ។

(១៧៧) អដ្ឋានមេតំ ភិក្ខវេ អនវកាសោ យំ ទិដ្ឋិសម្បន្នោ បុគ្គលោ បិតរំ ជីវិតា វោរោបេយ្យ នេតំ ឋានំ វិជ្ជតិ ។ ឋានញ្ច ខោ ឯតំ ភិក្ខវេ វិជ្ជតិ យំ បុថុជ្ជនោ បិតរំ ជីវិតា វោរោបេយ្យ ឋានមេតំ វិជ្ជតីតិ ។

(១៧៨) អដ្ឋានមេតំ ភិក្ខវេ អនវកាសោ យំ ទិដ្ឋិសម្បន្នោ បុគ្គលោ អរហន្តំ ជីវិតា វោរោបេយ្យ នេតំ ឋានំ វិជ្ជតិ ។ ឋានញ្ច ខោ ឯតំ ភិក្ខវេ វិជ្ជតិ យំ បុថុជ្ជនោ អរហន្តំ ជីវិតា វោរោបេយ្យ ឋានមេតំ វិជ្ជតីតិ ។



(១៧៦) ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលបរិបូណ៌ដោយទិដ្ឋិ គប្បីផ្តាច់បង់ជីវិតមាតា ដោយហេតុឯណា ហេតុនុ៎ះមិនមែនជាហេតុ មិនមែនជាបច្ច័យឡើយ គឺជាហេតុនុ៎ះ មិនដែលមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលជាបុថុជ្ជន គប្បីផ្តាច់បង់ជីវិតមាតា ដោយហេតុឯណា ហេតុនុ៎ះ ឈ្មោះថាជាហេតុ គឺជាហេតុនុ៎ះ តែងមាន ។

(១៧៧) ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលបរិបូណ៌ដោយទិដ្ឋិ គប្បីផ្តាច់បង់ជីវិតបិតា ដោយហេតុឯណា ហេតុនុ៎ះមិនមែនជាហេតុ មិនមែនជាបច្ច័យឡើយ គឺជាហេតុនុ៎ះ មិនដែលមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាបុថុជ្ជន គប្បីផ្តាច់បង់ជីវិតបិតា ដោយហេតុឯណា ហេតុនុ៎ះឈ្មោះថាជាហេតុ គឺជាហេតុនុ៎ះ តែងមាន ។

(១៧៨) ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលបរិបូណ៌ដោយទិដ្ឋិ គប្បីផ្តាច់បង់ជីវិតព្រះអរហន្ត ដោយហេតុឯណា ហេតុនុ៎ះមិនមែនជាហេតុ មិនមែនជាបច្ច័យឡើយ គឺជាហេតុនុ៎ះ មិនដែលមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលជាបុថុជ្ជន គប្បីផ្តាច់បង់ជីវិតព្រះអរហន្ត ដោយហេតុឯណា ហេតុនុ៎ះឈ្មោះថាជាហេតុ គឺជាហេតុនុ៎ះ តែងមាន ។

(១៥៩) អដ្ឋានមេតំ ភិក្ខវេ អនវកាសោ យំ ទិដ្ឋិសម្បន្នោ បុគ្គលោ តថាគតស្ស ទុដ្ឋេន ចិត្តេន លោហិតំ ឧប្បាទេយ្យ នេតំ ឋានំ វិជ្ជតិ ។ ឋានញ្ច ខោ ឯតំ ភិក្ខវេ វិជ្ជតិ យំ បុថុជ្ជនោ តថាគតស្ស ទុដ្ឋេន ចិត្តេន លោហិតំ ឧប្បាទេយ្យ ឋានមេតំ វិជ្ជតីតិ ។

(១៦០) អដ្ឋានមេតំ ភិក្ខវេ អនវកាសោ យំ ទិដ្ឋិសម្បន្នោ បុគ្គលោ សង្ឃំ ភិន្ទេយ្យ នេតំ ឋានំ វិជ្ជតិ ។ ឋានញ្ច ខោ ឯតំ ភិក្ខវេ វិជ្ជតិ យំ បុថុជ្ជនោ សង្ឃំ ភិន្ទេយ្យ ឋានមេតំ វិជ្ជតីតិ ។

(១៦១) អដ្ឋានមេតំ ភិក្ខវេ អនវកាសោ យំ ទិដ្ឋិសម្បន្នោ បុគ្គលោ អញ្ញំ សត្ថារំ ឧទ្ទិសេយ្យ នេតំ ឋានំ វិជ្ជតិ ។ ឋានញ្ច ខោ ឯតំ ភិក្ខវេ វិជ្ជតិ យំ បុថុជ្ជនោ អញ្ញំ សត្ថារំ ឧទ្ទិសេយ្យ ឋានមេតំ វិជ្ជតីតិ ។



(១៥៩) ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលបរិបូណ៌ដោយទិដ្ឋិ មានចិត្តប្រទូស្តចំពោះព្រះតថាគត ធ្វើលោហិតុប្បាទ ដោយហេតុឯណា ហេតុនុ៎ះមិនមែនជាហេតុ មិនមែនជាបច្ច័យឡើយ គឺជាហេតុនុ៎ះ មិនដែលមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលជាបុថុជ្ជន មានចិត្តប្រទូស្តចំពោះព្រះតថាគត ធ្វើលោហិតុប្បាទ ដោយហេតុឯណា ហេតុនុ៎ះឈ្មោះថាជាហេតុនឹងជាហេតុនុ៎ះ រមែងមាន ។

(១៦០) ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលបរិបូណ៌ដោយទិដ្ឋិ បំបែកសង្ឃ ដោយហេតុឯណា ហេតុនុ៎ះមិនមែនជាហេតុ មិនមែនជាបច្ច័យឡើយគឺជាហេតុនុ៎ះ មិនដែលមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលជាបុថុជ្ជន បំបែកសង្ឃ ដោយហេតុឯណា ហេតុនុ៎ះឈ្មោះថាជាហេតុនឹងជាហេតុនុ៎ះ រមែងមាន ។

(១៦១) ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលបរិបូណ៌ដោយទិដ្ឋិ ឧទ្ទិសនូវសាស្តាដទៃ ដោយហេតុឯណា ហេតុនុ៎ះមិនមែនជាហេតុ មិនមែនជាបច្ច័យឡើយគឺជាហេតុនុ៎ះ មិនដែលមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលជាបុថុជ្ជន ឧទ្ទិសនូវសាស្តាដទៃ ដោយហេតុឯណា ហេតុនុ៎ះឈ្មោះថាជាហេតុនឹងជាហេតុនុ៎ះ រមែងមាន ។

(១៦២) អដ្ឋានមេតំ ភិក្ខវេ អនវកាសោ យំ ឯកិស្សា លោកធាតុយា ទ្វេ អរហន្តោ សម្មាសម្ពុទ្ធា អបុព្វំ អចរិមំ ឧប្បជ្ជេយ្យុំ នេតំ ឋានំ វិជ្ជតិ ។ ឋានញ្ច ខោ ឯតំ ភិក្ខវេ វិជ្ជតិ យំ ឯកិស្សា លោកធាតុយា ឯកោ អរហំ សម្មាសម្ពុទ្ធោ ឧប្បជ្ជេយ្យ ឋានមេតំ វិជ្ជតីតិ ។

វគ្គោ បឋមោ ។

(១៦៣) អដ្ឋានមេតំ ភិក្ខវេ អនវកាសោ យំ ឯកិស្សា លោកធាតុយា ទ្វេ រាជានោ ចក្កវត្តី អបុព្វំ អចរិមំ ឧប្បជ្ជេយ្យុំ នេតំ ឋានំ វិជ្ជតិ ។ ឋានញ្ច ខោ ឯតំ ភិក្ខវេ វិជ្ជតិ យំ ឯកិស្សា លោកធាតុយា ឯកោ រាជា ចក្កវត្តី ឧប្បជ្ជេយ្យ ឋានមេតំ វិជ្ជតីតិ ។

(១៦៤) អដ្ឋានមេតំ ភិក្ខវេ អនវកាសោ យំ ឥត្ថី អរហំ អស្ស សម្មាសម្ពុទ្ធោ នេតំ ឋានំ វិជ្ជតិ ។ ឋានញ្ច ខោ ឯតំ ភិក្ខវេ វិជ្ជតិ យំ បុរិសោ អរហំ អស្ស សម្មាសម្ពុទ្ធោ ឋានមេតំ វិជ្ជតីតិ ។



(១៦២) ម្នាលភិក្ខុទាំងឡាយ ព្រះអរហន្តសម្មាសម្ពុទ្ធ ២ ព្រះអង្គ គប្បីកើតឡើង មិនមុនមិនក្រោយ ក្នុងលោកធាតុតែមួយ ដំណាលគ្នា ១ ដោយហេតុឯណា ហេតុនុ៎ះមិនមែនជាហេតុ មិនមែនជាបច្ច័យ គឺជាហេតុនុ៎ះមិនមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ ព្រះអរហន្តសម្មាសម្ពុទ្ធ ១ ព្រះអង្គ គប្បីកើតឡើង ក្នុងលោកធាតុតែមួយ ដោយហេតុឯណា ហេតុនុ៎ះឈ្មោះថាជាហេតុគឺជាហេតុនុ៎ះ តែងមាន ។

ចប់ វគ្គទី ១ ។

(១៦៣) ម្នាលភិក្ខុទាំងឡាយ ស្ដេចចក្រពត្តិ ២ អង្គ គប្បីកើតឡើង មិនមុនមិនក្រោយ ក្នុងលោកធាតុតែ ១ ដោយហេតុឯណា ហេតុនុ៎ះមិនមែនជាហេតុ មិនមែនជាបច្ច័យគឺជាហេតុនុ៎ះ មិនដែលមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ ស្ដេចចក្រពត្តិ ១ អង្គ គប្បីកើតឡើង ក្នុងលោកធាតុ ១ ដោយហេតុឯណា ហេតុនុ៎ះឈ្មោះថាជាហេតុគឺជាហេតុនុ៎ះ តែងមាន ។

(១៦៤) ម្នាលភិក្ខុទាំងឡាយ ស្រីបានជាព្រះអរហន្តសម្មាសម្ពុទ្ធ ដោយហេតុឯណា ហេតុនុ៎ះមិនមែនជាហេតុ មិនមែនជាបច្ច័យគឺជាហេតុនុ៎ះ មិនដែលមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុរសបានជាព្រះអរហន្តសម្មាសម្ពុទ្ធ ដោយហេតុឯណា ហេតុនុ៎ះឈ្មោះថាជាហេតុ គឺជាហេតុនុ៎ះ តែងមាន ។

(១៦៥) អដ្ឋានមេតំ ភិក្ខវេ អនវកាសោ យំ ឥត្ថី រាជា អស្ស ចក្កវត្តី នេតំ ឋានំ វិជ្ជតិ ។ ឋានញ្ច ខោ ឯតំ ភិក្ខវេ វិជ្ជតិ យំ បុរិសោ រាជា អស្ស ចក្កវត្តី ឋានមេតំ វិជ្ជតីតិ ។

(១៦៦) អដ្ឋានមេតំ ភិក្ខវេ អនវកាសោ យំ ឥត្ថី សក្កត្តំ ការេយ្យ ។បេ។ មារត្តំ ការេយ្យ ។បេ។ ព្រហ្មត្តំ ការេយ្យ នេតំ ឋានំ វិជ្ជតិ ។ ឋានញ្ច ខោ ឯតំ ភិក្ខវេ វិជ្ជតិ យំ បុរិសោ សក្កត្តំ ការេយ្យ ។បេ។ មារត្តំ ការេយ្យ ។បេ។ ព្រហ្មត្តំ ការេយ្យ ឋានមេតំ វិជ្ជតីតិ ។

(១៦៧) អដ្ឋានមេតំ ភិក្ខវេ អនវកាសោ យំ កាយទុច្ចរិតស្ស ឥដ្ឋោ កន្តោ មនាបោ វិបាកោ និព្វត្តេយ្យ នេតំ ឋានំ វិជ្ជតិ ។ ឋានញ្ច ខោ ឯតំ ភិក្ខវេ វិជ្ជតិ យំ កាយទុច្ចរិតស្ស អនិដ្ឋោ អកន្តោ អមនាបោ វិបាកោ និព្វត្តេយ្យ ឋានមេតំ វិជ្ជតីតិ ។



(១៦៥) ម្នាលភិក្ខុទាំងឡាយ ស្ត្រីបានជាស្តេចចក្រពត្តិ ដោយហេតុឯណា ហេតុនុ៎ះមិនមែនជាហេតុ មិនមែនជាបច្ច័យ គឺជាហេតុនុ៎ះ មិនដែលមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុរសបានជាស្តេចចក្រពត្តិ ដោយហេតុឯណា ហេតុនុ៎ះឈ្មោះថាជាហេតុគឺជាហេតុនុ៎ះ តែងមាន ។

(១៦៦) ម្នាលភិក្ខុទាំងឡាយ ស្ត្រីធ្វើជាព្រះឥន្ទ្រ ។បេ។ ធ្វើជាមារ ។បេ។ ធ្វើជាព្រហ្ម ដោយហេតុឯណា ហេតុនុ៎ះមិនមែនជាហេតុ មិនមែនជាបច្ច័យគឺជាហេតុនុ៎ះ មិនដែលមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុរសធ្វើជាព្រះឥន្ទ្រ ។បេ។ ធ្វើជាមារ ។បេ។ ធ្វើជាព្រហ្ម ដោយហេតុឯណា ហេតុនុ៎ះឈ្មោះថាជាហេតុគឺជាហេតុនុ៎ះ តែងមាន ។

(១៦៧) ម្នាលភិក្ខុទាំងឡាយ ផលរបស់កាយទុច្ចរិត ជាទីត្រេកអរ ជាទីពេញចិត្ត ជាទីគាប់ចិត្ត គប្បីកើតដោយហេតុឯណា ហេតុនុ៎ះ មិនមែនជាហេតុ មិនមែនជាបច្ច័យគឺជាហេតុនុ៎ះ មិនដែលមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ ផលរបស់កាយទុច្ចរិត មិនជាទីត្រេកអរ មិនជាទីពេញចិត្ត មិនជាទីគាប់ចិត្ត គប្បីកើតដោយហេតុឯណា ហេតុនុ៎ះ ឈ្មោះថាជាហេតុគឺជាហេតុនុ៎ះ តែងមាន ។

[១៦៨] អដ្ឋានមេតំ ភិក្ខវេ អនវកាសោ យំ វចីទុច្ចរិតស្ស ។បេ។

[១៦៩] អដ្ឋានមេតំ ភិក្ខវេ អនវកាសោ យំ មនោទុច្ចរិតស្ស ឥដ្ឋោ កន្តោ មនាបោ វិបាកោ និព្វត្តេយ្យ នេតំ ឋានំ វិជ្ជតិ ។ ឋានញ្ច ខោ ឯតំ ភិក្ខវេ វិជ្ជតិ យំ មនោទុច្ចរិតស្ស អនិដ្ឋោ អកន្តោ អមនាបោ វិបាកោ និព្វត្តេយ្យ ឋានមេតំ វិជ្ជតីតិ ។

[១៧០] អដ្ឋានមេតំ ភិក្ខវេ អនវកាសោ យំ កាយសុចរិតស្ស អនិដ្ឋោ អកន្តោ អមនាបោ វិបាកោ និព្វត្តេយ្យ នេតំ ឋានំ វិជ្ជតិ ។ ឋានញ្ច ខោ ឯតំ ភិក្ខវេ វិជ្ជតិ យំ កាយសុចរិតស្ស ឥដ្ឋោ កន្តោ មនាបោ វិបាកោ និព្វត្តេយ្យ ឋានមេតំ វិជ្ជតីតិ ។

[១៧១] អដ្ឋានមេតំ ភិក្ខវេ អនវកាសោ យំ វចីសុចរិតស្ស ។បេ។



[១៦៨] ម្នាលភិក្ខុទាំងឡាយ ផលរបស់វចីទុច្ចរិត ដោយហេតុឯណា ហេតុនុ៎ះមិនមែនជាហេតុ មិនមែនជាបច្ច័យ ។បេ។

[១៦៩] ម្នាលភិក្ខុទាំងឡាយ ផលរបស់មនោទុច្ចរិត ដែលជាទីត្រេកអរ ជាទីពេញចិត្ត ជាទីគាប់ចិត្ត គប្បីកើតដោយហេតុឯណា ហេតុនុ៎ះមិនមែនជាហេតុ មិនមែនជាបច្ច័យ គឺជាហេតុនុ៎ះ មិនដែលមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ ផលរបស់មនោទុច្ចរិត មិនជាទីត្រេកអរ មិនជាទីពេញចិត្ត មិនជាទីគាប់ចិត្ត គប្បីកើតដោយហេតុឯណា ហេតុនុ៎ះឈ្មោះថាជាហេតុ គឺជាហេតុនុ៎ះ រមែងមាន ។

[១៧០] ម្នាលភិក្ខុទាំងឡាយ ផលរបស់កាយសុចរិត មិនជាទីត្រេកអរ មិនជាទីពេញចិត្ត មិនជាទីគាប់ចិត្ត គប្បីកើតដោយហេតុឯណា ហេតុនុ៎ះមិនមែនជាហេតុ មិនមែនជាបច្ច័យ គឺជាហេតុនុ៎ះ មិនដែលមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ ផលរបស់កាយសុចរិត ជាទីត្រេកអរ ជាទីពេញចិត្ត ជាទីគាប់ចិត្ត គប្បីកើតដោយហេតុឯណា ហេតុនុ៎ះឈ្មោះថាជាហេតុ គឺជាហេតុនុ៎ះ រមែងមាន ។

[១៧១] ម្នាលភិក្ខុទាំងឡាយ ផលរបស់វចីសុចរិត ដោយហេតុឯណា ហេតុនុ៎ះមិនមែនជាហេតុ មិនមែនជាបច្ច័យ ។បេ។

(១៧២) អដ្ឋានមេតំ ភិក្ខវេ អនវកាសោ យំ មនោសុចរិតស្ស អនិដ្ឋោ អកន្តោ អមនាបោ វិបាកោ និព្វត្តេយ្យ នេតំ ឋានំ វិជ្ជតិ ។ ឋានញ្ច ខោ ឯតំ ភិក្ខវេ វិជ្ជតិ យំ មនោសុចរិតស្ស ឥដ្ឋោ កន្តោ មនាបោ វិបាកោ និព្វត្តេយ្យ ឋានមេតំ វិជ្ជតីតិ ។

វគ្គោ ទុតិយោ ។

(១៧៣) អដ្ឋានមេតំ ភិក្ខវេ អនវកាសោ យំ កាយទុច្ចរិតសមង្គី តន្និទានា តប្បច្ចយា កាយស្ស ភេទា បរម្មរណា សុគតិំ សគ្គំ លោកំ ឧបបជ្ជេយ្យ នេតំ ឋានំ វិជ្ជតិ ។ ឋានញ្ច ខោ ឯតំ ភិក្ខវេ វិជ្ជតិ យំ កាយទុច្ចរិតសមង្គី តន្និទានា តប្បច្ចយា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតិំ វិនិបាតំ និរយំ ឧបបជ្ជេយ្យ ឋានមេតំ វិជ្ជតីតិ ។

(១៧៤) អដ្ឋានមេតំ ភិក្ខវេ អនវកាសោ យំ វចីទុច្ចរិតសមង្គី ។ បេ ។



(១៧២) ម្នាលភិក្ខុទាំងឡាយ ផលរបស់មនោសុចរិត មិនជាទីត្រេកអរ មិនជាទីពេញចិត្ត មិនជាទីគាប់ចិត្ត គប្បីកើតដោយហេតុណា ហេតុនុ៎ះមិនមែនជាហេតុ មិនមែនជាបច្ច័យ ក៏ជាហេតុនុ៎ះ មិនដែលមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ ផលរបស់មនោសុចរិត ជាទីត្រេកអរ ជាទីពេញចិត្ត ជាទីគាប់ចិត្ត គប្បីកើតដោយហេតុណា ហេតុនុ៎ះឈ្មោះថាជាហេតុ ក៏ជាហេតុនុ៎ះ រមែងមាន ។

ចប់ វគ្គទី ២ ។

(១៧៣) ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកប្រកបដោយកាយទុច្ចរិត លុះបែកធ្លាយរាងកាយស្លាប់ទៅ ទៅកើតក្នុងសុគតិសួគ៌ទេវលោក ព្រោះមិនកើតនោះជាហេតុ ព្រោះមិនកើតនោះជាបច្ច័យ ដោយហេតុណា ហេតុនុ៎ះ មិនមែនជាហេតុ មិនមែនជាបច្ច័យ ក៏ជាហេតុនុ៎ះ មិនដែលមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកប្រកបដោយកាយទុច្ចរិត លុះបែកធ្លាយរាងកាយស្លាប់ទៅ ត្រូវទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ព្រោះមិនកើតនោះជាហេតុ ព្រោះមិនកើតនោះជាបច្ច័យ ដោយហេតុណា ហេតុនុ៎ះឈ្មោះថាជាហេតុ ក៏ជាហេតុនុ៎ះ រមែងមាន ។

(១៧៤) ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកប្រកបដោយវចីទុច្ចរិត ដោយហេតុណា ហេតុនុ៎ះមិនមែនជាហេតុ មិនមែនជាបច្ច័យ ។ បេ ។

(១៧៥) អដ្ឋានមេតំ ភិក្ខវេ អនវកាសោ យំ មនោទុច្ចរិតសមង្គី តន្និទានា តប្បច្ចយា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជេយ្យ នេតំ ឋានំ វិជ្ជតិ ។ ឋានញ្ច ខោ ឯតំ ភិក្ខវេ វិជ្ជតិ យំ មនោទុច្ចរិតសមង្គី តន្និទានា តប្បច្ចយា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជេយ្យ ឋានមេតំ វិជ្ជតីតិ ។

(១៧៦) អដ្ឋានមេតំ ភិក្ខវេ អនវកាសោ យំ កាយសុចរិតសមង្គី តន្និទានា តប្បច្ចយា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជេយ្យ នេតំ ឋានំ វិជ្ជតិ ។ ឋានញ្ច ខោ ឯតំ ភិក្ខវេ វិជ្ជតិ យំ កាយសុចរិតសមង្គី តន្និទានា តប្បច្ចយា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជេយ្យ ឋានមេតំ វិជ្ជតីតិ ។



[១៧៥] ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលប្រកបដោយមនោទុច្ចរិត លុះបែកធ្លាយរាងកាយស្លាប់ទៅ ទៅកើតក្នុងសុគតិសួគ៌ទេវលោក ព្រោះអំពើនោះជាហេតុ ព្រោះអំពើនោះជាបច្ច័យ ដោយហេតុណា ហេតុនុ៎ះ មិនមែនជាហេតុ មិនមែនជាបច្ច័យនឹងជាហេតុនុ៎ះ មិនដែលមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកប្រកបដោយមនោទុច្ចរិត លុះបែកធ្លាយរាងកាយស្លាប់ទៅ ត្រូវតែទៅកើតជាតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក ព្រោះអំពើនោះជាហេតុ ព្រោះអំពើនោះជាបច្ច័យ ដោយហេតុណា ហេតុនុ៎ះឈ្មោះថាជាហេតុនឹងជាហេតុនុ៎ះ តែមិនខាន ។

[១៧៦] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយកាយសុចរិត លុះបែកធ្លាយរាងកាយស្លាប់ទៅ ទៅកើតជាតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក ព្រោះអំពើនោះជាហេតុ ព្រោះអំពើនោះជាបច្ច័យ ដោយហេតុណា ហេតុនុ៎ះមិនមែនជាហេតុ មិនមែនជាបច្ច័យនឹងជាហេតុនុ៎ះ មិនដែលមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកប្រកបដោយកាយសុចរិត លុះបែកធ្លាយរាងកាយស្លាប់ទៅ ត្រូវតែទៅកើតក្នុងសុគតិសួគ៌ទេវលោក ព្រោះអំពើនោះជាហេតុ ព្រោះអំពើនោះជាបច្ច័យ ដោយហេតុណា ហេតុនុ៎ះឈ្មោះថាជាហេតុនឹងជាហេតុនុ៎ះ តែមិនខាន ។

(១៨៧) អដ្ឋានមេតំ ភិក្ខវេ អនវកាសោ យំ វចីសុចរិតសមង្គី ។ បេ ។

(១៨៨) អដ្ឋានមេតំ ភិក្ខវេ អនវកាសោ យំ មនោសុចរិតសមង្គី តន្និទានា តប្បច្ចយា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជេយ្យ នេតំ ឋានំ វិជ្ជតិ ។ ឋានញ្ច ខោ ឯតំ ភិក្ខវេ វិជ្ជតិ យំ មនោសុចរិតសមង្គី តន្និទានា តប្បច្ចយា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជេយ្យ ឋានមេតំ វិជ្ជតីតិ ។

វគ្គោ តតិយោ ។





(១៨៧) ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកបរិបូណ៌ដោយវចីសុចរិត ដោយហេតុណា ហេតុនុ៎ះមិនមែនជាហេតុ មិនមែនជាបច្ច័យ ។ បេ ។

(១៨៨) ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកបរិបូណ៌ដោយមនោសុចរិត លុះបែកធ្លាយរាងកាយស្លាប់ទៅ ទៅកើតជាតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក ព្រោះតំណើរនោះជាហេតុ ព្រោះតំណើរនោះជាបច្ច័យ ដោយហេតុណា ហេតុនុ៎ះមិនមែនជាហេតុ មិនមែនជាបច្ច័យ គឺជាហេតុមិនមែនដែលមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកបរិបូណ៌ដោយមនោសុចរិត លុះបែកធ្លាយរាងកាយស្លាប់ទៅ ត្រូវតែទៅកើតក្នុងសុគតិសួគ៌ទេវលោក ព្រោះតំណើរនោះជាហេតុ ព្រោះតំណើរនោះជាបច្ច័យ ដោយហេតុណា ហេតុនុ៎ះឈ្មោះថាជាហេតុពិតជាហេតុនុ៎ះ ពិតមិនខាន ។

ចប់ វគ្គទី ៣ ។

## អបរា ឯកធម្មាទិបាលិ

(១៧៩) ឯកធម្មោ ភិក្ខវេ ភាវិតោ ពហុលីកតោ ឯកន្តនិព្វិទាយ វិរាគាយ និរោធាយ ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ ។ កតមោ ឯកធម្មោ ។ ពុទ្ធានុស្សតិ ។ អយំ ខោ ភិក្ខវេ ឯកធម្មោ ភាវិតោ ពហុលីកតោ ឯកន្តនិព្វិទាយ វិរាគាយ និរោធាយ ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតីតិ ។

(១៨០) ឯកធម្មោ ភិក្ខវេ ភាវិតោ ពហុលីកតោ ឯកន្តនិព្វិទាយ វិរាគាយ និរោធាយ ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ ។ កតមោ ឯកធម្មោ ។ ធម្មានុស្សតិ... សង្ឃានុស្សតិ... សីលានុស្សតិ... ចាគានុស្សតិ... ទេវតានុស្សតិ... អានាបានស្សតិ... មរណស្សតិ... កាយគតាសតិ... ឧបសមានុស្សតិ ។ អយំ ខោ ភិក្ខវេ ឯកធម្មោ ភាវិតោ ពហុលីកតោ ឯកន្តនិព្វិទាយ វិរាគាយ

## ឯកធម្មាទិបាលិ ដទៃទៀត

(១៧៩) ម្នាលភិក្ខុទាំងឡាយ ធម៌មួយដែលបុគ្គលចំរើនហើយ ធ្វើឲ្យរឿយៗហើយ តែងប្រព្រឹត្តទៅ ដើម្បីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីរលត់ ដើម្បីរម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីនិព្វានដោយពិត ។ ធម៌មួយតើអ្វី ។ គឺពុទ្ធានុស្សតិ ។ ម្នាលភិក្ខុទាំងឡាយ ធម៌មួយនេះឯង ដែលបុគ្គលចំរើនហើយ ធ្វើឲ្យរឿយៗ ហើយ តែងប្រព្រឹត្តទៅ ដើម្បីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីរលត់ ដើម្បីរម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីនិព្វានដោយពិត ។

(១៨០) ម្នាលភិក្ខុទាំងឡាយ ធម៌មួយដែលបុគ្គលចំរើនហើយ ធ្វើឲ្យរឿយៗហើយ តែងប្រព្រឹត្តទៅ ដើម្បីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីរលត់ ដើម្បីរម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីនិព្វានដោយពិត ។ ធម៌មួយតើអ្វី ។ គឺធម្មានុស្សតិ... សង្ឃានុស្សតិ... សីលានុស្សតិ... ចាគានុស្សតិ... ទេវតានុស្សតិ... អានាបានស្សតិ... មរណស្សតិ... កាយគតាសតិ... ឧបសមានុស្សតិ ។ ម្នាលភិក្ខុទាំងឡាយ ធម៌មួយនេះឯង ដែលបុគ្គលចំរើនហើយ ធ្វើឲ្យរឿយៗ ហើយ តែងប្រព្រឹត្តទៅ ដើម្បីនឿយណាយ ដើម្បីប្រាសចាកតម្រេក

និរោធាយ ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ ។

វគ្គ បឋមោ ។

(១៨១) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យេន អនុប្បន្នា វា អកុសលា ធម្មា ឧប្បជ្ជន្តិ ឧប្បន្នា វា អកុសលា ធម្មា ភិយ្យោភាវាយ វេបុល្លាយ សំវត្តន្តិ យថយិទំ ភិក្ខវេ មិច្ឆាទិដ្ឋិ ។ មិច្ឆាទិដ្ឋិកស្ស ភិក្ខវេ អនុប្បន្នា ចេវ អកុសលា ធម្មា ឧប្បជ្ជន្តិ ឧប្បន្នា ច អកុសលា ធម្មា ភិយ្យោភាវាយ វេបុល្លាយ សំវត្តន្តីតិ ។

(១៨២) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យេន អនុប្បន្នា វា កុសលា ធម្មា ឧប្បជ្ជន្តិ ឧប្បន្នា វា កុសលា ធម្មា ភិយ្យោភាវាយ វេបុល្លាយ សំវត្តន្តិ យថយិទំ ភិក្ខវេ សម្មាទិដ្ឋិ ។ សម្មាទិដ្ឋិកស្ស ភិក្ខវេ អនុប្បន្នា ចេវ កុសលា ធម្មា ឧប្បជ្ជន្តិ ឧប្បន្នា ច កុសលា ធម្មា ភិយ្យោភាវាយ វេបុល្លាយ សំវត្តន្តីតិ ។





ដើម្បីរលត់ ដើម្បីស្ងប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីនិព្វានដោយពិត ។

ចប់ វគ្គ ទី ១ ។

(១៨១) ម្នាលភិក្ខុទាំងឡាយ តថាគតមិនឃើញធម៌ដទៃ សូម្បីតែធម៌មួយ ដែលជាហេតុនាំពួកអកុសលធម៌ ដែលមិនទាន់កើតឲ្យកើតឡើង ឬពួកអកុសលធម៌ ដែលកើតឡើងហើយឲ្យប្រព្រឹត្តទៅយ៉ាងធំទូលាយក្រៃលែង ដូចមិច្ឆាទិដ្ឋិនេះឡើយ ភិក្ខុទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ពួកអកុសលធម៌ ដែលមិនទាន់កើតឡើង រមែងកើតឡើង ឬពួកអកុសលធម៌ ដែលកើតឡើងហើយ ក៏រមែងប្រព្រឹត្តទៅយ៉ាងធំទូលាយក្រៃលែង ដល់បុគ្គលជាមិច្ឆាទិដ្ឋិ ។

(១៨២) ម្នាលភិក្ខុទាំងឡាយ តថាគតមិនឃើញធម៌ដទៃ សូម្បីតែធម៌មួយ ដែលជាហេតុនាំពួកកុសលធម៌ ដែលមិនទាន់កើតឲ្យកើតឡើង ឬពួកកុសលធម៌ ដែលកើតឡើងហើយ ឲ្យប្រព្រឹត្តទៅយ៉ាងធំទូលាយក្រៃលែង ដូចសម្មាទិដ្ឋិនេះឡើយ ភិក្ខុទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ពួកកុសលធម៌ដែលមិនទាន់កើត រមែងកើតឡើង ពួកកុសលធម៌ ដែលកើតឡើងហើយ ក៏ប្រព្រឹត្តទៅយ៉ាងធំទូលាយក្រៃលែង ដល់បុគ្គលជាសម្មាទិដ្ឋិ ។

(១៨៣) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យេន អនុប្បន្នា វា កុសលា ធម្មា នុប្បជ្ជន្តិ ឧប្បន្នា វា កុសលា ធម្មា បរិហាយន្តិ យថយិទំ ភិក្ខវេ មិច្ឆាទិដ្ឋិ ។ មិច្ឆាទិដ្ឋិកស្ស ភិក្ខវេ អនុប្បន្នា ចេវ កុសលា ធម្មា នុប្បជ្ជន្តិ ឧប្បន្នា ច កុសលា ធម្មា បរិហាយន្តីតិ ។

(១៨៤) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យេន អនុប្បន្នា វា អកុសលា ធម្មា នុប្បជ្ជន្តិ ឧប្បន្នា វា អកុសលា ធម្មា បរិហាយន្តិ យថយិទំ ភិក្ខវេ សម្មាទិដ្ឋិ ។ សម្មាទិដ្ឋិកស្ស ភិក្ខវេ អនុប្បន្នា ចេវ អកុសលា ធម្មា នុប្បជ្ជន្តិ ឧប្បន្នា ច អកុសលា ធម្មា បរិហាយន្តីតិ ។

(១៨៥) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យេន អនុប្បន្នា វា មិច្ឆាទិដ្ឋិ ឧប្បជ្ជតិ ឧប្បន្នា វា មិច្ឆាទិដ្ឋិ បវឌ្ឍតិ យថយិទំ ភិក្ខវេ អយោនិសោ មនសិការោ ។



(១៨៣) ម្នាលភិក្ខុទាំងឡាយ តថាគតពុំដែលមើលមិនឃើញធម៌ដទៃ សូម្បីតែធម៌មួយ ដែលជាហេតុនាំពួកកុសលធម៌ ដែលមិនទាន់កើត មិនឲ្យកើតឡើងផង ពួកកុសលធម៌ដែលកើតឡើងហើយ ឲ្យសាបសូន្យទៅវិញ ដូចមិច្ឆាទិដ្ឋិនេះឡើយ ភិក្ខុទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ពួកកុសលធម៌ ដែលមិនទាន់កើតឡើង រមែងមិនកើតឡើង ពួកកុសលធម៌ដែលកើតឡើងហើយ រមែងសាបសូន្យទៅវិញ ដល់បុគ្គលជាមិច្ឆាទិដ្ឋិ ។

(១៨៤) ម្នាលភិក្ខុទាំងឡាយ តថាគតពុំដែលមើលមិនឃើញធម៌ដទៃ សូម្បីតែធម៌មួយ ដែលជាហេតុនាំឲ្យពួកអកុសលធម៌ ដែលមិនទាន់កើតឡើង មិនឲ្យកើតឡើង ពួកអកុសលធម៌ដែលកើតឡើងហើយ ឲ្យសាបសូន្យទៅ ដូចសម្មាទិដ្ឋិនេះឡើយ ភិក្ខុទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ពួកអកុសលធម៌ដែលមិនទាន់កើតឡើង រមែងមិនកើតឡើង ពួកអកុសល-ធម៌ដែលកើតឡើងហើយ រមែងសាបសូន្យទៅ ដល់បុគ្គលជាសម្មាទិដ្ឋិ ។

(១៨៥) ម្នាលភិក្ខុទាំងឡាយ តថាគតពុំដែលមើលមិនឃើញធម៌ដទៃ សូម្បីតែធម៌មួយ ដែលជាហេតុនាំឲ្យមិច្ឆាទិដ្ឋិ ដែលមិនទាន់កើត ឲ្យកើតឡើង ឬមិច្ឆាទិដ្ឋិ ដែលកើតឡើងហើយ ឲ្យរឹតតែចំរើនឡើង ដូចគំនិតដែលត្រិះរិះមិនត្រូវផ្លូវនេះឡើយ ភិក្ខុទាំងឡាយ ។

អយោនិសោ ភិក្ខវេ មនសិករោតោ អនុប្បន្នា ចេវ មិច្ឆាទិដ្ឋិ ឧប្បជ្ជតិ ឧប្បន្នា ច មិច្ឆាទិដ្ឋិ បវឌ្ឍតីតិ ។

(១៨៦) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យេន អនុប្បន្នា វា សម្មាទិដ្ឋិ ឧប្បជ្ជតិ ឧប្បន្នា វា សម្មាទិដ្ឋិ បវឌ្ឍតិ យថយិទំ ភិក្ខវេ យោនិសោ មនសិការោ ។ យោនិសោ ភិក្ខវេ មនសិករោតោ អនុប្បន្នា ចេវ សម្មាទិដ្ឋិ ឧប្បជ្ជតិ ឧប្បន្នា ច សម្មាទិដ្ឋិ បវឌ្ឍតីតិ ។

(១៨៧) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យេនេវំ សត្តា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជន្តិ យថយិទំ ភិក្ខវេ មិច្ឆាទិដ្ឋិ ។ មិច្ឆាទិដ្ឋិយា ភិក្ខវេ សមន្នាគតា សត្តា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជន្តីតិ ។



ម្នាលភិក្ខុទាំងឡាយ មិច្ឆាទិដ្ឋិដែលមិនទាន់កើត ក៏កើតឡើង មិច្ឆាទិដ្ឋិដែលកើតឡើងហើយ ក៏រមែងចំរើនលូតលាស់ឡើង ដល់បុគ្គលមានចិត្តធ្វើទុកមិនត្រូវផ្លូវ ។

(១៨៦) ម្នាលភិក្ខុទាំងឡាយ តថាគតពុំឃើញធម៌ដទៃ សូម្បីតែធម៌មួយ ដែលជាហេតុនាំសម្មាទិដ្ឋិ ដែលមិនទាន់កើតឲ្យកើតឡើង ឬសម្មាទិដ្ឋិដែលកើតឡើងហើយ ឲ្យរមែងចំរើនលូតលាស់ឡើង ដូចមនសិការដែលធ្វើទុកក្នុងចិត្តដោយត្រូវផ្លូវនេះឡើយ ភិក្ខុទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ សម្មាទិដ្ឋិដែលមិនទាន់កើត ក៏កើតឡើង សម្មាទិដ្ឋិដែលកើតឡើងហើយ ក៏រមែងចំរើនលូតលាស់ឡើង ដល់បុគ្គលមានចិត្តធ្វើទុកត្រូវផ្លូវ ។

(១៨៧) ម្នាលភិក្ខុទាំងឡាយ តថាគតពុំឃើញធម៌ដទៃ សូម្បីតែធម៌មួយ ដែលជាហេតុនាំពួកសត្វ ដែលបែកធ្លាយរាងកាយស្លាប់ទៅ ឲ្យទៅកើតជាតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក ដូចជាមិច្ឆាទិដ្ឋិនេះឡើយ ភិក្ខុទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលប្រកបដោយមិច្ឆាទិដ្ឋិ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតជាតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក ។

(១៨៨) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យេនេវំ សត្តា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ យថយិទំ ភិក្ខវេ សម្មាទិដ្ឋិ ។ សម្មាទិដ្ឋិយា ភិក្ខវេ សមន្នាគតា សត្តា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តីតិ ។

(១៨៩) មិច្ឆាទិដ្ឋិកស្ស ភិក្ខវេ បុរិសបុគ្គលស្ស យញ្ចេវ កាយកម្មំ យថាទិដ្ឋិសមត្តំ សមាទិន្នំ យញ្ច វចីកម្មំ យថាទិដ្ឋិសមត្តំ សមាទិន្នំ យញ្ច មនោកម្មំ យថាទិដ្ឋិសមត្តំ សមាទិន្នំ យា ច ចេតនា យា ច បត្ថនា យោ ច បណិធិ យេ ច សង្ខារា សព្វេ តេ ធម្មា អនិដ្ឋាយ អកន្តាយ អមនាបាយ អហិតាយ ទុក្ខាយ សំវត្តន្តិ ។ តំ កិស្ស ហេតុ ។ ទិដ្ឋិ ហិ ភិក្ខវេ បាបិកា ។ សេយ្យថាបិ ភិក្ខវេ និម្ពពីជំ វា កោសាតកីពីជំ វា តិត្តកាលាពុពីជំ វា អល្លាយ បឋវិយា និក្ខិត្តំ



(១៨៨) ម្នាលភិក្ខុទាំងឡាយ តថាគតពិចារណាមើលមិនឃើញធម៌ដទៃ សូម្បីតែធម៌មួយ ដែលជាហេតុនាំពួកសត្វ ដែលបែកធ្លាយរាងកាយស្លាប់ទៅ ឲ្យទៅកើតក្នុងសុគតិសួគ៌ទេវលោក ដូចយ៉ាងសម្មាទិដ្ឋិនេះឡើយ ភិក្ខុទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលប្រកបដោយសម្មាទិដ្ឋិ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងកើតក្នុងសុគតិសួគ៌ទេវលោក ។

(១៨៩) ម្នាលភិក្ខុទាំងឡាយ កាយកម្មណាក្តី ដែលបុរសបុគ្គលជាមិច្ឆាទិដ្ឋិបានធ្វើពេញ បានសមាទានតាមទិដ្ឋិហើយ វចីកម្មណាក្តី ដែលបុរសបុគ្គលជាមិច្ឆាទិដ្ឋិបានធ្វើពេញ បានសមាទានតាមទិដ្ឋិហើយ មនោកម្មណាក្តី ដែលបុរសបុគ្គលជាមិច្ឆាទិដ្ឋិបានធ្វើពេញ បានសមាទានតាមទិដ្ឋិហើយ ចេតនាណាក្តី សេចក្តីប្រាថ្នាណាក្តី សេចក្តីប្រណិធានណាក្តី សង្ខារទាំងឡាយណាក្តី ធម៌ទាំងអស់នោះ សុទ្ធតែប្រព្រឹត្តទៅ ដើម្បីមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីគាប់ចិត្ត មិនជាប្រយោជន៍ ជាទុក្ខ ។ ដំណើរនោះព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះទិដ្ឋិជាធម្មជាតិដ៏លាមក ។ ម្នាលភិក្ខុទាំងឡាយ ដូចជាពូជស្ដៅក្តី ពូជខាតនិត្រក្តី ពូជត្រសក់ល្វីងក្តី ដែលបុគ្គលដាំ ក្នុងដីសើម

យញ្ចេវ បថវីរសំ ឧបាទិយតិ យញ្ច អាបោរសំ ឧបាទិយតិ សព្វន្តំ តិត្តកត្តាយ កដុកត្តាយ អសាតត្តាយ សំវត្តតិ ។ តំ កិស្ស ហេតុ ។ ពីជំ ហិ ភិក្ខវេ បាបកំ ។ ឯវមេវ ខោ ភិក្ខវេ មិច្ឆាទិដ្ឋិកស្ស បុរិសបុគ្គលស្ស យញ្ចេវ កាយកម្មំ យថាទិដ្ឋិសមត្តំ សមាទិន្នំ យញ្ច វចីកម្មំ យថាទិដ្ឋិសមត្តំ សមាទិន្នំ យញ្ច មនោកម្មំ យថាទិដ្ឋិសមត្តំ សមាទិន្នំ យា ច ចេតនា យា ច បត្ថនា យោ ច បណិធិ យេ ច សង្ខារា សព្វេ តេ ធម្មា អនិដ្ឋាយ អកន្តាយ អមនាបាយ អហិតាយ ទុក្ខាយ សំវត្តន្តិ ។ តំ កិស្ស ហេតុ ។ ទិដ្ឋិ ហិ ភិក្ខវេ បាបិកាតិ ។

(១៩០) សម្មាទិដ្ឋិកស្ស ភិក្ខវេ បុរិសបុគ្គលស្ស យញ្ចេវ កាយកម្មំ យថាទិដ្ឋិសមត្តំ សមាទិន្នំ យញ្ច វចីកម្មំ យថាទិដ្ឋិសមត្តំ សមាទិន្នំ យញ្ច មនោកម្មំ យថាទិដ្ឋិសមត្តំ សមាទិន្នំ យា ច ចេតនា យា ច បត្ថនា យោ ច បណិធិ



ដែលស្រូបយករសដីណាក្តី ស្រូបយករសទឹកណាក្តី រសជាតិទាំងអស់នោះ តែងប្រព្រឹត្តទៅដើម្បីល្វីងខាំងមិនឆ្ងាញ់ ។ ដំណើរនោះព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះពូជជារបស់មិនល្អ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ កាយកម្មណាក្តី ដែលបុរសបុគ្គល ជាមិច្ឆាទិដ្ឋិ បានបំពេញ បានសមាទានកាន់តាមទិដ្ឋិហើយ វចីកម្មណាក្តី ដែលបុរសបុគ្គល ជាមិច្ឆាទិដ្ឋិបានបំពេញ បានសមាទានកាន់តាមទិដ្ឋិហើយ មនោកម្មណាក្តី ដែលបុរសបុគ្គល ជាមិច្ឆាទិដ្ឋិបានបំពេញ បានសមាទានកាន់តាមទិដ្ឋិហើយ ចេតនាណាក្តី សេចក្តីប្រាថ្នាណាក្តី សេចក្តីប្រណិធានណាក្តី សង្ខារទាំងឡាយណាក្តី ធម៌ទាំងអស់នោះ តែងប្រព្រឹត្តទៅ ដើម្បីមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីគាប់ចិត្ត មិនជាប្រយោជន៍ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះទិដ្ឋិ ជារបស់អាក្រក់ គឺយ៉ាងនេះឯង ។

(១៩០) ម្នាលភិក្ខុទាំងឡាយ កាយកម្មណាក្តី ដែលបុរសបុគ្គល ជាសម្មាទិដ្ឋិបានបំពេញ បានសមាទានកាន់តាមទិដ្ឋិហើយ វចីកម្មណាក្តី ដែលបុគ្គលជាសម្មាទិដ្ឋិបានបំពេញ បានសមាទានកាន់តាមទិដ្ឋិហើយ មនោកម្មណាក្តី ដែលបុរសបុគ្គលជាសម្មាទិដ្ឋិបានបំពេញ បានសមាទានកាន់តាមទិដ្ឋិហើយ ចេតនាណាក្តី សេចក្តីប្រាថ្នាណាក្តី

យេ ច សង្ខារា សព្វេ តេ ធម្មា ឥដ្ឋាយ កន្តាយ មនាបាយ ហិតាយ សុខាយ សំវត្តន្តិ ។ តំ កិស្ស ហេតុ ។ ទិដ្ឋិ ហិ ភិក្ខវេ ភទ្ទិកា ។ សេយ្យថាបិ ភិក្ខវេ ឧច្ឆុពីជំ វា សាលិពីជំ វា មុទ្ទិកាពីជំ វា អល្លាយ បឋវិយា និក្ខិត្តំ យញ្ចេវ បឋវីរសំ ឧបាទិយតិ យញ្ច អាបោរសំ ឧបាទិយតិ សព្វន្តំ មធុរត្តាយ សាតត្តាយ អសេចនកត្តាយ សំវត្តតិ ។ តំ កិស្ស ហេតុ ។ ពីជំ ហិ ភិក្ខវេ ភទ្ទកំ ។ ឯវមេវ ខោ ភិក្ខវេ សម្មាទិដ្ឋិកស្ស បុរិសបុគ្គលស្ស យញ្ចេវ កាយកម្មំ យថាទិដ្ឋិសមត្តំ សមាទិន្នំ យញ្ច វចីកម្មំ យថាទិដ្ឋិសមត្តំ សមាទិន្នំ យញ្ច មនោកម្មំ យថាទិដ្ឋិសមត្តំ សមាទិន្នំ យា ច ចេតនា យា ច បត្ថនា យោ ច បណិធិ យេ ច សង្ខារា សព្វេ តេ ធម្មា ឥដ្ឋាយ កន្តាយ មនាបាយ ហិតាយ សុខាយ សំវត្តន្តិ ។ តំ កិស្ស ហេតុ ។ ទិដ្ឋិ ហិ ភិក្ខវេ ភទ្ទិកាតិ ។

វគ្គោ ទុតិយោ ។



សេចក្តីប្រណិធានណាក្តី សង្ខារទាំងឡាយណាក្តី ធម៌ទាំងអស់នោះ តែងប្រព្រឹត្តទៅ ដើម្បីជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ជាប្រយោជន៍ ជាសុខ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះទិដ្ឋិ ជាធម្មជាតចំរើន ។ ម្នាលភិក្ខុទាំងឡាយ ដូចពូជអំពៅក្តី ពូជស្រូវសាលីក្តី ពូជចន្ទន៍ក្តី ដែលបុគ្គលដាំក្នុងដីសើម តែងស្រូបយករសដីណាក្តី ស្រូបយករសទឹកណាក្តី រសជាតិទាំងអស់នោះ តែងប្រព្រឹត្តទៅ ដើម្បីរសផ្អែម មិនច្រឡំដោយរសឯទៀត ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះពូជ ជារបស់ចំរើន យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ កាយកម្មណាក្តី ដែលបុរសបុគ្គលជាសម្មាទិដ្ឋិ បានបំពេញ បានសមាទានតាមទិដ្ឋិហើយ វចីកម្មណាក្តី ដែលបុរសបុគ្គល ជាសម្មាទិដ្ឋិបានបំពេញ បានសមាទានតាមទិដ្ឋិហើយ មនោកម្មណាក្តី ដែលបុរសបុគ្គល ជាសម្មាទិដ្ឋិ បានបំពេញ បានសមាទានតាមទិដ្ឋិហើយ ចេតនាណាក្តី សេចក្តីប្រាថ្នាណាក្តី សេចក្តីប្រណិធានណាក្តី សង្ខារទាំងឡាយណាក្តី ធម៌ទាំងអស់នោះ តែងប្រព្រឹត្តទៅ ដើម្បីជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ជាប្រយោជន៍ ជាសុខ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះទិដ្ឋិ ជាធម្មជាតចំរើន គឺយ៉ាងនេះឯង ។

ចប់ វគ្គទី ២ ។

[១៩០] ឯកបុគ្គលោ ភិក្ខវេ លោកេ ឧប្បជ្ជមានោ ឧប្បជ្ជតិ ពហុជនាហិតាយ ពហុជនាសុខាយ ពហុនោ ជនស្ស អនត្ថាយ អហិតាយ ទុក្ខាយ ទេវមនុស្សានំ ។ កតមោ ឯកបុគ្គលោ ។ មិច្ឆាទិដ្ឋិកោ ហោតិ វិបរីតទស្សនោ សោ ពហុជនំ សទ្ធម្មា វុដ្ឋាបេត្វា អសទ្ធម្មេ បតិដ្ឋាបេតិ ។ អយំ ខោ ភិក្ខវេ ឯកបុគ្គលោ លោកេ ឧប្បជ្ជមានោ ឧប្បជ្ជតិ ពហុជនាហិតាយ ពហុជនាសុខាយ ពហុនោ ជនស្ស អនត្ថាយ អហិតាយ ទុក្ខាយ ទេវមនុស្សានន្តិ ។

[១៩១] ឯកបុគ្គលោ ភិក្ខវេ លោកេ ឧប្បជ្ជមានោ ឧប្បជ្ជតិ ពហុជនហិតាយ ពហុជនសុខាយ ពហុនោ ជនស្ស អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ ។ កតមោ ឯកបុគ្គលោ ។ សម្មាទិដ្ឋិកោ ហោតិ អវិបរីតទស្សនោ សោ ពហុជនំ អសទ្ធម្មា វុដ្ឋាបេត្វា សទ្ធម្មេ បតិដ្ឋាបេតិ ។ អយំ ខោ ភិក្ខវេ ឯកបុគ្គលោ



[១៩០] ម្នាលភិក្ខុទាំងឡាយ បុគ្គលមួយ កាលកើតឡើងក្នុងលោក ក៏កើតឡើង ដើម្បីមិនជាប្រយោជន៍ ដល់ជនច្រើន ដើម្បីមិនជាសុខ ដល់ជនច្រើន ដើម្បីសេចក្តីវិនាស ដល់ជនច្រើន ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ដល់ទេវតានិងមនុស្សទាំងឡាយ ។ បុគ្គលម្នាក់ តើដូចម្តេច ។ គឺបុគ្គលជាមិច្ឆាទិដ្ឋិ ជាអ្នកយល់ខុស បុគ្គលនោះ រមែងនាំជនច្រើនឲ្យឃ្លាតចាកព្រះសទ្ធម្ម ឲ្យតាំងនៅក្នុងអសទ្ធម្ម ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលម្នាក់នេះឯង កាលកើតឡើងក្នុងលោក ក៏កើតឡើង ដើម្បីមិនជាប្រយោជន៍ ដល់ជនច្រើន ដើម្បីមិនជាសុខ ដល់ជនច្រើន ដើម្បីសេចក្តីវិនាសដល់ជនច្រើន ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ដល់ទេវតានិងមនុស្សទាំងឡាយ ។

[១៩១] ម្នាលភិក្ខុទាំងឡាយ បុគ្គលម្នាក់កាលកើតឡើងក្នុងលោក ក៏កើតឡើង ដើម្បីជាប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខ ដល់ជនច្រើន ដើម្បីសេចក្តីចំរើន ដល់ជនច្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ ។ បុគ្គលម្នាក់ តើដូចម្តេច ។ គឺបុគ្គលជាសម្មាទិដ្ឋិជាអ្នកយល់ត្រូវ បុគ្គលនោះ រមែងនាំជនច្រើនឲ្យឃ្លាតចាកអសទ្ធម្ម ឲ្យតាំងនៅក្នុងព្រះសទ្ធម្ម ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលម្នាក់នេះឯង

លោកេ ឧប្បជ្ជមានោ ឧប្បជ្ជតិ ពហុជនហិតាយ ពហុជនសុខាយ ពហុនោ ជនស្ស អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានន្តិ ។

(១៨៣) នាហំ ភិក្ខវេ អញ្ញំ ឯកធម្មម្បិ សមនុបស្សាមិ យំ ឯវំ មហាសាវជ្ជំ យថយិទំ ភិក្ខវេ មិច្ឆាទិដ្ឋិ ។ មិច្ឆាទិដ្ឋិបរមានិ ភិក្ខវេ វជ្ជានីតិ (១) ។

(១៨៤) នាហំ ភិក្ខវេ អញ្ញំ ឯកបុគ្គលម្បិ សមនុបស្សាមិ យោ ឯវំ ពហុជនាហិតាយ បដិបន្នោ ពហុជនាសុខាយ ពហុនោ ជនស្ស អនត្ថាយ អហិតាយ ទុក្ខាយ ទេវមនុស្សានំ យថយិទំ ភិក្ខវេ មក្ខលិ មោឃបុរិសោ ។ សេយ្យថាបិ ភិក្ខវេ នទីមុខេ ខិប្បំ ឧឌ្ឌេយ្យ(២) ពហូនំ មច្ឆានំ អហិតាយ ទុក្ខាយ អនយាយ ព្យសនាយ ។ ឯវមេវ ខោ ភិក្ខវេ មក្ខលិ មោឃបុរិសោ មនុស្សខិប្បំ មញ្ញេ លោកេ ឧប្បន្នោ ពហូនំ សត្តានំ អហិតាយ ទុក្ខាយ អនយាយ ព្យសនាយាតិ ។

១ ឧ. ម. មហាសាវជ្ជានីតិ ។ ២ ម. ឱឌ្ឌេយ្យ ។



កាលកើតឡើងក្នុងលោក ក៏កើតឡើងដើម្បីជាប្រយោជន៍ ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីសេចក្តីចំរើនដល់ជនច្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ ។

[១៨៣] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងមើលមិនឃើញធម៌ដទៃ សូម្បីតែធម៌មួយ ដែលមានទោសធំយ៉ាងនេះដូចមិច្ឆាទិដ្ឋិនេះឡើយ ភិក្ខុទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ទោសទាំងឡាយ មានតែមិច្ឆាទិដ្ឋិជាទោសក្រៃលែង ។

[១៨៤] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងមើលមិនឃើញបុគ្គលដទៃ សូម្បីតែបុគ្គលម្នាក់ ជាអ្នកប្រតិបត្តិដើម្បីមិនជាប្រយោជន៍ ដល់ជនច្រើន ដើម្បីមិនជាសេចក្តីសុខ ដល់ជនច្រើន ដើម្បីសេចក្តីវិនាសដល់ជនច្រើន ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ដល់ទេវតានិងមនុស្សទាំងឡាយ យ៉ាងនេះ ដូចមក្ខលិមោឃ(១) បុរសនេះឡើយ ភិក្ខុទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ដូចបុគ្គលដាក់លបទៅមាត់ស្ទឹង ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ដើម្បីសេចក្តីមិនចំរើន ដើម្បីសេចក្តីវិនាសដល់ត្រីជាច្រើន យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ មក្ខលិមោឃបុរស កើតឡើងហើយក្នុងលោក ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ដើម្បីសេចក្តីមិនចំរើន ដើម្បីសេចក្តីវិនាស ដល់ពួកសត្វជាច្រើន ប្រហែលគ្នានឹងលបដាក់មនុស្ស ឃាត់ដំណើររបស់មហាជនមិនឲ្យទៅស្ថានសួគ៌និព្វានបាន ក៏យ៉ាងនោះឯង ។

១ សំដៅយកឈ្មោះ មក្ខលិគោសាល ។ អដ្ឋកថា ។

(១៩៥) ទុរក្ខាតេ ភិក្ខវេ ធម្មវិនយេ យោ ច សមាទបេតិ យញ្ច សមាទបេតិ យោ ច សមាទបិតោ តថត្តាយ បដិបជ្ជតិ សព្វេ តេ ពហុំ អបុញ្ញំ បសវន្តិ ។ តំ កិស្ស ហេតុ ។ ទុរក្ខាតត្តា ភិក្ខវេ ធម្មស្សាតិ ។

(១៩៦) ស្វាក្ខាតេ ភិក្ខវេ ធម្មវិនយេ យោ ច សមាទបេតិ យញ្ច សមាទបេតិ យោ ច សមាទបិតោ តថត្តាយ បដិបជ្ជតិ សព្វេ តេ ពហុំ បុញ្ញំ បសវន្តិ ។ តំ កិស្ស ហេតុ ។ ស្វាក្ខាតត្តា ភិក្ខវេ ធម្មស្សាតិ ។

(១៩៧) ទុរក្ខាតេ ភិក្ខវេ ធម្មវិនយេ ទាយកេន មត្តា ជានិតព្វា នោ បដិគ្គាហកេន ។ តំ កិស្ស ហេតុ ។ ទុរក្ខាតត្តា ភិក្ខវេ ធម្មស្សាតិ ។



(១៩៥) ម្នាលភិក្ខុទាំងឡាយ បុគ្គល (ជាអាចារ្យ) ណាក្តី បបួលគេ ក្នុងធម្មវិន័យ ដែលសាស្តាជាអសព្វញ្ញូពោលមិនត្រូវ បបួលនូវបុគ្គល (ជាអន្តេវាសិក) ណាក្តី បុគ្គល (ជាអន្តេវាសិក) ណា ដែលអាចារ្យបបួលហើយប្រតិបត្តិតាមយ៉ាងនោះ បុគ្គលទាំងអស់នោះ តែងបាននូវបាបជាច្រើន ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះធម៌ដែលគេពោលខុស ។

(១៩៦) ម្នាលភិក្ខុទាំងឡាយ បុគ្គល (ជាអាចារ្យ) ណាក្តី បបួលគេ ក្នុងធម្មវិន័យដែលសាស្តាជាសព្វញ្ញូពោលត្រូវ បបួលនូវបុគ្គល (ជាអន្តេវាសិក) ណាក្តី បុគ្គល (ជាអន្តេវាសិក) ណា ដែលអាចារ្យបបួលហើយប្រតិបត្តិតាមយ៉ាងនោះ បុគ្គលទាំងអស់នោះ តែងបាននូវបុណ្យជាច្រើន ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះធម៌ដែលគេពោលត្រឹមត្រូវ ។

(១៩៧) ម្នាលភិក្ខុទាំងឡាយ ក្នុងធម្មវិន័យដែលសាស្តាជាអសព្វញ្ញូពោលមិនត្រូវជា បុគ្គលជាទាយក (អ្នកឲ្យ) ត្រូវដឹងប្រមាណ បុគ្គលជាបដិគ្គាហក (អ្នកទទួល) មិនបាច់ដឹងប្រមាណទេ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះធម៌ដែលសាស្តាជាអសព្វញ្ញូពោលខុស ។

(១៩៨) ស្វាក្ខាតេ ភិក្ខវេ ធម្មវិនយេ បដិគ្គាហកេន មត្តា ជានិតព្វា នោ ទាយកេន ។ តំ កិស្ស ហេតុ ។ ស្វាក្ខាតត្តា ភិក្ខវេ ធម្មស្សាតិ ។

(១៩៩) ទុរក្ខាតេ ភិក្ខវេ ធម្មវិនយេ យោ អារទ្ធវីរិយោ សោ ទុក្ខំ វិហរតិ ។ តំ កិស្ស ហេតុ ។ ទុរក្ខាតត្តា ភិក្ខវេ ធម្មស្សាតិ ។

(២០០) ស្វាក្ខាតេ ភិក្ខវេ ធម្មវិនយេ យោ កុសីតោ សោ ទុក្ខំ វិហរតិ ។ តំ កិស្ស ហេតុ ។ ស្វាក្ខាតត្តា ភិក្ខវេ ធម្មស្សាតិ ។

(២០១) ទុរក្ខាតេ ភិក្ខវេ ធម្មវិនយេ យោ កុសីតោ សោ សុខំ វិហរតិ ។ តំ កិស្ស ហេតុ ។ ទុរក្ខាតត្តា ភិក្ខវេ ធម្មស្សាតិ ។



(១៩៨) ម្នាលភិក្ខុទាំងឡាយ ក្នុងធម្មវិន័យដែលសាស្ដាជាសព្វញ្ញូពោលត្រឹមត្រូវហើយ បដិគ្គាហកត្រូវដឹងប្រមាណ ទាយកមិនបាច់ដឹងប្រមាណទេ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះធម៌ដែលសាស្ដាជាសព្វញ្ញូពោលត្រឹមត្រូវ ។

(១៩៩) ម្នាលភិក្ខុទាំងឡាយ ក្នុងធម្មវិន័យ ដែលសាស្ដាជាអសព្វញ្ញូពោលមិនត្រឹមត្រូវហើយ បុគ្គលណាមានព្យាយាមប្រារព្ធ បុគ្គលនោះ តែងនៅជាទុក្ខ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះធម៌ដែលសាស្ដាជាអសព្វញ្ញូពោលខុស ។

(២០០) ម្នាលភិក្ខុទាំងឡាយ ក្នុងធម្មវិន័យដែលសាស្ដាជាសព្វញ្ញូពោលត្រឹមត្រូវហើយ បុគ្គលណាខ្ជិលច្រអូស បុគ្គលនោះ តែងនៅជាទុក្ខ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះធម៌ដែលសាស្ដាជាសព្វញ្ញូពោលត្រឹមត្រូវ ។

(២០១) ម្នាលភិក្ខុទាំងឡាយ ក្នុងធម្មវិន័យដែលសាស្ដាជាអសព្វញ្ញូពោលមិនត្រឹមត្រូវហើយ បុគ្គលណាខ្ជិលច្រអូស បុគ្គលនោះ តែងនៅជាសុខ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះធម៌ដែលសាស្ដាជាអសព្វញ្ញូពោលខុស ។

វីរិយសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ... ចិត្តសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ... វីមំសាសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ... សទ្ធិន្ទ្រិយំ ភាវេតិ... វីរិយិន្ទ្រិយំ ភាវេតិ... សតិន្ទ្រិយំ ភាវេតិ... សមាធិន្ទ្រិយំ ភាវេតិ... បញ្ញិន្ទ្រិយំ ភាវេតិ... សទ្ធាពលំ ភាវេតិ... វីរិយពលំ ភាវេតិ... សតិពលំ ភាវេតិ... សមាធិពលំ ភាវេតិ... បញ្ញាពលំ ភាវេតិ... សតិសម្ពោជ្ឈង្គំ ភាវេតិ... ធម្មវិចយសម្ពោជ្ឈង្គំ ភាវេតិ... វីរិយសម្ពោជ្ឈង្គំ ភាវេតិ... បីតិសម្ពោជ្ឈង្គំ ភាវេតិ... បស្សទ្ធិសម្ពោជ្ឈង្គំ ភាវេតិ... សមាធិសម្ពោជ្ឈង្គំ ភាវេតិ... ឧបេក្ខាសម្ពោជ្ឈង្គំ ភាវេតិ... សម្មាទិដ្ឋឹ ភាវេតិ... សម្មាសង្កប្បំ ភាវេតិ... សម្មាកម្មន្តំ ភាវេតិ... សម្មាវាចំ ភាវេតិ... សម្មាអាជីវំ ភាវេតិ... សម្មាវាយាមំ ភាវេតិ... សម្មាសតឹ ភាវេតិ... សម្មាសមាធឹ ភាវេតិ...

[៦១០] អជ្ឈត្តំ រូបសញ្ញី ពហិទ្ធា រូបានិ បស្សតិ បរិត្តានិ សុវណ្ណទុព្ពណ្ណានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ...



ចំរើនឥទ្ធិបាទ ប្រកបដោយចិត្តសមាធិប្បធានសង្ខារ... ចំរើនឥទ្ធិបាទ ប្រកបដោយវីមំសាសមាធិប្បធានសង្ខារ... ចំរើនសទ្ធិន្ទ្រិយ... ចំរើនវីរិយិន្ទ្រិយ... ចំរើនសតិន្ទ្រិយ... ចំរើនសមាធិន្ទ្រិយ... ចំរើនបញ្ញិន្ទ្រិយ... ចំរើនសទ្ធាពល... ចំរើនវីរិយពល... ចំរើនសតិពល... ចំរើនសមាធិពល... ចំរើនបញ្ញាពល... ចំរើនសតិសម្ពោជ្ឈង្គ... ចំរើនធម្មវិចយសម្ពោជ្ឈង្គ... ចំរើនវីរិយសម្ពោជ្ឈង្គ... ចំរើនបីតិសម្ពោជ្ឈង្គ... ចំរើនបស្សទ្ធិសម្ពោជ្ឈង្គ... ចំរើនសមាធិសម្ពោជ្ឈង្គ... ចំរើនឧបេក្ខាសម្ពោជ្ឈង្គ... ចំរើនសម្មាទិដ្ឋិ... ចំរើនសម្មាសង្កប្ប... ចំរើនសម្មាកម្មន្ត... ចំរើនសម្មាវាចា... ចំរើនសម្មាអាជីវ... ចំរើនសម្មាវាយាម... ចំរើនសម្មាសតិ... ចំរើនសម្មាសមាធិ...

[៦១០] បុគ្គលមានសេចក្តីសំគាល់ក្នុងរូបខាងក្នុង(១) ឃើញនូវរូបខាងក្រៅ(២) ដែលតូចៗ មានសម្បុរល្អក្តីមិនល្អក្តី គ្របសង្កត់នូវរូបទាំងនោះ ហើយជាបុគ្គលមានសេចក្តីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញ ...

---

១ សំដៅយក សក់ព្រោមកាំស្រមើលភ្នែកជាដើម ។ ២ សំដៅយកនិមិត្តខាងក្រៅដែលកើតឡើង ក្នុងវេលាធ្វើបរិកម្មរូបខាងក្នុងនោះ ។

(២១១) អជ្ឈត្តំ រូបសញ្ញី ពហិទ្ធា រូបានិ បស្សតិ អប្បមាណានិ សុវណ្ណទុព្វណ្ណានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ...

(២១២) អជ្ឈត្តំ អរូបសញ្ញី ពហិទ្ធា រូបានិ បស្សតិ បរិត្តានិ សុវណ្ណទុព្វណ្ណានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ...

(២១៣) អជ្ឈត្តំ អរូបសញ្ញី ពហិទ្ធា រូបានិ បស្សតិ អប្បមាណានិ សុវណ្ណទុព្វណ្ណានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ...

(២១៤) អជ្ឈត្តំ អរូបសញ្ញី ពហិទ្ធា រូបានិ បស្សតិ នីលានិ នីលវណ្ណានិ នីលនិទស្សនានិ នីលនិភាសានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ...



(២១១) បុគ្គលមានសេចក្ដីសំគាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅដែលជារូបធំ មានសម្បុរល្អក្ដីមានសម្បុរអាក្រក់ គ្របសង្កត់នូវរូបទាំងនោះ ហើយជាបុគ្គលមានសេចក្ដីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញ...

(២១២) បុគ្គលមិនមានសេចក្ដីសំគាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ដែលជារូបតូច មានសម្បុរល្អក្ដីមានសម្បុរអាក្រក់ គ្របសង្កត់នូវរូបទាំងនោះ ហើយជាបុគ្គលមានសេចក្ដីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញ...

(២១៣) បុគ្គលមិនមានសេចក្ដីសំគាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ដែលជារូបធំ មានសម្បុរល្អក្ដីមានសម្បុរអាក្រក់ គ្របសង្កត់នូវរូបទាំងនោះ ហើយជាបុគ្គលមានសេចក្ដីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញ...

(២១៤) បុគ្គលមិនមានសេចក្ដីសំគាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ដែលជារូបខៀវ មានសម្បុរខៀវ ប្រាកដជាសម្បុរខៀវ មានរស្មីខៀវ គ្របសង្កត់នូវរូបទាំងនោះ ហើយជាបុគ្គលមានសេចក្ដីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញ...

អថ ខោ ឯតេវ សត្តា ពហុតរា យេ ទុប្បញ្ញា ជឡា ឯឡមូគា ន បដិពលា សុភាសិតទុព្ភាសិតស្ស អត្ថមញ្ញាតុំ ។ ឯវមេវ ខោ ភិក្ខវេ អប្បកា តេ សត្តា យេ អរិយេន បញ្ញាចក្ខុនា សមន្នាគតា អថ ខោ ឯតេវ សត្តា ពហុតរា យេ អវិជ្ជាគតា សម្មូឡ្ហា ។ ឯវមេវ ខោ ភិក្ខវេ អប្បកា តេ សត្តា យេ លភន្តិ តថាគតំ ទស្សនាយ អថ ខោ ឯតេវ សត្តា ពហុតរា យេ ន លភន្តិ តថាគតំ ទស្សនាយ ។ ឯវមេវ ខោ ភិក្ខវេ អប្បកា តេ សត្តា យេ លភន្តិ តថាគតប្បវេទិតំ ធម្មវិនយំ សវនាយ អថ ខោ ឯតេវ សត្តា ពហុតរា យេ ន លភន្តិ តថាគតប្បវេទិតំ ធម្មវិនយំ សវនាយ ។ ឯវមេវ ខោ ភិក្ខវេ អប្បកា តេ សត្តា យេ សុត្វា ធម្មំ ធារេន្តិ អថ ខោ ឯតេវ សត្តា ពហុតរា យេ សុត្វា ធម្មំ ន ធារេន្តិ ។ ឯវមេវ ខោ ភិក្ខវេ អប្បកា តេ សត្តា យេ ធាតានំ ធម្មានំ អត្ថំ ឧបបរិក្ខន្តិ



ពួកសត្វដែលឥតប្រាជ្ញា ជាមនុស្សគល្ងង់ល្ងើ មិនអាចនឹងដឹងសេចក្តីនៃសុភាសិត ទុព្ភាសិតបាន ច្រើនជាង គឺយ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលប្រកបដោយបញ្ញាចក្ខុដ៏ប្រសើរ មានចំនួនតិច ពួកសត្វដែលលុះក្នុងអំណាចអវិជ្ជា ជាមនុស្សវង្វេង ច្រើនជាង គឺយ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលបានឃើញតថាគត មានប្រមាណតិច សត្វទាំងឡាយ ដែលមិនបានឃើញតថាគតច្រើនជាង គឺយ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលបានស្តាប់ធម្មវិន័យ តថាគតសំដែងហើយ មានចំនួនតិច ពួកសត្វដែលមិនបានស្តាប់ធម្មវិន័យ តថាគតសំដែង ច្រើនជាង គឺយ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលស្តាប់ធម៌ហើយ ចងចាំបាន មានចំនួនតិច ពួកសត្វដែលស្តាប់ធម៌ហើយ ចងចាំមិនបាន ច្រើនជាង គឺយ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលពិចារណានូវសេចក្តីនៃធម៌ទាំងឡាយដែលខ្លួនចងចាំបានហើយ

ថ ខោ ឯតេវ សត្តា ពហុតរា យេ ធតានំ ធម្មានំ អត្ថំ ន ឧបបរិក្ខន្តិ ។ ឯវមេវ ខោ ភិក្ខវេ អប្បកា តេ សត្តា យេ អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មំ បដិបជ្ជន្តិ អថ ខោ ឯតេវ សត្តា ពហុតរា យេ អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មំ ន បដិបជ្ជន្តិ ។ ឯវមេវ ខោ ភិក្ខវេ អប្បកា តេ សត្តា យេ សំវេជនីយេសុ ឋានេសុ សំវិជ្ជន្តិ អថ ខោ ឯតេវ សត្តា ពហុតរា យេ សំវេជនីយេសុ ឋានេសុ ន សំវិជ្ជន្តិ ។ ឯវមេវ ខោ ភិក្ខវេ អប្បកា តេ សត្តា យេ សំវិគ្គា យោនិសោ បទហន្តិ អថ ខោ ឯតេវ សត្តា ពហុតរា យេ សំវិគ្គា យោនិសោ ន បទហន្តិ ។ ឯវមេវ ខោ ភិក្ខវេ អប្បកា តេ សត្តា យេ វវស្សគ្គារម្មណំ ករិត្វា លភន្តិ សមាធឹ លភន្តិ ចិត្តស្សេកគ្គតំ អថ ខោ ឯតេវ សត្តា ពហុតរា យេ វវស្សគ្គារម្មណំ ករិត្វា ន លភន្តិ សមាធឹ ន លភន្តិ ចិត្តស្សេកគ្គតំ ។



ខាងចំនួនតិច ពួកសត្វដែលមិនពិចារណានូវសេចក្តីអធិប្បាយនៃធម៌ទាំង-ឡាយដែលខ្លួនចេះចាំបានហើយ ច្រើនជាង ពួកនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលដឹងច្បាស់នូវសេចក្តីអធិប្បាយ ដឹងច្បាស់នូវបាលី ហើយប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌ មានប្រមាណតិច ពួកសត្វដែលដឹងច្បាស់នូវសេចក្តីអធិប្បាយ ដឹងច្បាស់នូវបាលី ហើយមិនប្រតិបត្តិធម៌សមគួរដល់ធម៌ ច្រើនជាង ពួកនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលសង្វេគ ក្នុងហេតុដែលគួរសង្វេគ មានចំនួនតិច ពួកសត្វដែលមិនសង្វេគ ក្នុងហេតុដែលគួរសង្វេគ ច្រើនជាង ពួកនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលសង្វេគហើយ ផ្គងព្យាយាមឡើង ដោយការយកចិត្តទុកដាក់ មានចំនួនតិច ពួកសត្វដែលសង្វេគហើយ មិនផ្គងព្យាយាមឡើង ដោយការយកចិត្តទុកដាក់ ច្រើនជាង ពួកនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលធ្វើព្រះនិព្វាន ឲ្យជាអារម្មណ៍ហើយបាននូវសមាធិ(១) បាននូវឯកគ្គតាចិត្ត មានចំនួនតិច ពួកសត្វដែលធ្វើព្រះនិព្វាន ឲ្យជាអារម្មណ៍ហើយមិនបាននូវសមាធិ មិនបាននូវឯកគ្គតាចិត្ត ច្រើនជាង ពួកនោះដែរ ។

១ មគ្គសមាធិនិងផលសមាធិ ។ អដ្ឋកថា ។

ឯវមេវ ខោ ភិក្ខវេ អប្បកា តេ សត្តា យេ អន្នគ្គរសគ្គានំ លាភិនោ អថ ខោ ឯតេវ សត្តា ពហុតរា យេ អន្នគ្គរសគ្គានំ ន លាភិនោ ឧញ្ឆេន កបាលាភតេន យាបេន្តិ ។ ឯវមេវ ខោ ភិក្ខវេ អប្បកា តេ សត្តា យេ អត្ថរសស្ស ធម្មរសស្ស វិមុត្តិរសស្ស លាភិនោ អថ ខោ ឯតេវ សត្តា ពហុតរា យេ អត្ថរសស្ស ធម្មរសស្ស វិមុត្តិរសស្ស ន លាភិនោ ។ តស្មាតិហ ភិក្ខវេ ឯវំ សិក្ខិតព្វំ អត្ថរសស្ស ធម្មរសស្ស វិមុត្តិរសស្ស លាភិនោ ភវិស្សាមាតិ ។ ឯវំ ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។

(២៥២) សេយ្យថាបិ ភិក្ខវេ អប្បមត្តកំ ឥមស្មិំ ជម្ពុទីបេ អារាមរាមណេយ្យកំ វនរាមណេយ្យកំ ភូមិរាមណេយ្យកំ បោក្ខរណីរាមណេយ្យកំ អថ ខោ ឯតទេវ ពហុតរំ យទិទំ ឧក្កូលវិក្កូលំ នទីវិទុគ្គំ ខាណុកណ្ដកដ្ឋានំ បព្វតវិសមំ ។ ឯវមេវ ខោ ភិក្ខវេ អប្បកា តេ សត្តា យេ មនុស្សា ចុតា មនុស្សេសុ បច្ចាជាយន្តិ



ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលជាអ្នកបាននូវបាយដ៏ប្រសើរនិងរសដ៏ប្រសើរមានចំនួនតិច ពួកសត្វដែលជាអ្នកមិនបាននូវបាយដ៏ប្រសើរ និងរសដ៏ប្រសើរ តែចិញ្ចឹមជីវិតដោយបាយដែលសូមគេដាក់ក្នុងផ្ដិល រើសរេង ដោយភក្តដែលគេដាក់ក្នុងករោះយកមកឲ្យ ច្រើនជាង គឺយ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលជាអ្នកបាននូវអត្ថរស (ផល៤) ធម្មរស (មគ្គ៤) វិមុត្តិរស (ព្រះនិព្វាន) មានចំនួនតិច ពួកសត្វដែលជាអ្នកមិនបាននូវអត្ថរស ធម្មរស វិមុត្តិរស មានចំនួនច្រើនជាង គឺយ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ អ្នកទាំងឡាយ គួរសិក្សាយ៉ាងនេះ ថា យើងទាំងឡាយនឹងបាននូវអត្ថរស ធម្មរស វិមុត្តិរស ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គួរសិក្សាយ៉ាងនេះឯង ។

(២៥២) ម្នាលភិក្ខុទាំងឡាយ ដូចអារាមដែលជាទីរីករាយ ព្រៃជាទីរីករាយ ភូមិភាគជាទីរីករាយ ស្រះបោក្ខរណីជាទីរីករាយ ក្នុងជម្ពូទ្វីបនេះ មានចំនួនតិច ទីទួលដែលខ្ពស់ទាប ទីទំនាបជ្រោះស្ទឹង ទីមានគល់ឈើនិងបន្លា ភ្នំមិនរាបស្មើ ច្រើនជាង យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលច្យុតអំពីមនុស្សលោក កើតក្នុងមនុស្សលោកវិញ មានចំនួនតិច

អថ ខោ ឯតេវ សត្តា ពហុតរា យេ មនុស្សា ចុតា និរយេ បច្ចាជាយន្តិ តិរច្ឆានយោនិយា បច្ចាជាយន្តិ បេត្តិវិសយេ បច្ចាជាយន្តិ ។ ឯវមេវ ខោ ភិក្ខវេ អប្បកា តេ សត្តា យេ មនុស្សា ចុតា ទេវេសុ បច្ចាជាយន្តិ អថ ខោ ឯតេវ សត្តា ពហុតរា យេ មនុស្សា ចុតា និរយេ បច្ចាជាយន្តិ តិរច្ឆានយោនិយា បច្ចាជាយន្តិ បេត្តិវិសយេ បច្ចាជាយន្តិ ។ ឯវមេវ ខោ ភិក្ខវេ អប្បកា តេ សត្តា យេ ទេវា ចុតា ទេវេសុ បច្ចាជាយន្តិ អថ ខោ ឯតេវ សត្តា ពហុតរា យេ ទេវា ចុតា និរយេ បច្ចាជាយន្តិ តិរច្ឆានយោនិយា បច្ចាជាយន្តិ បេត្តិវិសយេ បច្ចាជាយន្តិ ។ ឯវមេវ ខោ ភិក្ខវេ អប្បកា តេ សត្តា យេ ទេវា ចុតា មនុស្សេសុ បច្ចាជាយន្តិ អថ ខោ ឯតេវ សត្តា ពហុតរា យេ ទេវា ចុតា និរយេ បច្ចាជាយន្តិ តិរច្ឆានយោនិយា បច្ចាជាយន្តិ បេត្តិវិសយេ បច្ចាជាយន្តិ ។ ឯវមេវ ខោ ភិក្ខវេ



ពួកសត្វដែលច្យុតអំពីមនុស្សលោក កើតក្នុងនរក កើតក្នុងកំណើតតិរច្ឆាន កើតក្នុងបិត្តិវិស័យ ច្រើនជាង ក៏យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលច្យុត អំពីមនុស្សលោក កើតក្នុងទេវលោក មានចំនួនតិច ពួកសត្វដែលច្យុតអំពីមនុស្សលោក កើតក្នុងនរក កើតក្នុងកំណើតតិរច្ឆាន កើតក្នុងបិត្តិវិស័យ ច្រើនជាង ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលច្យុត អំពីទេវលោក កើតក្នុងទេវលោកវិញ មានចំនួនតិច ពួកសត្វដែលច្យុត អំពីទេវលោក កើតក្នុងនរក កើតក្នុងកំណើតតិរច្ឆាន កើតក្នុងបិត្តិវិស័យ ច្រើនជាង ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលច្យុត អំពីទេវលោក កើតក្នុងមនុស្សលោក មានចំនួនតិច ពួកសត្វដែលច្យុត អំពីទេវលោក កើតក្នុងនរក កើតក្នុងកំណើតតិរច្ឆាន កើតក្នុងបិត្តិវិស័យ ច្រើនជាង ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ

អប្បកា តេ សត្តា យេ និរយា ចុតា មនុស្សេសុ បច្ចាជាយន្តិ អថ ខោ ឯតេវ សត្តា ពហុតរា យេ និរយា ចុតា និរយេ បច្ចាជាយន្តិ តិរច្ឆានយោនិយា បច្ចាជាយន្តិ បិត្តិវិសយេ បច្ចាជាយន្តិ ។ ឯវមេវ ខោ ភិក្ខវេ អប្បកា តេ សត្តា យេ និរយា ចុតា ទេវេសុ បច្ចាជាយន្តិ អថ ខោ ឯតេវ សត្តា ពហុតរា យេ និរយា ចុតា និរយេ បច្ចាជាយន្តិ តិរច្ឆានយោនិយា បច្ចាជាយន្តិ បិត្តិវិសយេ បច្ចាជាយន្តិ ។ ឯវមេវ ខោ ភិក្ខវេ អប្បកា តេ សត្តា យេ តិរច្ឆានយោនិយា ចុតា មនុស្សេសុ បច្ចាជាយន្តិ អថ ខោ ឯតេវ សត្តា ពហុតរា យេ តិរច្ឆានយោនិយា ចុតា និរយេ បច្ចាជាយន្តិ តិរច្ឆានយោនិយា បច្ចាជាយន្តិ បិត្តិវិសយេ បច្ចាជាយន្តិ ។ ឯវមេវ ខោ ភិក្ខវេ អប្បកា តេ សត្តា យេ តិរច្ឆានយោនិយា ចុតា ទេវេសុ បច្ចាជាយន្តិ អថ ខោ ឯតេវ សត្តា ពហុតរា យេ តិរច្ឆានយោនិយា ចុតា និរយេ បច្ចាជាយន្តិ តិរច្ឆានយោនិយា បច្ចាជាយន្តិ បិត្តិវិសយេ បច្ចាជាយន្តិ ។



ពួកសត្វដែលច្យុតអំពីនរក កើតក្នុងមនុស្សលោក មានចំនួនតិច ពួកសត្វដែលច្យុតអំពីនរក កើតក្នុងនរកវិញ កើតក្នុងកំណើតតិរច្ឆាន កើតក្នុងបិត្តិវិស័យ ច្រើនជាង គឺយ៉ាងនេះដែរ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលច្យុតអំពីនរក កើតក្នុងទេវលោក មានចំនួនតិច ពួកសត្វដែលច្យុតអំពីនរក កើតក្នុងនរកវិញ កើតក្នុងកំណើតតិរច្ឆាន កើតក្នុងបិត្តិវិស័យ ច្រើនជាង គឺយ៉ាងនេះដែរ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលច្យុតអំពីតិរច្ឆាន កើតក្នុងមនុស្សលោក មានចំនួនតិច ពួកសត្វដែលច្យុតអំពីតិរច្ឆាន កើតក្នុងនរក កើតក្នុងកំណើតតិរច្ឆាន កើតក្នុងបិត្តិវិស័យ ច្រើនជាង គឺយ៉ាងនេះដែរ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលច្យុតអំពីតិរច្ឆាន កើតក្នុងទេវលោក មានចំនួនតិច ពួកសត្វដែលច្យុតអំពីកំណើតតិរច្ឆាន កើតក្នុងនរក កើតក្នុងកំណើតតិរច្ឆាន កើតក្នុងបិត្តិវិស័យ ច្រើនជាង គឺយ៉ាងនេះដែរ ។

ឯវមេវ ខោ ភិក្ខវេ អប្បកា តេ សត្តា យេ បេត្តិវិសយា ចុតា មនុស្សេសុ បច្ចាជាយន្តិ អថ ខោ ឯតេវ សត្តា ពហុតរា យេ បេត្តិវិសយា ចុតា និរយេ បច្ចាជាយន្តិ តិរច្ឆានយោនិយា បច្ចាជាយន្តិ បេត្តិវិសយេ បច្ចាជាយន្តិ ។ ឯវមេវ ខោ ភិក្ខវេ អប្បកា តេ សត្តា យេ បេត្តិវិសយា ចុតា ទេវេសុ បច្ចាជាយន្តិ អថ ខោ ឯតេវ សត្តា ពហុតរា យេ បេត្តិវិសយា ចុតា និរយេ បច្ចាជាយន្តិ តិរច្ឆានយោនិយា បច្ចាជាយន្តិ បេត្តិវិសយេ បច្ចាជាយន្តិ ។

វគ្គោ បញ្ចមោ ។



ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលច្យុតអំពីបិត្តិវិស័យ កើតក្នុងមនុស្សលោក មានចំនួនតិច ពួកសត្វដែលច្យុតអំពីបិត្តិវិស័យ កើតក្នុងនរក កើតក្នុងកំណើតតិរច្ឆាន កើតក្នុងបិត្តិវិស័យ ច្រើនជាង ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលច្យុតអំពីបិត្តិវិស័យ កើតក្នុងទេវលោក មានចំនួនតិច ពួកសត្វដែលច្យុតអំពីបិត្តិវិស័យ កើតក្នុងនរក កើតក្នុងកំណើតតិរច្ឆាន កើតក្នុងបិត្តិវិស័យ ច្រើនជាង ក៏យ៉ាងនោះដែរ ។

ចប់ វគ្គទី ៥ ។

# បសាទករធម្មទីប្រាំ

(២០៧) អឌ្ឍមិទំ ភិក្ខវេ លាភានំ យទិទំ អារញ្ញកត្តំ បិណ្ឌបាតិកត្តំ បំសុកូលិកត្តំ តេចីវរិកត្តំ ធម្មកថិកត្តំ វិនយធរត្តំ ពាហុសច្ចំ ថាវេយ្យំ អាកប្បសម្បទា បរិវារសម្បទា មហាបរិវារតា កោលបុត្តី វណ្ណពោក្ខរតា កល្យាណវាក្ករណតា អប្បិច្ឆតា អប្បាពាធតាតិ ។

(២០៨) អច្ឆរាសង្ឃាតមត្តម្បិ ចេ ភិក្ខវេ ភិក្ខុ បឋមំ ឈានំ ភាវេតិ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ អរិត្តជ្ឈានោ វិហរតិ សត្ថុសាសនករោ ឱវាទប្បដិករោ អមោឃំ រដ្ឋបិណ្ឌំ ភុញ្ជតិ កោ បន វាទោ យេ នំ ពហុលីករោន្តីតិ ។

(២០៩) អច្ឆរាសង្ឃាតមត្តម្បិ ចេ ភិក្ខវេ ភិក្ខុ ទុតិយំ ឈានំ ភាវេតិ ... តតិយំ ឈានំ ភាវេតិ ... ចតុត្ថំ ឈានំ ភាវេតិ ... មេត្តំ ចេតោវិមុត្តឹ ភាវេតិ ... ករុណំ ចេតោវិមុត្តឹ ភាវេតិ ... មុទិតំ ចេតោវិមុត្តឹ ភាវេតិ ... ឧបេក្ខំ ចេតោវិមុត្តឹ ភាវេតិ ...

# បសាទករធម្មទីប្រាំ

(២០៧) ម្នាលភិក្ខុទាំងឡាយ ភាពជាអ្នកប្រព្រឹត្តនៅក្នុងព្រៃជាធុតង្គ ភាពជាអ្នកប្រព្រឹត្តបិណ្ឌបាតិកធុតង្គ ភាពជាអ្នកប្រព្រឹត្តបំសុកូលិកធុតង្គ ភាពជាអ្នកប្រព្រឹត្តតេចីវរិកធុតង្គ ភាពជាធម្មកថិក ភាពជាវិន័យធរ ភាពជាពហុស្សូត ភាពជាអ្នកឋាវរ(*) ការបរិបូណ៌ ដោយអាកប្បកិរិយា ការបរិបូណ៌ដោយបរិវារ ភាពជាអ្នកមានបរិវារច្រើន ភាពជាកុលបុត្រ ភាពជាអ្នកមានរូបល្អ ភាពជាអ្នកមានសំដីពីរោះ ភាពជាអ្នកប្រាថ្នាតិច ភាពជាអ្នកមានអាពាធតិច នេះជាលាភ ពាក់កណ្តាលនៃលាភទាំងឡាយ ។

(២០៨) ម្នាលភិក្ខុទាំងឡាយ បើភិក្ខុចំរើនបឋមជ្ឈាន ត្រឹមតែមួយផ្ទាត់ម្រាមដៃ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះគេហៅថា ជាអ្នកមិនទទេចាកឈាន ជាអ្នកធ្វើតាមពាក្យប្រដៅរបស់ព្រះសាស្តា ធ្វើតាមឱវាទ បរិភោគបិណ្ឌបាតរបស់អ្នកស្រុក មិនឥតប្រយោជន៍ ចាំបាច់ពោលអ្វី ដល់ពួកភិក្ខុអ្នកធ្វើឈានឲ្យច្រើននោះ ។

(២០៩) ម្នាលភិក្ខុទាំងឡាយ បើភិក្ខុចំរើនទុតិយជ្ឈាន ត្រឹមតែមួយផ្ទាត់ម្រាមដៃ ... ចំរើនតតិយជ្ឈាន ... ចំរើនចតុត្ថជ្ឈាន ... ចំរើនមេត្តាចេតោវិមុត្តិ ... ចំរើនករុណាចេតោវិមុត្តិ ... ចំរើនមុទិតាចេតោវិមុត្តិ ... ចំរើនឧបេក្ខាចេតោវិមុត្តិ ...

---

* [illegible] ។ អដ្ឋកថា ។

កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ... វេទនាសុ វេទនានុបស្សី វិហរតិ ។បេ។ ចិត្តេ ចិត្តានុបស្សី វិហរតិ ។បេ។ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ... អនុប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ អនុប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វិរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ... ឧប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ បហានាយ ឆន្ទំ ជនេតិ វាយមតិ វិរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ... អនុប្បន្នានំ កុសលានំ ធម្មានំ ឧប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វិរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ... ឧប្បន្នានំ កុសលានំ ធម្មានំ ឋិតិយា អសម្មោសាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា ឆន្ទំ ជនេតិ វាយមតិ វិរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ... ឆន្ទសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ...



ពិចារណាឃើញកាយក្នុងកាយ មានព្យាយាមដុតកំដៅកិលេស មានសម្បជញ្ញៈ មានសតិ បន្ទោបង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ... ពិចារណាឃើញវេទនាក្នុងវេទនា ។បេ។ ពិចារណាឃើញចិត្តក្នុងចិត្ត ។បេ។ ពិចារណាឃើញធម៌ក្នុងធម៌ មានព្យាយាមដុតកំដៅកិលេស មានសម្បជញ្ញៈ មានសតិ បន្ទោបង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក... ធ្វើឆន្ទៈឲ្យកើត ព្យាយាមប្រឹងប្រែងផ្គង តាំងចិត្តដើម្បីញ៉ាំងធម៌ជាអកុសលបាបដ៏លាមកដែលមិនទាន់កើត មិនឲ្យកើតឡើងបាន... ធ្វើឆន្ទៈឲ្យកើតឡើង ព្យាយាមប្រឹងប្រែងផ្គង តាំងចិត្តដើម្បីលះបង់ធម៌ជាអកុសលបាបដ៏លាមកដែលកើតឡើងហើយ... ធ្វើឆន្ទៈឲ្យកើតឡើង ព្យាយាមប្រឹងប្រែងផ្គង តាំងចិត្ត ដើម្បីញ៉ាំងធម៌ជាកុសលដែលមិនទាន់កើត ឲ្យកើតឡើង... ធ្វើឆន្ទៈឲ្យកើត ព្យាយាមប្រឹងប្រែង ផ្គងតាំងចិត្ត ដើម្បីធ្វើធម៌ជាកុសលដែលកើតឡើង ហើយឲ្យឋិតនៅ មិនឲ្យវិនាស ឲ្យរឹតតែចម្រើន បរិបូណ៌ដោយភាវនាឡើង... ចំរើនឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិប្បធានសង្ខារ... ចំរើនឥទ្ធិបាទ ប្រកបដោយវិរិយសមាធិប្បធានសង្ខារ ...

វីរិយសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ... ចិត្តសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ... វីមំសាសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ... សទ្ធិន្ទ្រិយំ ភាវេតិ... វីរិយិន្ទ្រិយំ ភាវេតិ... សតិន្ទ្រិយំ ភាវេតិ... សមាធិន្ទ្រិយំ ភាវេតិ... បញ្ញិន្ទ្រិយំ ភាវេតិ... សទ្ធាពលំ ភាវេតិ... វីរិយពលំ ភាវេតិ... សតិពលំ ភាវេតិ... សមាធិពលំ ភាវេតិ... បញ្ញាពលំ ភាវេតិ... សតិសម្ពោជ្ឈង្គំ ភាវេតិ... ធម្មវិចយសម្ពោជ្ឈង្គំ ភាវេតិ... វីរិយសម្ពោជ្ឈង្គំ ភាវេតិ... បីតិសម្ពោជ្ឈង្គំ ភាវេតិ... បស្សទ្ធិសម្ពោជ្ឈង្គំ ភាវេតិ... សមាធិសម្ពោជ្ឈង្គំ ភាវេតិ... ឧបេក្ខាសម្ពោជ្ឈង្គំ ភាវេតិ... សម្មាទិដ្ឋឹ ភាវេតិ... សម្មាសង្កប្បំ ភាវេតិ... សម្មាវាចំ ភាវេតិ... សម្មាកម្មន្តំ ភាវេតិ... សម្មាអាជីវំ ភាវេតិ... សម្មាវាយាមំ ភាវេតិ... សម្មាសតឹ ភាវេតិ... សម្មាសមាធឹ ភាវេតិ...

[៤១០] អជ្ឈត្តំ រូបសញ្ញី ពហិទ្ធា រូបានិ បស្សតិ បរិត្តានិ សុវណ្ណទុព្វណ្ណានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំ សញ្ញី ហោតិ...



រមែងចំរើនឥទ្ធិបាទ ប្រកបដោយចិត្តសមាធិប្បធានសង្ខារ... ចំរើនឥទ្ធិបាទ ប្រកបដោយវីមំសាសមាធិប្បធានសង្ខារ... ចំរើនសទ្ធិន្ទ្រិយ... ចំរើនវីរិយិន្ទ្រិយ... ចំរើនសតិន្ទ្រិយ... ចំរើនសមាធិន្ទ្រិយ... ចំរើនបញ្ញិន្ទ្រិយ... ចំរើនសទ្ធាពល... ចំរើនវីរិយពល... ចំរើនសតិពល... ចំរើនសមាធិពល... ចំរើនបញ្ញាពល... ចំរើនសតិសម្ពោជ្ឈង្គ... ចំរើនធម្មវិចយសម្ពោជ្ឈង្គ... ចំរើនវីរិយសម្ពោជ្ឈង្គ... ចំរើនបីតិសម្ពោជ្ឈង្គ... ចំរើនបស្សទ្ធិសម្ពោជ្ឈង្គ... ចំរើនសមាធិសម្ពោជ្ឈង្គ... ចំរើនឧបេក្ខាសម្ពោជ្ឈង្គ... ចំរើនសម្មាទិដ្ឋិ... ចំរើនសម្មាសង្កប្ប... ចំរើនសម្មាវាចា... ចំរើនសម្មាកម្មន្ត... ចំរើនសម្មាអាជីវ... ចំរើនសម្មាវាយាម... ចំរើនសម្មាសតិ... ចំរើនសម្មាសមាធិ...

[៤១០] បុគ្គលមានសេចក្ដីសំគាល់ក្នុងរូបខាងក្នុង(១) ឃើញនូវរូបទាំងឡាយខាងក្រៅ(២) ដែលជារបស់តូច មានសម្បុរល្អនិងសម្បុរអាក្រក់ គ្របសង្កត់នូវរូបទាំងនោះ ហើយជាបុគ្គលមានសេចក្ដីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញ ...

---

១ សំដៅយក សក់ប្រមាត់ប្រស្រីម្ចាស់ខ្លួន ។ ២ សំដៅយកនិមិត្តខាងក្រៅដែលកើតឡើង ក្នុងវេលាកំពុងធ្វើបរិកម្មទៅតាមនិមិត្តនោះ ។

(៤១១) អជ្ឈត្តំ រូបសញ្ញី ពហិទ្ធា រូបានិ បស្សតិ អប្បមាណានិ សុវណ្ណទុព្វណ្ណានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំ សញ្ញី ហោតិ...

(៤១២) អជ្ឈត្តំ អរូបសញ្ញី ពហិទ្ធា រូបានិ បស្សតិ បរិត្តានិ សុវណ្ណទុព្វណ្ណានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំ សញ្ញី ហោតិ...

(៤១៣) អជ្ឈត្តំ អរូបសញ្ញី ពហិទ្ធា រូបានិ បស្សតិ អប្បមាណានិ សុវណ្ណទុព្វណ្ណានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំ សញ្ញី ហោតិ...

(៤១៤) អជ្ឈត្តំ អរូបសញ្ញី ពហិទ្ធា រូបានិ បស្សតិ នីលានិ នីលវណ្ណានិ នីលនិទស្សនានិ នីលនិភាសានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំ សញ្ញី ហោតិ...



(៤១១) បុគ្គលមានសេចក្តីសំគាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅដែលជារូបធំ មានសម្បុរល្អខ្លះមានសម្បុរអាក្រក់ គ្របសង្កត់នូវរូបទាំងនោះ ហើយជាបុគ្គលមានសេចក្តីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញ...

(៤១២) បុគ្គលមិនមានសេចក្តីសំគាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ដែលជារូបតូច មានសម្បុរល្អខ្លះសម្បុរអាក្រក់ គ្របសង្កត់នូវរូបទាំងនោះ ហើយជាបុគ្គលមានសេចក្តីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញ...

(៤១៣) បុគ្គលមិនមានសេចក្តីសំគាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ដែលជារូបធំ មានសម្បុរល្អខ្លះមានសម្បុរអាក្រក់ គ្របសង្កត់នូវរូបទាំងនោះ ហើយជាបុគ្គលមានសេចក្តីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញ...

(៤១៤) បុគ្គលមិនមានសេចក្តីសំគាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ដែលជារូបខៀវ មានសម្បុរខៀវ បញ្ចេញសម្បុរខៀវ ពន្លឺខៀវ គ្របសង្កត់នូវរូបទាំងនោះ ហើយជាបុគ្គលមានសេចក្តីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញ...

[២១៥] អជ្ឈត្តំ អរូបសញ្ញី ពហិទ្ធា រូបានិ បស្សតិ បីតានិ បីតវណ្ណានិ បីតនិទស្សនានិ បីតនិភាសានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំ សញ្ញី ហោតិ...

[២១៦] អជ្ឈត្តំ អរូបសញ្ញី ពហិទ្ធា រូបានិ បស្សតិ លោហិតកានិ លោហិតកវណ្ណានិ លោហិតកនិទស្សនានិ លោហិតកនិភាសានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំ សញ្ញី ហោតិ...

[២១៧] អជ្ឈត្តំ អរូបសញ្ញី ពហិទ្ធា រូបានិ បស្សតិ ឱទាតានិ ឱទាតវណ្ណានិ ឱទាតនិទស្សនានិ ឱទាតនិភាសានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំ សញ្ញី ហោតិ... រូបី រូបានិ បស្សតិ...

[២១៨] អជ្ឈត្តំ អរូបសញ្ញី ពហិទ្ធា រូបានិ បស្សតិ... សុភន្តេវ អធិមុត្តោ ហោតិ...

[២១៩] សព្វសោ រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិការា អនន្តោ អាកាសោតិ អាកាសានញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ...





[២១៥] បុគ្គលមិនមានសេចក្ដីសំគាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ដែលជារូបលឿង មានសម្បុរលឿង បញ្ចេញសម្បុរលឿង មានរស្មីលឿង គ្របសង្កត់នូវរូបទាំងនោះ ហើយជាបុគ្គលមានសេចក្ដីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញ...

[២១៦] បុគ្គលមិនមានសេចក្ដីសំគាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ដែលជារូបក្រហម មានសម្បុរក្រហម បញ្ចេញសម្បុរក្រហម មានរស្មីក្រហម គ្របសង្កត់នូវរូបទាំងនោះ ហើយជាបុគ្គលមានសេចក្ដីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញ...

[២១៧] បុគ្គលមិនមានសេចក្ដីសំគាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ដែលជារូបស មានសម្បុរស បញ្ចេញសម្បុរស មានរស្មីស គ្របសង្កត់នូវរូបទាំងនោះ ហើយជាបុគ្គលមានសេចក្ដីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញ ... បុគ្គលមានរូប តែងឃើញនូវរូប ...

[២១៨] បុគ្គលមិនមានសេចក្ដីសំគាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ... ជាបុគ្គលនៅតែកកស៊ិណារម្មណ៍ដ៏ល្អ...

[២១៩] បុគ្គលព្រោះប្រព្រឹត្តកន្លងនូវរូបសញ្ញាសព្វគ្រប់ ធ្វើបដិឃសញ្ញាឲ្យវិនាស មិនអើពើនឹងនានត្តសញ្ញា ក៏ចូលកាន់អាកាសានញ្ចាយតនៈ ដោយពិចារណាថា អាកាសមិនមានទីបំផុត...

(៤៤០) សព្វសោ អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ...

(៤៤១) សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ...

(៤៤២) សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម នេវសញ្ញានាសញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ...

(៤៤៣) សព្វសោ នេវសញ្ញានាសញ្ញាយតនំ សមតិក្កម្ម សញ្ញាវេទយិតនិរោធំ ឧបសម្បជ្ជ វិហរតិ...

(៤៤៤) បឋវីកសិណំ ភាវេតិ... អាបោកសិណំ ភាវេតិ... តេជោកសិណំ ភាវេតិ... វាយោកសិណំ ភាវេតិ... នីលកសិណំ ភាវេតិ... បីតកសិណំ ភាវេតិ... លោហិតកសិណំ ភាវេតិ... ឱទាតកសិណំ ភាវេតិ... អាកាសកសិណំ ភាវេតិ... វិញ្ញាណកសិណំ ភាវេតិ... អសុភសញ្ញំ ភាវេតិ... មរណសញ្ញំ ភាវេតិ... អាហារេ បដិកូលសញ្ញំ ភាវេតិ... សព្វលោកេ អនភិរតសញ្ញំ ភាវេតិ...



[៤៤០] បុគ្គលព្រោះប្រព្រឹត្តកន្លងនូវអាកាសានញ្ចាយតនៈសព្វគ្រប់ ចូលកាន់វិញ្ញាណញ្ចាយតនៈ ដោយពិចារណាថា វិញ្ញាណមិនមានទីបំផុត...

[៤៤១] បុគ្គលព្រោះប្រព្រឹត្តកន្លងនូវវិញ្ញាណញ្ចាយតនៈសព្វគ្រប់ ក៏ចូលកាន់អាកិញ្ចញ្ញាយតនៈ ដោយពិចារណាថា អ្វីនិចតួចមិនមាន...

[៤៤២] បុគ្គលព្រោះប្រព្រឹត្តកន្លងនូវអាកិញ្ចញ្ញាយតនៈសព្វគ្រប់ ក៏ចូលកាន់នេវសញ្ញានាសញ្ញាយតនៈ...

[៤៤៣] បុគ្គលព្រោះប្រព្រឹត្តកន្លងនូវនេវសញ្ញានាសញ្ញាយតនៈ ក៏ចូលកាន់សញ្ញាវេទយិតនិរោធ(១)...

[៤៤៤] បុគ្គលចំរើនបឋវីកសិណ... ចំរើនអាបោកសិណ... ចំរើនតេជោកសិណ... ចំរើនវាយោកសិណ... ចំរើននីលកសិណ... ចំរើនបីតកសិណ... ចំរើនលោហិតកសិណ... ចំរើនឱទាតកសិណ... ចំរើនអាកាសកសិណ... ចំរើនវិញ្ញាណកសិណ... ចំរើនអសុភសញ្ញា... ចំរើនមរណសញ្ញា... ចំរើនអាហារេ បដិកូលសញ្ញា... ចំរើនសព្វលោកេ អនភិរតសញ្ញា...

---

១ ពីព្រះសូត្រ ៤១០ ដល់ ៤៤៣ ហៅបច្ចុប្បន្ន ០៨ ត្រង់សម្ពន្ធសូត្រ ចំនួន ៦ ត្រង់ បរាជិកាសូត្រ ។

### បរិភោគរដ្ឋបិណ្ឌ

អនិច្ចសញ្ញំ ភាវេតិ... អនិច្ចេ ទុក្ខសញ្ញំ ភាវេតិ... ទុក្ខេ អនត្តសញ្ញំ ភាវេតិ... បហានសញ្ញំ ភាវេតិ... វិរាគសញ្ញំ ភាវេតិ... និរោធសញ្ញំ ភាវេតិ... អសុភសញ្ញំ ភាវេតិ... អាទីនវសញ្ញំ ភាវេតិ... មរណសញ្ញំ ភាវេតិ... អាហារេ បដិក្កូលសញ្ញំ ភាវេតិ... សព្វលោកេ អនភិរតសញ្ញំ ភាវេតិ... អដ្ឋិកសញ្ញំ ភាវេតិ... បុឡុវកសញ្ញំ ភាវេតិ... វិនីលកសញ្ញំ ភាវេតិ... វិច្ឆិទ្ទកសញ្ញំ ភាវេតិ... ឧទ្ធុមាតកសញ្ញំ ភាវេតិ... ពុទ្ធានុស្សតឹ ភាវេតិ... ធម្មានុស្សតឹ ភាវេតិ... សង្ឃានុស្សតឹ ភាវេតិ... សីលានុស្សតឹ ភាវេតិ... ចាគានុស្សតឹ ភាវេតិ... ទេវតានុស្សតឹ ភាវេតិ... អានាបានស្សតឹ ភាវេតិ... មរណស្សតឹ ភាវេតិ... កាយគតាសតឹ ភាវេតិ... ឧបសមានុស្សតឹ ភាវេតិ... បឋមជ្ឈានសហគតំ សទ្ធិន្ទ្រិយំ ភាវេតិ... វីរិយិន្ទ្រិយំ ភាវេតិ... សតិន្ទ្រិយំ ភាវេតិ... សមាធិន្ទ្រិយំ ភាវេតិ... បញ្ញិន្ទ្រិយំ ភាវេតិ... សទ្ធាពលំ ភាវេតិ... វីរិយពលំ ភាវេតិ... សតិពលំ ភាវេតិ... សមាធិពលំ ភាវេតិ...



### បរិភោគរដ្ឋបិណ្ឌ

ចំរើនអនិច្ចសញ្ញា... ចំរើនអនិច្ចេ ទុក្ខសញ្ញា... ចំរើនទុក្ខេ អនត្តសញ្ញា... ចំរើនបហានសញ្ញា... ចំរើនវិរាគសញ្ញា... ចំរើននិរោធសញ្ញា... ចំរើនអសុភសញ្ញា... ចំរើនអាទីនវសញ្ញា... ចំរើនមរណសញ្ញា... ចំរើនអាហារេបដិក្កូលសញ្ញា... ចំរើនសព្វលោកេអនភិរតសញ្ញា... ចំរើនអដ្ឋិកសញ្ញា... ចំរើនបុឡុវកសញ្ញា... ចំរើនវិនីលកសញ្ញា... ចំរើនវិច្ឆិទ្ទកសញ្ញា... ចំរើនឧទ្ធុមាតកសញ្ញា... ចំរើនពុទ្ធានុស្សតិ... ចំរើនធម្មានុស្សតិ... ចំរើនសង្ឃានុស្សតិ... ចំរើនសីលានុស្សតិ... ចំរើនចាគានុស្សតិ... ចំរើនទេវតានុស្សតិ... ចំរើនអានាបានស្សតិ... ចំរើនមរណស្សតិ... ចំរើនកាយគតាសតិ... ចំរើនឧបសមានុស្សតិ... ចំរើនសទ្ធិន្ទ្រិយប្រកបដោយបឋមជ្ឈាន... ចំរើនវីរិយិន្ទ្រិយ... ចំរើនសតិន្ទ្រិយ... ចំរើនសមាធិន្ទ្រិយ... ចំរើនបញ្ញិន្ទ្រិយ... ចំរើនសទ្ធាពល... ចំរើនវីរិយពល... ចំរើនសតិពល... ចំរើនសមាធិពល...

បញ្ញាពលំ ភាវេតិ... ទុតិយជ្ឈានសហគតំ ។បេ។ តតិយជ្ឈានសហគតំ ។បេ។ ចតុត្ថជ្ឈានសហគតំ ។បេ។ មេត្តាសហគតំ ។បេ។ ករុណាសហគតំ ។បេ។ មុទិតាសហគតំ ។បេ។ ឧបេក្ខាសហគតំ សទ្ធិន្ទ្រិយំ ភាវេតិ... វីរិយិន្ទ្រិយំ ភាវេតិ... សតិន្ទ្រិយំ ភាវេតិ... សមាធិន្ទ្រិយំ ភាវេតិ... បញ្ញិន្ទ្រិយំ ភាវេតិ... សទ្ធាពលំ ភាវេតិ... វីរិយពលំ ភាវេតិ... សតិពលំ ភាវេតិ... សមាធិពលំ ភាវេតិ... បញ្ញាពលំ ភាវេតិ... អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ អរិត្តជ្ឈានោ វិហរតិ សត្ថុសាសនករោ ឱវាទបតិករោ អមោឃំ រដ្ឋបិណ្ឌំ ភុញ្ជតិ កោ បន វាទោ យេ នំ ពហុលីករោន្តីតិ ។

(១៨៥) យស្ស កស្សចិ ភិក្ខវេ មហាសមុទ្ទោ ចេតសា ផុដោ អន្តោគធា តស្ស កុន្នទិយោ យា កាចិ សមុទ្ទង្គមា ឯវមេវ ខោ ភិក្ខវេ យស្ស កស្សចិ កាយគតាសតិ ភាវិតា ពហុលីកតា អន្តោគធា តស្ស កុសលា ធម្មា យេ កេចិ វិជ្ជាភាគិយាតិ ។



ចំរើនបញ្ញាពល... ប្រកបដោយទុតិយជ្ឈាន ។បេ។ ប្រកបដោយតតិយជ្ឈាន ។បេ។ ប្រកបដោយចតុត្ថជ្ឈាន ។បេ។ ប្រកបដោយមេត្តា ។បេ។ ប្រកបដោយករុណា ។បេ។ ប្រកបដោយមុទិតា ។បេ។ ចំរើនសទ្ធិន្ទ្រិយ ប្រកបដោយឧបេក្ខា... ចំរើនវីរិយិន្ទ្រិយ... ចំរើនសតិន្ទ្រិយ... ចំរើនសមាធិន្ទ្រិយ... ចំរើនបញ្ញិន្ទ្រិយ... ចំរើនសទ្ធាពល...ចំរើនវីរិយពល... ចំរើនសតិពល... ចំរើនសមាធិពល... ចំរើនបញ្ញាពល... ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះហៅថា ជាអ្នកមានឈានមិនទទេ ជាអ្នកធ្វើតាមពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា ធ្វើតាមឱវាទ ឆាន់ដុំបាយរបស់អ្នកដែនមិនឥតប្រយោជន៍ទទេ ចាំបាច់និយាយថ្វី ដល់ពួកភិក្ខុដែលចំរើនឈានឲ្យច្រើននោះ ។

(១៨៥) ម្នាលភិក្ខុទាំងឡាយ មហាសមុទ្រដែលបុគ្គលណាមួយបានផ្សាយទៅដោយចិត្តហើយ ស្ទឹងតូចៗទាំងឡាយដែលហូរទៅកាន់សមុទ្រ គង់ជាការចុះរួមក្នុងបុគ្គលនោះ ដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ កាយគតាសតិ ដែលបុគ្គលណាមួយចំរើនហើយ ធ្វើឲ្យច្រើនហើយ ពួកកុសលធម៌ទាំងឡាយ ដែលជាចំណែកនៃវិជ្ជា គង់ជាការចុះរួមក្នុងបុគ្គលនោះ យ៉ាងនោះដែរ ។

[២២៦] ឯកធម្មោ ភិក្ខវេ ភាវិតោ ពហុលីកតោ មហតោ សំវេគាយ សំវត្តតិ មហតោ អត្ថាយ សំវត្តតិ មហតោ យោគក្ខេមាយ សំវត្តតិ សតិសម្បជញ្ញាយ សំវត្តតិ ញាណទស្សនប្បដិលាភាយ សំវត្តតិ ទិដ្ឋធម្មសុខវិហារាយ សំវត្តតិ វិជ្ជាវិមុត្តិផលសច្ឆិកិរិយាយ សំវត្តតិ ។ កតមោ ឯកធម្មោ ។ កាយគតាសតិ ។ អយំ ខោ ភិក្ខវេ ឯកធម្មោ ភាវិតោ ពហុលីកតោ មហតោ សំវេគាយ សំវត្តតិ មហតោ អត្ថាយ សំវត្តតិ មហតោ យោគក្ខេមាយ សំវត្តតិ សតិសម្បជញ្ញាយ សំវត្តតិ ញាណទស្សនប្បដិលាភាយ សំវត្តតិ ទិដ្ឋធម្មសុខវិហារាយ សំវត្តតិ វិជ្ជាវិមុត្តិផលសច្ឆិកិរិយាយ សំវត្តតិ ។

[២២៧] ឯកធម្មេ ភិក្ខវេ ភាវិតេ ពហុលីកតេ កាយោបិ បស្សម្ភតិ ចិត្តម្បិ បស្សម្ភតិ



(២២៦) ម្នាលភិក្ខុទាំងឡាយ ធម៌មួយយ៉ាងដែលបុគ្គលបានចំរើនហើយ បានធ្វើឲ្យច្រើន ហើយ តែងប្រព្រឹត្តទៅ ដើម្បីសេចក្តីសង្វេគច្រើន តែងប្រព្រឹត្តទៅ ដើម្បីសេចក្តីចំរើនច្រើន តែងប្រព្រឹត្តទៅ ដើម្បីសេចក្តីក្សេមចាកយោគៈច្រើន តែងប្រព្រឹត្តទៅ ដើម្បីបាននូវសតិនិងសម្បជញ្ញៈ តែងប្រព្រឹត្តទៅ ដើម្បីបាននូវញាណទស្សនៈ តែងប្រព្រឹត្តទៅ ដើម្បីនៅជាសុខក្នុងបច្ចុប្បន្ន តែងប្រព្រឹត្តទៅ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវវិជ្ជា(១) វិមុត្តិ(២) និងផល(៣) ។ ធម៌មួយយ៉ាងតើអ្វី ។ គឺកាយគតាសតិ ។ ម្នាលភិក្ខុទាំងឡាយ ធម៌មួយយ៉ាងនេះឯង ដែលបុគ្គលបានចំរើនហើយ បានធ្វើឲ្យច្រើន ហើយ តែងប្រព្រឹត្តទៅ ដើម្បីសេចក្តីសង្វេគច្រើន តែងប្រព្រឹត្តទៅ ដើម្បីសេចក្តីចំរើនច្រើន តែងប្រព្រឹត្តទៅ ដើម្បីសេចក្តីក្សេមចាកយោគៈច្រើន តែងប្រព្រឹត្តទៅ ដើម្បីបាននូវសតិនិងសម្បជញ្ញៈ តែងប្រព្រឹត្តទៅ ដើម្បីបាននូវញាណទស្សនៈ តែងប្រព្រឹត្តទៅ ដើម្បីនៅជាសុខក្នុងទិដ្ឋធម្មនេះ តែងប្រព្រឹត្តទៅ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវ វិជ្ជា វិមុត្តិ និងផល ។

(២២៧) ម្នាលភិក្ខុទាំងឡាយ កាលបើធម៌មួយយ៉ាងដែលបុគ្គលបានចំរើន បានធ្វើឲ្យច្រើនហើយ កាយក៏រមែងស្ងប់រម្ងាប់ ចិត្តក៏រមែងស្ងប់រម្ងាប់

---

១. បានដល់បញ្ញាដ៏សម្បយុត្តដោយមគ្គ ។ ២. បានដល់សម្បយុត្តធម៌ដែលកើតព្រមគ្នានឹងមគ្គញ្ញាណនោះ ។ ៣. បានដល់អរហត្តផល ។

វិតក្កវិចារាបិ វូបសម្មន្តិ កេវលាបិ វិជ្ជាភាគិយា ធម្មា ភាវនាបារិបូរឹ គច្ឆន្តិ ។ កតមស្មឹ ឯកធម្មេ ។ កាយគតាសតិយា ។ ឯកស្មឹ ខោ ភិក្ខវេ ឯកធម្មេ ភាវិតេ ពហុលីកតេ កាយោបិ បស្សម្ភតិ ចិត្តម្បិ បស្សម្ភតិ វិតក្កវិចារាបិ វូបសម្មន្តិ កេវលាបិ វិជ្ជាភាគិយា ធម្មា ភាវនាបារិបូរឹ គច្ឆន្តីតិ ។

(៦៦៨) ឯកធម្មេ ភិក្ខវេ ភាវិតេ ពហុលីកតេ អនុប្បន្នា ចេវ អកុសលា ធម្មា នុប្បជ្ជន្តិ ឧប្បន្នា ច អកុសលា ធម្មា បហីយន្តិ(១) ។ កតមស្មឹ ឯកធម្មេ ។ កាយគតាសតិយា ។ ឯកស្មឹ ខោ ភិក្ខវេ ឯកធម្មេ ភាវិតេ ពហុលីកតេ អនុប្បន្នា ចេវ អកុសលា ធម្មា នុប្បជ្ជន្តិ ឧប្បន្នា ច អកុសលា ធម្មា បហីយន្តីតិ ។

(៦៦៩) ឯកធម្មេ ភិក្ខវេ ភាវិតេ ពហុលីកតេ អនុប្បន្នា ចេវ កុសលា ធម្មា ឧប្បជ្ជន្តិ ឧប្បន្នា ច កុសលា ធម្មា ភិយ្យោភាវាយ វេបុល្លាយ សំវត្តន្តិ ។

---
១ ម. វិភាយន្តិ ។



ទាំងវិតក្កៈនឹងវិចារៈ ក៏រមែងស្ងប់រម្ងាប់ ពួកធម៌ទាំងអស់ដែលជាចំណែកនៃវិជ្ជា ក៏រមែងដល់នូវការចំរើនពេញលេញ ។ ធម៌មួយយ៉ាងដីតើ ។ គឺកាយគតាសតិ ។ ម្នាលភិក្ខុទាំងឡាយ កាលបើធម៌មួយយ៉ាងនេះឯង ដែលបុគ្គលបានចំរើន បានធ្វើឲ្យច្រើនៗហើយ កាយក្តី រមែងស្ងប់រម្ងាប់ ចិត្តក្តី រមែងស្ងប់រម្ងាប់ វិតក្កៈនឹងវិចារៈក្តី រមែងស្ងប់រម្ងាប់ ពួកធម៌ទាំងអស់ដែលជាចំណែកនៃវិជ្ជា ក៏ដល់នូវការចំរើនពេញលេញ ។

(៦៦៨) ម្នាលភិក្ខុទាំងឡាយ កាលបើធម៌មួយយ៉ាង ដែលបុគ្គលបានចំរើន បានធ្វើឲ្យច្រើនៗហើយ ពួកអកុសលធម៌ដែលមិនទាន់កើតឡើងក្តី មិនមែនកើតឡើង ពួកអកុសលធម៌ដែលកើតឡើងហើយក្តី រមែងសាបសូន្យទៅ ។ ធម៌មួយយ៉ាងដីតើ ។ គឺកាយគតាសតិ ។ ម្នាលភិក្ខុទាំងឡាយ កាលបើធម៌មួយយ៉ាងនេះឯង ដែលបុគ្គលបានចំរើន បានធ្វើឲ្យច្រើនៗហើយ ពួកអកុសលធម៌ដែលមិនទាន់កើតឡើងក្តី មិនមែនកើតឡើង ពួកអកុសលធម៌ដែលកើតឡើងហើយក្តី រមែងសាបសូន្យទៅ ។

(៦៦៩) ម្នាលភិក្ខុទាំងឡាយ កាលបើធម៌មួយយ៉ាង ដែលបុគ្គលបានចំរើន បានធ្វើឲ្យច្រើនៗហើយ ពួកកុសលធម៌ដែលមិនទាន់កើតឡើងក្តី នឹងកើតឡើង ពួកកុសលធម៌ដែលកើតឡើងហើយក្តី ក៏រមែងប្រព្រឹត្តទៅ ដើម្បីចំរើនទូលាយ ។

កតមស្មឹ ឯកធម្មេ ។ កាយគតាសតិយា ។ ឥមស្មឹ ខោ ភិក្ខវេ ឯកធម្មេ ភាវិតេ ពហុលីកតេ អនុប្បន្នា ចេវ កុសលា ធម្មា ឧប្បជ្ជន្តិ ឧប្បន្នា ច កុសលា ធម្មា ភិយ្យោភាវាយ វេបុល្លាយ សំវត្តន្តិ ។

(២៣០) ឯកធម្មេ ភិក្ខវេ ភាវិតេ ពហុលី-កតេ អវិជ្ជា បហីយតិ វិជ្ជា ឧប្បជ្ជតិ អស្មិមានោ បហីយតិ អនុសយា សមុគ្ឃាតំ គច្ឆន្តិ សញ្ញោ-ជនា បហីយន្តិ ។ កតមស្មឹ ឯកធម្មេ ។ កាយគតាសតិយា ។ ឥមស្មឹ ខោ ភិក្ខវេ ឯកធម្មេ ភាវិតេ ពហុលីកតេ អវិជ្ជា បហីយតិ វិជ្ជា ឧប្បជ្ជតិ អស្មិមានោ បហីយតិ អនុសយា សមុគ្ឃាតំ គច្ឆន្តិ សញ្ញោជនា បហីយន្តិ ។

(២៣១) ឯកធម្មេ ភិក្ខវេ ភាវិតេ ពហុលី-កតេ បញ្ញាបភេទាយ សំវត្តតិ អនុបាទាបរិនិព្វានាយ សំវត្តតិ ។ កតមស្មឹ ឯកធម្មេ ។ កាយគតាសតិ ។



ធម៌មួយយ៉ាងតើអ្វី ។ គឺកាយគតាសតិ ។ ម្នាលភិក្ខុទាំងឡាយ កាលបើធម៌មួយយ៉ាងនេះ ដែលបុគ្គលបានចំរើន បានធ្វើឲ្យច្រើនៗហើយ ពួកកុសលធម៌ ដែលមិនទាន់កើតឡើង ក៏កើតឡើង ពួកកុសលធម៌ ដែលកើតឡើងហើយ រមែងប្រព្រឹត្តទៅ ដើម្បីចំរើនទូលាយ ។

(២៣០) ម្នាលភិក្ខុទាំងឡាយ កាលបើធម៌មួយយ៉ាង ដែលបុគ្គលបានចំរើន បានធ្វើឲ្យច្រើនៗហើយ អវិជ្ជា រមែងសាបសូន្យទៅ វិជ្ជា រមែងកើតឡើង អស្មិមានះ រមែងសាបសូន្យទៅ អនុស័យ (គឺកិលេសដែលដេកត្រាំក្នុងសន្តាន) រមែងដល់នូវការដកឡើង សញ្ញោជនៈ (គឺធម៌ជាគ្រឿងចងនឹងទាក់) រមែងសាបសូន្យទៅ ។ ធម៌មួយយ៉ាងតើអ្វី ។ គឺកាយគតាសតិ ។ ម្នាលភិក្ខុទាំងឡាយ កាលបើធម៌មួយយ៉ាងនេះ ដែលបុគ្គលបានចំរើន បានធ្វើឲ្យច្រើនៗហើយ អវិជ្ជា រមែងសាបសូន្យទៅ វិជ្ជា រមែងកើតឡើង អស្មិមានះ រមែងសាបសូន្យទៅ អនុស័យ រមែងដល់នូវការដកឡើង សញ្ញោជនៈ រមែងសាបសូន្យទៅ ។

(២៣១) ម្នាលភិក្ខុទាំងឡាយ ធម៌មួយយ៉ាងដែលបុគ្គលបានចំរើន បានធ្វើឲ្យច្រើនៗហើយ តែងប្រព្រឹត្តទៅដើម្បីចំរើនបញ្ញា តែងប្រព្រឹត្តទៅ ដើម្បីបាននូវអនុបាទាបរិនិព្វាន ។ ធម៌មួយយ៉ាងតើអ្វី ។ គឺកាយគតាសតិ ។

អយំ ខោ ភិក្ខវេ ឯកធម្មោ ភាវិតោ ពហុលីកតោ បញ្ញាបដិលាភាយ សំវត្តតិ អនុបាទាបរិនិព្វានាយ សំវត្តតីតិ ។

(២៣៦) ឯកធម្មេ ភិក្ខវេ ភាវិតេ ពហុលីកតេ អនេកធាតុប្បដិវេធោ ហោតិ នានាធាតុប្បដិវេធោ ហោតិ អនេកធាតុប្បដិសម្ភិទា ហោតិ ។ កតមស្មឹ ឯកធម្មេ ។ កាយគតាសតិយា ។ ឥមស្មឹ ខោ ភិក្ខវេ ឯកធម្មេ ភាវិតេ ពហុលីកតេ អនេកធាតុប្បដិវេធោ ហោតិ នានាធាតុប្បដិវេធោ ហោតិ អនេកធាតុប្បដិសម្ភិទា ហោតីតិ ។

(២៣៧) ឯកធម្មោ ភិក្ខវេ ភាវិតោ ពហុលីកតោ សោតាបត្តិផលសច្ឆិកិរិយាយ សំវត្តតិ សកទាគាមិផលសច្ឆិកិរិយាយ សំវត្តតិ អនាគាមិផលសច្ឆិកិរិយាយ សំវត្តតិ អរហត្តផលសច្ឆិកិរិយាយ សំវត្តតិ ។ កតមោ ឯកធម្មោ ។ កាយគតាសតិ ។ អយំ ខោ ភិក្ខវេ ឯកធម្មោ ភាវិតោ ពហុលីកតោ សោតាបត្តិផលសច្ឆិកិរិយាយ សំវត្តតិ



ម្នាលភិក្ខុទាំងឡាយ ធម៌មួយយ៉ាងនេះឯង ដែលបុគ្គលបានចំរើន បានធ្វើឲ្យច្រើនហើយ តែងប្រព្រឹត្តទៅដើម្បីចំរើនបញ្ញា តែងប្រព្រឹត្តទៅដើម្បីបាននូវអនុបាទាបរិនិព្វាន ។

(២៣៦) ម្នាលភិក្ខុទាំងឡាយ កាលបើធម៌មួយយ៉ាង ដែលបុគ្គលបានចំរើន បានធ្វើឲ្យច្រើនហើយ ការត្រាស់ដឹងធាតុច្រើនប្រការ ការត្រាស់ដឹងធាតុផ្សេងៗ ការបែកធ្លាយនូវធាតុច្រើនប្រការ រមែងមាន ។ ធម៌មួយយ៉ាងគឺអ្វី ។ គឺកាយគតាសតិ ។ ម្នាលភិក្ខុទាំងឡាយ កាលបើធម៌មួយយ៉ាងនេះឯង ដែលបុគ្គលបានចំរើន បានធ្វើឲ្យច្រើនហើយ ការត្រាស់ដឹងធាតុច្រើនប្រការ ការត្រាស់ដឹងធាតុផ្សេងៗ ការបែកធ្លាយនូវធាតុច្រើនប្រការ រមែងមាន ។

(២៣៧) ម្នាលភិក្ខុទាំងឡាយ ធម៌មួយយ៉ាង ដែលបុគ្គលបានចំរើន បានធ្វើឲ្យច្រើនហើយ តែងប្រព្រឹត្តទៅដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ប្រព្រឹត្តទៅដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ប្រព្រឹត្តទៅដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ប្រព្រឹត្តទៅដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តផល ។ ធម៌មួយយ៉ាងគឺអ្វី ។ គឺកាយគតាសតិ ។ ម្នាលភិក្ខុទាំងឡាយ ធម៌មួយយ៉ាងនេះឯង ដែលបុគ្គលបានចំរើន បានធ្វើឲ្យច្រើនហើយ តែងប្រព្រឹត្តទៅដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល

សកទាគាមិផលសច្ឆិកិរិយាយ សំវត្តតិ អនាគាមិ-ផលសច្ឆិកិរិយាយ សំវត្តតិ អរហត្តផលសច្ឆិកិ-រិយាយ សំវត្តតីតិ ។

(២៣៤) ឯកធម្មោ ភិក្ខវេ ភាវិតោ ពហុលីកតោ បញ្ញាបដិលាភាយ សំវត្តតិ បញ្ញាវុឌ្ឍិយា សំវត្តតិ បញ្ញាវេបុល្លាយ សំវត្តតិ មហា-បញ្ញតាយ សំវត្តតិ បុថុបញ្ញតាយ សំវត្តតិ វិបុលបញ្ញតាយ(១) សំវត្តតិ គម្ភីរបញ្ញតាយ សំវត្តតិ អសាមន្តបញ្ញ-តាយ(២) សំវត្តតិ ភូរិបញ្ញតាយ សំវត្តតិ បញ្ញាពាហុ-ល្លាយ សំវត្តតិ សីឃបញ្ញតាយ សំវត្តតិ លហុប-ញ្ញតាយ សំវត្តតិ ហាសបញ្ញតាយ សំវត្តតិ ជវន-បញ្ញតាយ សំវត្តតិ តិក្ខបញ្ញតាយ សំវត្តតិ និព្វេ-ធិកបញ្ញតាយ សំវត្តតិ ។ កតមោ ឯកធម្មោ ។ កាយគតាសតិ ។ ឥមំ ខោ ភិក្ខវេ ឯកធម្មោ ភាវិតោ ពហុលីកតោ បញ្ញាបដិលាភាយ សំវត្តតិ

១ ម. វិបុលតាយ ។ ២ ឱ. អសមន្តបញ្ញតាយ ។ អដ្ឋកថាយម្បិ ឯវមេវ ។



ប្រព្រឹត្តទៅដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ប្រព្រឹត្តទៅដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ប្រព្រឹត្តទៅដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តផល ។

(២៣៤) ម្នាលភិក្ខុទាំងឡាយ ធម៌មួយយ៉ាង ដែលបុគ្គលបានចំរើនហើយ ធ្វើឲ្យច្រើនហើយ រមែងប្រព្រឹត្តទៅដើម្បីបានបញ្ញា ប្រព្រឹត្តទៅដើម្បីចំរើនបញ្ញា ប្រព្រឹត្តទៅដើម្បីទូលាយបញ្ញា ប្រព្រឹត្តទៅដើម្បីបញ្ញាធំ ប្រព្រឹត្តទៅដើម្បីបញ្ញាក្រាស់ ប្រព្រឹត្តទៅដើម្បីបញ្ញាទូលាយ ប្រព្រឹត្តទៅដើម្បីបញ្ញាជ្រៅ ប្រព្រឹត្តទៅដើម្បីបញ្ញាដ៏វិសេសកន្លងអ្នកដទៃ ដែលអ្នកដទៃមិនអាចគ្របសង្កត់បាន ប្រព្រឹត្តទៅដើម្បីបញ្ញាក្រាស់ដូចផែនដី ប្រព្រឹត្តទៅដើម្បីបញ្ញាច្រើន ប្រព្រឹត្តទៅដើម្បីបញ្ញារួសរាន់ ប្រព្រឹត្តទៅដើម្បីបញ្ញារហ័ស ប្រព្រឹត្តទៅដើម្បីបញ្ញារីករាយ ប្រព្រឹត្តទៅដើម្បីបញ្ញាជាគ្រឿងស្ទុះទៅ ប្រព្រឹត្តទៅដើម្បីបញ្ញាមុត ប្រព្រឹត្តទៅដើម្បីបញ្ញាជាគ្រឿងទំលាយនូវកិលេស ។ ធម៌មួយយ៉ាងតើដូចម្តេច ។ គឺកាយគតាសតិ ។ ម្នាលភិក្ខុទាំងឡាយ ធម៌មួយយ៉ាងនេះឯង ដែលបុគ្គលបានចំរើនហើយ ធ្វើឲ្យច្រើនហើយ រមែងប្រព្រឹត្តទៅដើម្បីបានបញ្ញា

បញ្ញាវុឌ្ឍិយា សំវត្តតិ បញ្ញាវេបុល្លាយ សំវត្តតិ មហាបញ្ញតាយ សំវត្តតិ បុថុបញ្ញតាយ សំវត្តតិ វិបុលបញ្ញតាយ សំវត្តតិ គម្ភីរបញ្ញតាយ សំវត្តតិ អសមន្តបញ្ញតាយ សំវត្តតិ ភូរិបញ្ញតាយ សំវត្តតិ បញ្ញាពាហុល្លាយ សំវត្តតិ សីឃបញ្ញតាយ សំវត្តតិ លហុបញ្ញតាយ សំវត្តតិ ហាសបញ្ញតាយ សំវត្តតិ ជវនបញ្ញតាយ សំវត្តតិ តិក្ខបញ្ញតាយ សំវត្តតិ និព្វេធិកបញ្ញតាយ សំវត្តតីតិ ។

[២៣៥] អមតន្តេ ភិក្ខវេ ន បរិភុញ្ជន្តិ យេ កាយគតាសតឹ ន បរិភុញ្ជន្តិ ។ អមតន្តេ ភិក្ខវេ បរិភុញ្ជន្តិ យេ កាយគតាសតឹ បរិភុញ្ជន្តីតិ ។

[២៣៦] អមតន្តេសំ ភិក្ខវេ អបរិភុត្តំ យេសំ កាយគតាសតិ អបរិភុត្តា ។ អមតន្តេសំ ភិក្ខវេ បរិភុត្តំ យេសំ កាយគតាសតិ បរិភុត្តាតិ ។



ប្រព្រឹត្តទៅដើម្បីចំរើនបញ្ញា ប្រព្រឹត្តទៅដើម្បីទូលាយបញ្ញា ប្រព្រឹត្តទៅដើម្បីបញ្ញាធំ ប្រព្រឹត្តទៅដើម្បីបញ្ញាក្រាស់ ប្រព្រឹត្តទៅដើម្បីបញ្ញាទូលាយ ប្រព្រឹត្តទៅដើម្បីបញ្ញាជ្រៅ ប្រព្រឹត្តទៅដើម្បីបញ្ញាដ៏វិសេសក្តីឥតអ្នកណាស្មើ ដែលអ្នកដទៃមិនអាចក្រាស់ដ៏ទូន ប្រព្រឹត្តទៅដើម្បីបញ្ញាក្រាស់ដូចផែនដី ប្រព្រឹត្តទៅដើម្បីបញ្ញាច្រើន ប្រព្រឹត្តទៅដើម្បីបញ្ញារួសរាន់ ប្រព្រឹត្តទៅដើម្បីបញ្ញារហ័ស ប្រព្រឹត្តទៅដើម្បីបញ្ញារីករាយ ប្រព្រឹត្តទៅដើម្បីបញ្ញាជាគ្រឿងស្ទុះទៅ ប្រព្រឹត្តទៅដើម្បីបញ្ញាមុត ប្រព្រឹត្តទៅដើម្បីបញ្ញាជាគ្រឿងទំលាយនូវកិលេស ។

[២៣៥] ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុណាមិនបរិភោគនូវកាយគតាសតិ ពួកភិក្ខុនោះឈ្មោះថាមិនបរិភោគនូវព្រះនិព្វាន ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុណាបរិភោគនូវកាយគតាសតិ ពួកភិក្ខុនោះរមែងឈ្មោះថាបរិភោគនូវព្រះនិព្វាន ។

(២៣៦) ម្នាលភិក្ខុទាំងឡាយ កាយគតាសតិដែលពួកភិក្ខុណាមិនបរិភោគ ព្រះនិព្វានក៏ឈ្មោះថា ពួកភិក្ខុទាំងនោះមិនបរិភោគដែរ ។ ម្នាលភិក្ខុទាំងឡាយ កាយគតាសតិ ដែលពួកភិក្ខុណា បរិភោគហើយ ព្រះនិព្វានក៏ឈ្មោះថា ពួកភិក្ខុនោះបរិភោគដែរ ។

[៦៣៧] អមតន្តេសំ ភិក្ខវេ បរិហីនំ យេសំ កាយគតាសតិ បរិហីនា ។ អមតន្តេសំ ភិក្ខវេ អបរិហីនំ យេសំ កាយគតាសតិ អបរិហីនា ។

[៦៣៨] អមតន្តេសំ ភិក្ខវេ វិរទ្ធំ យេសំ កាយគតាសតិ វិរទ្ធា ។ អមតន្តេសំ ភិក្ខវេ អារទ្ធំ យេសំ កាយគតាសតិ អារទ្ធា ។

[៦៣៩] អមតន្តេ ភិក្ខវេ បមាទិំសុ(១) យេ កាយគតាសតឹ បមាទិំសុ ។ អមតន្តេ ភិក្ខវេ នប្បមាទិំសុ យេ កាយគតាសតឹ ន ប្បមាទិំសុ ។

[៦៤០] អមតន្តេសំ ភិក្ខវេ សម្មុដ្ឋំ យេសំ កាយគតាសតិ សម្មុដ្ឋា ។ អមតន្តេសំ ភិក្ខវេ អសម្មុដ្ឋំ យេសំ កាយគតាសតិ អសម្មុដ្ឋាតិ ។

១ ម. បមាទំសុ ។



[៦៣៧] ម្នាលភិក្ខុទាំងឡាយ កាយគតាសតិរបស់ពួកភិក្ខុណា សាបសូន្យហើយ ព្រះនិព្វានរបស់ពួកភិក្ខុនោះ ក៏ឈ្មោះថាសាបសូន្យដែរ ។ ម្នាលភិក្ខុទាំងឡាយ កាយគតាសតិរបស់ពួកភិក្ខុណាមិនសាបសូន្យ ព្រះនិព្វានរបស់ពួកភិក្ខុនោះ ក៏ឈ្មោះថាមិនសាបសូន្យដែរ ។

[៦៣៨] ម្នាលភិក្ខុទាំងឡាយ កាយគតាសតិដែលពួកភិក្ខុណាបោះបង់ហើយ ព្រះនិព្វានក៏ឈ្មោះថា ពួកភិក្ខុនោះបោះបង់ដែរ ។ ម្នាលភិក្ខុទាំងឡាយ កាយគតាសតិ ដែលពួកភិក្ខុណាប្រារព្ធហើយ ព្រះនិព្វានក៏ឈ្មោះថា ពួកភិក្ខុនោះប្រារព្ធដែរ ។

[៦៣៩] ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុណា ប្រមាទកាយគតាសតិ ពួកភិក្ខុនោះក៏ឈ្មោះថា ប្រមាទព្រះនិព្វានដែរ ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុណា មិនប្រមាទកាយគតាសតិ ពួកភិក្ខុនោះក៏ឈ្មោះថា មិនប្រមាទព្រះនិព្វានដែរ ។

[៦៤០] ម្នាលភិក្ខុទាំងឡាយ កាយគតាសតិដែលពួកភិក្ខុណាភ្លេចភ្លាំងហើយ ព្រះនិព្វានក៏ឈ្មោះថា ពួកភិក្ខុនោះភ្លេចភ្លាំងដែរ ។ ម្នាលភិក្ខុទាំងឡាយ កាយគតាសតិដែលពួកភិក្ខុណាមិនភ្លេចភ្លាំង ព្រះនិព្វានក៏ឈ្មោះថា ពួកភិក្ខុនោះមិនភ្លេចភ្លាំងដែរ ។

(៦៤១) អមតន្តេសំ ភិក្ខវេ អនាសេវិតំ យេសំ កាយគតាសតិ អនាសេវិតា ។ អមតន្តេសំ ភិក្ខវេ អាសេវិតំ យេសំ កាយគតាសតិ អាសេវិតាតិ ។

(៦៤២) អមតន្តេសំ ភិក្ខវេ អភាវិតំ យេសំ កាយគតាសតិ អភាវិតា ។ អមតន្តេសំ ភិក្ខវេ ភាវិតំ យេសំ កាយគតាសតិ ភាវិតាតិ ។

(៦៤៣) អមតន្តេសំ ភិក្ខវេ អពហុលីកតំ យេសំ កាយគតាសតិ អពហុលីកតា ។ អមតន្តេសំ ភិក្ខវេ ពហុលីកតំ យេសំ កាយគតាសតិ ពហុលីកតាតិ ។

(៦៤៤) អមតន្តេសំ ភិក្ខវេ អនភិញ្ញាតំ យេសំ កាយគតាសតិ អនភិញ្ញាតា ។ អមតន្តេសំ ភិក្ខវេ អភិញ្ញាតំ យេសំ កាយគតាសតិ អភិញ្ញាតាតិ ។



(៦៤១) ម្នាលភិក្ខុទាំងឡាយ កាយគតាសតិដែលពួកភិក្ខុណាមិនបានគប់ប្រសព្វ ព្រះនិព្វានក៏ឈ្មោះថា ពួកភិក្ខុនោះមិនគប់ប្រសព្វដែរ ។ ម្នាលភិក្ខុទាំងឡាយ កាយគតាសតិដែលពួកភិក្ខុណា បានគប់ប្រសព្វហើយ ព្រះនិព្វានក៏ឈ្មោះថា ពួកភិក្ខុនោះបានគប់ប្រសព្វដែរ ។

(៦៤២) ម្នាលភិក្ខុទាំងឡាយ កាយគតាសតិដែលពួកភិក្ខុណាមិនបានចំរើន ព្រះនិព្វានក៏ឈ្មោះថា ពួកភិក្ខុនោះមិនបានចំរើនដែរ ។ ម្នាលភិក្ខុទាំងឡាយ កាយគតាសតិដែលពួកភិក្ខុណា បានចំរើនហើយ ព្រះនិព្វានក៏ឈ្មោះថា ពួកភិក្ខុនោះបានចំរើនដែរ ។

(៦៤៣) ម្នាលភិក្ខុទាំងឡាយ កាយគតាសតិដែលពួកភិក្ខុណាមិនធ្វើឲ្យរឿយៗ ព្រះនិព្វានក៏ឈ្មោះថា ពួកភិក្ខុនោះមិនធ្វើឲ្យរឿយៗ ដែរ ។ ម្នាលភិក្ខុទាំងឡាយ កាយគតាសតិដែលពួកភិក្ខុណាធ្វើឲ្យរឿយៗ ហើយ ព្រះនិព្វានក៏ឈ្មោះថា ពួកភិក្ខុនោះធ្វើឲ្យរឿយៗ ដែរ ។

(៦៤៤) ម្នាលភិក្ខុទាំងឡាយ កាយគតាសតិដែលពួកភិក្ខុណាមិនដឹងច្បាស់ហើយ ព្រះនិព្វានក៏ឈ្មោះថា ពួកភិក្ខុនោះមិនដឹងច្បាស់ដែរ ។ ម្នាលភិក្ខុទាំងឡាយ កាយគតាសតិដែលពួកភិក្ខុណាច្បាស់ដឹងហើយ ព្រះនិព្វានក៏ឈ្មោះថា ពួកភិក្ខុនោះច្បាស់ដឹងដែរ ។

បសាទករធម្មាទិបាឡិ

(៤៤៨) អមតន្តេសំ ភិក្ខវេ អបរិញ្ញាតំ យេសំ កាយគតាសតិ អបរិញ្ញាតា ។ អមតន្តេសំ ភិក្ខវេ បរិញ្ញាតំ យេសំ កាយគតាសតិ បរិញ្ញាតា ។

(៤៤៩) អមតន្តេសំ ភិក្ខវេ អសច្ឆិកតំ យេសំ កាយគតាសតិ អសច្ឆិកតា ។ អមតន្តេសំ ភិក្ខវេ សច្ឆិកតំ យេសំ កាយគតាសតិ សច្ឆិកតា(១) ។

ឯកនិបាតស្ស សុត្តសហស្សំ សមត្តំ ។

---

១ ម. ឥតោ បរំ ឥទមវោច ភគវា អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ទិស្សន្តិ ។



បសាទករធម្មាទិបាលី

(៤៤៨) ម្នាលភិក្ខុទាំងឡាយ កាយគតាសតិដែលពួកភិក្ខុណាមិនកំណត់ដឹង ព្រះនិព្វានក៏ឈ្មោះថា ពួកភិក្ខុនោះមិនកំណត់ដឹងដែរ ។ ម្នាលភិក្ខុទាំងឡាយ កាយគតាសតិដែលពួកភិក្ខុណាកំណត់ដឹងហើយ ព្រះនិព្វានក៏ឈ្មោះថា ពួកភិក្ខុនោះកំណត់ដឹងដែរ ។

(៤៤៩) ម្នាលភិក្ខុទាំងឡាយ កាយគតាសតិដែលពួកភិក្ខុណាមិនធ្វើឲ្យជាក់ច្បាស់ ព្រះនិព្វានក៏ឈ្មោះថា ពួកភិក្ខុនោះមិនធ្វើឲ្យជាក់ច្បាស់ដែរ ។ ម្នាលភិក្ខុទាំងឡាយ កាយគតាសតិដែលពួកភិក្ខុណាបានធ្វើឲ្យជាក់ច្បាស់ហើយ ព្រះនិព្វានក៏ឈ្មោះថា ពួកភិក្ខុនោះបានធ្វើឲ្យជាក់ច្បាស់ដែរ ។

ចប់ សូត្រ ១ ពាន់ក្នុងឯកនិបាត ។

# សុត្តន្តបិដកេ អង្គុត្តរនិកាយស្ស ទុកនិបាតោ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

## បឋមបណ្ណាសកោ

(៦៤៧) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច ទ្វេមានិ ភិក្ខវេ វជ្ជានិ ។ កតមានិ ទ្វេ ។ ទិដ្ឋធម្មិកញ្ច វជ្ជំ សម្បរាយិកញ្ច វជ្ជំ ។ កតមញ្ច ភិក្ខវេ ទិដ្ឋធម្មិកំ វជ្ជំ ។ ឥធ ភិក្ខវេ ឯកច្ចោ បស្សតិ ចោរំ អាគុចារឹ រាជានោ គហេត្វា វិវិធា កម្មការណា ការេន្តេ កសាហិបិ តាឡេន្តេ វេត្តេហិបិ តាឡេន្តេ អឌ្ឍទណ្ឌកេហិបិ តាឡេន្តេ ហត្ថម្បិ ឆិន្ទន្តេ បាទម្បិ ឆិន្ទន្តេ ហត្ថបាទម្បិ ឆិន្ទន្តេ

# សុត្តន្តបិដក អង្គុត្តរនិកាយ ទុកនិបាត

សូមនមស្ការព្រះដ៏មានព្រះភាគអរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ ។

## បឋមបណ្ណាសក

(៦៤៧) ខ្ញុំបាទបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយក្នុងទីនោះឯងថា ម្នាលភិក្ខុទាំងឡាយ ដូច្នេះ ។ ភិក្ខុទាំងនោះទទួលព្រះពុទ្ធដីកាព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ទោសទាំងឡាយនេះមាន ២ ប្រការ ។ ទោស ២ ប្រការដូចម្តេចខ្លះ ។ គឺទោសដែលឲ្យផលក្នុងបច្ចុប្បន្ននេះ ១ ទោសដែលឲ្យផលក្នុងលោកខាងមុខ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះទោសដែលឲ្យផលក្នុងបច្ចុប្បន្ន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ឃើញស្តេចឲ្យចាប់ចោរដែលប្រព្រឹត្តអំពើអាក្រក់ ហើយធ្វើនូវកម្មករណ៍ទាំងឡាយផ្សេង ៗ គឺ វាយដោយរំពាត់ខ្លះ វាយដោយផ្តៅខ្លះ វាយដោយដំបងខ្លីខ្លះ កាត់ដៃខ្លះ កាត់ជើងខ្លះ កាត់ទាំងដៃទាំងជើងខ្លះ

កណ្ណំបិ ឆិន្ទន្តេ នាសំបិ ឆិន្ទន្តេ កណ្ណនាសំបិ ឆិន្ទន្តេ ពិលង្គថាលិកំបិ ការេន្តេ សង្ខមុណ្ឌិកំបិ ការេន្តេ រាហុមុខំបិ ការេន្តេ ជោតិមាលិកំបិ ការេន្តេ ហត្ថបជ្ជោតិកំបិ ការេន្តេ ឯរកវត្តិកំបិ ការេន្តេ ចីរកវាសិកំបិ ការេន្តេ ឯណេយ្យកំ ការេន្តេ ពឡិសមំសិកំបិ ការេន្តេ កហាបណ-កំបិ ការេន្តេ ខារាបតច្ឆិកំបិ ការេន្តេ បលិ-ឃបរិវត្តិកំបិ ការេន្តេ បលាលបីឋកំបិ ការេន្តេ តត្តេនបិ តេលេន ឱសិញ្ចន្តេ សុនខេហិបិ ខាទាបេន្តេ ជីវន្តំបិ សូលេ ឧត្តាសេន្តេ អសិ-នាបិ សីសំ ឆិន្ទន្តេ ។ តស្ស មយ្ហំ ហោតិ ។



កាត់ស្លឹកត្រចៀកខ្លះ កាត់ច្រមុះខ្លះ កាត់ទាំងស្លឹកត្រចៀកទាំងច្រមុះខ្លះ ធ្វើនូវពិលង្គថាលិកកម្ម (គឺការធ្វើដែលគេធ្វើក្បាលឱ្យដូចជាឆ្នាំងដាក់ទឹកជ្រក់) ខ្លះ ធ្វើនូវសង្ខមុណ្ឌិកកម្ម (គឺការធ្វើដែលគេគម្រោះស្បែកក្បាល ឱ្យលើងដូចជាសម្បកស័ង្ខ) ខ្លះ ធ្វើនូវរាហុមុខកម្ម (គឺការធ្វើដែលគេធ្វើមាត់ឱ្យដូចជាមាត់រាហុ) ខ្លះ ធ្វើនូវជោតិមាលិកកម្ម (គឺការធ្វើដែលគេរុំខ្លួនទាំងមូលហើយសំពត់ប្រឡាក់ប្រេង) ខ្លះ ធ្វើនូវហត្ថបជ្ជោតិកកម្ម (គឺការធ្វើដែលគេរុំដៃហើយសំពត់ប្រឡាក់ប្រេង) ខ្លះ ធ្វើនូវឯរកវត្តិកកម្ម (គឺការធ្វើដែលគេធ្វើស្វាជាគម្លាត់ស្បែកពពែ) ខ្លះ ធ្វើនូវចីរកវាសិកកម្ម (គឺការធ្វើដែលគេធ្វើឱ្យដូចជាសំពត់សម្បកឈើ) ខ្លះ ធ្វើនូវឯណេយ្យកកម្ម (គឺការធ្វើដែលគេធ្វើឱ្យដូចជាកើងសត្វក្រោយ) ខ្លះ ធ្វើនូវពឡិសមំសិកកម្ម (គឺការធ្វើដែលគេឆ្កឹចសាច់ហើយការទ្រសន្ទូច) ខ្លះ ធ្វើនូវកហាបណកកម្ម (គឺការធ្វើដែលគេធ្វើឱ្យខ្លួនសរីរៈប្រមាណប៉ុនកហាបណៈមួយ) ខ្លះ ធ្វើនូវខារាបតច្ឆិកកម្ម (គឺការធ្វើដែលគេយកទឹកអំបិលស្រោច) ខ្លះ ធ្វើនូវបលិឃបរិវត្តកកម្ម (គឺការធ្វើដែលគេធ្វើដូចជាបង្វិលដើមត្នោតឬសសរគោល) ខ្លះ ធ្វើនូវបលាលបីឋកកម្ម (គឺការធ្វើដែលគេធ្វើឱ្យដូចជាកណ្តាប់ចំបើង) ខ្លះ ស្រោចដោយប្រេងដែលក្តៅខ្លះ ឱ្យឆ្កែខាំខ្លះ ឱ្យដេកផ្ងារលើឈើអណ្តូកទាំងរស់ខ្លះ កាត់ក្បាលដោយដាវខ្លះ ។ បុរសបុគ្គលនោះ (បានឃើញហើយ) គិតយ៉ាងនេះ ។

យថារូបានំ ខោ បាបកានំ កម្មានំ ហេតុ ចោរំ អាគុចារឹ រាជានោ គហេត្វា វិវិធា កម្មការណា ការេន្តិ កសាហិបិ តាឡេន្តិ ។បេ។ អសិនាបិ សីសំ ឆិន្ទន្តិ ។ អហញ្ចេវ ខោ បន ឯវរូបំ បាបកម្មំ ករេយ្យំ មំបិ រាជានោ គហេត្វា ឯវរូបា វិវិធា កម្មការណា ការេយ្យុំ កសាហិបិ តាឡេយ្យុំ ។បេ។ អសិនាបិ សីសំ ឆិន្ទេយ្យុន្តិ ។ សោ ទិដ្ឋធម្មិកស្ស វជ្ជស្ស ភីតោ ន បរេសំ បាភតំ វិលុម្បន្តោ(១) ចរតិ ។ ឥទំ វុច្ចតិ ភិក្ខវេ ទិដ្ឋធម្មិកំ វជ្ជំ ។ កតមញ្ច ភិក្ខវេ សម្បរាយិកំ វជ្ជំ ។ ឥធ ភិក្ខវេ ឯកច្ចោ ឥតិ បដិសញ្ចិក្ខតិ កាយទុច្ចរិតស្ស ខោ បាបកោ(២) វិបាកោ អភិសម្បរាយំ វចីទុច្ចរិតស្ស ខោ បាបកោ វិបាកោ អភិសម្បរាយំ មនោទុច្ចរិតស្ស ខោ បាបកោ វិបាកោ អភិសម្បរាយំ អហញ្ចេវ ខោ បន កាយេន ទុច្ចរិតំ ចរេយ្យំ វាចាយ ទុច្ចរិតំ ចរេយ្យំ មនសា ទុច្ចរិតំ ចរេយ្យំ

១ ម. វិលុម្បេន្តោ ។ ២ ម. សព្វត្ថ បាបកោតិ បទំ នត្ថិ ។



ពួកស្ដេចឡើងចាប់ចោរដែលប្រព្រឹត្តអំពើអាក្រក់ ហើយធ្វើដោយកម្មករណ៍ផ្សេងៗ គឺវាយដោយរំពាត់ខ្លះ ។បេ។ កាត់ក្បាលដោយដាវខ្លះ ព្រោះហេតុអំពើអាក្រក់មានសភាពយ៉ាងណា ។ ប្រសិនបើអាត្មាអញធ្វើអំពើអាក្រក់មានសភាពយ៉ាងនោះវិញ ពួកស្ដេចនឹងចាប់អាត្មាអញ ហើយគប្បីធ្វើដោយកម្មករណ៍ផ្សេងៗមានសភាពដូច្នោះដែរ គឺវាយដោយរំពាត់ខ្លះ ។បេ។ កាត់ក្បាលដោយដាវខ្លះ ។ បុគ្គលនោះ ខ្លាចទោសដែលឡើងក្នុងបច្ចុប្បន្ននេះ គឺលែងលួចឆក់ទ្រព្យរបស់បុគ្គលដទៃ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទោសឡើងក្នុងបច្ចុប្បន្ននេះ ។ ម្នាលភិក្ខុទាំងឡាយ ចុះទោសដែលឡើងក្នុងលោកខាងមុខ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ពិចារណាឃើញច្បាស់ដូច្នេះថា ផលវិបាករបស់កាយទុច្ចរិតដ៏មានក្នុងលោកខាងមុខ ផលវិបាករបស់វចីទុច្ចរិតដ៏មានក្នុងលោកខាងមុខ ផលវិបាករបស់មនោទុច្ចរិតដ៏មានក្នុងលោកខាងមុខ ប្រសិនបើអាត្មាអញប្រព្រឹត្តទុច្ចរិតដោយកាយក្ដី ប្រព្រឹត្តទុច្ចរិតដោយវាចាក្ដី ប្រព្រឹត្តទុច្ចរិតដោយចិត្តក្ដី

កិញ្ច តំ យេនាហំ(១) កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជេយ្យន្តិ ។ សោ សម្បរាយិកស្ស វជ្ជស្ស ភីតោ កាយទុច្ចរិតំ បហាយ កាយសុចរិតំ ភាវេតិ វចីទុច្ចរិតំ បហាយ វចីសុចរិតំ ភាវេតិ មនោទុច្ចរិតំ បហាយ មនោសុចរិតំ ភាវេតិ សុទ្ធំ អត្តានំ បរិហរតិ ។ ឥទំ វុច្ចតិ ភិក្ខវេ សម្បរាយិកំ វជ្ជំ ។ ឥមានិ ខោ ភិក្ខវេ ទ្វេ វជ្ជានិ ។ តស្មាតិហ ភិក្ខវេ ឯវំ សិក្ខិតព្វំ ទិដ្ឋធម្មិកស្ស វជ្ជស្ស ភាយិស្សាម សម្បរាយិកស្ស វជ្ជស្ស ភាយិស្សាម វជ្ជភីរុនោ ភវិស្សាម វជ្ជភយទស្សាវិនោតិ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វំ ។ វជ្ជភីរុនោ ភិក្ខវេ វជ្ជភយទស្សាវិនោ ឯតំ បាដិកង្ខំ យំ បរិមុច្ចិស្សតិ សព្វវជ្ជេហីតិ ។

១ ម. យាហំ ។



ទំពើណាមួយ ក៏សុទ្ធតែជាហេតុនាំឲ្យអាត្មាអញ លុះទំលាយរាងកាយ បន្ទាប់អំពីមរណៈ ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ។ បុគ្គលនោះ ខ្លាចចំពោះទោសដែលឲ្យផលក្នុងលោកខាងមុខ ហើយលះកាយទុច្ចរិត ចំរើនកាយសុចរិត លះវចីទុច្ចរិត ចំរើនវចីសុចរិត លះមនោទុច្ចរិត ចំរើនមនោសុចរិត ហើយរក្សាខ្លួនឲ្យបរិសុទ្ធ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទោសដែលឲ្យផលក្នុងលោកខាងមុខ ។ ម្នាលភិក្ខុទាំងឡាយ ទោសមាន ២ ប្រការនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ អ្នកទាំងឡាយគប្បីសិក្សា ក្នុងសាសនានេះយ៉ាងនេះថា យើងទាំងឡាយ នឹងខ្លាចចំពោះទោស ដែលឲ្យផលក្នុងបច្ចុប្បន្ននេះ នឹងខ្លាចចំពោះទោស ដែលឲ្យផលក្នុងលោកខាងមុខ នឹងជាអ្នកខ្លាចចំពោះទោសជាប្រក្រតី ជាអ្នកឃើញភ័យក្នុងទោសជាប្រក្រតី ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ជាអ្នកខ្លាចចំពោះទោសជាប្រក្រតី ឃើញនូវភ័យ ក្នុងទោសជាប្រក្រតី គប្បីប៉ុនប៉ងចំពោះហេតុ ដែលនាំឲ្យខ្លួនរួចផុតចាកទោសទាំងពួង ។

[៦៤៨] ឆយិមានិ ភិក្ខវេ ឋានានិ ទុក្ករានិ លោកស្មឹ ។ កតមានិ ឆ ។ យញ្ច ភិក្ខវេ អគារំ អជ្ឈាវសតិ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានុប្បាទនត្ថំ ឋានំ យញ្ច អគារស្មា អនគារិយំ បព្វជិតស្ស សព្វូបធិប្បដិនិស្សគ្គំ ឋានំ ។ ឆ ឥមានិ ខោ ភិក្ខវេ ឆ ឋានានិ ទុក្ករានិ លោកស្មឹ ។ ឯតទគ្គំ ភិក្ខវេ ឥមេសំ ឆន្នំ ឋានានំ យទិទំ សព្វូបធិប្បដិនិស្សគ្គំ ឋានំ ។ តស្មាតិហ ភិក្ខវេ ឯវំ សិក្ខិតព្វំ សព្វូបធិប្បដិនិស្សគ្គំ ឋានំ ឋានមភិសម្ពុជ្ឈាមិ ឯវំ ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។



[៦៤៨] ម្នាលភិក្ខុទាំងឡាយ សេចក្តីព្យាយាម ៦ ប្រការនេះ បុគ្គលធ្វើបាន ដោយកម្រក្នុងលោក ។ សេចក្តីព្យាយាម ៦ ប្រការ ដូចម្តេចខ្លះ ។ គឺពួកគ្រហស្ថដែលនៅគ្រប់គ្រងផ្ទះ ធ្វើព្យាយាម ដើម្បីញុំាងចីវរប្បច្ច័យ បិណ្ឌបាតប្បច្ច័យ សេនាសនប្បច្ច័យនឹងបរិក្ខារគឺថ្នាំជាបច្ច័យដល់អ្នកជម្ងឺឲ្យកើតឡើងបាន ១ ពួកកុលបុត្រដែលចេញចាកផ្ទះបួសកាន់ផ្នួស ធ្វើព្យាយាម ដើម្បីលះបង់នូវឧបធិក្កិលេសទាំងពួងបាន ១ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីព្យាយាមទាំង ៦ ប្រការនេះឯង បុគ្គលធ្វើបាន ដោយកម្រក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ បណ្តាសេចក្តីព្យាយាមទាំង ៦ ប្រការនេះ សេចក្តីព្យាយាម ដើម្បីលះបង់នូវឧបធិក្កិលេសទាំងពួងនុ៎ះជាការប្រសើរជាង ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ អ្នកទាំងឡាយគប្បីសិក្សា ក្នុងសាសនានេះយ៉ាងនេះថា យើងទាំងឡាយនឹងធ្វើព្យាយាម ដើម្បីលះបង់នូវឧបធិក្កិលេសទាំងពួង ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ត្រូវសិក្សាយ៉ាងនេះ ។

(២៤៩) ទ្វេមេ ភិក្ខវេ ធម្មា តបនីយា ។ កតមេ ទ្វេ ។ ឥធ ភិក្ខវេ ឯកច្ចស្ស កាយទុច្ចរិតំ កតំ ហោតិ អកតំ ហោតិ កាយសុចរិតំ វចីទុច្ចរិតំ កតំ ហោតិ អកតំ ហោតិ វចីសុចរិតំ មនោទុច្ចរិតំ កតំ ហោតិ អកតំ ហោតិ មនោសុចរិតំ សោ កាយទុច្ចរិតំ មេ កតន្តិ តប្បតិ អកតំ មេ កាយសុចរិតន្តិ តប្បតិ វចីទុច្ចរិតំ មេ កតន្តិ តប្បតិ អកតំ មេ វចីសុចរិតន្តិ តប្បតិ មនោទុច្ចរិតំ មេ កតន្តិ តប្បតិ អកតំ មេ មនោសុចរិតន្តិ តប្បតិ ។ ឥមេ ខោ ភិក្ខវេ ទ្វេ ធម្មា តបនីយាតិ ។

(២៥០) ទ្វេមេ ភិក្ខវេ ធម្មា អតបនីយា ។ កតមេ ទ្វេ ។ ឥធ ភិក្ខវេ ឯកច្ចស្ស កាយសុចរិតំ កតំ ហោតិ អកតំ ហោតិ កាយទុច្ចរិតំ វចីសុចរិតំ កតំ ហោតិ អកតំ ហោតិ វចីទុច្ចរិតំ មនោសុចរិតំ កតំ ហោតិ



(២៤៩) ម្នាលភិក្ខុទាំងឡាយ ធម៌ដែលជាទីតាំងនៃសេចក្ដីក្ដៅក្រហាយនេះ មាន ២ ប្រការ ។ ធម៌ដែលជាទីតាំងនៃសេចក្ដីក្ដៅក្រហាយ ២ ប្រការ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ធ្វើកាយទុច្ចរិត មិនធ្វើកាយសុចរិត ធ្វើវចីទុច្ចរិត មិនធ្វើវចីសុចរិត ធ្វើមនោទុច្ចរិត មិនធ្វើមនោសុចរិត បុគ្គលនោះ ក៏ក្ដៅក្រហាយថា កាយទុច្ចរិត អាត្មាអញបានធ្វើហើយ ក្ដៅក្រហាយថា កាយសុចរិត អាត្មាអញមិនបានធ្វើឡើយ ក្ដៅក្រហាយថា វចីទុច្ចរិត អាត្មាអញបានធ្វើហើយ ក្ដៅក្រហាយថា វចីសុចរិត អាត្មាអញមិនបានធ្វើឡើយ ក្ដៅក្រហាយថា មនោទុច្ចរិត អាត្មាអញបានធ្វើហើយ ក្ដៅក្រហាយថា មនោសុចរិត អាត្មាអញមិនបានធ្វើឡើយ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលជាទីតាំងនៃសេចក្ដីក្ដៅក្រហាយ មាន ២ ប្រការនេះឯង ។

(២៥០) ម្នាលភិក្ខុទាំងឡាយ ធម៌ដែលមិនជាទីតាំងនៃសេចក្ដីក្ដៅក្រហាយនេះមាន ២ ប្រការ ។ ធម៌ដែលមិនជាទីតាំងនៃសេចក្ដីក្ដៅក្រហាយ ២ ប្រការ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ធ្វើកាយសុចរិត មិនធ្វើកាយទុច្ចរិត ធ្វើវចីសុចរិត មិនធ្វើវចីទុច្ចរិត ធ្វើមនោសុចរិត

អកតំ ហោតិ មនោទុច្ចរិតំ សោ កាយសុចរិតំ មេ
កតន្តិ ន តប្បតិ អកតំ មេ កាយទុច្ចរិតន្តិ
ន តប្បតិ វចីសុចរិតំ មេ កតន្តិ ន តប្បតិ
អកតំ មេ វចីទុច្ចរិតន្តិ ន តប្បតិ មនោសុចរិតំ
មេ កតន្តិ ន តប្បតិ អកតំ មេ មនោ-
ទុច្ចរិតន្តិ ន តប្បតិ ។ ឥមេ ខោ ភិក្ខវេ
ទ្វេ ធម្មា អតបនីយាតិ ។

[៤៩០] ទ្វិន្នាហំ ភិក្ខវេ ធម្មានំ ឧបញ្ញាសិំ
យា ច អសន្តុដ្ឋិតា កុសលេសុ ធម្មេសុ យា ច
អប្បដិវានិតា បធានស្មឹ ។ អប្បដិវានំ សុទាហំ
ភិក្ខវេ បទហាមិ កាមំ តចោ ច ន្ហារុ ច អដ្ឋិ ច
អវសិស្សតុ សរីរេ ឧបសុស្សតុ មំសលោហិតំ យន្តំ
បុរិសថាមេន បុរិសវីរិយេន បុរិសបរក្កមេន បត្តព្វំ
ន តំ អបាបុណិត្វា វីរិយស្ស សណ្ឋានំ ភវិស្សតីតិ



មិនធ្វើបាបមនោទុច្ចរិត បុគ្គលនោះមិនក្ដៅក្រហាយ ដោយគិតឃើញថា ការសុ-
ចរិត អាត្មាអញបានធ្វើហើយ មិនក្ដៅក្រហាយ ដោយគិតឃើញថា
កាយទុច្ចរិត អាត្មាអញមិនបានធ្វើឡើយ មិនក្ដៅក្រហាយ ដោយគិតឃើញ
ថា វចីសុចរិត អាត្មាអញបានធ្វើហើយ មិនក្ដៅក្រហាយ ដោយគិតឃើញ
ថា វចីទុច្ចរិត អាត្មាអញមិនបានធ្វើឡើយ មិនក្ដៅក្រហាយ ដោយគិត
ឃើញថា មនោសុចរិត អាត្មាអញបានធ្វើហើយ មិនក្ដៅក្រហាយ ដោយគិត
ឃើញថា មនោទុច្ចរិត អាត្មាអញមិនបានធ្វើឡើយ ។ ម្នាលភិក្ខុទាំងឡាយ
ធម៌ដែលមិនជាទីតាំងនៃសេចក្ដីក្ដៅក្រហាយ នេះ ២ ប្រការប៉ុណ្ណេះឯង ។

[៤៩១] ម្នាលភិក្ខុទាំងឡាយ តថាគតបានត្រាស់ដឹងនូវធម៌
២ ប្រការ គឺ សេចក្ដីមិនសន្ដោស ក្នុងកុសលធម៌ទាំងឡាយ ១ សេចក្ដី
មិនរួញរា ក្នុងព្យាយាម ១ ។ ម្នាលភិក្ខុទាំងឡាយ តថាគតផ្គងចិត្ត
ប្រារព្ធសេចក្ដីមិនរួញរាថា ស្បែក សរសៃ ឆ្អឹង ចូរឲ្យសល់នៅ
ចុះ សាច់និងឈាមក្នុងសរីរៈ ចូរស្ងួតហែងទៅចុះ គុណវិសេសណា
ដែលបុគ្គលគួរបានដល់ ដោយកម្លាំងរបស់បុរស ដោយព្យាយាមរបស់
បុរស ដោយសេចក្ដីប្រឹងប្រែងរបស់បុរស (បើ) មិនទាន់បានដល់នូវ
គុណវិសេសនោះ ដរាបណា នឹងមិនបញ្ឈប់នូវសេចក្ដីព្យាយាមទៅវិញឡើយ

តស្ស មយ្ហំ ភិក្ខវេ អប្បមាទាធិគតា ពោធិ(១) អប្បមាទាធិគតោ អនុត្តរោ យោគក្ខេមោ ។ តុម្ហេ ចេបិ ភិក្ខវេ អប្បដិវានំ បទហេយ្យាថ កាមំ តចោ ច ន្ហារុ ច អដ្ឋិ ច អវសិស្សតុ សរីរេ ឧបសុស្សតុ មំសលោហិតំ យន្តំ បុរិសត្ថាមេន បុរិសវីរិយេន បុរិសបរក្កមេន បត្តព្វំ ន តំ អបា- បុណិត្វា វីរិយស្ស សណ្ឋានំ ភវិស្សតីតិ តុម្ហេបិ ភិក្ខវេ នចិរស្សេវ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្ម- ចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរិស្សថ ។ តស្មាតិហ ភិក្ខវេ ឯវំ សិក្ខិតព្វំ អប្បដិវានំ បទហិស្សាម កាមំ តចោ ច ន្ហារុ ច អដ្ឋិ ច អវសិស្សតុ សរីរេ ឧបសុស្សតុ មំសលោហិតំ យន្តំ បុរិ- សត្ថាមេន បុរិសវីរិយេន បុរិសបរក្កមេន បត្តព្វំ

---

១ ឱ. សម្ពោធិ ។



ម្នាលភិក្ខុទាំងឡាយ ពោធិញ្ញាណនៃតថាគតបានសម្រេចហើយដោយសេចក្តីមិនប្រមាទ ធម៌ជាគ្រឿងក្សេមចាកយោគៈដ៏ប្រសើរ ក៏តថាគតបានសម្រេចដោយសេចក្តីមិនប្រមាទដែរ ។ ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយតម្កល់ទុកនូវសេចក្តីមិនរួញរាថា ស្បែក សរសៃ ឆ្អឹង សូមឲ្យសល់នៅចុះ សាច់និងឈាមក្នុងសរីរៈចូរហួតហែងទៅចុះ គុណវិសេសណា ដែលបុគ្គលគួរបានដល់ ដោយកំឡាំងរបស់បុរស ដោយសេចក្តីព្យាយាមរបស់បុរស ដោយសេចក្តីប្រឹងប្រែងរបស់បុរស (បើ) មិនទាន់ដល់គុណ- វិសេសនោះទេ នឹងមិនបញ្ឈប់នូវព្យាយាមចោលឡើយ ម្នាលភិក្ខុទាំងឡាយ ពួកកុលបុត្រចេញចាកផ្ទះចូលកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា សូម្បីអ្នកទាំងឡាយក៏បានធ្វើឲ្យជាក់ច្បាស់នូវអនុត្តរធម៌នោះ ជាទីបំផុតនៃព្រហ្មចរិយធម៌ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯងក្នុងបច្ចុប្បន្នធម៌ដោយកាលមិនយូរឡើយ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ អ្នកទាំងឡាយគប្បីសិក្សា ក្នុងសាសនានេះយ៉ាងនេះថា យើងទាំងឡាយនឹងតម្កល់ទុកនូវសេចក្តីមិនរួញរាថា ស្បែក សរសៃ ឆ្អឹង សូមឲ្យសល់នៅចុះ សាច់និងឈាមក្នុងសរីរៈ ចូរហួតហែងទៅចុះ គុណវិសេសណា ដែលបុគ្គលគួរបានដល់ ដោយកំឡាំងរបស់បុរស ដោយសេចក្តីព្យាយាមរបស់បុរស ដោយសេចក្តីប្រឹងប្រែងរបស់បុរស

ន តំ អនាបុច្ឆិត្វា ភិយ្យស្ស សណ្ឋានំ ករីស្សតីតិ ឯវំ ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។

[២៥៦] ទ្វេមេ ភិក្ខវេ ធម្មា ។ កតមេ ទ្វេ ។ យា ច សញ្ញោជនិយេសុ ធម្មេសុ អស្សាទានុបស្សិតា យា ច សញ្ញោជនិយេសុ ធម្មេសុ និព្វិទានុបស្សិតា ។ សញ្ញោជនិយេសុ ភិក្ខវេ ធម្មេសុ អស្សាទានុបស្សី វិហរន្តោ រាគំ នប្បជហតិ ទោសំ នប្បជហតិ មោហំ នប្បជហតិ រាគំ អប្បហាយ ទោសំ អប្បហាយ មោហំ អប្បហាយ ន បរិមុច្ចតិ ជាតិយា ជរាមរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ ន បរិមុច្ចតិ ទុក្ខស្មាតិ វទាមិ ។ សញ្ញោជនិយេសុ ភិក្ខវេ ធម្មេសុ និព្វិទានុបស្សី វិហរន្តោ រាគំ បជហតិ ទោសំ បជហតិ មោហំ បជហតិ រាគំ បហាយ ទោសំ បហាយ មោហំ បហាយ



(ការ) មិនកាន់ផលនូវគុណវិសេសនោះទេ ដើម្បីមិនបញ្ចប់នូវព្រហ្មចារ្យ ឡើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គួរសិក្សាយ៉ាងនេះ ។

(២៥៦) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយនេះមាន ២ ប្រការ ។ ធម៌ ២ ប្រការ តើដូចម្តេច ។ គឺការពិចារណាឃើញដោយសេចក្តីត្រេកអរ ក្នុងសញ្ញោជនិយ(១)ធម៌ទាំងឡាយ ១ ការពិចារណាឃើញដោយសេចក្តីនឿយណាយក្នុងសញ្ញោជនិយធម៌ទាំងឡាយ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកពិចារណាឃើញដោយសេចក្តីត្រេកអរក្នុងសញ្ញោជនិយធម៌ទាំងឡាយ រមែងលះបង់រាគៈមិនបាន លះបង់ទោសៈមិនបាន លះបង់មោហៈមិនបានទេ លុះលះបង់រាគៈមិនបាន លះបង់ទោសៈមិនបាន លះបង់មោហៈមិនបានហើយ រមែងមិនរួចចាកជាតិ ជរា មរណៈ សោកៈ បរិទេវៈ (សេចក្តីខ្សឹកខ្សួល) សេចក្តីទុក្ខទោមនស្ស សេចក្តីចង្អៀតចិត្ត តថាគត ពោលថាភិក្ខុនោះមិនបានរួចផុតចាកសេចក្តីទុក្ខឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកពិចារណាឃើញដោយសេចក្តីនឿយណាយក្នុងសញ្ញោ-ជនិយធម៌ទាំងឡាយ រមែងលះបង់រាគៈ លះបង់ទោសៈ លះបង់មោហៈ បាន លុះលះបង់រាគៈ លះបង់ទោសៈ លះបង់មោហៈ បានហើយ

---

១ ធម៌ជាបច្ច័យនៃសញ្ញោជនៈ ១០ ប្រការ ។

បរិមុច្ចតិ ជាតិយា ជរាមរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ បរិមុច្ចតិ ទុក្ខស្មាតិ វទាមិ ។ ឥមេ ខោ ភិក្ខវេ ទ្វេ ធម្មាតិ ។

(២៩៣) ទ្វេមេ ភិក្ខវេ ធម្មា កណ្ហា ។ កតមេ ទ្វេ ។ អហិរិកញ្ច អនោត្តប្បញ្ច ។ ឥមេ ខោ ភិក្ខវេ ទ្វេ ធម្មា កណ្ហាតិ ។

(២៩៤) ទ្វេមេ ភិក្ខវេ ធម្មា សុក្កា ។ កតមេ ទ្វេ ។ ហិរី ច ឱត្តប្បញ្ច ។ ឥមេ ខោ ភិក្ខវេ ទ្វេ ធម្មា សុក្កាតិ ។

(២៩៥) ទ្វេមេ ភិក្ខវេ សុក្កា ធម្មា លោកំ បាលេន្តិ ។ កតមេ ទ្វេ ។ ហិរី ច ឱត្តប្បញ្ច ។ ឥមេ ច ភិក្ខវេ ទ្វេ សុក្កា ធម្មា លោកំ ន បាលេយ្យុំ នយិធ បញ្ញាយេថ មាតាតិ វា មាតុច្ឆាតិ វា មាតុលានីតិ វា អាចរិយភរិយាតិ វា គរូនំ ទារាតិ វា សម្ភេទំ លោកោ អគមិស្ស យថា អជេឡកា កុក្កុដសូករា សោណសិង្គាលា ។



រមែងរួចស្រឡះចាកជាតិ ជរា មរណៈ សោកៈ បរិទេវៈ ទុក្ខទោមនស្ស ឧបាយាសទាំងឡាយ តថាគតពោលថា បុគ្គលនោះ រមែងរួចស្រឡះចាកទុក្ខបាន ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយមាន ២ ប្រការនេះ ។

(២៩៣) ម្នាលភិក្ខុទាំងឡាយ ធម៌ខ្មៅនេះមាន ២ ប្រការ ។ ធម៌ ២ ប្រការតើដូចម្តេច ។ គឺការមិនមានហិរិ ១ មិនមានឱត្តប្បៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ខ្មៅមាន ២ ប្រការនេះ ។

(២៩៤) ម្នាលភិក្ខុទាំងឡាយ ធម៌សទាំងឡាយ មាន ២ ប្រការ ។ ធម៌សទាំង ២ ប្រការតើដូចម្តេច ។ គឺហិរិ ១ ឱត្តប្បៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ស មាន ២ ប្រការនេះ ។

(២៩៥) ម្នាលភិក្ខុទាំងឡាយ ធម៌ស ២ ប្រការនេះ តែងគ្រប់គ្រងសត្វលោក ។ ធម៌ស ២ ប្រការតើដូចម្តេច ។ គឺ ហិរិ ១ ឱត្តប្បៈ ១ ។ ម្នាលភិក្ខុទាំងឡាយ (បើ) ធម៌សទាំងឡាយ ២ ប្រការនេះ មិនគ្រប់គ្រងសត្វលោកទេ ត្រង់ការថា មាតា ជាម្តាយមីង ជាម្តាយមីង ជាភរិយារបស់អាចារ្យ ជាប្រពន្ធរបស់គ្រូ មិនប្រាកដក្នុងលោកនេះឡើយ សត្វលោកនឹងដល់នូវការប្រឡូកប្រឡំគ្នាដូចសត្វពពែ ចៀម មាន់ ជ្រូក សុនខនិងចចក ទាំងឡាយ ។

យេសំ ច ខោ ភិក្ខវេ ឥមេ ទ្វេ សុក្កា ធម្មា លោកំ បាលេន្តិ តស្មា បញ្ញាយតិ មាតាតិ វា មាតុច្ឆាតិ វា មាតុលានីតិ វា អាចរិយភរិយាតិ វា គរូនំ ទារាតិ វាតិ ។

[៤៩៦] ទ្វេមា ភិក្ខវេ វស្សូបនាយិកា ។ កតមា ទ្វេ ។ បុរិមិកា ច បច្ឆិមិកា ច ។ ឥមា ខោ ភិក្ខវេ ទ្វេ វស្សូបនាយិកាតិ ។

កម្មករណវគ្គោ បឋមោ ។

[៤៩៧] ទ្វេមានិ ភិក្ខវេ ពលានិ ។ កតមានិ ទ្វេ ។ បដិសង្ខានពលញ្ច ភាវនាពលញ្ច ។ កតមញ្ច ភិក្ខវេ បដិសង្ខានពលំ ។ ឥធ ភិក្ខវេ ឯកច្ចោ ឥតិ បដិសញ្ចិក្ខតិ កាយទុច្ចរិតស្ស ខោ បាបកោ វិបាកោ ទិដ្ឋេ ចេវ ធម្មេ អភិសម្បរាយញ្ច វចីទុច្ចរិតស្ស បាបកោ វិបាកោ ទិដ្ឋេ ចេវ ធម្មេ អភិសម្បរាយញ្ច មនោទុច្ចរិតស្ស បាបកោ វិបាកោ ទិដ្ឋេ ចេវ ធម្មេ អភិសម្បរាយញ្ចាតិ



ម្នាលភិក្ខុទាំងឡាយ ព្រោះធម៌ស ២ ប្រការនេះ រក្សាទុកនូវសត្វលោក បានជាគេឲ្យឈ្មោះថា មាតាក្តី ថា ម្តាយមីងក្តី ថា ម្តាយមាក្តី ថា ភរិយារបស់អាចារ្យក្តី ថា ប្រពន្ធរបស់គ្រូក្តី កើតមានប្រាកដ (ក្នុងលោក) ។

[៤៩៦] ម្នាលភិក្ខុទាំងឡាយ ថ្ងៃចូលវស្សានេះ មាន ២ ហើយ ។ ថ្ងៃចូលវស្សាមាន ២ យ៉ាងតើដូចម្តេច ។ គឺបុរិមិកាវស្សា (ថ្ងៃចូលវស្សាមុន) ១ បច្ឆិមិកាវស្សា (ថ្ងៃចូលវស្សាក្រោយ) ១ ។ ម្នាលភិក្ខុទាំងឡាយ ថ្ងៃចូលវស្សាមាន ២ យ៉ាងនេះឯង ។

ចប់ កម្មករណវគ្គ ទី ១ ។

[៤៩៧] ម្នាលភិក្ខុទាំងឡាយ កំឡាំងនេះមាន ២ ប្រការ ។ កំឡាំង ២ ប្រការតើដូចម្តេច ។ កំឡាំងគឺការពិចារណា ១ កំឡាំងគឺការចំរើន ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះកំឡាំងគឺការពិចារណា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ពិចារណាដូច្នេះថា ផលដ៏លាមករបស់កាយទុច្ចរិត (កើតមាន) ក្នុងលោកនេះផង ក្នុងលោកខាងមុខផង ផលដ៏លាមករបស់វចីទុច្ចរិត (កើតមាន) ក្នុងលោកនេះផង ក្នុងលោកខាងមុខផង ផលដ៏លាមករបស់មនោទុច្ចរិត(កើតមាន) ក្នុងលោកនេះផង ក្នុងលោកខាងមុខផង ។

សោ តំ បដិសង្ខាយ កាយទុច្ចរិតំ បហាយ កាយសុចរិតំ ភាវេតិ វចីទុច្ចរិតំ បហាយ វចីសុចរិតំ ភាវេតិ មនោទុច្ចរិតំ បហាយ មនោសុចរិតំ ភាវេតិ សុទ្ធំ អត្តានំ បរិហរតិ ឥទំ វុច្ចតិ ភិក្ខវេ បដិសង្ខានពលំ ។ កតមញ្ច ភិក្ខវេ ភាវនាពលំ ។ តត្រ ភិក្ខវេ យមិទំ ភាវនាពលំ សេក្ខមេតំ ពលំ ។ សេក្ខំ ហិ សោ ភិក្ខវេ(១) ពលំ អាគម្ម រាគំ បជហតិ ទោសំ បជហតិ មោហំ បជហតិ រាគំ បហាយ ទោសំ បហាយ មោហំ បហាយ យំ អកុសលំ ន តំ ករោតិ យំ បាបំ ន តំ សេវតិ ឥទំ វុច្ចតិ ភិក្ខវេ ភាវនាពលំ ឥមានិ ខោ ភិក្ខវេ ទ្វេ ពលានីតិ ។

(៦៥៨) ទ្វេមានិ ភិក្ខវេ ពលានិ ។ កតមានិ ទ្វេ ។ បដិសង្ខានពលញ្ច ភាវនាពលញ្ច ។

១ ម. [illegible] ។



បុគ្គលនោះ ពិចារណាដូច្នេះហើយ ក៏លះបង់កាយទុច្ចរិត ចំរើនកាយសុចរិត លះបង់វចីទុច្ចរិត ចំរើនវចីសុចរិត លះបង់មនោទុច្ចរិត ចំរើនមនោសុចរិត ហើយរក្សាខ្លួនឲ្យបរិសុទ្ធ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កំឡាំងគឺការពិចារណា ។ ម្នាលភិក្ខុទាំងឡាយ ចុះកំឡាំងគឺការចំរើន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បណ្តាកំឡាំងទាំង ២ ប្រការនោះ កំឡាំងគឺការចំរើននេះ ឈ្មោះថា កំឡាំងនៃញាណរបស់សេក្ខបុគ្គលដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលនោះអាស្រ័យកំឡាំងនៃញាណរបស់សេក្ខបុគ្គល ហើយក៏លះបង់នូវរាគៈ លះបង់នូវទោសៈ លះបង់នូវមោហៈ លុះលះបង់នូវរាគៈ លះបង់នូវទោសៈ លះបង់នូវមោហៈបានហើយ ទើបមិនធ្វើអំពើដែលជាអកុសល មិនសេពគប់នូវអំពើដែលជាបាប ម្នាលភិក្ខុទាំងឡាយ នេះហៅថា កំឡាំងគឺការចំរើន ។ ម្នាលភិក្ខុទាំងឡាយ កំឡាំងមាន ២ ប្រការនេះឯង ។

[៦៥៨] ម្នាលភិក្ខុទាំងឡាយ កំឡាំងនេះមាន២ប្រការ ។ កំឡាំង២ប្រការ គឺអ្វីខ្លះ ។ កំឡាំងគឺការពិចារណា១ កំឡាំងគឺការចំរើន១ ។

កតមញ្ច ភិក្ខវេ បដិសង្ខានពលំ ។ ឥធ ភិក្ខវេ ឯកច្ចោ ឥតិ បដិសញ្ចិក្ខតិ កាយទុច្ចរិតស្ស ខោ បាបកោ វិបាកោ ទិដ្ឋេ ចេវ ធម្មេ អភិសម្បរាយេ វចីទុច្ចរិតស្ស បាបកោ វិបាកោ ទិដ្ឋេ ចេវ ធម្មេ អភិសម្បរាយេ មនោទុច្ចរិតស្ស បាបកោ វិបាកោ ទិដ្ឋេ ចេវ ធម្មេ អភិសម្បរាយេចាតិ សោ ឥតិ បដិសង្ខាយ កាយទុច្ចរិតំ បហាយ កាយសុចរិតំ ភាវេតិ វចីទុច្ចរិតំ បហាយ វចីសុចរិតំ ភាវេតិ មនោទុច្ចរិតំ បហាយ មនោសុចរិតំ ភាវេតិ សុទ្ធំ អត្តានំ បរិហរតិ ឥទំ វុច្ចតិ ភិក្ខវេ បដិសង្ខានពលំ ។ កតមញ្ច ភិក្ខវេ ភាវនាពលំ ។ ឥធ ភិក្ខវេ ភិក្ខុ សតិសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ធម្មវិចយសម្ពោជ្ឈង្គំ ភាវេតិ... វីរិយសម្ពោជ្ឈង្គំ ភាវេតិ... បីតិសម្ពោជ្ឈង្គំ ភាវេតិ ..



ម្នាលភិក្ខុទាំងឡាយ កំឡាំងនៃការពិចារណា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ពិចារណាឃើញដូច្នេះថា ផលដ៏លាមករបស់កាយទុច្ចរិត (កើតមាន) ក្នុងលោកនេះផង ក្នុងលោកខាងមុខផង ផលដ៏លាមករបស់វចីទុច្ចរិត (កើតមាន) ក្នុងលោកនេះផង ក្នុងលោកខាងមុខផង ផលដ៏លាមករបស់មនោទុច្ចរិត (កើតមាន) ក្នុងលោកនេះផង ក្នុងលោកខាងមុខផង លុះបុគ្គលនោះពិចារណាឃើញដូច្នេះហើយ ទើបលះបង់កាយទុច្ចរិត ចំរើនកាយសុចរិត លះបង់វចីទុច្ចរិត ចំរើនវចីសុចរិត លះបង់មនោទុច្ចរិត ចំរើនមនោសុចរិត ហើយរក្សាខ្លួនឲ្យបរិសុទ្ធ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កំឡាំងនៃការពិចារណា ។ ម្នាលភិក្ខុទាំងឡាយ ចុះកំឡាំងនៃភាវនា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចំរើននូវសតិសម្ពោជ្ឈង្គ អាស្រ័យវិវេក អាស្រ័យវិរាគ អាស្រ័យនិរោធ បង្អោនទៅដើម្បីលះបង់ ចំរើននូវធម្មវិចយសម្ពោជ្ឈង្គ ... ចំរើននូវវីរិយសម្ពោជ្ឈង្គ ... ចំរើននូវបីតិសម្ពោជ្ឈង្គ ...

បស្សទ្ធិសម្ពោជ្ឈង្គំ ភាវេតិ... សមាធិសម្ពោជ្ឈង្គំ ភាវេតិ... ឧបេក្ខាសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ឥទំ វុច្ចតិ ភិក្ខវេ ភាវនាពលំ ។ ឥមានិ ខោ ភិក្ខវេ ទ្វេ ពលានីតិ ។

(២៥៨) ទ្វេមានិ ភិក្ខវេ ពលានិ ។ កតមានិ ទ្វេ ។ បដិសង្ខានពលញ្ច ភាវនាពលញ្ច ។ កតមញ្ច ភិក្ខវេ បដិសង្ខានពលំ ។ ឥធ ភិក្ខវេ ឯកច្ចោ ឥតិ បដិសញ្ចិក្ខតិ កាយទុច្ចរិតស្ស ខោ បាបកោ វិបាកោ ទិដ្ឋេ ចេវ ធម្មេ អភិសម្បរាយញ្ច វចីទុច្ចរិតស្ស ខោ បាបកោ វិបាកោ ទិដ្ឋេ ចេវ ធម្មេ អភិសម្បរាយញ្ច មនោទុច្ចរិតស្ស ខោ បាបកោ វិបាកោ ទិដ្ឋេ ចេវ ធម្មេ អភិសម្បរាយញ្ចាតិ សោ ឥតិ បដិសង្ខាយ កាយទុច្ចរិតំ បហាយ កាយសុចរិតំ ភាវេតិ វចីទុច្ចរិតំ បហាយ វចីសុចរិតំ ភាវេតិ មនោទុច្ចរិតំ បហាយ មនោសុចរិតំ ភាវេតិ សុទ្ធំ អត្តានំ បរិហរតិ ឥទំ វុច្ចតិ ភិក្ខវេ បដិសង្ខានពលំ ។ កតមញ្ច ភិក្ខវេ ភាវនាពលំ ។ ឥធ ភិក្ខវេ ភិក្ខុ



ចំរើននូវបស្សទ្ធិសម្ពោជ្ឈង្គ... ចំរើននូវសមាធិសម្ពោជ្ឈង្គ... ចំរើននូវឧបេក្ខាសម្ពោជ្ឈង្គដែលអាស្រ័យវិវេក អាស្រ័យវិរាគ អាស្រ័យនិរោធ បង្អោនទៅដើម្បីលះបង់ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កំឡាំងនៃភាវនា ។ ម្នាលភិក្ខុទាំងឡាយ កំឡាំងមាន ២ ប្រការនេះឯង ។

(២៥៨) ម្នាលភិក្ខុទាំងឡាយ កំឡាំងនេះមាន ២ ប្រការ ។ កំឡាំង ២ ប្រការ តើដូចម្តេច ។ កំឡាំងគឺការពិចារណា ១ កំឡាំងគឺភាវនា ១ ។ ម្នាលភិក្ខុទាំងឡាយ កំឡាំងគឺការពិចារណា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ពិចារណាឃើញដូច្នេះថា ផលដ៏លាមករបស់កាយទុច្ចរិត (ក៏មាន) ក្នុងលោកនេះផង ក្នុងលោកខាងមុខផង ផលដ៏លាមករបស់វចីទុច្ចរិត (ក៏មាន) ក្នុងលោកនេះផង ក្នុងលោកខាងមុខផង ផលដ៏លាមករបស់មនោទុច្ចរិត (ក៏មាន) ក្នុងលោកនេះផង ក្នុងលោកខាងមុខផង លុះបុគ្គលនោះពិចារណាដូច្នេះហើយ ទើបលះបង់កាយទុច្ចរិត ចំរើនកាយសុចរិត លះបង់វចីទុច្ចរិត ចំរើនវចីសុចរិត លះបង់មនោទុច្ចរិត ចំរើនមនោសុចរិត ហើយរក្សាខ្លួនឲ្យបរិសុទ្ធ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កំឡាំងគឺការពិចារណា ។ ម្នាលភិក្ខុទាំងឡាយ កំឡាំងគឺភាវនា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ

វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ បីតិយា ច វិរាគា ឧបេក្ខកោ ច វិហរតិ សតោ ច សម្បជានោ សុខញ្ច កាយេន បដិសំវេទេតិ យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិហារីតិ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្វេវ សោមនស្ស-ទោមនស្សានំ អត្ថង្គមា អទុក្ខមសុខំ ឧបេក្ខាសតិ-បារិសុទ្ធឹ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ឥទំ វុច្ចតិ ភិក្ខវេ ឈានពលំ ។ ឥមានិ ខោ ភិក្ខវេ ឆ ពលានីតិ ។



ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលទាំងឡាយ ចូលកាន់បឋមជ្ឈាន ដែលប្រកបដោយវិតក្កៈ វិចារៈមានបីតិនិងសុខៈ ដែលកើតអំពីសេចក្ដីស្ងប់ស្ងាត់ជាអារម្មណ៍ ព្រោះរម្ងាប់វិតក្កៈ វិចារៈ ភិក្ខុនោះក៏ចូលទុតិយជ្ឈានជាទីផូរផង់ ប្រព្រឹត្តទៅខាងក្នុងនៃសន្តានចិត្ត ជាចិត្តខ្ពស់ឯក មិនមាន វិតក្កៈ វិចារៈ មានតែបីតិនិងសុខៈ ដែលកើតអំពីសមាធិ ព្រោះលះបីតិចេញ ភិក្ខុនោះក៏ជាបុគ្គលព្រងើយ មានស្មារតី មានសេចក្ដីដឹងខ្លួន បានទទួលសុខដោយនាមកាយ ព្រះអរិយបុគ្គលទាំងឡាយ តែងសរសើរនូវបុគ្គល ដែលបានចូលតតិយជ្ឈាននោះ ថាជាបុគ្គលមានចិត្តព្រងើយ ជាអ្នកមានស្មារតី មានប្រក្រតីនៅជាសុខ ព្រោះតតិយជ្ឈានណា ក៏ចូលកាន់តតិយជ្ឈាននោះ ព្រោះលះបង់នូវសុខផង លះបង់នូវទុក្ខផង ព្រោះអស់ទៅនៃសោមនស្សនិងទោមនស្ស ក្នុងកាលមុនផង ភិក្ខុនោះក៏ចូលកាន់ចតុត្ថជ្ឈាន ឥតទុក្ខឥតសុខ មានសតិដ៏បរិសុទ្ធ ដោយឧបេក្ខា ម្នាលភិក្ខុទាំងឡាយ នេះហៅថា កំឡាំងនៃឈាន ។ ម្នាលភិក្ខុទាំងឡាយ កំឡាំងមាន ៦ ប្រការនេះឯង ។

[៦៦០] ទ្វេមា ភិក្ខវេ តថាគតស្ស ធម្មទេសនា ។ កតមា ទ្វេ ។ សង្ខិត្តេន ច វិត្ថារេន ច ។ ឥមា ខោ ភិក្ខវេ ទ្វេ តថាគតស្ស ធម្មទេសនាតិ ។

[៦៦១] យស្មឹ ភិក្ខវេ អធិករណេ អាបន្នោ(១) ច ភិក្ខុ ចោទកោ ច ភិក្ខុ ន សាធុកំ អត្តនាវ អត្តានំ បច្ចវេក្ខតិ តស្សេតំ ភិក្ខវេ អធិករណំ បាដិកង្ខំ ទីឃត្តាយ ខរត្តាយ វាឡត្តាយ សំវត្តិស្សតិ ភិក្ខូ ច ន ផាសុំ វិហរិស្សន្តិ ។ យស្មិញ្ច ខោ ភិក្ខវេ អធិករណេ អាបន្នោ(១) ច ភិក្ខុ ចោទកោ ច ភិក្ខុ សាធុកំ អត្តនាវ អត្តានំ បច្ចវេក្ខតិ តស្សេតំ ភិក្ខវេ អធិករណំ បាដិកង្ខំ ន ទីឃត្តាយ ន ខរត្តាយ ន វាឡត្តាយ សំវត្តិស្សតិ ភិក្ខូ ច ផាសុំ វិហរិស្សន្តិ ។ កថញ្ច ភិក្ខវេ អាបន្នោ(១) ភិក្ខុ សាធុកំ អត្តនាវ អត្តានំ បច្ចវេក្ខតិ ។

១ ម. អាបត្តាបន្នោ ។



[៦៦០] ម្នាលភិក្ខុទាំងឡាយ ធម្មទេសនារបស់តថាគតនេះ មាន ២ ប្រការ ។ ធម្មទេសនាមាន ២ ប្រការតើអ្វីខ្លះ ។ គឺទេសនាដោយសង្ខេប ១ ទេសនាដោយពិស្តារ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម្មទេសនារបស់តថាគត មាន ២ ប្រការនេះឯង ។

[៦៦១] ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកត្រូវអាបត្តិ ភិក្ខុជាអ្នកចោទក្តី មិនពិចារណានូវខ្លួនដោយខ្លួនឯង ឲ្យត្រឹមត្រូវក្នុងអធិករណ៍ណា ម្នាលភិក្ខុទាំងឡាយ ហេតុក្នុងអធិករណ៍នុ៎ះនឹងមានប្រាកដ ប្រព្រឹត្តទៅដើម្បីតាំងនៅអស់កាលយូរ ដើម្បីសេចក្តីរឹងរូស ដើម្បីសេចក្តីកោងកាច ភិក្ខុទាំងឡាយនឹងមិនបាននៅសប្បាយឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកត្រូវអាបត្តិ ភិក្ខុជាអ្នកចោទក្តី ពិចារណានូវខ្លួនដោយខ្លួនឯង ឲ្យត្រឹមត្រូវក្នុងអធិករណ៍ណា ហេតុក្នុងអធិករណ៍នោះ នឹងមានប្រាកដ តែមិនប្រព្រឹត្តទៅដើម្បីតាំងនៅអស់កាលយូរ មិនប្រព្រឹត្តទៅដើម្បីរឹងរូស មិនប្រព្រឹត្តទៅដើម្បីសេចក្តីកោងកាច ទាំងភិក្ខុទាំងឡាយ ក៏នៅសប្បាយបាន ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកត្រូវអាបត្តិ ពិចារណានូវខ្លួនដោយខ្លួនឯង ឲ្យត្រឹមត្រូវ តើដូចម្តេច ។

ឥធ ភិក្ខវេ អាបន្នោ(១) ភិក្ខុ ឥតិ បដិសញ្ចិក្ខតិ អហំ ខោ អកុសលំ អាបន្នោ កញ្ចិទេវ ទេសំ កាយេន តស្មា មំ សោ(២) ភិក្ខុ អទ្ទស អកុសលំ អាបជ្ជមានំ កញ្ចិទេវ ទេសំ កាយេន នោ ចេ អហំ អកុសលំ អាបជ្ជេយ្យំ កញ្ចិទេវ ទេសំ កាយេន ន មំ សោ ភិក្ខុ បស្សេយ្យ អកុសលំ អាបជ្ជមានំ កញ្ចិទេវ ទេសំ កាយេន យស្មា ច ខោ អហំ អកុសលំ អាបន្នោ កញ្ចិទេវ ទេសំ កាយេន តស្មា មំ សោ ភិក្ខុ អទ្ទស អកុសលំ អាបជ្ជមានំ កញ្ចិទេវ ទេសំ កាយេន ទិស្វា ច បន មំ សោ ភិក្ខុ អកុសលំ អាបជ្ជមានំ កញ្ចិទេវ ទេសំ កាយេន អនត្តមនោ អហោសិ អនត្តមនោ សមានោ អនត្តមនវចនំ មំ សោ ភិក្ខុ អវច អនត្តមនវចនាហំ តេន ភិក្ខុនា វុត្តោ សមានោ អនត្តមនោ អហោសឹ អនត្តមនោ សមានោ បរេសំ អារោចេសឹ

១ ម. អាបត្តាបន្នោ ។ ២ ឱ. តំ មំ សោ ។



ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ ភិក្ខុជាអ្នកត្រូវអាបត្តិ ពិចារណាឃើញដូច្នេះថា អាត្មាអញត្រូវអាបត្តិណាមួយ ដែលជាអកុសលដោយកាយហើយ ហេតុដូច្នោះបានជាភិក្ខុនោះបានឃើញអាត្មាអញត្រូវអាបត្តិណាមួយ ជាអកុសលដោយកាយមិនខាន ប្រសិនបើអាត្មាអញមិនត្រូវអាបត្តិណាមួយ ជាអកុសលដោយកាយទេ ភិក្ខុនោះ ក៏មិនគប្បីឃើញអាត្មាអញត្រូវអាបត្តិណាមួយ ជាអកុសលដោយកាយឡើយ មួយវិញទៀត ព្រោះអាត្មាអញបានត្រូវអាបត្តិណាមួយ ជាអកុសលដោយកាយ បានជាភិក្ខុនោះឃើញអាត្មាអញត្រូវអាបត្តិមួយ ជាអកុសលដោយកាយមិនខាន លុះភិក្ខុនោះ ឃើញអាត្មាអញត្រូវអាបត្តិណាមួយដោយកាយហើយ ក៏អាក់អន់ចិត្ត លុះភិក្ខុនោះ អាក់អន់ចិត្តហើយ ទើបបានពោលពាក្យ មិនជាទីពេញចិត្តនឹងអាត្មាអញ កាលភិក្ខុនោះពោលពាក្យ មិនជាទីពេញចិត្តហើយ អាត្មាអញក៏អាក់អន់ចិត្តដែរ កាលបើអាត្មាអញ អាក់អន់ចិត្តហើយ ទើបប្រាប់ដល់ពួកភិក្ខុដទៃថា

ឥតិ មមេវ តត្ថ អច្ចយោ អច្ចគមា សុង្កទាយិកំវ ភណ្ឌស្មឹ ឯវំ ខោ ភិក្ខវេ អាបន្នេន ភិក្ខុនា សាធុកំ អត្តនាវ អត្តានំ បច្ចវេក្ខិតព្វំ ។ កថញ្ច ភិក្ខវេ ចោទកេន ភិក្ខុនា សាធុកំ អត្តនាវ អត្តានំ បច្ចវេក្ខិតព្វំ ។ ឥធ ភិក្ខវេ ចោទកេន ភិក្ខុនា ឥតិ បដិសញ្ចិក្ខិតព្វំ អយំ ខោ ភិក្ខុ អកុសលំ អាបន្នោ កិញ្ចិទេវ ទេសំ កាយេន តស្មា(១) អហំ ឥមំ ភិក្ខុំ អទ្ទសំ អកុសលំ អាបជ្ជមានំ កិញ្ចិទេវ ទេសំ កាយេន នោ ចេ អយំ ភិក្ខុ អកុសលំ អាបជ្ជេយ្យ កិញ្ចិទេវ ទេសំ កាយេន នាហំ ឥមំ ភិក្ខុំ បស្សេយ្យំ អកុសលំ អាបជ្ជមានំ កិញ្ចិទេវ ទេសំ កាយេន យស្មា ច ខោ អយំ ភិក្ខុ អកុសលំ អាបន្នោ កិញ្ចិទេវ ទេសំ កាយេន តស្មា អហំ ឥមំ ភិក្ខុំ អទ្ទសំ អកុសលំ អាបជ្ជមានំ កិញ្ចិទេវ ទេសំ កាយេន ទិស្វា ច បនាហំ ឥមំ ភិក្ខុំ អកុសលំ អាបជ្ជមានំ កិញ្ចិទេវ ទេសំ កាយេន អនត្តមនោ អហោសឹ

១ ៖ ពហំ ។



ទោសត្រូវលើខ្ញុំណាហើយ ព្រោះអធិករណ៍នោះ ដូចជាទោសត្រូវអ្នកថ្វាយស្នួយ ព្រោះនាំរបស់គេចពន្ធ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឈ្មោះថា ភិក្ខុជាអ្នកត្រូវអាបត្តិ ពិចារណានូវខ្លួនដោយខ្លួនឯងឲ្យត្រឹមត្រូវ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកចោទ ពិចារណានូវខ្លួនដោយខ្លួនឯងឲ្យត្រឹមត្រូវ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ ភិក្ខុជាអ្នកចោទ ពិចារណាឃើញដូច្នេះថា ភិក្ខុនេះត្រូវអាបត្តិណាមួយ ជាអកុសលដោយកាយហើយ ហេតុដូច្នោះ បានជាអាត្មាអញឃើញភិក្ខុនេះត្រូវអាបត្តិណាមួយ ជាអកុសលដោយកាយ ប្រសិនបើភិក្ខុនេះមិនគប្បីត្រូវអាបត្តិណាមួយជាអកុសលដោយកាយទេ អាត្មាអញក៏មិនគប្បីឃើញភិក្ខុនេះត្រូវអាបត្តិណាមួយ ជាអកុសលដោយកាយឡើយ មួយវិញទៀត ព្រោះភិក្ខុនេះត្រូវអាបត្តិណាមួយ ជាអកុសលដោយកាយ បានជាអាត្មាអញឃើញភិក្ខុនេះត្រូវអាបត្តិណាមួយ ជាអកុសលដោយកាយ លុះអាត្មាអញឃើញភិក្ខុនេះត្រូវអាបត្តិណាមួយ ជាអកុសលដោយកាយហើយ ក៏មានសេចក្តីអាក់អន់ចិត្ត

អត្តមនោ សមានោ អនត្តមនវចនាហំ ឥមំ ភិក្ខុំ អវចំ អនត្តមនវចនាយំ ភិក្ខុ មយា វុត្តោ សមានោ អនត្តមនោ អហោសិ អនត្តមនោ សមានោ បរេសំ អារោចេសិ ឥតិ មមេវ តត្ថ អច្ចយោ អច្ចគមា សុំកទាយិកំវ ភណ្ឌស្មិន្តិ ឯវំ ខោ ភិក្ខវេ ចោទកោ ភិក្ខុ សាធុកំ អត្តនាវ អត្តានំ បច្ចវេក្ខតិ ។ យស្មឹ ភិក្ខវេ អធិករណេ អាបន្នោ ច ភិក្ខុ ចោទកោ ច ភិក្ខុ ន សាធុកំ អត្តនាវ អត្តានំ បច្ចវេក្ខន្តិ តស្សេតំ ភិក្ខវេ អធិករណំ បាដិកង្ខំ ទីឃត្តាយ ខរត្តាយ វាឡត្តាយ សំវត្តិស្សតិ ភិក្ខូ ច ន ផាសុំ វិហរិស្សន្តិ ។ យស្មឹ ច ខោ ភិក្ខវេ អធិករណេ អាបន្នោ ច ភិក្ខុ ចោទកោ ច ភិក្ខុ សាធុកំ អត្តនាវ អត្តានំ បច្ចវេក្ខន្តិ តស្សេតំ ភិក្ខវេ អធិករណំ បាដិកង្ខំ ន ទីឃត្តាយ ន ខរត្តាយ ន វាឡត្តាយ សំវត្តិស្សតិ ភិក្ខូ ច ផាសុំ វិហរិស្សន្តីតិ ។



កាលអាត្មាអញខាក់អន់ចិត្ត ទើបបានពោលពាក្យមិនជាទីពេញចិត្តនឹងភិក្ខុនេះ ឯភិក្ខុនេះ លុះអាត្មាអញពោលពាក្យ មិនជាទីពេញចិត្តហើយ ក៏មានសេចក្តីខាក់អន់ចិត្តដែរ កាលខាក់អន់ចិត្តហើយទើបប្រាប់ដល់ពួកភិក្ខុដទៃថា ទោសត្រូវលើខ្ញុំករុណាហើយ ព្រោះអធិករណ៍នោះ ដូចជាទោសត្រូវអ្នកថ្វាយសួយ ព្រោះនាំរបស់គេចេញ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឈ្មោះថា ភិក្ខុជាអ្នកចោទពិចារណាខ្លួនដោយខ្លួនឯងឲ្យត្រឹមត្រូវ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកត្រូវអាបត្តិ ភិក្ខុជាអ្នកចោទក្តី មិនពិចារណាខ្លួនដោយខ្លួនឯង ឲ្យត្រឹមត្រូវក្នុងអធិករណ៍ណា ម្នាលភិក្ខុទាំងឡាយ ហេតុក្នុងអធិករណ៍នោះ នឹងមានប្រាកដ ប្រព្រឹត្តទៅដើម្បីតាំងនៅអស់កាលយូរ ដើម្បីសេចក្តីរឹងរូស ដើម្បីសេចក្តីកោងកាច ទាំងភិក្ខុទាំងឡាយក៏នឹងមិនបាននៅសប្បាយឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកត្រូវអាបត្តិ ភិក្ខុជាអ្នកចោទក្តី ពិចារណាខ្លួនដោយខ្លួនឯងឲ្យត្រឹមត្រូវ ក្នុងអធិករណ៍ណា ម្នាលភិក្ខុទាំងឡាយ ហេតុក្នុងអធិករណ៍នុ៎ះ នឹងមានប្រាកដ តែមិនប្រព្រឹត្តទៅដើម្បីតាំងនៅអស់កាលយូរ ដើម្បីសេចក្តីរឹងរូស ដើម្បីសេចក្តីកោងកាចទេ ទាំងភិក្ខុទាំងឡាយក៏នឹងបាននៅសប្បាយផង ។

(២៦២) អថ ខោ អញ្ញតរោ ព្រាហ្មណោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោ ព្រាហ្មណោ ភគវន្តំ ឯតទវោច កោ នុ ខោ ភោ គោតម ហេតុ កោ បច្ចយោ យេនមិធេកច្ចេ សត្តា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជន្តីតិ ។ អធម្មចរិយាវិសមចរិយាហេតុ ខោ ព្រាហ្មណ ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជន្តីតិ ។ កោ បន ភោ គោតម ហេតុ កោ បច្ចយោ យេនមិធេកច្ចេ សត្តា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តីតិ ។ ធម្មចរិយាសមចរិយាហេតុ ខោ ព្រាហ្មណ ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តីតិ ។



(២៦២) គ្រានោះ មានព្រាហ្មណ៍ម្នាក់ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរីករាយនឹងព្រះមានព្រះភាគ លុះពោលពាក្យគួររីករាយនឹងពាក្យគួររលឹកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះព្រាហ្មណ៍នោះអង្គុយក្នុងទីសមគួរហើយ ទើបក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចំរើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលបណ្តាលឲ្យសត្វពួកខ្លះ ក្នុងលោកនេះទំលាយរាងកាយបន្ទាប់អំពីមរណៈ ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ សត្វពួកខ្លះ ក្នុងលោកនេះ លុះតែទំលាយរាងកាយ បន្ទាប់អំពីមរណៈ ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក យ៉ាងនេះ ព្រោះហេតុប្រព្រឹត្តមិនត្រូវតាមធម៌ ប្រព្រឹត្តមិនស្មើ ។ បពិត្រព្រះគោតមដ៏ចំរើន ចុះអ្វីជាហេតុ អ្វីជាបច្ច័យ ដែលបណ្តាលឲ្យសត្វពួកខ្លះ ក្នុងលោកនេះ លុះទំលាយរាងកាយបន្ទាប់អំពីមរណៈ ទៅកើតក្នុងសុគតិ សួគ៌ ទេវលោក ។ ម្នាលព្រាហ្មណ៍ សត្វពួកខ្លះ ក្នុងលោកនេះ លុះទំលាយរាងកាយ បន្ទាប់អំពីមរណៈ ទៅកើតក្នុងសុគតិ សួគ៌ ទេវលោក យ៉ាងនេះ ព្រោះហេតុប្រព្រឹត្តត្រូវតាមធម៌ ប្រព្រឹត្តស្មើ ។

អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម សេយ្យថាបិ ភោ គោតម និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលបជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវំ ភោតា គោតមេន អនេកបរិយាយេន ធម្មោ បកាសិតោ ឯសាហំ ភវន្តំ គោតមំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតន្តិ ។

(៤២៣) អថ ខោ ជាណុស្សោណី ព្រាហ្មណោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ជាណុស្សោណី ព្រាហ្មណោ ភគវន្តំ ឯតទវោច កោ នុ ខោ ភោ គោតម ហេតុ កោ បច្ចយោ យេនមិធេកច្ចេ សត្តា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជន្តីតិ ។



បពិត្រព្រះគោតមដ៏ចំរើន ពីរោះណាស់ បពិត្រព្រះគោតមដ៏ចំរើន ពីរោះណាស់ បពិត្រព្រះអង្គដ៏ចំរើន ធម៌ដែលព្រះគោតមដ៏ចំរើន សំដែងហើយដោយអនេកបរិយាយយ៉ាងនេះ ដូចជាមនុស្សចាប់របស់ដែលគេផ្កាប់ចុះឲ្យផ្ងារឡើង ពុំនោះដូចជា មនុស្សបើកបង្ហាញរបស់ដែលគេលាក់បិទបាំង ពុំនោះសោតដូចជា មនុស្សប្រាប់ផ្លូវដល់អ្នកវង្វេងទិស ឬក៏ដូចជា មនុស្សកាន់ប្រទីបទ្រោលបំភ្លឺក្នុងទីងងឹតដោយគិតថា មនុស្សអ្នកមានភ្នែកភ្លឺទាំងឡាយនឹងបានឃើញនូវរូប ខ្ញុំព្រះអង្គសូមដល់នូវព្រះគោតមដ៏ចំរើនផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹងទីរលឹក សូមព្រះគោតមដ៏ចំរើន ជ្រាបនូវខ្ញុំព្រះអង្គថាជា ឧបាសកអ្នកដល់សរណគមន៍ ស្មើដោយជីវិត តាំងដើមតាំងអំពីថ្ងៃនេះទៅ ។

(៤២៣) គ្រានោះ ជាណុស្សោណីព្រាហ្មណ៍ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយក៏ពោលពាក្យរីករាយនឹងព្រះដ៏មានព្រះភាគ លុះពោលពាក្យគួររីករាយនឹងពាក្យគួររលឹកហើយ ទើបអង្គុយក្នុងទីដ៏សមគួរ ។ លុះជាណុស្សោណីព្រាហ្មណ៍ អង្គុយក្នុងទីសមគួរហើយ ទើបក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចំរើនអ្វីជាហេតុ អ្វីជាបច្ច័យ ដែលបណ្តាលឲ្យសត្វពួកខ្លះ ក្នុងលោកនេះ លុះទំលាយរាងកាយបន្ទាប់អំពីមរណៈ ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ។

កតត្តា ច ព្រាហ្មណ អកតត្តា ច ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជន្តិ ។ កោ បន ភោ គោតម ហេតុ កោ បច្ចយោ យេនមិធេកច្ចេ សត្តា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ ។ កតត្តា ច ព្រាហ្មណ អកតត្តា ច ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ ។ ន ខោ អហំ ឥមស្ស ភោតោ គោតមស្ស សង្ខិត្តេន ភាសិតស្ស វិត្ថារេន(១) អត្ថំ អាជានាមិ(១) សាធុ មេ ភវំ គោតមោ តថា ធម្មំ ទេសេតុ យថា អហំ ឥមស្ស ភោតោ គោតមស្ស សង្ខិត្តេន ភាសិតស្ស វិត្ថារេន អត្ថំ អាជានេយ្យន្តិ ។ តេនហិ ព្រាហ្មណ សុណាហិ សាធុកំ មនសិការោហិ ភាសិស្សាមីតិ ។ ឯវំ ភោតិ ខោ ជាណុស្សោណី ព្រាហ្មណោ ភគវតោ បច្ចស្សោសិ ។

១ ម. ឯត្តកេន វិត្ថារេន អត្ថំ អាជានេយ្យាមិ ទិស្សតិ ។



ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ សត្វពួកខ្លះក្នុងលោកនេះ លុះទំលាយកាយបន្ទាប់អំពីមរណៈ ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក យ៉ាងនេះ ព្រោះអំពើដែលខ្លួនធ្វើផង មិនធ្វើផង ។ បពិត្រព្រះគោតមដ៏ចំរើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលបណ្តាលឲ្យសត្វពួកខ្លះ ក្នុងលោកនេះ លុះទំលាយកាយ បន្ទាប់អំពីមរណៈទៅកើតក្នុងសុគតិ សួគ៌ ទេវលោក ។ ម្នាលព្រាហ្មណ៍ សត្វពួកខ្លះក្នុងលោកនេះ លុះទំលាយកាយ បន្ទាប់អំពីមរណៈ ទៅកើតក្នុងសុគតិ សួគ៌ ទេវលោក យ៉ាងនេះ ព្រោះអំពើដែលខ្លួនធ្វើផង មិនធ្វើផង ។ ព្រាហ្មណ៍ក្រាបបង្គំទូលថា ភាសិតរបស់ព្រះគោតមដ៏ចំរើន នេះសង្ខេបពេកណាស់ ខ្ញុំព្រះអង្គមិនអាចនឹងដឹងសេចក្តី ដោយពិស្តារបានទេ ។ សូមព្រះគោតមដ៏ចំរើនទ្រង់សំដែងធម៌ តាមទំនងដែលខ្ញុំព្រះអង្គគប្បីយល់ច្បាស់សេចក្តីនៃភាសិតដែលព្រះគោតមដ៏ចំរើនទ្រង់សំដែងដោយសង្ខេបនេះ ដោយសេចក្តីពិស្តារឲ្យបាន ។ ម្នាលព្រាហ្មណ៍ បើដូច្នោះអ្នកចូរស្តាប់ ចូរប្រុងចិត្តឲ្យស្រួលបួលចុះ តថាគតនឹងសំដែង ។ ជាណុស្សោណីព្រាហ្មណ៍ទទួលព្រះពុទ្ធដីការបស់ព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។

ភគវា ឯតទវោច ឥធ ព្រាហ្មណ ឯកច្ចស្ស កាយទុច្ចរិតំ កតំ ហោតិ អកតំ ហោតិ កាយសុចរិតំ វចីទុច្ចរិតំ កតំ ហោតិ អកតំ ហោតិ វចីសុចរិតំ មនោទុច្ចរិតំ កតំ ហោតិ អកតំ ហោតិ មនោសុចរិតំ ឯវំ ខោ ព្រាហ្មណ កតត្តា ច អកតត្តា ច ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជន្តិ ឥធ បន ព្រាហ្មណ ឯកច្ចស្ស កាយសុចរិតំ កតំ ហោតិ អកតំ ហោតិ កាយទុច្ចរិតំ វចីសុចរិតំ កតំ ហោតិ អកតំ ហោតិ វចីទុច្ចរិតំ មនោសុចរិតំ កតំ ហោតិ អកតំ ហោតិ មនោទុច្ចរិតំ ឯវំ ខោ ព្រាហ្មណ កតត្តា ច អកតត្តា ច ឯវមិធេកច្ចេ សត្តា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តីតិ ។ អភិក្កន្តំ ភោ គោតម ។បេ។ ឧបាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតន្តិ ។



ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលព្រាហ្មណ៍ សត្វពួកខ្លះ ក្នុងលោកនេះ ធ្វើតែកាយទុច្ចរិត មិនធ្វើកាយសុចរិត ធ្វើតែវចីទុច្ចរិត មិនធ្វើវចីសុចរិត ធ្វើតែមនោទុច្ចរិត មិនធ្វើមនោសុចរិត ម្នាលព្រាហ្មណ៍ សត្វពួកខ្លះក្នុងលោកនេះ លុះទំលាយខន្ធកាយ បន្ទាប់អំពីមរណៈតែងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក យ៉ាងនេះ ព្រោះអំពើដែលខ្លួនធ្វើផង មិនធ្វើផង ដូច្នេះ ម្នាលព្រាហ្មណ៍ ឯសត្វពួកខ្លះ ក្នុងលោកនេះ ធ្វើតែកាយសុចរិត មិនធ្វើកាយទុច្ចរិត ធ្វើតែវចីសុចរិត មិនធ្វើវចីទុច្ចរិត ធ្វើតែមនោសុចរិត មិនធ្វើមនោទុច្ចរិត ម្នាលព្រាហ្មណ៍ សត្វពួកខ្លះក្នុងលោកនេះ លុះទំលាយខន្ធកាយ បន្ទាប់អំពីមរណៈតែងទៅកើតក្នុងសុគតិ សួគ៌ ទេវលោក យ៉ាងនេះ ព្រោះអំពើដែលខ្លួនធ្វើផង មិនធ្វើផង ដូច្នេះ ។ ព្រាហ្មណ៍ក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចំរើន ពីរោះណាស់ ។បេ។ សូមព្រះគោតមដ៏ចំរើនជ្រាបច្បាស់នូវខ្ញុំព្រះអង្គថាជាឧបាសកអ្នកដល់នូវសរណៈស្មើដោយជីវិតចាប់ដើមអំពីថ្ងៃនេះតទៅ ។

(១៦៦) អថ ខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ អានន្ទំ ភគវា ឯតទវោច ឯកំសេនាហំ អានន្ទ អករណីយំ វទាមិ កាយទុច្ចរិតំ វចីទុច្ចរិតំ មនោទុច្ចរិតន្តិ ។ យមិទំ ភន្តេ ភគវតា ឯកំសេន អករណីយំ អក្ខាតំ កាយទុច្ចរិតំ វចីទុច្ចរិតំ មនោទុច្ចរិតំ តស្មឹ អករណីយេ កយិរមានេ កោ អាទីនវោ បាដិកង្ខោតិ ។ យមិទំ អានន្ទ មយា ឯកំសេន អករណីយំ អក្ខាតំ កាយទុច្ចរិតំ វចីទុច្ចរិតំ មនោទុច្ចរិតំ តស្មឹ អករណីយេ កយិរមានេ អយំ អាទីនវោ បាដិកង្ខោ អត្តាបិ អត្តានំ ឧបវទតិ អនុវិច្ច វិញ្ញូ គរហន្តិ បាបកោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ សម្មូឡ្ហោ កាលំ ករោតិ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ យមិទំ អានន្ទ មយា ឯកំសេន អករណីយំ អក្ខាតំ កាយទុច្ចរិតំ វចីទុច្ចរិតំ មនោទុច្ចរិតំ



(១៦៦) សម័យនោះ ព្រះអានន្ទដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ថ្វាយបង្គំព្រះដ៏មានព្រះភាគហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះអានន្ទដ៏មានអាយុអង្គុយក្នុងទីដ៏សមគួរហើយ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលអានន្ទ តថាគតសំដែងថា បុគ្គលមិនគួរធ្វើកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត សោះឡើយ ។ ព្រះអានន្ទក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ព្រះអង្គទ្រង់សំដែងថា បុគ្គលមិនគួរធ្វើ កាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត សោះឡើយ កាលបើបុគ្គលធ្វើ នូវអំពើដែលមិនគួរធ្វើនោះ តើនឹងបានទទួលទោសដូចម្តេច ។ ម្នាលអានន្ទ ដែលតថាគតសំដែងថា បុគ្គលមិនគួរធ្វើ កាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិតនេះ សោះឡើយ កាលបើបុគ្គលធ្វើ នូវអំពើដែលមិនគួរធ្វើនោះ នឹងបានទទួលទោស ដូច្នេះ គឺខ្លួនឯងតិះដៀលខ្លួនឯងបានផង ពួកបណ្ឌិត ពិចារណាហើយតិះដៀលបានផង កិត្តិសព្ទដ៏អាក្រក់ ល្បីខ្ចរទៅផង វង្វេងធ្វើកាលកិរិយាផង លុះទំលាយកាយ បន្ទាប់អំពីមរណៈ ក៏ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ផង ម្នាលអានន្ទ ដែលតថាគតសំដែងថា បុគ្គលមិនគួរធ្វើ កាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត សោះឡើយ

តស្មឹ អករណីយេ កយិរមានេ អយំ អាទីនវោ បាដិកង្ខោ ឯកំសេនាហំ អានន្ទ ករណីយំ វទាមិ កាយសុចរិតំ វចីសុចរិតំ មនោសុចរិតន្តិ ។ យមិទំ ភន្តេ ភគវតា ឯកំសេន ករណីយំ អក្ខាតំ កាយសុចរិតំ វចីសុចរិតំ មនោសុចរិតំ តស្មឹ ករណីយេ កយិរមានេ កោ អានិសំសោ បាដិកង្ខោតិ ។ យមិទំ អានន្ទ មយា ឯកំសេន ករណីយំ អក្ខាតំ កាយសុចរិតំ វចីសុចរិតំ មនោសុចរិតំ តស្មឹ ករណីយេ កយិរមានេ អយំ អានិសំសោ បាដិកង្ខោ អត្តាបិ អត្តានំ ន ឧបវទតិ អនុវិច្ច វិញ្ញូ បសំសន្តិ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ អសម្មុឡ្ហោ កាលំ ករោតិ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ យមិទំ អានន្ទ មយា ឯកំសេន ករណីយំ អក្ខាតំ កាយសុចរិតំ វចីសុចរិតំ មនោសុចរិតំ តស្មឹ ករណីយេ កយិរមានេ អយំ អានិសំសោ បាដិកង្ខោតិ ។



កាលបើបុគ្គលធ្វើ ត្រង់អំពើដែលមិនគួរធ្វើនោះ នឹងបានទទួលទោសនេះ ម្នាលអានន្ទ តថាគតសំដែងថា បុគ្គលគួរធ្វើតែកាយសុចរិត វចីសុចរិត មនោសុចរិត មួយយ៉ាង ។ បពិត្រព្រះអង្គដ៏ចំរើន ព្រះអង្គទ្រង់សំដែងថា បុគ្គលគួរធ្វើតែកាយសុចរិត វចីសុចរិត មនោសុចរិត តែមួយយ៉ាងនេះ កាលបើបុគ្គលធ្វើត្រង់អំពើដែលគួរធ្វើនោះ តើនឹងបានទទួលអានិសង្សដូចម្តេច ។ ម្នាលអានន្ទ ដែលតថាគតសំដែងថា បុគ្គលគួរធ្វើតែកាយសុចរិត វចីសុចរិត មនោសុចរិត មួយយ៉ាងនេះ កាលបើបុគ្គលធ្វើត្រង់អំពើដែលគួរធ្វើនោះ នឹងបានទទួលអានិសង្ស ដូច្នេះ គឺ ខ្លួនឯងនឹងតិះដៀលខ្លួនឯងមិនបានផង ពួកបណ្ឌិត ពិចារណាហើយតែងសរសើរផង កិត្តិសព្ទដ៏ល្អល្បីខ្ចរទៅផង មិនវង្វេងស្លាប់ផង លុះទំលាយកាយ បន្ទាប់អំពីមរណៈ ទៅកើតក្នុងសុគតិ សួគ៌ទេវលោកផង ម្នាលអានន្ទ ដែលតថាគតសំដែងថា បុគ្គលគួរធ្វើតែកាយសុចរិត វចីសុចរិត មនោសុចរិត មួយយ៉ាងនេះ កាលបើបុគ្គលធ្វើ ត្រង់អំពើដែលគួរធ្វើនោះ នឹងបានទទួលអានិសង្ស នេះមិនខាន ។

(២៦៥) អកុសលំ ភិក្ខវេ បជហថ សក្កា ភិក្ខវេ អកុសលំ បជហិតុំ នោ ចេ តំ ភិក្ខវេ សក្កា អភវិស្ស អកុសលំ បជហិតុំ នាហំ ឯវំ វទេយ្យំ អកុសលំ ភិក្ខវេ បជហថាតិ យស្មា ច ខោ ភិក្ខវេ សក្កា អកុសលំ បជហិតុំ តស្មាហំ ឯវំ វទាមិ អកុសលំ ភិក្ខវេ បជហថាតិ អកុសលញ្ចហិទំ ភិក្ខវេ បហីនំ អហិតាយ ទុក្ខាយ សំវត្តេយ្យ នាហំ ឯវំ វទេយ្យំ អកុសលំ ភិក្ខវេ បជហថាតិ យស្មា ច ខោ ភិក្ខវេ អកុសលំ បហីនំ ហិតាយ សុខាយ សំវត្តតិ តស្មាហំ ឯវំ វទាមិ អកុសលំ ភិក្ខវេ បជហថាតិ កុសលំ ភិក្ខវេ ភាវេថ សក្កា ភិក្ខវេ កុសលំ ភាវេតុំ នោ ចេតំ ភិក្ខវេ សក្កា អភវិស្ស កុសលំ ភាវេតុំ នាហំ ឯវំ វទេយ្យំ





(២៦៥) ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរលះអកុសលចេញ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គង់អាចនឹងលះអកុសលចេញបាន ម្នាលភិក្ខុទាំងឡាយ ប្រសិនបើអ្នកទាំងឡាយ មិនអាចនឹងលះអកុសលនោះចេញបានទេ តថាគតក៏មិនគប្បីពោលយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរលះអកុសលចេញឡើយ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែអ្នកទាំងឡាយ អាចនឹងលះអកុសលចេញបាន បានជាតថាគតពោលយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរលះអកុសលចេញ ម្នាលភិក្ខុទាំងឡាយ បើអកុសលនេះដែលបុគ្គលលះរួចហើយនៅតែប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខដែល តថាគតក៏មិនគប្បីពោលយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរលះអកុសលចេញឡើយ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែអកុសលដែលបុគ្គលលះរួចហើយ តែងប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ និងសេចក្តីសុខវិញ បានជាតថាគតពោលយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរលះអកុសលចេញ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរចំរើនកុសលចុះ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ អាចនឹងចំរើនកុសលបាន ម្នាលភិក្ខុទាំងឡាយ ប្រសិនបើអ្នកទាំងឡាយ មិនអាចនឹងចំរើនកុសលនុ៎ះបានទេ តថាគតក៏មិនគប្បីពោលយ៉ាងនេះថា

កុសលំ ភិក្ខវេ ភាវេថាតិ យស្មា ច ខោ ភិក្ខវេ សក្កា កុសលំ ភាវេតុំ តស្មាហំ ឯវំ វទាមិ កុសលំ ភិក្ខវេ ភាវេថាតិ កុសលញ្ចហិទំ ភិក្ខវេ ភាវិតំ អហិតាយ ទុក្ខាយ សំវត្តេយ្យ(១) នាហំ ឯវំ វទេយ្យំ(២) កុសលំ ភិក្ខវេ ភាវេថាតិ យស្មា ច ខោ ភិក្ខវេ កុសលំ ភាវិតំ ហិតាយ សុខាយ សំវត្តតិ តស្មាហំ ឯវំ វទាមិ កុសលំ ភិក្ខវេ ភាវេថាតិ ។

(២៦៦) ទ្វេមេ ភិក្ខវេ ធម្មា សទ្ធម្មស្ស សម្មោសាយ អន្តរធានាយ សំវត្តន្តិ ។ កតមេ ទ្វេ ។ ទុន្និក្ខិត្តញ្ច បទព្យញ្ជនំ អត្ថោ ច ទុន្នីតោ ។ ទុន្និក្ខិត្តស្ស ភិក្ខវេ បទព្យញ្ជនស្ស អត្ថោបិ ទុន្នយោ ហោតិ ។ ឥមេ ខោ ភិក្ខវេ ទ្វេ ធម្មា សទ្ធម្មស្ស សម្មោសាយ អន្តរធានាយ សំវត្តន្តិ ។

---

១ ម. សំវត្តតិ ។ ២ ម. នាហំ វទាមិ ។



ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរចំរើនកុសលចុះ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែអ្នកទាំងឡាយអាចនឹងចំរើនកុសលបាន បានជាតថាគតពោលយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរចំរើនកុសលចុះ ម្នាលភិក្ខុទាំងឡាយ បើកុសលនេះដែលបុគ្គលចំរើនហើយ នៅតែប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍នឹងសេចក្តីទុក្ខដែល តថាគតក៏មិនគប្បីពោលយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរចំរើនកុសលឡើយ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែកុសលដែលបុគ្គលចំរើនហើយប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍នឹងសេចក្តីសុខ បានជាតថាគតពោលយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរចំរើនកុសលចុះ ។

(២៦៦) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ ២ ប្រការនេះ តែងប្រព្រឹត្តទៅ ដើម្បីសេចក្តីភាន់ភាំង ដើម្បីសេចក្តីសាបសូន្យនៃព្រះសទ្ធម្ម ធម៌ ២ ប្រការ តើដូចម្តេច ។ គឺបទនិងព្យញ្ជនៈដែលអាចារ្យដាក់ទុកខុស ១ សេចក្តីដែលអាចារ្យនាំមកខុស ១ ម្នាលភិក្ខុទាំងឡាយ បើបទនិងព្យញ្ជនៈ ដែលអាចារ្យដាក់ទុកខុសហើយ ឬសេចក្តីដែលអាចារ្យនាំមកក៏ខុសដែរ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ២ ប្រការនេះ តែងប្រព្រឹត្តទៅ ដើម្បីសេចក្តីភាន់ភាំង ដើម្បីសេចក្តីសាបសូន្យនៃព្រះសទ្ធម្ម ។

ទ្វេមេ ភិក្ខវេ ធម្មា សទ្ធម្មស្ស ឋិតិយា អសម្មោសាយ អនន្តរធានាយ សំវត្តន្តិ ។ កតមេ ទ្វេ ។ សុនិក្ខិត្តញ្ច បទព្យញ្ជនំ អត្ថោ ច សុនីតោ ។ សុនិក្ខិត្តស្ស ភិក្ខវេ បទព្យញ្ជនស្ស អត្ថោបិ សុនយោ ហោតិ ។ ឥមេ ខោ ភិក្ខវេ ទ្វេ ធម្មា សទ្ធម្មស្ស ឋិតិយា អសម្មោសាយ អនន្តរធានាយ សំវត្តន្តីតិ ។

អធិករណវគ្គោ ទុតិយោ ។

[២៦៧] ទ្វេមេ ភិក្ខវេ ពាលា ។ កតមេ ទ្វេ ។ យោ ច អច្ចយំ អច្ចយតោ ន បស្សតិ យោ ច អច្ចយំ ទេសេន្តស្ស យថាធម្មំ ន បដិគ្គណ្ហាតិ ។ ឥមេ ខោ ភិក្ខវេ ទ្វេ ពាលា ។ ទ្វេមេ ភិក្ខវេ បណ្ឌិតា ។ កតមេ ទ្វេ ។ យោ ច អច្ចយំ អច្ចយតោ បស្សតិ យោ ច អច្ចយំ ទេសេន្តស្ស យថាធម្មំ បដិគ្គណ្ហាតិ ។ ឥមេ ខោ ភិក្ខវេ ទ្វេ បណ្ឌិតាតិ ។



ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ២ ប្រការនេះ តែងប្រព្រឹត្តទៅ ដើម្បីឋិតនៅ មិនភ្លាំងភ្លាត់ មិនសាបសូន្យនៃព្រះសទ្ធម្ម ។ ធម៌ ២ ប្រការ តើដូចម្តេច ។ គឺបទនិងព្យញ្ជនៈដែលអាចារ្យដំកល់ទុកត្រូវ ១ សេចក្តីដែលអាចារ្យនាំមកត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ បើបទនិងព្យញ្ជនៈដែលអាចារ្យដំកល់ទុកត្រូវហើយ សូម្បីប្រសេចក្តីដែលអាចារ្យនាំមកក៏ត្រូវដែរ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ២ ប្រការនេះ តែងប្រព្រឹត្តទៅ ដើម្បីឋិតនៅ មិនភ្លាំងភ្លាត់ មិនសាបសូន្យនៃព្រះសទ្ធម្មឡើយ ។

ចប់ អធិករណវគ្គ ទី ២ ។

(២៦៧) ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលនេះមាន ២ ពួក ។ បុគ្គលពាលមាន ២ ពួក តើដូចម្តេច ។ គឺបុគ្គលមិនឃើញទោសតាមទោស ១ បុគ្គលកាលបើគេប្រាប់ទោស ក៏មិនព្រមទទួលទោសតាមធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលមាន ២ ពួកនេះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាបណ្ឌិតនេះមាន ២ ពួក ។ បុគ្គលជាបណ្ឌិតមាន ២ ពួក តើដូចម្តេច ។ គឺបុគ្គលឃើញទោសតាមទោស ១ បុគ្គលកាលបើគេប្រាប់ទោស ក៏ព្រមទទួលទោសតាមធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាបណ្ឌិតមាន ២ ពួកនេះឯង ។

(២៦៨) ទ្វេមេ ភិក្ខវេ តថាគតំ អព្ភាចិក្ខន្តិ ។ កតមេ ទ្វេ ។ ទុដ្ឋោ វា ទោសន្តរោ សទ្ធោ វា ទុគ្គហិតេន ។ ឥមេ ខោ ភិក្ខវេ ទ្វេ តថាគតំ អព្ភាចិក្ខន្តីតិ ។

(២៦៩) ទ្វេមេ ភិក្ខវេ តថាគតំ អព្ភាចិក្ខន្តិ ។ កតមេ ទ្វេ ។ យោ ច អភាសិតំ អលបិតំ តថាគតេន ភាសិតំ លបិតំ តថាគតេនាតិ ទីបេតិ យោ ច ភាសិតំ លបិតំ តថាគតេន អភាសិតំ អលបិតំ តថាគតេនាតិ ទីបេតិ ។ ឥមេ ខោ ភិក្ខវេ ទ្វេ តថាគតំ អព្ភាចិក្ខន្តិ ។ ទ្វេមេ ភិក្ខវេ តថាគតំ នាព្ភាចិក្ខន្តិ ។ កតមេ ទ្វេ ។



(២៦៨) ម្នាលភិក្ខុទាំងឡាយ បុគ្គល ២ ពួកនេះតែងពោលបង្កាច់ព្រះតថាគត ។ បុគ្គល ២ ពួក តើដូចម្ដេច ។ គឺបុគ្គលជាអ្នកក្រោធមានទោសចិត្តនៅខាង(១)ក្នុង ១ បុគ្គលជាអ្នកជឿដោយប្រកាន់(២)ខុស ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ២ ពួកនេះ តែងពោលបង្កាច់ព្រះតថាគត ។

(២៦៩) ម្នាលភិក្ខុទាំងឡាយ បុគ្គល ២ ពួកនេះតែងពោលបង្កាច់ព្រះតថាគត ។ បុគ្គល ២ ពួក តើដូចម្ដេច ។ គឺបុគ្គលសំដែងនូវពាក្យដែលព្រះតថាគតមិនបានសំដែង មិនបានពោល ថាជាពាក្យដែលព្រះតថាគតបានសំដែង បានពោល ១ បុគ្គលសំដែងនូវពាក្យ ដែលព្រះតថាគតបានសំដែង បានពោល ថាជាពាក្យដែលព្រះតថាគតមិនបានសំដែង មិនបានពោល ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល២ពួកនេះ តែងពោលបង្កាច់ព្រះតថាគត ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ២ ពួកនេះ មិនពោលបង្កាច់ព្រះតថាគតទេ ។ បុគ្គល ២ ពួក តើដូចម្ដេច ។

---

១ បានដល់បុគ្គលដែលមានទោសចិត្តជានិច្ច បុគ្គលនេះតែងពោលទោសថា ព្រះសមណគោតមលោកមិនមានធម៌ដ៏ប្រសើរជាងធម៌របស់មនុស្សទេ តែងពោលបង្កាច់ព្រះអង្គ ដូចសុនក្ខត្តលិច្ឆវី ។

២– បានដល់បុគ្គលអប្បឥតបញ្ញា មានតែសទ្ធាគ្រាល សេចក្ដីជ្រះថ្លាតិច តែងជឿថា ព្រះពុទ្ធព្រះអង្គជាលោកុត្តរទាំងអស់ សូម្បីអាការៈទាំង ៣២ មានសក់ជាដើមរបស់ព្រះអង្គ ក៏ជាលោកុត្តរដែរ ដូច្នេះឈ្មោះថា ពោលបង្កាច់ព្រះអង្គដែរ ។ (អដ្ឋកថា) ។

យោ ច អភាសិតំ អលបិតំ តថាគតេន អភាសិតំ អលបិតំ តថាគតេនាតិ ទីបេតិ យោ ច ភាសិតំ លបិតំ តថាគតេន ភាសិតំ លបិតំ តថាគតេនាតិ ទីបេតិ ។ ឥមេ ខោ ភិក្ខវេ ទ្វេ តថាគតំ នាព្ភាចិក្ខន្តីតិ ។

(២៧០) ទ្វេមេ ភិក្ខវេ តថាគតំ អព្ភាចិក្ខន្តិ ។ កតមេ ទ្វេ ។ យោ ច នេយ្យត្ថំ សុត្តន្តំ នីតត្ថោ សុត្តន្តោតិ ទីបេតិ យោ ច នីតត្ថំ សុត្តន្តំ នេយ្យត្ថោ សុត្តន្តោតិ ទីបេតិ ។ ឥមេ ខោ ភិក្ខវេ ទ្វេ តថាគតំ អព្ភាចិក្ខន្តិ ។ ទ្វេមេ ភិក្ខវេ តថាគតំ នាព្ភាចិក្ខន្តិ ។ កតមេ ទ្វេ ។



គឺបុគ្គលសំដែងនូវពាក្យដែលព្រះតថាគត មិនបានសំដែង មិនបានពោល ថាជាពាក្យដែលព្រះតថាគត មិនបានសំដែង មិនបានពោល ១ បុគ្គលសំដែងនូវពាក្យដែលព្រះតថាគត បានសំដែង បានពោល ថាជាពាក្យដែលព្រះតថាគត បានសំដែង បានពោល ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ២ ពួកនេះឯង មិនពោលបង្កាច់ព្រះតថាគតឡើយ ។

(២៧០) ម្នាលភិក្ខុទាំងឡាយ បុគ្គល ២ ពួកនេះ តែងពោលបង្កាច់ព្រះតថាគត ។ បុគ្គលទាំង ២ ពួក តើដូចម្តេច ។ គឺបុគ្គលដែលសំដែងសូត្រមានសេចក្តីជាបុគ្គលាធិដ្ឋាន(១) ថាជាសូត្រមានសេចក្តីជាធម្មាធិដ្ឋានទៅវិញ ១ ដែលសំដែងសូត្រមានសេចក្តីជាធម្មាធិដ្ឋាន(២) ថាជាសូត្រមានសេចក្តីជាបុគ្គលាធិដ្ឋានទៅវិញ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ២ ពួកនេះ តែងពោលបង្កាច់ព្រះតថាគត ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ២ ពួកនេះ មិនពោលបង្កាច់ព្រះតថាគតទេ ។ បុគ្គល ២ ពួក តើដូចម្តេច ។

---

១- បានដល់ព្រះសូត្រដែលសំដែងបុគ្គលាធិដ្ឋាន គឺបទទ្រង់សំដែងថា ម្នាលភិក្ខុទាំងឡាយ បុគ្គលពួក ១ បុគ្គលពួក ២ បុគ្គលពួក ៣ បុគ្គលពួក ៤ ជាដើម ហៅថា ព្រះសូត្រជានេយ្យត្ថ ។

២- បានដល់ព្រះសូត្រដែលសំដែងជាធម្មាធិដ្ឋាន គឺបទសំដែងថា អនិច្ចំ ទុក្ខំ អនត្តា ជាដើមហៅថា ព្រះសូត្រជានីតត្ថ (អដ្ឋកថា) ។

យោ ច នេយ្យត្ថំ សុត្តន្តំ នេយ្យត្ថោ សុត្តន្តោតិ ទីបេតិ យោ ច នីតត្ថំ សុត្តន្តំ នីតត្ថោ សុត្តន្តោតិ ទីបេតិ ។ ឥមេ ខោ ភិក្ខវេ ទ្វេ តថាគតំ នាព្ភាចិក្ខន្តីតិ ។

(២៧៥) បដិច្ឆន្នកម្មន្តស្ស ភិក្ខវេ ទ្វិន្នំ គតីនំ អញ្ញតរា គតិ បាដិកង្ខា និរយោ វា តិរច្ឆានយោនិ វា ។ អប្បដិច្ឆន្នកម្មន្តស្ស ភិក្ខវេ ទ្វិន្នំ គតីនំ អញ្ញតរា គតិ បាដិកង្ខា ទេវា វា មនុស្សា វាតិ ។

(២៧៦) មិច្ឆាទិដ្ឋិកស្ស ភិក្ខវេ ទ្វិន្នំ គតីនំ អញ្ញតរា គតិ បាដិកង្ខា និរយោ វា តិរច្ឆានយោនិ វា ។ សម្មាទិដ្ឋិកស្ស ភិក្ខវេ ទ្វិន្នំ គតីនំ អញ្ញតរា គតិ បាដិកង្ខា ទេវា វា មនុស្សា វាតិ ។

(២៧៧) ទុស្សីលស្ស ភិក្ខវេ ទ្វេ បដិគ្គហា និរយោ វា តិរច្ឆានយោនិ វា ។ សីលវតោ ភិក្ខវេ ទ្វេ បដិគ្គហា ទេវា វា មនុស្សា វាតិ ។



និងបុគ្គលសំដែងសូត្រមានសេចក្តីជាបុគ្គលនាំចេញ ថាជាសូត្រមានសេចក្តីជាបុគ្គលនាំចេញ ១ បុគ្គលសំដែងសូត្រមានសេចក្តីជាធម្មជាតិនាំចេញ ថាជាសូត្រមានសេចក្តីជាធម្មជាតិនាំចេញ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ២ ពួកនេះ មិនពោលបង្កាច់ព្រះតថាគតឡើយ ។

(២៧៥) ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអ្នកបិទបាំងនូវបាបកម្ម នឹងបាននូវគតិ(១)ពីរយ៉ាង គតិណាមួយគឺនរក ឬកំណើតតិរច្ឆានពុំលែងឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាអ្នកមិនបិទបាំងនូវបាបកម្ម នឹងបាននូវគតិពីរយ៉ាង គតិណាមួយគឺទេវតា ឬមនុស្សពុំលែងឡើយ ។

(២៧៦) ម្នាលភិក្ខុទាំងឡាយ បុគ្គលជាមិច្ឆាទិដ្ឋិ នឹងបាននូវគតិពីរយ៉ាង គតិណាមួយគឺនរក ឬកំណើតតិរច្ឆានពុំខានឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាសម្មាទិដ្ឋិ នឹងបាននូវគតិពីរយ៉ាង គតិណាមួយគឺទេវតា ឬមនុស្សពុំខានឡើយ ។

(២៧៧) ម្នាលភិក្ខុទាំងឡាយ បុគ្គលទ្រុស្តសីល រមែងទទួលឋាន ២ ប្រការ គឺ នរក ១ កំណើតតិរច្ឆាន ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកមានសីល រមែងទទួលឋាន ២ ប្រការគឺទេវតា ១ មនុស្ស ១ ។

---
១ គឺកំណើតទៅកាន់ ។

(២៧៦) ទ្វេមេ ភិក្ខវេ អត្ថវសេ សម្បស្សមានោ អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវាមិ ។ កតមេ ទ្វេ ។ អត្តនោ ច ទិដ្ឋធម្មសុខវិហារំ សម្បស្សមានោ បច្ឆិមញ្ច ជនតំ អនុកម្បមានោ ។ ឥមេ ខោ អហំ ភិក្ខវេ ទ្វេ អត្ថវសេ សម្បស្សមានោ អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវាមីតិ ។

(២៧៧) ទ្វេមេ ភិក្ខវេ ធម្មា វិជ្ជាភាគិយា ។ កតមេ ទ្វេ ។ សមថោ ច វិបស្សនា ច ។ សមថោ ភិក្ខវេ ភាវិតោ កិមត្ថមនុភោតិ (១) ។ ចិត្តំ ភាវីយតិ ។ ចិត្តំ ភាវិតំ កិមត្ថមនុភោតិ ។ យោ រាគោ សោ បហីយតិ ។ វិបស្សនា ភិក្ខវេ ភាវិតា កិមត្ថមនុភោតិ ។ បញ្ញា ភាវីយតិ ។ បញ្ញា ភាវិតា កិមត្ថមនុភោតិ ។ យា អវិជ្ជា សា បហីយតីតិ ។

---

១ ឱ. កមត្ថមនុភោតិ ។ ម. កិមត្ថមនុភោតិ ។



(២៧៦) ម្នាលភិក្ខុទាំងឡាយ តថាគតពិចារណាឃើញអំណាចប្រយោជន៍ពីរប្រការ ទើបគប់រកនូវសេនាសនៈស្ងាត់ គឺដីនៅក្នុងព្រៃ ។ អំណាចប្រយោជន៍ ២ ប្រការ តើដូចម្តេច ។ គឺតថាគតពិចារណាឃើញធម៌ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្នរបស់ខ្លួន ១ មានសេចក្តីអនុគ្រោះប្រជុំជនជាន់ក្រោយ ១ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពិចារណាឃើញអំណាចប្រយោជន៍ពីរប្រការនេះ ទើបគប់រកនូវសេនាសនៈស្ងាត់ គឺដីនៅក្នុងព្រៃ ។

(២៧៧) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយពីរប្រការនេះ ជាចំណែកនៃវិជ្ជា ។ ធម៌ពីរប្រការ តើដូចម្តេច ។ គឺសមថៈ ១ វិបស្សនា ១ ។ ម្នាលភិក្ខុទាំងឡាយ សមថៈដែលបុគ្គលចំរើនហើយ នឹងសម្រេចប្រយោជន៍អ្វី ។ នឹងញុំាងចិត្តឲ្យចំរើន ។ ចិត្តដែលចំរើនហើយ នឹងសម្រេចប្រយោជន៍អ្វី ។ នឹងលះបង់នូវរាគៈចេញបាន ។ ម្នាលភិក្ខុទាំងឡាយ វិបស្សនាដែលបុគ្គលចំរើនហើយ នឹងសម្រេចប្រយោជន៍អ្វី ។ នឹងញុំាងបញ្ញាឲ្យចំរើន ។ បញ្ញាដែលចំរើនហើយ នឹងសម្រេចប្រយោជន៍អ្វី ។ នឹងលះនូវអវិជ្ជាចេញបាន

(២៧៦) រាគូបក្កិលិដ្ឋំ វា ភិក្ខវេ ចិត្តំ ន វិមុច្ចតិ អវិជ្ជូបក្កិលិដ្ឋា វា បញ្ញា ន ភាវិយតិ ។ ឥតិ ខោ (១) ភិក្ខវេ រាគវិរាគា ចេតោវិមុត្តិ អវិជ្ជាវិរាគា បញ្ញាវិមុត្តីតិ ។

ពាលវគ្គោ តតិយោ ។

(២៧៧) អសប្បុរិសភូមិញ្ច វោ ភិក្ខវេ ទេសេស្សាមិ សប្បុរិសភូមិញ្ច តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវម្ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច កតមា ច ភិក្ខវេ អសប្បុរិសភូមិ ។ អសប្បុរិសោ ភិក្ខវេ អកតញ្ញូ ហោតិ អកតវេទី អសព្ភិ ហេតំ ភិក្ខវេ ឧបញ្ញាតំ យទិទំ អកតញ្ញុតា អកតវេទិតា ។ កេវលា(២) ឯសា ភិក្ខវេ អសប្បុរិសភូមិ យទិទំ អកតញ្ញុតា អកតវេទិតា ។

---

១ ។ ឱ. ម. ។ ២ ម. កេវលំ ។



(២៧៦) ម្នាលភិក្ខុទាំងឡាយ ចិត្តដែលសៅហ្មងដោយរាគៈហើយ រមែងមិនរួចផុតស្រឡះ ឬបញ្ញាដែលសៅហ្មងដោយអវិជ្ជាហើយ រមែងមិនចំរើនឡើយ ។ ម្នាលភិក្ខុទាំងឡាយ ចេតោវិមុត្តិកើត ព្រោះប្រាសចាករាគៈ បញ្ញាវិមុត្តិកើត ព្រោះប្រាសចាកអវិជ្ជា ដោយប្រការដូច្នេះ ។

ចប់ ពាលវគ្គ ទី ៣ ។

(២៧៧) ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងប្រាប់នូវអសប្បុរិសភូមិ ១ សប្បុរិសភូមិ ១ ដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរស្តាប់នូវភូមិទាំងពីរនោះ ចូរប្រុងចិត្តឲ្យប្រពៃ តថាគតនឹងសំដែង ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកា របស់ព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ អសប្បុរិសភូមិ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អសប្បុរស រមែងមិនដឹងឧបការៈដែលគេធ្វើហើយ(ដល់ខ្លួន) ទាំងមិនធ្វើឧបការៈដែលគេធ្វើហើយឲ្យប្រាកដឡើង ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងពីរនេះ ដែលពួកអសប្បុរស បានពោលសរសើរហើយ គឺការមិនដឹងឧបការៈដែលគេធ្វើហើយ ១ មិនធ្វើឧបការៈដែលគេធ្វើហើយឲ្យប្រាកដឡើង ១ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងពីរនេះ សុទ្ធតែជាអសប្បុរិសភូមិទាំងអស់ គឺការមិនដឹងឧបការៈដែលគេធ្វើហើយ ១ មិនធ្វើឧបការៈដែលគេធ្វើហើយឲ្យប្រាកដឡើង ១ ។

សប្បុរិសោ ច ខោ ភិក្ខវេ កតញ្ញូ ហោតិ កតវេទី សតំ ហេតំ ភិក្ខវេ ឧបញ្ញាតំ យទិទំ កតញ្ញុតា កតវេទិតា កេវលា ឯសា ភិក្ខវេ សប្បុរិសភូមិ យទិទំ កតញ្ញុតា កតវេទិតាតិ ។

(២៧៨) ទ្វិន្នាហំ ភិក្ខវេ ន សុប្បដិការំ វទាមិ ។ កតមេសំ ទ្វិន្នំ ។ មាតុ ច បិតុ ច ។ ឯកេន ភិក្ខវេ អំសេន មាតរំ បរិហរេយ្យ ឯកេន អំសេន បិតរំ បរិហរេយ្យ វស្សសតាយុកោ វស្សសតជីវី សោ ច នេសំ ឧច្ឆាទនបរិមទ្ទន-ន្ហាបនសម្ពាហនេន បដិជគ្គេយ្យ តេ ច តត្ថេវ មុត្តករីសំ ចជេយ្យុំ ន ត្វេវ ភិក្ខវេ មាតាបិតូនំ កតំ វា ហោតិ បដិកតំ វា ។ ឥមិស្សា ច ភិក្ខវេ មហាបថវិយា បហូតសត្តរតនាយ មាតាបិតរោ ឥស្សរាធិបច្ចេ រជ្ជេ បតិដ្ឋាបេយ្យ ន ត្វេវ ភិក្ខវេ



ម្នាលភិក្ខុទាំងឡាយ ឯសប្បុរសរមែងដឹងឧបការៈដែលគេធ្វើហើយ ដឹងធ្វើឧបការៈដែលគេធ្វើហើយឲ្យប្រាកដឡើង ម្នាលភិក្ខុទាំងឡាយ គតិតាំងពីដើមនេះដែលពួកសប្បុរសបានពោលសរសើរហើយ គឺការដឹងឧបការៈដែលគេធ្វើហើយ១ ធ្វើឧបការៈដែលគេធ្វើហើយឲ្យប្រាកដឡើង១ ។ ម្នាលភិក្ខុទាំងឡាយ គតិតាំងពីដើមនេះ សុទ្ធតែជាសប្បុរសភូមិទាំងអស់ គឺការដឹងឧប-ការៈដែលគេធ្វើហើយ១ ធ្វើឧបការៈដែលគេធ្វើហើយឲ្យប្រាកដឡើង១ ។

(២៧៨) ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលមិនងាយនឹងធ្វើការតបគុណដល់បុគ្គលពីរពួកបានទេ ។ បុគ្គលពីរពួកតើពួកណាខ្លះ ។ គឺ មាតា១ បិតា១ ។ ម្នាលភិក្ខុទាំងឡាយ កុលបុត្តមានអាយុ ១០០ ឆ្នាំរស់នៅអស់កាលដ៏ ១០០ ឆ្នាំ គប្បីបញ្ជិះមាតាដោយស្មាម្ខាង បញ្ជិះបិតាដោយស្មាម្ខាង កុលបុត្តនោះបម្រើមាតាបិតាទាំងពីរនោះ ដោយការដុសលាបប្រេងច្របាច់ខ្លួនក្រសោបគ្រែខ្លួនដែលងូតទឹកកក់ច្របាច់ដៃជើង ឯមាតាបិតាទាំងពីរនោះក៏បន្ទោបង់មូត្រគូថលើស្មាកុលបុត្តនោះឯង ម្នាលភិក្ខុទាំងឡាយ (ហេតុមានប្រមាណប៉ុណ្ណេះ) គង់មិនទាន់ហៅថាធ្វើ ឬ ថាធ្វើតបដល់មាតានិងបិតាឡើយ ។ ម្នាលភិក្ខុទាំងឡាយ កុលបុត្តគប្បីតាំងមាតានិងបិតាឲ្យតាំងនៅក្នុងឥស្សរិយសម្បត្តិ មានឥស្សរភាពជាអធិបតី លើផែនដីធំ ដែលមានកែវទាំង ៧ ប្រការច្រើនលើស ម្នាលភិក្ខុទាំងឡាយ

មាតាបិតូនំ កតំ វា ហោតិ បដិកតំ វា ។ តំ កិស្ស ហេតុ ។ ពហុការា ភិក្ខវេ មាតាបិតរោ បុត្តានំ អាបាទកា បោសកា ឥមស្ស លោកស្ស ទស្សេតារោ ។ យោ ច ខោ ភិក្ខវេ មាតាបិតរោ អស្សទ្ធេ សទ្ធាសម្បទាយ សមាទបេតិ និវេសេតិ បតិដ្ឋាបេតិ ទុស្សីលេ សីលសម្បទាយ សមាទបេតិ និវេសេតិ បតិដ្ឋាបេតិ មច្ឆរី ចាគសម្បទាយ សមាទបេតិ និវេសេតិ បតិដ្ឋាបេតិ ទុប្បញ្ញេ បញ្ញាសម្បទាយ សមាទបេតិ និវេសេតិ បតិដ្ឋាបេតិ ឯត្តាវតា ខោ ភិក្ខវេ មាតាបិតូនំ កតញ្ច ហោតិ បដិកតញ្ចាតិ ។

(២៧៨) អថ ខោ អញ្ញតរោ ព្រាហ្មណោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោ ព្រាហ្មណោ ភគវន្តំ ឯតទវោច កិំវាទី ភវំ គោតមោ កិមក្ខាយីតិ ។



(ហេតុមានប្រមាណប៉ុណ្ណេះ) គង់មិនមែនហៅថា ធ្វើឲ្យ ឬធ្វើតបដល់មាតាបិតាឡើយ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថាមាតាបិតា មានឧបការៈច្រើនដល់បុត្រទាំងឡាយ ព្រោះជាអ្នកថែរក្សាចិញ្ចឹមបង្ហាញនូវលោកនេះ ។ ម្នាលភិក្ខុទាំងឡាយ (ឯ) បុគ្គលណាមួយ ដឹកនាំមាតាបិតា ដែលមិនមានសទ្ធា ឲ្យកាន់យក ឲ្យអាស្រ័យនៅ ឲ្យតាំងនៅក្នុងសទ្ធាសម្បទា ដែលទ្រុស្តសីល ឲ្យកាន់យក ឲ្យអាស្រ័យនៅ ឲ្យតាំងនៅក្នុងសីលសម្បទា ដែលកំណាញ់ ឲ្យកាន់យក ឲ្យអាស្រ័យនៅ ឲ្យតាំងនៅក្នុងចាគសម្បទា ដែលឥតបញ្ញា ឲ្យកាន់យក ឲ្យអាស្រ័យនៅ ឲ្យតាំងនៅក្នុងបញ្ញាសម្បទា ម្នាលភិក្ខុទាំងឡាយ ហេតុមានប្រមាណប៉ុណ្ណេះ ទើបហៅថា ធ្វើឲ្យ ឬធ្វើតបដល់មាតាបិតាបាន ។

(២៧៨) គ្រានោះ មានព្រាហ្មណ៍ម្នាក់ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយនឹងព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យគួរជាទីរីករាយ និងពាក្យគួររឭកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះព្រាហ្មណ៍នោះ អង្គុយក្នុងទីដ៏សមគួរហើយ ទើបក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា ព្រះគោតមដ៏ចម្រើន ព្រះអង្គមានលទ្ធិដូចម្តេច ទ្រង់សំដែងសេចក្តីប្រាកដដូចម្តេច ?

កិរិយវាទី ចាហំ ព្រាហ្មណ អកិរិយវាទី ចាតិ ។ យថាកថំ បន ភវំ គោតមោ កិរិយវាទី ច អកិរិយវាទី ចាតិ ។ អកិរិយំ ខោ អហំ ព្រាហ្មណ វទាមិ កាយទុច្ចរិតស្ស វចីទុច្ចរិតស្ស មនោទុច្ចរិតស្ស អនេកវិហិតានំ បាបកានំ អកុសលានំ ធម្មានំ អកិរិយំ វទាមិ ។ កិរិយញ្ច ខោ អហំ ព្រាហ្មណ វទាមិ កាយសុចរិតស្ស វចីសុចរិតស្ស មនោសុចរិតស្ស អនេកវិហិតានំ កុសលានំ ធម្មានំ កិរិយំ វទាមិ ។ ឯវំ ខោ អហំ ព្រាហ្មណ កិរិយវាទី ច អកិរិយវាទី ចាតិ ។ អភិក្កន្តំ ភោ គោតម ។ បេ ។ ឧបាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតន្តិ ។



ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ តថាគតសំដែងថា អំពើដែលបុគ្គលគួរធ្វើក៏មាន ថា មិនគួរធ្វើក៏មាន ។ ចុះព្រះគោតមដ៏ចំរើនទ្រង់សំដែងថា អំពើគួរធ្វើក៏មាន ថា អំពើមិនគួរធ្វើក៏មានតើ ដូចម្តេច ។ ម្នាលព្រាហ្មណ៍ តថាគតពោលថា កាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត ជាអំពើមិនគួរធ្វើ ពោលនូវអកុសលធម៌ទាំងឡាយដ៏លាមកជាច្រើនប្រការ ថាជាអំពើមិនគួរធ្វើផង ។ មួយទៀត ម្នាលព្រាហ្មណ៍ តថាគតពោលនូវកាយសុចរិត វចីសុចរិត មនោសុចរិត ថាជាអំពើគួរធ្វើ ពោលនូវកុសលធម៌ទាំងឡាយច្រើនប្រការ ថាជាអំពើគួរធ្វើផង ។ ម្នាលព្រាហ្មណ៍ តថាគតជាអ្នកសំដែងថា អំពើគួរធ្វើក៏មាន ថា អំពើមិនគួរធ្វើក៏មាន យ៉ាងនេះ ។ បពិត្រព្រះគោតមដ៏ចំរើន ភ្លឺណាស់ ។ បេ ។ សូមព្រះគោតមដ៏ចំរើន ទ្រង់ចាំទុកនូវខ្ញុំព្រះអង្គថា ជាឧបាសក អ្នកដល់នូវសរណគមន៍ស្មើដោយជីវិត តាំងពីថ្ងៃនេះជាដើមរៀងទៅ ។

[២៥០] អថ ខោ អនាថបិណ្ឌិកោ គហបតិ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អនាថបិណ្ឌិកោ គហបតិ ភគវន្តំ ឯតទវោច កតិ នុ ខោ ភន្តេ លោកេ ទក្ខិណេយ្យា កត្ថ ច ទានំ ទាតព្វន្តិ ។ ទ្វេ ខោ គហបតិ លោកេ ទក្ខិណេយ្យា សេក្ខោ ច អសេក្ខោ ច ។ ឥមេ ខោ គហបតិ ទ្វេ លោកេ ទក្ខិណេយ្យា ឯត្ថ ច ទានំ ទាតព្វន្តិ ។ ឥទមវោច ភគវា ឥទំ វត្វាន សុគតោ អថាបរំ ឯតទវោច សត្ថា

សេក្ខោ ច អសេក្ខោ ច ឥមស្មឹ លោកេ
អាហុនេយ្យា យជមានានំ ហោន្តិ
តេ ឧជ្ជុភូតា កាយេន វាចាយ ឧទ ចេតសា
ខេត្តំ យជមានានំ ឯត្ថ ទិន្នំ មហប្ផលន្តិ ។



[២៥០] គ្រានោះ អនាថបិណ្ឌិកគហបតី ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះអនាថបិណ្ឌិកគហបតី អង្គុយក្នុងទីដ៏សមគួរហើយ ទើបក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ទក្ខិណេយ្យបុគ្គលក្នុងលោកមានប៉ុន្មានពួក មួយទៀត បុគ្គលគួរឲ្យទានក្នុងបុគ្គលដូចម្ដេច ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលគហបតី ទក្ខិណេយ្យបុគ្គលក្នុងលោកមាន ២ ពួក គឺសេក្ខបុគ្គល ១ អសេក្ខបុគ្គល ១ ។ ម្នាលគហបតី ទក្ខិណេយ្យបុគ្គល ក្នុងលោកមាន ២ ពួកនេះ មួយវិញទៀត បុគ្គលគួរឲ្យទានក្នុងបុគ្គលពួកនេះ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ពុទ្ធដីកានេះ លុះព្រះសុគតជាសាស្ដា ទ្រង់មានព្រះតម្រាស់ដូច្នេះហើយ ក៏ទ្រង់ពោលពាក្យដូច្នេះទៀតថា

សេក្ខបុគ្គលក្តី អសេក្ខបុគ្គលក្តី ជាបុគ្គលគួរទទួលទានរបស់
អ្នកឲ្យទាន ក្នុងលោកនេះ បុគ្គលទាំងនោះជាអ្នកប្រតិបត្តិ
ត្រង់ដោយ កាយ វាចាចិត្ត ជាស្រែបុណ្យដ៏ប្រសើរ របស់
អ្នកឲ្យទាន ឯទានដែលបុគ្គលឲ្យហើយចំពោះបុគ្គលពួកនេះ
ជាទានមានផលច្រើន ។

[២៨១] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អាយស្មា សារីបុត្តោ សាវត្ថិយំ វិហរតិ បុព្វារាមេ មិគារមាតុបាសាទេ ។ តត្រ ខោ អាយស្មា សារីបុត្តោ ភិក្ខូ អាមន្តេសិ អាវុសោ ភិក្ខវោតិ ។ អាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ សារីបុត្តស្ស បច្ចស្សោសុំ ។ អាយស្មា សារីបុត្តោ ឯតទវោច អជ្ឈត្តសញ្ញោជនញ្ច អាវុសោ បុគ្គលំ ទេសេស្សាមិ ពហិទ្ធាសញ្ញោជនញ្ច តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ អាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ សារីបុត្តស្ស បច្ចស្សោសុំ ។ អាយស្មា សារីបុត្តោ ឯតទវោច កតមោ ចាវុសោ អជ្ឈត្តសញ្ញោជនោ បុគ្គលោ ។ ឥធាវុសោ ភិក្ខុ សីលវា ហោតិ បាតិមោក្ខសំវរសំវុតោ វិហរតិ អាចារគោចរសម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខតិ សិក្ខាបទេសុ



[២៨១] សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅ ក្នុងវត្តអារាមរបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ព្រះសារីបុត្តមានអាយុ គង់នៅក្នុងប្រាសាទរបស់មិគារមាតា ក្នុងបុព្វារាម ទៀបក្រុងសាវត្ថីដែរ ។ ក្នុងទីនោះ ព្រះសារីបុត្តដ៏មានអាយុ ហៅពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយដ៏មានអាយុ ។ ពួកភិក្ខុទាំងនោះ ទទួលតបពាក្យរបស់ព្រះសារីបុត្តមានអាយុថា ករុណាអាវុសោ ។ ទើបព្រះសារីបុត្តមានអាយុ ពោលថាដូច្នេះថា ម្នាលអាវុសោ ខ្ញុំនឹងសំដែងនូវបុគ្គលដែលមានសញ្ញោជនៈខាងក្នុងផង នូវបុគ្គលដែលមានសញ្ញោជនៈខាងក្រៅផង អ្នកទាំងឡាយចូរចាំស្តាប់នូវបុគ្គលនោះ ចូរប្រុងស្មារតីឲ្យប្រពៃចុះ ខ្ញុំនឹងសំដែង ។ ភិក្ខុទាំងនោះ ទទួលតបពាក្យរបស់ព្រះសារីបុត្តមានអាយុថា ករុណាអាវុសោ ។ ព្រះសារីបុត្តមានអាយុ បានសំដែងដូច្នេះថា ម្នាលអាវុសោ បុគ្គលដែលមានសញ្ញោជនៈខាងក្នុងតើដូចម្តេច ។ ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីលសង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈ និងគោចរៈ ឃើញភ័យចំពោះទោសតិចតួច សមាទានសិក្សា ក្នុងសិក្ខាបទទាំងឡាយ

សោ កាយស្ស ភេទា បរម្មរណា អញ្ញតរំ ទេវនិកាយំ ឧបបជ្ជតិ សោ តតោ ចុតោ អាគាមី ហោតិ អាគន្តា ឥត្ថត្តំ អយំ វុច្ចតាវុសោ អជ្ឈត្តសញ្ញោជនោ បុគ្គលោ អាគាមី អាគន្តា ឥត្ថត្តំ ។ កតមោ ចាវុសោ ពហិទ្ធាសញ្ញោជនោ បុគ្គលោ ។ ឥធាវុសោ ភិក្ខុ សីលវា ហោតិ បាតិមោក្ខសំវរសំវុតោ វិហរតិ អាចារគោចរសម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខតិ សិក្ខាបទេសុ សោ អញ្ញតរំ សន្តំ ចេតោវិមុត្តិំ ឧបសម្បជ្ជ វិហរតិ សោ កាយស្ស ភេទា បរម្មរណា អញ្ញតរំ ទេវនិកាយំ ឧបបជ្ជតិ ។ សោ តតោ ចុតោ អនាគាមី ហោតិ អនាគន្តា ឥត្ថត្តំ ។ អយំ វុច្ចតាវុសោ ពហិទ្ធាសញ្ញោជនោ បុគ្គលោ អនាគាមី អនាគន្តា ឥត្ថត្តំ ។ បុន ចបរំ អាវុសោ



លុះភិក្ខុនោះទំលាយរាងកាយបន្ទាប់អំពីមរណៈ ទៅកើតក្នុងទេវនិកាយណាមួយ (កាមាវចរទេវលោក) លុះភិក្ខុនោះ ច្យុតចាកទេវនិកាយនោះហើយ រមែងមានដំណើរមកកាន់មនុស្សលោកនេះម្ដងទៀត ម្នាលអាវុសោ នេះហៅថាបុគ្គលមានសញ្ញោជនៈខាងក្នុង រមែងមានដំណើរមកកាន់មនុស្សលោកនេះ ។ ម្នាលអាវុសោ ចុះបុគ្គលមានសញ្ញោជនៈខាងក្រៅ តើដូចម្ដេច ។ ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល សង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈ និងគោចរៈ ឃើញភ័យចំពោះទោសតិចតួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ភិក្ខុនោះបានចូលកាន់ចេតោវិមុត្តិ ដែលជាធម្មជាតិស្ងប់ចាកកិលេសណាមួយ សម្រេចសម្រាន្តនៅ លុះភិក្ខុនោះទំលាយរាងកាយបន្ទាប់អំពីមរណៈ ទៅកើតក្នុងទេវនិកាយណាមួយ (សុទ្ធាវាស ៥ ជាន់ណាមួយ) លុះភិក្ខុនោះច្យុតអំពីទេវនិកាយនោះ ជាអ្នកមិនមានដំណើរមកកាន់កាមភពនេះ (ទៀតឡើយ) ម្នាលអាវុសោ នេះហៅថាបុគ្គលមានសញ្ញោជនៈខាងក្រៅ ជាអ្នកមិនមានដំណើរមកកាន់កាមភពនេះទៀតឡើយ ។ ម្នាលអាវុសោ ហេតុដទៃនៅមានទៀត

ភិក្ខុ សីលវា ហោតិ បាតិមោក្ខសំវរសំវុតោ វិហរតិ អាចារគោចរសម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខតិ សិក្ខាបទេសុ សោ កាមានំយេវ និព្វិទាយ វិរាគាយ និរោធាយ បដិបន្នោ ហោតិ សោ ភវានំយេវ និព្វិទាយ វិរាគាយ និរោធាយ បដិបន្នោ ហោតិ សោ តណ្ហាក្ខយាយ បដិបន្នោ ហោតិ សោ លោភក្ខយាយ បដិបន្នោ ហោតិ សោ កាយស្ស ភេទា បរម្មរណា អញ្ញតរំ ទេវនិកាយំ ឧបបជ្ជតិ សោ តតោ ចុតោ អនាគាមី ហោតិ អនាគន្តា ឥត្ថត្តំ អយំ វុច្ចតាវុសោ ពហិទ្ធាសញ្ញោជនោ បុគ្គលោ អនាគាមី អនាគន្តា ឥត្ថត្តន្តិ ។

អថ ខោ សម្ពហុលា សមចិត្តា ទេវតា យេន ភគវា តេនុបសង្កមិំសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋំសុ ។ ឯកមន្តំ ឋិតា ខោ តា ទេវតា ភគវន្តំ ឯតទវោចុំ



ភិក្ខុជាអ្នកមានសីលសង្រួម ក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈ និងគោចរៈ ឃើញភ័យក្នុងទោសតិចតួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ភិក្ខុនោះប្រតិបត្តិដើម្បីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីរលត់ទៅនៃកាមទាំងឡាយ ភិក្ខុនោះប្រតិបត្តិដើម្បីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីរលត់ទៅនៃភពទាំងឡាយ ភិក្ខុនោះប្រតិបត្តិ ដើម្បីអស់ទៅនៃតណ្ហា ភិក្ខុនោះប្រតិបត្តិ ដើម្បីអស់ទៅនៃលោភៈ លុះភិក្ខុនោះទំលាយរាងកាយខាងមុខអំពីមរណៈទៅ ក៏កើតក្នុងទេវនិកាយណាមួយ លុះភិក្ខុនោះច្យុតអំពីទេវនិកាយនោះ ជាអ្នកមិនមកកាន់កំណើតមកកាន់ភាពនេះទៀតឡើយ ម្នាលអាវុសោ នេះហៅថា បុគ្គលមានសញ្ញោជនៈខាងក្រៅ ជាអ្នកមិនមកវិញ មិនមកកាន់ភាពនេះទៀតឡើយ ។ លំដាប់នោះ ពួកទេវតាច្រើនអង្គឈ្មោះសមចិត្ត (មានអត្តភាពល្អិត) ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយឋិតនៅក្នុងទីដ៏សមគួរ ។ លុះទេវតាទាំងនោះ ឋិតនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា

ឯសោ ភន្តេ អាយស្មា សារីបុត្តោ បុព្វារាមេ មិគារ-
មាតុបាសាទេ ភិក្ខូនំ អជ្ឈត្តសញ្ញោជនញ្ច បុគ្គលំ
ទេសេតិ ពហិទ្ធាសញ្ញោជនញ្ច ហដ្ឋា ភន្តេ បរិសា
សាធុ ភន្តេ ភគវា យេនាយស្មា សារីបុត្តោ
តេនុបសង្កមតុ អនុកម្បំ ឧបាទាយាតិ ។ អធិវាសេសិ
ភគវា តុណ្ហីភាវេន ។ អថខោ ភគវា សេយ្យថាបិ
នាម ពលវា បុរិសោ សមិញ្ជិតំ វា ពាហំ បសារេយ្យ
បសារិតំ វា ពាហំ សមិញ្ជេយ្យ ឯវមេវ ជេតវនេ
អន្តរហិតោ បុព្វារាមេ មិគារមាតុបាសាទេ អាយស្មតោ
សារីបុត្តស្ស បមុខេ(១) បាតុរហោសិ ។ និសីទិ
ភគវា បញ្ញត្តេ អាសនេ ។ អាយស្មាបិ ខោ
សារីបុត្តោ ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។
ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ សារីបុត្តំ ភគវា
ឯតទវោច ឥធ សារីបុត្ត សម្ពហុលា សមចិត្តា ទេវតា

១ ម. សម្មុខេ ។



បពិត្រព្រះអង្គដ៏ចំរើន ព្រះសារីបុត្តដ៏មានអាយុអង្គនុ៎ះ សំដែងនូវបុគ្គល
ដែលមានសញ្ញោជនៈខាងក្នុងផង បុគ្គលដែលមានសញ្ញោជនៈខាងក្រៅ
ផង ដល់ពួកភិក្ខុ នៅឯប្រាសាទនៃមិគារមាតាក្នុងបុព្វារាម បពិត្រព្រះអង្គដ៏
ចំរើន ពួកបរិស័ទមានចិត្តត្រេកអរ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មាន
ព្រះភាគអាស្រ័យសេចក្ដីអនុគ្រោះ ទ្រង់ស្ដេចចូលទៅរកព្រះសារីបុត្តមាន
អាយុផងចុះ ។ ព្រះដ៏មានព្រះភាគទ្រង់ទទួលនិមន្តដោយតុណ្ហីភាព ។
លំដាប់នោះ ព្រះមានព្រះភាគទ្រង់ក្នុងដំណរ៍បាត់ព្រះអង្គចេញពីវត្ត
ជេតពន ទៅប្រាកដក្នុងទីចំពោះមុខព្រះសារីបុត្តដ៏មានអាយុនៅឯប្រា-
សាទនៃមិគារមាតាក្នុងបុព្វារាម (ក្នុងមួយរំពេច) ដូចបុរសអ្នកមានកំឡាំង
លាដៃដែលបត់ចូលឬបត់ដៃដែលលាចេញ ដូច្នោះដែរ ។ ព្រះដ៏មានព្រះ
ភាគគង់លើអាសនៈដែលគេក្រាលថ្វាយហើយ ។ ចំណែកព្រះសារីបុត្តមានអាយុ
ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយគង់ក្នុងទីដ៏សមគួរ ។ លុះព្រះសារី-
បុត្តមានអាយុគង់ក្នុងទីដ៏សមគួរហើយ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់
ដូច្នេះថា ម្នាលសារីបុត្ត ក្នុងទីនេះមានពួកទេវតាច្រើនអង្គឈ្មោះសមចិត្តា

យេនាហំ តេនុបសង្កមិំសុ ឧបសង្កមិត្វា មំ អភិវាទេត្វា ឯកមន្តំ អដ្ឋំសុ ។ ឯកមន្តំ ឋិតា ខោ សារីបុត្ត តា ទេវតា មំ ឯតទវោចុំ ឯសោ ភន្តេ អាយស្មា សារីបុត្តោ បុព្វារាមេ មិគារមាតុបាសាទេ ភិក្ខូនំ អជ្ឈត្តសញ្ញោជនញ្ច បុគ្គលំ ទេសេតិ ពហិទ្ធា-សញ្ញោជនញ្ច ហដ្ឋា ភន្តេ បរិសា សាធុ ភន្តេ ភគវា យេនាយស្មា សារីបុត្តោ តេនុបសង្កមតុ អនុកម្បំ ឧបាទាយាតិ ។ តា ខោ បន សារីបុត្ត ទេវតា ទសបិ ហុត្វា វីសម្បិ ហុត្វា តិំសម្បិ ហុត្វា ចត្តាឡីសម្បិ ហុត្វា បញ្ញាសម្បិ ហុត្វា សដ្ឋីម្បិ ហុត្វា អារគ្គកោដិនិតុទនមត្តេបិ តិដ្ឋន្តិ ន ច អញ្ញមញ្ញំ ព្យាពាធេន្តិ ។ សិយា ខោ បន តេ សារីបុត្ត ឯវមស្ស តត្ថ នូន តាសំ ទេវតានំ តថាចិត្តំ ភាវិតំ យេន តា ទេវតា ទសបិ ហុត្វា វីសម្បិ ហុត្វា តិំសម្បិ ហុត្វា ចត្តាឡីសម្បិ ហុត្វា



នាំគ្នាចូលមករកតថាគត លុះចូលមកដល់ហើយ ក៏ថ្វាយបង្គំតថាគតហើយ ឋិតនៅក្នុងទីដ៏សមគួរ ។ ម្នាលសារីបុត្ត លុះទេវតាទាំងនោះឋិតនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបទូលនឹងតថាគតដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ព្រះសារីបុត្តដ៏មានអាយុនុ៎ះ សំដែងនូវបុគ្គលដែលមានសញ្ញោជនៈខាងក្នុងផង បុគ្គលដែលមានសញ្ញោជនៈខាងក្រៅផង ដល់ភិក្ខុទាំងឡាយ នៅប្រាសាទនៃមិគារមាតា ក្នុងបុព្វារាម បពិត្រព្រះអង្គដ៏ចំរើន ពួកបរិស័ទក៏មានចិត្តរីករាយ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគទ្រង់អាស្រ័យសេចក្ដីអនុគ្រោះ ទ្រង់ស្ដេចចូលទៅរកព្រះសារីបុត្តដ៏មានអាយុនុ៎ះ ។ ម្នាលសារីបុត្ត ពួកទេវតាទាំងនោះមានចំនួន ១០ អង្គខ្លះ ២០ អង្គខ្លះ ៣០ អង្គខ្លះ ៤០ អង្គខ្លះ ៥០ អង្គខ្លះ ៦០ អង្គខ្លះ ឋិតនៅក្នុងទីត្រឹមតែចុងដែកស្រួចបាន តែមិនបៀតបៀនគ្នានឹងគ្នាឡើយ ម្នាលសារីបុត្ត ឯងនឹងគប្បីមានគំនិតយ៉ាងនេះថា ចិត្តដែលពួកទេវតាទាំងនោះ ក្នុងទីប្រជុំនោះ បានអប់រំចំរើនហើយដូច្នោះ ទើបពួកទេវតាទាំងនោះមានចំនួន ១០ អង្គខ្លះ ២០ អង្គខ្លះ ៣០ អង្គខ្លះ ៤០ អង្គខ្លះ

បញ្ញាសមត្តំ ហត្ថា សដ្ឋិមត្តំ ហត្ថា អាវាហោ ពាធិតទទ-
មាត្តម្បិ តិដ្ឋតិ ឧ ឧ ព្រហ្មញ្ញំ ព្យាកាលេត្តីតិ ១
ទោ បនេតំ សារីបុត្ត យំ ឧដ្តំ ភវោ សារីបុត្ត
តាសំ ទៅតាធំ គជាខិត្តំ ពោវិតំ យេន តា ទៅតា
នេរម័ ហុត្វា ១ ហេ ១ ឧ ឧ ព្រហ្មញ្ញំ ព្យាកាលេត្តិ
តស្សាតិហ សារីបុត្ត យំ សិក្ខិតព្វំ សន្តិន្ទ្រិយា
ភវិស្សាម សន្តមានសាតិ ឯវញ្ហិ តេ(១) សារីបុត្ត
សិក្ខិតព្វំ សន្តិន្ទ្រិយានញ្ហិ តេ(១) សារីបុត្ត
សន្តមានសានំ សន្តំយេវ កាយកម្មំ ភវិស្សតិ សន្តំ
វចីកម្មំ សន្តំ មនោកម្មំ សន្តំយេវ ឧបហារំ
ឧបហរិស្សាម សព្រហ្មចារីសូតិ ឯវញ្ហិ តេ(១)
សារីបុត្ត សិក្ខិតព្វំ អនស្សុំ ខោ សារីបុត្ត អញ្ញ-
តិត្ថិយា បរិព្វាជកា យេ ឥមំ ធម្មបរិយាយំ
ន សុណិស្សន្តីតិ ។

---

១ ឱ. ម. ឯវញ្ហិ ហិ ។ សន្តិន្ទ្រិយានញ្ហិ ហិ ។





៥០ ហត្ថខ្លះ ៦០ ហត្ថខ្លះ បើគេទៅតាមទីទួលពេញដោយរងើកភ្លើងដែលស្រួច
ប៉ុណ្ណោះ តែមិនប្រៀបប្រៀបដល់ត្រឹមទីនោះឡើយ ម្នាលសារីបុត្ត ដំណើរ
ដែលតថាគតឃើញហើយនេះ ម្នាលសារីបុត្ត ពួកទេវតាទាំងនោះ គឺទី
ប្រជុំនេះ សុទ្ធតែមានចិត្តប្រកបហើយដូចគ្នា ទើបបានជាទេវតាទាំងនោះ
មានចំនួន ១០ហត្ថខ្លះ ។ បេ ។ តែគង់មិនប្រៀបប្រៀបដល់ត្រឹមទីនោះឡើយ
ម្នាលសារីបុត្ត ព្រោះហេតុនោះ គួរតែអ្នកសិក្សាយ៉ាងនេះថា
យើងនឹងជាអ្នកមានឥន្ទ្រិយស្ងប់ស្ងាត់ មានចិត្តស្ងប់ស្ងាត់ ម្នាលសារីបុត្ត អ្នកទាំង
ឡាយគួរសិក្សាយ៉ាងនេះ ម្នាលសារីបុត្ត លុះអ្នកទាំងឡាយ មានឥន្ទ្រិយ
ស្ងប់ស្ងាត់ មានចិត្តស្ងប់ស្ងាត់ ពិតហើយ កាយកម្មនឹងស្ងប់ស្ងាត់ផង
វចីកម្មនឹងស្ងប់ស្ងាត់ផង មនោកម្មនឹងស្ងប់ស្ងាត់ផង ដោយចំណងថា
យើងនឹងប្រមូលបង្អោនការផ្ដល់ (គ្រឿងសក្ការៈ) ចំពោះពួកសព្រហ្មចារី
ម្នាលសារីបុត្ត អ្នកទាំងឡាយ គួរសិក្សាយ៉ាងនេះ ម្នាលសារីបុត្ត ពួក
អន្យតិរ្ថិយ បរិព្វាជកណា មិនបានស្ដាប់ធម្មបរិយាយនេះ ពួកអន្យតិរ្ថិយ
បរិព្វាជកទាំងនោះ វិនាសហើយផង ។

(២៨២) ឯកំ សមយំ អាយស្មា មហាកច្ចានោ វរណាយំ វិហរតិ កទ្ទមទហតីរេ[១] ។ អថខោ អារាមទណ្ឌោ ព្រាហ្មណោ យេនាយស្មា មហាកច្ចានោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា មហាកច្ចានេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អារាមទណ្ឌោ ព្រាហ្មណោ អាយស្មន្តំ មហាកច្ចានំ ឯតទវោច កោ នុ ខោ ភោ កច្ចាន ហេតុ កោ បច្ចយោ យេន ខត្តិយាបិ ខត្តិយេហិ វិវទន្តិ ព្រាហ្មណាបិ ព្រាហ្មណេហិ វិវទន្តិ គហបតិកាបិ គហបតិកេហិ វិវទន្តីតិ ។ កាមរាគវិនិវេសវិនិពន្ធបលិគេធបរិយុដ្ឋានជ្ឈោសានហេតុ ខោ ព្រាហ្មណ ខត្តិយាបិ ខត្តិយេហិ វិវទន្តិ ព្រាហ្មណាបិ ព្រាហ្មណេហិ វិវទន្តិ គហបតិកាបិ គហបតិកេហិ វិវទន្តីតិ ។ កោ បន ភោ កច្ចាន ហេតុ កោ បច្ចយោ យេន សមណាបិ សមណេហិ វិវទន្តីតិ ។

---

១ ម. កន្ទរាតីរេ ។



(២៨២) សម័យមួយ ព្រះមហាកច្ចានៈដ៏មានអាយុ គង់នៅក្បែរឆ្នេរស្រះកទ្ទមៈ ជិតក្រុងវរណា ។ គ្រានោះ អារាមទណ្ឌព្រាហ្មណ៍ចូលទៅរកព្រះមហាកច្ចានៈដ៏មានអាយុ លុះចូលទៅដល់ហើយក៏រីករាយនឹងព្រះមហាកច្ចានៈដ៏មានអាយុ ហើយនិយាយពាក្យដែលគួររីករាយនិងពាក្យដែលគួររលឹក ហើយក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះអារាមទណ្ឌព្រាហ្មណ៍អង្គុយក្នុងទីដ៏សមគួរហើយ ទើបនិយាយនឹងព្រះមហាកច្ចានៈដ៏មានអាយុដូច្នេះថា បពិត្រព្រះកច្ចានៈដ៏ចំរើន អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យពួកខត្តិយៈទាស់ទែងនឹងពួកខត្តិយៈក៏មាន ពួកព្រាហ្មណ៍ទាស់ទែងនឹងពួកព្រាហ្មណ៍ក៏មាន ពួកគហបតីទាស់ទែងនឹងពួកគហបតីក៏មាន ។ ព្រះមហាកច្ចានៈតបថា ម្នាលព្រាហ្មណ៍ ពួកខត្តិយៈទាស់ទែងនឹងពួកខត្តិយៈក៏មាន ពួកព្រាហ្មណ៍ទាស់ទែងនឹងពួកព្រាហ្មណ៍ក៏មាន ពួកគហបតីទាស់ទែងនឹងពួកគហបតីក៏មាន ព្រោះហេតុតែកាមរាគ ជាចំណងនៃចិត្ត ធ្វើឲ្យជាប់ជំពាក់ គ្របសង្កត់ប្រើក ។ បពិត្រព្រះកច្ចានៈដ៏ចំរើន ចុះអ្វីជាហេតុ ចុះអ្វីជាបច្ច័យ ដែលនាំឲ្យពួកសមណៈទាស់ទែងនឹងពួកសមណៈ ។

ទិដ្ឋិរាគវិនិវេសវិនិពន្ធបលិគេធបរិយុដ្ឋានជ្ឈោសាន-
ហេតុ(១) ខោ ព្រាហ្មណ សមណាបិ សមណេហិ
វិវទន្តីតិ ។ អត្ថិ បន ភោ គោតម កោចិ លោកស្មឹ
យោ ឥមញ្ចេវ កាមរាគវិនិវេសវិនិពន្ធបលិគេធបរិយុដ្ឋា-
នជ្ឈោសានំ សមតិក្កន្តោ ឥមញ្ច ទិដ្ឋិរាគវិនិវេសវិនិ-
ពន្ធបលិគេធបរិយុដ្ឋានជ្ឈោសានំ សមតិក្កន្តោតិ ។ អត្ថិ
ព្រាហ្មណ លោកស្មឹ យោ ឥមញ្ចេវ កាមរាគវិនិវេស-
វិនិពន្ធបលិគេធបរិយុដ្ឋានជ្ឈោសានំ សមតិក្កន្តោ ឥមញ្ច
ទិដ្ឋិរាគវិនិវេសវិនិពន្ធបលិគេធបរិយុដ្ឋានជ្ឈោសានំ សម-
តិក្កន្តោតិ ។ កោ បន សោ ភោ គោតម លោកស្មឹ
យោ ឥមញ្ចេវ កាមរាគវិនិវេសវិនិពន្ធបលិគេធបរិ-
យុដ្ឋានជ្ឈោសានំ សមតិក្កន្តោ ឥមញ្ច ទិដ្ឋិរាគវិនិវេស-
វិនិពន្ធបលិគេធបរិយុដ្ឋានជ្ឈោសានំ សមតិក្កន្តោតិ ។

១- ម. ទិដ្ឋិរាគវិនិវេសវិនិពន្ធបលិគេធបរិយុដ្ឋានជ្ឈោសានហេតុ ។



ម្នាលព្រាហ្មណ៍ ពួកសមណៈទាស់ទែងនឹងពួកសមណៈ ព្រោះហេតុតែទិដ្ឋិរាគៈ ជាចំណងចងរឹតធ្វើឲ្យជាប់ជំពាក់គ្របសង្កត់រួបរឹត ។ បពិត្រព្រះគោតមដ៏ចំរើន ចុះបុគ្គលណាមួយក្នុងលោក ជាអ្នកប្រព្រឹត្តកន្លងនូវកាមរាគៈដែលជាចំណងចងរឹត ធ្វើឲ្យជាប់ជំពាក់គ្របសង្កត់រួបរឹតនេះចេញបានផង ជាអ្នកប្រព្រឹត្តកន្លងនូវទិដ្ឋិរាគៈ ដែលជាចំណងចងរឹតធ្វើឲ្យជាប់ជំពាក់គ្របសង្កត់នេះចេញបានផង មានខ្លះឬទេ ។ ម្នាលព្រាហ្មណ៍ បុគ្គលជាអ្នកប្រព្រឹត្តកន្លងនូវកាមរាគៈ ដែលជាចំណងចងរឹត ធ្វើឲ្យជាប់ជំពាក់គ្របសង្កត់រួបរឹតនេះចេញបានផង ជាអ្នកប្រព្រឹត្តកន្លងនូវទិដ្ឋិរាគៈ ដែលជាចំណងចងរឹតធ្វើឲ្យជាប់ជំពាក់គ្របសង្កត់រួបរឹតនេះចេញបានផង រមែងមានក្នុងលោក ។ បពិត្រព្រះគោតមដ៏ចំរើន ចុះក្នុងលោកនេះ មានបុគ្គលណាហ្ន៎ ដែលជាអ្នកប្រព្រឹត្តកន្លងនូវកាមរាគៈ ដែលជាចំណងចងរឹតធ្វើឲ្យជាប់ជំពាក់គ្របសង្កត់រួតរឹតនេះចេញបានផង ជាអ្នកប្រព្រឹត្តកន្លងនូវទិដ្ឋិរាគៈ ដែលជាចំណងចងរឹត ធ្វើឲ្យជាប់ជំពាក់គ្របសង្កត់រួបរឹតនេះចេញបានផង ។

អត្ថិ ព្រាហ្មណ បុរត្ថិមេសុ ជនបទេសុ សាវត្ថី នាម នគរំ តត្ថ សោ ភគវា ឯតរហិ វិហរតិ អរហំ សម្មាសម្ពុទ្ធោ សោ ហិ ព្រាហ្មណ ភគវា ឧច្ចេ កាមភវាទិវិសេសវិនិមុត្តបលិភេទបរិយុដ្ឋានវេល្លោសានំ សមតិក្កន្តោ ឥមញ្ច ចិន្តកាទិវិសេសវិនិមុត្តបលិភេទបរិយុដ្ឋានវេល្លោសានំ សមតិក្កន្តោតិ ។ ឯវំ វុត្តេ កោកមនណ្ឌោ ព្រាហ្មណោ ឧដ្ឋាយាសនា ឯកំសំ ឧត្តរាសង្គំ ករិត្វា ទក្ខិណជាណុមណ្ឌលំ បថវិយំ និហន្ត្វា យេន ភគវា តេនញ្ជលិំ បណាមេត្វា តិក្ខត្តុំ ឧទានំ ឧទានេសិ នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស យោ ហិ សោ ភគវា ឧច្ចេ កាមភវាទិវិសេសវិនិមុត្តបលិភេទបរិយុដ្ឋានវេល្លោសានំ សមតិក្កន្តោ ឥមញ្ច ចិន្តកាទិវិសេសវិនិមុត្តបលិភេទបរិយុដ្ឋានវេល្លោសានំ សមតិក្កន្តោតិ ។ អភិក្កន្តំ ភោ គោតម



ម្នាលព្រាហ្មណ៍ មាននគរឈ្មោះសាវត្ថីនៅក្នុងជនបទទិសខាងកើត សម្តេចព្រះដ៏មានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់គង់នៅឡើយក្នុងនោះ ម្នាលព្រាហ្មណ៍ ព្រះដ៏មានព្រះភាគអង្គនោះហើយ ដែលជាអ្នកប្រព្រឹត្តក្នុងទីខ្ពស់កាមភព ដែលជាទំហំទីបទពិសេស ធ្វើឲ្យដាច់ចាកគ្រឿងស្ទាក់ស្ទើរគឺនេះចេញចាកផង ជាអ្នកប្រព្រឹត្តក្នុងទីខ្ពស់ចិន្តកៈ ដែលជាទំហំទីបទពិសេសធ្វើឲ្យដាច់ចាកគ្រឿងស្ទាក់ស្ទើរគឺនេះចេញចាកផង ។ លុះព្រះគន្ធាឧះមីហនពោះ សំដែងយ៉ាងនេះហើយ ទើបការមនណ្ឌព្រាហ្មណ៍ក្រោកចាកអាសនៈ ធ្វើសំពត់ឧត្តរាសង្គៈឆៀងស្មាម្ខាង លុតមណ្ឌលជង្គង់ខាងស្តាំលើផែនដី ប្រណម្យអញ្ជលីចំពោះព្រះដ៏មានព្រះភាគ បន្លឺឧទានបីដងថា សូមក្រាបថ្វាយបង្គំចំពោះព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ សូមក្រាបថ្វាយបង្គំ ចំពោះព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធអង្គនោះ សូមក្រាបថ្វាយបង្គំ ចំពោះព្រះដ៏មានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ ព្រោះព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ប្រព្រឹត្តក្នុងទីខ្ពស់កាមភព ដែលជាទំហំទីបទពិសេសធ្វើឲ្យដាច់ចាកគ្រឿងស្ទាក់ស្ទើរគឺនេះចេញចាកផង ទ្រង់ប្រព្រឹត្តក្នុងទីខ្ពស់ចិន្តកៈ ដែលជាទំហំទីបទពិសេសធ្វើឲ្យដាច់ចាកគ្រឿងស្ទាក់ស្ទើរគឺនេះចេញចាកផង ។ បពិត្រព្រះគោតមដ៏ចំរើន ពីរោះណាស់

អភិក្កន្តំ ភោ កច្ចាន សេយ្យថាបិ ភោ កច្ចាន និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលបជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវំ ភោតា កច្ចានេន អនេកបរិយាយេន ធម្មោ បកាសិតោ ឯសាហំ ភោ កច្ចាន តំ ភវន្តំ(១) គោតមំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ មំ ភវំ កច្ចានោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតន្តិ ។

(៤៨៣) ឯកំ សមយំ អាយស្មា មហាកច្ចានោ មធុរាយំ វិហរតិ គុន្ទាវនេ ។ អថខោ កណ្ឌរាយនោ ព្រាហ្មណោ យេនាយស្មា មហាកច្ចានោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា មហាកច្ចានេន សទ្ធិំ សម្មោទិ ។បេ។ ឯកមន្តំ និសិន្នោ ខោ កណ្ឌរាយនោ ព្រាហ្មណោ អាយស្មន្តំ មហាកច្ចានំ ឯតទវោច

១. ម. ឧ. ភវន្តំ ។



បពិត្រព្រះកច្ចានៈដ៏ចំរើន ពីរោះណាស់ បពិត្រព្រះកច្ចានៈដ៏ចំរើន ធម៌ដែលព្រះកច្ចានៈដ៏ចំរើន បានប្រកាសហើយ ដោយអនេកបរិយាយយ៉ាងនេះ (ភ្លឺច្បាស់ណាស់) ដូចគេផ្ងាររបស់ដែលផ្កាប់ទុក ពុំនោះដូចគេបើករបស់បិទបាំងទុក ពុំនោះសោតដូចគេប្រាប់ផ្លូវដល់អ្នកវង្វេងទិស ពុំនោះដូចជាមនុស្សកាន់ប្រទីបទ្រោលបំភ្លឺ ក្នុងទីងងឹតដោយគិតថា ពួកសត្វមានចក្ខុ នឹងមើលឃើញរូបទាំងឡាយបាន ដូច្នោះ បពិត្រព្រះកច្ចានៈដ៏ចំរើន ខ្ញុំព្រះករុណាសូមដល់នូវព្រះគោតមដ៏ចំរើននោះផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹងទីរលឹក សូមព្រះកច្ចានៈដ៏ចំរើន ចាំទុកនូវខ្ញុំព្រះករុណាថា ជាឧបាសកអ្នកដល់សរណគមន៍ ស្មើដោយជីវិតតាំងពីថ្ងៃនេះទៅ ។

(៤៨៣) សម័យមួយ ព្រះមហាកច្ចានៈដ៏មានអាយុគង់នៅក្នុងគុន្ទាវន(១)ទៀបក្រុងមធុរា ។ គ្រានោះ កណ្ឌរាយនព្រាហ្មណ៍ចូលទៅរកព្រះមហាកច្ចានៈដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏រីករាយនឹងព្រះមហាកច្ចានៈដ៏មានអាយុ ។បេ។ លុះកណ្ឌរាយនព្រាហ្មណ៍អង្គុយក្នុងទីដ៏សមគួរហើយ ទើបពោលនឹងព្រះមហាកច្ចានៈដ៏មានអាយុដូច្នេះ ថា

១ អដ្ឋកថា គុន្ទាវនជាឈ្មោះនៃព្រៃ ១ ក្នុងដែនមធុរា ។

សុតមេតំ ភោ គោតម ន សមណោ គោតមោ ព្រាហ្មណេ ជិណ្ណេ វុឌ្ឍេ មហល្លកេ អទ្ធគតេ វយោអនុប្បត្តេ អភិវាទេតិ វា បច្ចុដ្ឋេតិ វា អាសនេន វា និមន្តេតីតិ តយិទំ(១) ភោ គោតម តថេវ ន ហិ ភវំ គោតមោ ព្រាហ្មណេ ជិណ្ណេ វុឌ្ឍេ មហល្លកេ អទ្ធគតេ វយោអនុប្បត្តេ អភិវាទេតិ វា បច្ចុដ្ឋេតិ វា អាសនេន វា និមន្តេតិ តយិទំ ភោ គោតម ន សម្បន្នមេវាតិ ។ អត្ថិ ព្រាហ្មណ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ថេរករណា ច អក្ខាតា ទហរករណា ច វុឌ្ឍោ ចេបិ ព្រាហ្មណ ហោតិ អសីតិកោ វា នវុតិកោ វា វស្សសតិកោ វា ជាតិយា សោ ច កាមេ បរិភុញ្ជតិ កាមមជ្ឈេ វសតិ

---

១- ម. តទិទំ ។



បពិត្រព្រះគោតមដ៏ចំរើន ខ្ញុំបានឮដំណឹងនេះថា ព្រះសមណគោតមមិនសំពះ មិនក្រោកទទួល មិនអញ្ជើញ ដោយអាសនៈចំពោះពួកព្រាហ្មណ៍ដែលចាស់ជរាគ្រាំគ្រា មានអាយុច្រើន ល្មមនៅបានយូរឆ្នាំមកហើយ មានអាយុល្មមដល់នៅក្នុងបច្ឆិមវ័យ នោះឡើយ បពិត្រព្រះគោតមដ៏ចំរើន ពាក្យដែលខ្ញុំបានឮមកនោះប្រាកដមែន ព្រះគោតមដ៏ចំរើន មិនសំពះ មិនក្រោកទទួល មិនអញ្ជើញ ដោយអាសនៈចំពោះពួកព្រាហ្មណ៍ដែលចាស់គ្រាំគ្រា មានអាយុច្រើន នៅបានយូរឆ្នាំមកហើយ មានអាយុល្មមដល់នៅក្នុងបច្ឆិមវ័យ នោះឡើយ បពិត្រព្រះគោតមដ៏ចំរើន ក៏ដូចជាការមិនសំពះជាដើមនោះ មិនសមគួរទេ ។ ព្រះគោតមដ៏មានអាយុតបថា ម្នាលព្រាហ្មណ៍ ព្រះដ៏មានព្រះភាគ អរហន្តសម្មាសម្ពុទ្ធគឺនោះ ព្រះអង្គទ្រង់ជ្រាប ទ្រង់ឃើញហើយ ទ្រង់សំដែងវុឌ្ឍិធម៌ (ជាធម៌មនុស្សចាស់) ផង ទហរធម៌ (ជាធម៌មនុស្សក្មេង) ផង ម្នាលព្រាហ្មណ៍ ប្រសិនបើមនុស្សចាស់ មានអាយុ ៨០ ឆ្នាំក្តី ៩០ ឆ្នាំក្តី ១០០ ឆ្នាំក្តី រាប់តាំងចាប់កំណើតមក ប៉ុន្តែមនុស្សនោះនៅបរិភោគកាម ក្រាំនៅក្នុងកណ្តាលកាម

កាយបរិឡាហេន បរិឌយ្ហតិ កាយបរិតស្សនាហិ ខជ្ជតិ
កាយបរិហារិយសង្ខារា ទុក្ខា អថខោ សោ
ពាលោ ច ជោតេស្ស(១) សិទ្ធំ គច្ឆតិ ឧទាហ
ថេរំ ព្រាហ្មណោ ហោតិ យុត្តំ សុត្វា កាយស្សភេទោ
កាត្រូច យោគ្យាខេន សមណាកោ បរិមេន វិយ សោ
សោ ច ន កាយបរិទុក្ខតិ ន កាយមជ្ឈេ វិសតិ
ន កាយបរិឡាហេន បរិឌយ្ហតិ ន កាយបរិតស្សនា
ខជ្ជតិ ន កាយបរិហារិយសង្ខារា ទុក្ខា អថខោ
សោ បណ្ឌិតោ ជោតេស្ស សិទ្ធំ គច្ឆតីតិ ។ អថ វុត្ត
កណ្ឌាភយតោ ព្រាហ្មណោ ទុក្ខាយាសនា បរិតំ សំ
ទុក្ខកសន្តំ តសិត្វា ឧបាកច់ សុដំ គិត្វាដំ ការេ
សិរសា វន្ទតិ វន្ទិត្វា វន្ទិត្វា មិយំ បិតា
ឧបាក មយំ ឧបាក្ខមិយំ បិតា អតិក្កន្តំ ភោ
គោតម ។បេ។ ឧបាសកំ មំ ភវំ គោតមោ
ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតន្តិ ។

---

១ ម. ឧបោរ ចេវ ឥតិ បទំ នត្ថិ ។



ក្តៅក្រហាយដោយកំដៅកាយ ក្រៀមក្រំរឹតតែក្រៃលែងសន្ធឹក ដោយខ្វល់ខ្វាយ
ស្រេកឃ្លានកាយ មនុស្សនោះហៅថា មនុស្សក្រខ្វក់ដោយពិត មិនតែប៉ុណ្ណោះ
បាស់ខ្ញុំឡើយ ម្នាលព្រាហ្មណ៍ ប្រាកដថា មនុស្សក្រខ្វក់នៅដំបូងនឹងរួច
មានចេញទៅ ប្រកបដោយវិញ្ញាណអំពើ គឺបដិវេធ ចំណែកមនុស្សនោះមិនបា-
រោគកាយ មិនក្រៅទោសរឹកណ្តាលកាយ មិនក្តៅក្រហាយដោយកំដៅកាយ
មិនក្រៀមក្រំរឹតតែក្រៃលែងសន្ធឹក មិនខ្វល់ខ្វាយស្រេកឃ្លានកាយ មនុស្សនោះហើយ
ហៅថាបណ្ឌិតពិត ជាបាស់ខ្ញុំដោយពិត ។ លុះព្រះតថាគតទ្រង់សំដែងគាថា
ហើយនិយាយចប់ហើយ ទណ្ឌាភយព្រាហ្មណ៍ ក៏ត្រេកអរដោយទឹកចិត្តរីករាយ ធ្វើ
សំពះដល់ព្រះតថាគត ក្រាបបង្គំដោយការគួរ ប្រកាសថ្លែងនូវបែបទីពឹងហើយ
ទើបក្រាបទូល ព្រះពុទ្ធដីកាសំដែងជាមនុស្សរបស់ ព្រះតថាគតមានព្រះភាគ ចំពោះព្រះ
ករុណាជាមនុស្សក្រខ្វក់បានដោយ គ្រឹះបាវក ចាប់តាំងពីព្រះតថាគតជាអ្នក
ពីពេលណាស់ ។ បេ ។ សូមព្រះតថាគតជាអំពើ ចាំទុកខ្ញុំព្រះករុណាជាអ្នក
ឧបាសកដល់សរណគមន៍ ស្មើដោយជីវិត តាំងពីថ្ងៃនេះទៅ ។

(២៨៦) យស្មឹ ភិក្ខវេ សមយេ ចោរា ពលវន្តោ ហោន្តិ រាជានោ តស្មឹ សមយេ ទុព្វលា ហោន្តិ តស្មឹ ភិក្ខវេ សមយេ រញ្ញោ ន ផាសុ ហោតិ អតិយាតុំ វា និយ្យាតុំ វា បច្ចន្តិមេ វា ជនបទេ អនុសញ្ញាតុំ(១) ព្រាហ្មណគហបតិកានំបិ តស្មឹ សមយេ ន ផាសុ ហោតិ អតិយាតុំ វា និយ្យាតុំ វា ពាហិរានិ វា កម្មន្តានិ បដិវេក្ខិតុំ ។ ឯវមេវ ខោ ភិក្ខវេ យស្មឹ សមយេ បាបភិក្ខូ ពលវន្តោ ហោន្តិ បេសលា ភិក្ខូ តស្មឹ សមយេ ទុព្វលា ហោន្តិ តស្មឹ ភិក្ខវេ សមយេ បេសលា ភិក្ខូ តុណ្ហីភូតា តុណ្ហីភូតា សង្ឃមជ្ឈេ សង្កសាយន្តិ(២) បច្ចន្តិមេ វា ជនបទេ ភជន្តិ ។ តយិទំ ភិក្ខវេ ហោតិ ពហុជនាហិតាយ ពហុជនាសុខាយ ពហុនោ ជនស្ស អនត្ថាយ អហិតាយ ទុក្ខាយ ទេវមនុស្សានំ ។

១ ម. អនុសញ្ញាយិតុំ ។ ២ ម. សង្កុសាយន្តិ ។



(២៨៦) ម្នាលភិក្ខុទាំងឡាយ សម័យណា ពួកចោរមានកំឡាំង សម័យនោះ ពួកស្តេចក៏ខានកំឡាំងទៅ ម្នាលភិក្ខុទាំងឡាយ សម័យនោះ ស្តេចមានព្រះរាជដំណើរត្រឡប់ចូលមកក្តី ចេញទៅកាន់ក្រៅក្តី នឹងត្រួតត្រាកិច្ចការក្នុងជនបទជាប់ព្រំដែនក្តី ក៏មិនបានសេចក្តីសុខសប្បាយ ឡើយក្នុងសម័យនោះ សូម្បីពួកព្រាហ្មណ៍និងគហបតី នឹងមានដំណើរត្រឡប់ចូលមកក្តី ចេញទៅកាន់ក្រៅក្តី ត្រួតត្រាការងារខាងក្រៅក្តី ក៏មិនបានសុខសប្បាយឡើយ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីនុ៎ះឧបមេយ្យដូច្នោះដែរ ក្នុងសម័យណា ពួកភិក្ខុបាបមានកំឡាំង សម័យនោះ ពួកភិក្ខុជាអ្នកមានសីលជាទីស្រឡាញ់ រមែងខានកំឡាំងទៅ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យនោះ ពួកភិក្ខុជាអ្នកមានសីលជាទីស្រឡាញ់ នៅស្ងៀមឈឹង នៅស្ងៀមឈឹង គង់អង្គុយក្នុងកណ្តាលជំនុំសង្ឃ ឬនៅក្នុងជនបទជាប់ព្រំដែន ។ ម្នាលភិក្ខុទាំងឡាយ ហេតុនោះ តែងប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ដល់ជនច្រើន ដើម្បីមិនបានសេចក្តីសុខដល់ជនច្រើន ដើម្បីសេចក្តីវិនាសដល់ជនច្រើន ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ដល់ទេវតានិងមនុស្សទាំងឡាយ ។

យស្មឹ ភិក្ខវេ សមយេ រាជានោ ពលវន្តោ ហោន្តិ ចោរា តស្មឹ សមយេ ទុព្វលា ហោន្តិ តស្មឹ ភិក្ខវេ សមយេ រញ្ញោ សុខំ ហោតិ អតិយាតុំ វា និយ្យាតុំ វា បច្ចន្តិមេ វា ជនបទេ អនុសញ្ញាតុំ ព្រាហ្មណគហបតិកានំបិ តស្មឹ សមយេ សុខំ ហោតិ អតិយាតុំ វា និយ្យាតុំ វា ពាហិរានិ វា កម្មន្តានិ បដិវេក្ខិតុំ ។ ឯវមេវ ខោ ភិក្ខវេ យស្មឹ សមយេ បេសលា ភិក្ខូ ពលវន្តោ ហោន្តិ បាបភិក្ខូ តស្មឹ សមយេ ទុព្វលា ហោន្តិ តស្មឹ ភិក្ខវេ សមយេ បាបភិក្ខូ តុណ្ហីភូតា តុណ្ហីភូតា វា សង្ឃមជ្ឈេ សំកសាយន្តិ យេន វា តេន វា បលាយន្តិ(១) ។ តទស្ស ភិក្ខវេ ហោតិ ពហុជនហិតាយ ពហុជនសុខាយ ពហុនោ ជនស្ស អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ ។

១ ម. យេន វា តេន វា បក្កន្តិ ។ ឱ. យេន វា តេន វា បលាយន្តិ ។



ម្នាលភិក្ខុទាំងឡាយ សម័យណា ពួកស្តេចមានកំឡាំង សម័យនោះ ពួកចោរតែងមានកំឡាំងខ្សោយ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យនោះ ស្តេចនឹងមានព្រះរាជដំណើរត្រឡប់ចូលមកក្តី ចេញទៅកាន់ក្រៅក្តី នឹងត្រួតត្រាកិច្ចការ ក្នុងជនបទជាដែនក្តី តែងមានសេចក្តីសុខស្រួល ក្នុងសម័យនោះ សូម្បីពួកព្រាហ្មណ៍និងគហបតីទាំងឡាយ នឹងមានដំណើរត្រឡប់ចូលមកក្តី ចេញទៅកាន់ក្រៅក្តី ត្រួតត្រាការងារខាងក្រៅក្តី ក៏បានសេចក្តីសុខស្រួល មានឧបមាយ៉ាងណា ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីឧបមេយ្យក៏ដូច្នោះដែរ ក្នុងសម័យណា ពួកភិក្ខុមានសីលជាទីស្រឡាញ់ មានកំឡាំង សម័យនោះ ពួកភិក្ខុបាបមានកំឡាំងខ្សោយ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យនោះ ពួកភិក្ខុបាបនៅស្ងៀមឈឹង នៅស្ងៀមឈឹង អង្គុយសំកុកនៅក្នុងកណ្តាលជំនុំសង្ឃ ឬរត់គេចទៅតាមទីផ្សេងៗ ។ ម្នាលភិក្ខុទាំងឡាយ ហេតុនោះតែងប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីសេចក្តីចំរើនដល់ជនច្រើន ដើម្បីប្រយោជន៍ទាំងសេចក្តីសុខដល់ទេវតានិងមនុស្សទាំងឡាយ ។

(២៨៧) ទ្វិន្នាហំ ភិក្ខវេ មិច្ឆាបដិបត្តិំ ន វណ្ណេមិ គិហិស្ស វា បព្វជិតស្ស វា ។ គិហី វា ភិក្ខវេ បព្វជិតោ វា មិច្ឆាបដិបន្នោ មិច្ឆាបដិបត្តាធិករណហេតុ នារាធកោ ហោតិ ញាយំ ធម្មំ កុសលំ ។ ទ្វិន្នាហំ ភិក្ខវេ សម្មាបដិបត្តិំ វណ្ណេមិ គិហិស្ស វា បព្វជិតស្ស វា ។ គិហី វា ភិក្ខវេ បព្វជិតោ វា សម្មាបដិបន្នោ សម្មាបដិបត្តាធិករណហេតុ អារាធកោ ហោតិ ញាយំ ធម្មំ កុសលំ ។

[២៨៨] យេ តេ ភិក្ខវេ ភិក្ខូ ទុគ្គហីតេហិ សុត្តន្តេហិ ព្យញ្ជនប្បដិរូបកេហិ អត្ថញ្ច ធម្មញ្ច បដិពាហន្តិ តេ ភិក្ខវេ ភិក្ខូ ពហុជនាហិតាយ បដិបន្នា ពហុជនាសុខាយ ពហុនោ ជនស្ស អនត្ថាយ អហិតាយ ទុក្ខាយ ទេវមនុស្សានំ ពហុញ្ច តេ ភិក្ខវេ ភិក្ខូ អបុញ្ញំ បសវន្តិ តេ ចិមំ សទ្ធម្មំ អន្តរធាបេន្តិ ។



(២៨៧) ម្នាលភិក្ខុទាំងឡាយ តថាគតមិនសរសើរសេចក្តីប្រតិបត្តិខុសរបស់បុគ្គលពីរពួក គឺគ្រហស្ថ១ បព្វជិត១ ។ ម្នាលភិក្ខុទាំងឡាយ គ្រហស្ថក្តី បព្វជិតក្តី ដែលប្រតិបត្តិខុសហើយ ជាបុគ្គលមិនគាប់នឹងញាណ សម្រេចនូវកុសលធម៌ព្រមទាំងវិបស្សនា ព្រោះហេតុតែការប្រតិបត្តិខុសនោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ តថាគតសរសើរសេចក្តីប្រតិបត្តិត្រូវរបស់បុគ្គលពីរពួក គឺគ្រហស្ថ១ បព្វជិត១ ។ ម្នាលភិក្ខុទាំងឡាយ គ្រហស្ថក្តី បព្វជិតក្តី ដែលប្រតិបត្តិត្រូវហើយ ជាបុគ្គលគាប់នឹងញាណ សម្រេចនូវកុសលធម៌ព្រមទាំងវិបស្សនា ព្រោះហេតុតែការប្រតិបត្តិត្រូវ

[២៨៨] ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុណា ហាមឃាត់អត្ថផង ធម៌ផង ដោយសូត្រទាំងឡាយដែលខ្លួនរៀនខុស តែសមឡើតាមព្យញ្ជនៈ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះឈ្មោះថា ប្រតិបត្តិដើម្បីមិនជាប្រយោជន៍ដល់ជនច្រើន ដើម្បីមិនមានសេចក្តីសុខដល់ជនច្រើន ដើម្បីមិនចំរើនដល់ជនច្រើន ដើម្បីមិនជាប្រយោជន៍ទាំងនាំសេចក្តីទុក្ខ ដល់ទេវតានិងមនុស្សទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះតែងបានបាបច្រើន មិនតែប៉ុណ្ណោះ ភិក្ខុទាំងនោះឈ្មោះថា ធ្វើព្រះសទ្ធម្ម គឺសាសនានេះឲ្យអន្តរធានទៅផង ។

យេ តេ ភិក្ខវេ ភិក្ខូ សុគ្គហិតេហិ សុត្តន្តេហិ ព្យញ្ជនប្បតិរូបកេហិ អត្ថញ្ច ធម្មញ្ច អនុលោមេន្តិ តេ ភិក្ខវេ ភិក្ខូ ពហុជនហិតាយ បដិបន្នា ពហុជនសុខាយ ពហុនោ ជនស្ស អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ ពហុញ្ច តេ ភិក្ខវេ ភិក្ខូ បុញ្ញំ បសវន្តិ តេ ចិមំ សទ្ធម្មំ ឋបេន្តីតិ ។

សមចិត្តវគ្គោ ចតុត្ថោ ។

[២៨៧] ទ្វេមា ភិក្ខវេ បរិសា ។ កតមា ទ្វេ ។ ឧត្តានា ច បរិសា គម្ភីរា ច បរិសា ។ កតមា ច ភិក្ខវេ ឧត្តានា បរិសា ។ ឥធ ភិក្ខវេ យស្សំ បរិសាយំ ភិក្ខូ ឧទ្ធតា ហោន្តិ ឧន្នឡា ចបលា មុខរា វិកិណ្ណវាចា មុដ្ឋស្សតី អសម្បជានា អសមាហិតា វិព្ភន្តចិត្តា បាកតិន្ទ្រិយា អយំ វុច្ចតិ ភិក្ខវេ ឧត្តានា បរិសា ។ កតមា ច ភិក្ខវេ គម្ភីរា បរិសា ។



ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុណា ប្រព្រឹត្តតាមអត្ថផង ធម៌ផង ដោយសូត្រទាំងឡាយដែលខ្លួនរៀនត្រឹមត្រូវ សមស្របតាមព្យញ្ជនៈ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះឈ្មោះថា ប្រតិបត្តិដើម្បីជាប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីសេចក្តីចំរើនដល់ជនច្រើន ដើម្បីជាប្រយោជន៍ទាំងជាសេចក្តីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះតែងបានបុណ្យច្រើន មិនតែប៉ុណ្ណោះ ភិក្ខុទាំងនោះឈ្មោះថាធ្វើព្រះសទ្ធម្មនេះឲ្យឋិតនៅបានយូរ ។

ចប់ សមចិត្តវគ្គ ទី ៤ ។

(២៨៧) ម្នាលភិក្ខុទាំងឡាយ បរិស័ទទាំងឡាយនេះមាន ២ពួក ។ បរិស័ទ ២ពួក តើដូចម្តេច ។ គឺបរិស័ទរាក់ ១ បរិស័ទជ្រៅ ១ ។ ម្នាលភិក្ខុទាំងឡាយ បរិស័ទរាក់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុក្នុងសាសនានេះ ជាឧទ្ធតរាយមាយ មានមានះដូចដើមស្គី មានចិត្តឃ្លើនឃ្លោង ជាមនុស្សរាក់ ពោលពាក្យសំដីរាយមាយ មានស្មារតីភាន់ច្រឡំ មិនដឹងខ្លួន មិនមានចិត្តតាំងខ្ជាប់ខ្ជួន មានចិត្តវិលវល់ មានឥន្ទ្រិយមិនសង្រួមទៅជាប្រក្រតី ក្នុងបរិស័ទណា ម្នាលភិក្ខុទាំងឡាយ បរិស័ទនេះហៅថា បរិស័ទរាក់ ។ ម្នាលភិក្ខុទាំងឡាយ ចុះបរិស័ទជ្រៅតើដូចម្តេច ។

ឥធ ភិក្ខវេ យស្សំ បរិសាយំ ភិក្ខូ អនុទ្ធតា ហោន្តិ អនុន្នឡា អចបលា អមុខរា អវិកិណ្ណវាចា ឧបដ្ឋិតស្សតី សម្បជានា សមាហិតា ឯកគ្គចិត្តា សំវុតិន្ទ្រិយា អយំ វុច្ចតិ ភិក្ខវេ អនុទ្ធតា បរិសា ។ ឥមា ខោ ភិក្ខវេ ទ្វេ បរិសា ។ ឯតទគ្គំ ភិក្ខវេ ឥមាសំ ទ្វិន្នំ បរិសានំ យទិទំ អនុទ្ធតា បរិសាតិ ។

[២៨៥] ទ្វេមា ភិក្ខវេ បរិសា ។ កតមា ទ្វេ ។ វគ្គា ច បរិសា សមគ្គា ច បរិសា ។ កតមា ច ភិក្ខវេ វគ្គា បរិសា ។ ឥធ ភិក្ខវេ យស្សំ បរិសាយំ ភិក្ខូ ភណ្ឌនជាតា កលហជាតា វិវាទាបន្នា អញ្ញមញ្ញំ មុខសត្តីហិ វិតុទន្តា វិហរន្តិ អយំ វុច្ចតិ ភិក្ខវេ វគ្គា បរិសា ។ កតមា ច ភិក្ខវេ សមគ្គា បរិសា ។



ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុក្នុងបរិសទណានេះ មានចិត្តមិនរាយមាយ មិនមានមានះដុះឡើង មិនឃ្លេងឃ្លោង មិនមានមាត់រឹង មិនមានពាក្យរាយមាយ មានស្មារតីតាំងមាំ មានសេចក្ដីដឹងខ្លួន មានចិត្តខ្ជាប់ខ្ជួន មានចិត្តនឹងនួន សង្រួមឥន្ទ្រិយ ក្នុងបរិសទណា ម្នាលភិក្ខុទាំងឡាយ បរិសទនេះហៅថា បរិសទស្ងប់ ។ ម្នាលភិក្ខុទាំងឡាយ បរិសទទាំងឡាយមាន ២ ពួកនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាបរិសទទាំង ២ ពួកនេះ បរិសទស្ងប់នេះឯងប្រសើរ ។

(២៨៥) ម្នាលភិក្ខុទាំងឡាយ បរិសទទាំងឡាយនេះមាន ២ ពួក ។ បរិសទ ២ ពួក តើដូចម្ដេច ។ គឺបរិសទបែកគ្នា ១ បរិសទព្រមព្រៀងគ្នា ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះបរិសទបែកគ្នា តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុក្នុងបរិសទណានេះ កើតមានការឈ្លោះគ្នា កើតមានការទាស់ទែងគ្នា ដល់នូវសេចក្ដីប្រកួតប្រកាន់គ្នា តែងពោលចាក់ដោតគ្នានឹងគ្នា ដោយលំពែងគឺមាត់ក្នុងបរិសទណា ម្នាលភិក្ខុទាំងឡាយ បរិសទនេះហៅថា បរិសទបែកគ្នា ។ ម្នាលភិក្ខុទាំងឡាយ ចុះបរិសទព្រមព្រៀងគ្នា តើដូចម្ដេច ។

ឥធ ភិក្ខវេ យស្សំ បរិសាយំ ភិក្ខូ សមគ្គា សម្មោទមានា អវិវទមានា ខីរោទកីភូតា អញ្ញមញ្ញំ បិយចក្ខូហិ សម្បស្សន្តា វិហរន្តិ អយំ វុច្ចតិ ភិក្ខវេ សមគ្គា បរិសា ។ ឥមា ខោ ភិក្ខវេ ទ្វេ បរិសា ។ ឯតទគ្គំ ភិក្ខវេ ឥមាសំ ទ្វិន្នំ បរិសានំ យទិទំ សមគ្គា បរិសាតិ ។

(២៨៩) ទ្វេមា ភិក្ខវេ បរិសា ។ កតមា ទ្វេ ។ អនគ្គវតី ច បរិសា អគ្គវតី ច បរិសា ។ កតមា ច ភិក្ខវេ អនគ្គវតី បរិសា ។ ឥធ ភិក្ខវេ យស្សំ បរិសាយំ ថេរា ភិក្ខូ ពាហុលិកា ហោន្តិ សាថលិកា ឱក្កមនេ បុព្វង្គមា បវិវេកេ និក្ខិត្តធុរា ន វីរិយំ អារភន្តិ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយ តេសំ បច្ឆិមា ជនតា ទិដ្ឋានុគតឹ អាបជ្ជតិ សាបិ ហោតិ ពាហុលិកា សាថលិកា



ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុក្នុងបរិស័ទណានេះជាអ្នកព្រមព្រៀងគ្នា មាន សេចក្ដីរីករាយនឹងគ្នា មិនប្រកួតប្រកាន់គ្នានឹងគ្នា ដូចជាទឹកដោះ ច្របល់នឹងទឹក តែងមើលមើលទៅគ្នានឹងគ្នា ដោយចក្ខុជាទីស្រឡាញ់ ក្នុងបរិស័ទណា ម្នាលភិក្ខុទាំងឡាយ បរិស័ទនេះហៅថា បរិស័ទព្រមព្រៀងគ្នា ម្នាលភិក្ខុទាំងឡាយ បរិស័ទទាំងឡាយមាន ២ ពួកនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាបរិស័ទទាំង ២ ពួកនេះ បរិស័ទជាអ្នកព្រមព្រៀងគ្នានុ៎ះឯងប្រសើរ ។

(២៨៩) ម្នាលភិក្ខុទាំងឡាយ បរិស័ទទាំងឡាយនេះ មាន ២ ពួក ។ បរិស័ទ ២ ពួក តើដូចម្ដេច ។ គឺបរិស័ទមានតែមិនប្រសើរ ១ បរិស័ទមានតែប្រសើរ ១ ។ ម្នាលភិក្ខុទាំងឡាយ បរិស័ទមានតែមិនប្រសើរ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុជាថេរៈក្នុងបរិស័ទណានេះ ជាអ្នកលោភច្រើន ជាអ្នកកាន់ធូរ ជាអ្នកដឹកនាំក្នុងការថយក្រោយ ដាក់ធុរៈក្នុងវិវេក មិនផ្ដើមព្យាយាម ដើម្បីដល់នូវគុណដែលមិនទាន់បានដល់ ដើម្បីសម្រេចនូវគុណដែលមិនទាន់បានសម្រេច ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណដែលមិនទាន់ជាក់ច្បាស់ ប្រជុំជនជាន់ក្រោយក៏ដល់នូវទិដ្ឋានុគតិ យកគម្រប់តាមព្រះថេរៈទាំងនោះ សូម្បីប្រជុំជននោះ ក៏ជាអ្នកលោភច្រើន ជាអ្នកកាន់ធូរ

## ទុតិយបណ្ណាសកេ បរិសវគ្គោ

ឱក្កមនេ បុព្វង្គមា បវិវេកេ និក្ខិត្តធុរា ន វីរិយំ អារភតិ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយ អយំ វុច្ចតិ ភិក្ខវេ អនគ្គវតី បរិសា ។ កតមា ច ភិក្ខវេ អគ្គវតី បរិសា ។ ឥធ ភិក្ខវេ យស្សំ បរិសាយំ ថេរា ភិក្ខូ ន ពាហុលិកា ហោន្តិ ន សាថលិកា ឱក្កមនេ និក្ខិត្តធុរា បវិវេកេ បុព្វង្គមា វីរិយំ អារភន្តិ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយ តេសំ បច្ឆិមា ជនតា ទិដ្ឋានុគតឹ អាបជ្ជតិ សាបិ ហោតិ ន ពាហុលិកា ន សាថលិកា ឱក្កមនេ និក្ខិត្តធុរា បវិវេកេ បុព្វង្គមា វីរិយំ អារភតិ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយ អយំ វុច្ចតិ ភិក្ខវេ អគ្គវតី បរិសា ។



## ទុតិយបណ្ណាសក បរិសវគ្គ

ជាអ្នកផ្តើមក្នុងការថយក្រោយ ដាក់ធុរៈក្នុងវិវេក មិនផ្តើមព្យាយាម ដើម្បីដល់នូវគុណដែលមិនទាន់បានដល់ ដើម្បីសម្រេចនូវគុណដែលមិនទាន់បានសម្រេច ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណដែលមិនទាន់ជាក់ច្បាស់ ក្នុងបរិស័ទណា ម្នាលភិក្ខុទាំងឡាយ បរិស័ទនេះហៅថា បរិស័ទមានតែមិនប្រសើរ ។ ម្នាលភិក្ខុទាំងឡាយ ចុះបរិស័ទមានតែប្រសើរ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុជាថេរៈក្នុងសាសនានេះ មិនជាអ្នកលោភច្រើន ជាអ្នកមិនធូរ ជាអ្នកដាក់ធុរៈក្នុងការថយក្រោយ ជាប្រធានក្នុងវិវេក ផ្តើមព្យាយាម ដើម្បីដល់នូវគុណដែលមិនទាន់បានដល់ ដើម្បីសម្រេចនូវគុណដែលមិនទាន់បានសម្រេច ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណដែលមិនទាន់បានជាក់ច្បាស់ ប្រជុំជនខាងក្រោយនឹងយកតម្រាប់តាមព្រះថេរៈទាំងនោះ សូម្បីប្រជុំជននោះ មិនជាអ្នកលោភច្រើន ជាអ្នកមិនកាន់ធូរ ជាអ្នកមិនដាក់ធុរៈក្នុងការថយក្រោយជាប្រធានក្នុងវិវេក ផ្តើមព្យាយាមដើម្បីដល់នូវគុណដែលមិនទាន់បានដល់ ដើម្បីសម្រេចនូវគុណដែលមិនទាន់សម្រេច ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណដែលមិនទាន់ជាក់ច្បាស់ ក្នុងបរិស័ទណា ម្នាលភិក្ខុទាំងឡាយ បរិស័ទនេះ ហៅថា បរិស័ទមានតែដ៏ប្រសើរ ។

ឥមា ខោ ភិក្ខវេ ទ្វេ បរិសា ។ ឯតទគ្គំ ភិក្ខវេ ឥមាសំ ទ្វិន្នំ បរិសានំ យទិទំ អគ្គវតី បរិសាតិ ។

[២៩០] ទ្វេមា ភិក្ខវេ បរិសា ។ កតមា ទ្វេ ។ អនរិយា ច បរិសា អរិយា ច បរិសា ។ កតមា ច ភិក្ខវេ អនរិយា បរិសា ។ ឥធ ភិក្ខវេ យស្សំ បរិសាយំ ភិក្ខូ ឥទំ ទុក្ខន្តិ យថាភូតំ នប្បជានន្តិ អយំ ទុក្ខសមុទយោតិ យថាភូតំ នប្បជានន្តិ អយំ ទុក្ខនិរោធោតិ យថាភូតំ នប្បជានន្តិ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ នប្បជានន្តិ អយំ វុច្ចតិ ភិក្ខវេ អនរិយា បរិសា ។ កតមា ច ភិក្ខវេ អរិយា បរិសា ។ ឥធ ភិក្ខវេ យស្សំ បរិសាយំ ភិក្ខូ ឥទំ ទុក្ខន្តិ យថាភូតំ បជានន្តិ អយំ ទុក្ខសមុទយោតិ យថាភូតំ បជានន្តិ អយំ ទុក្ខនិរោធោតិ យថាភូតំ បជានន្តិ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ បជានន្តិ អយំ វុច្ចតិ ភិក្ខវេ អរិយា បរិសា ។



ម្នាលភិក្ខុទាំងឡាយ បរិស័ទមានពីរពួកនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាបរិស័ទទាំងពីរពួកនេះ បរិស័ទណាដែលប្រសើរទៅដោយជនប្រសើរ ។

(២៩០) ម្នាលភិក្ខុទាំងឡាយ បរិស័ទនេះមាន ២ ពួក ។ បរិស័ទ ២ ពួក តើដូចម្ដេច ។ គឺបរិស័ទមិនប្រសើរ១ បរិស័ទប្រសើរ១ ។ ម្នាលភិក្ខុទាំងឡាយ បរិស័ទមិនប្រសើរ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុក្នុងសាសនានេះ មិនដឹងច្បាស់តាមពិតថា នេះជាទុក្ខ មិនដឹងច្បាស់តាមពិតថា នេះហេតុនាំឲ្យកើតឡើងនៃទុក្ខ មិនដឹងច្បាស់តាមពិតថា នេះជាទីរលត់ទុក្ខ មិនដឹងច្បាស់តាមពិតថា នេះបដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខ ក្នុងបរិស័ទណា ម្នាលភិក្ខុទាំងឡាយ បរិស័ទនេះ ហៅថាបរិស័ទមិនប្រសើរ ។ ម្នាលភិក្ខុទាំងឡាយ ចុះបរិស័ទប្រសើរ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុក្នុងសាសនានេះ ដឹងច្បាស់តាមពិតថា នេះទុក្ខ ដឹងច្បាស់តាមពិតថា នេះហេតុនាំឲ្យកើតឡើងនៃទុក្ខ ដឹងច្បាស់តាមពិតថា នេះជាទីរលត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះបដិបទា ជាដំណើរទៅកាន់ទីរលត់ទុក្ខ ក្នុងបរិស័ទណា ម្នាលភិក្ខុទាំងឡាយ បរិស័ទនេះ ហៅថាបរិស័ទប្រសើរ ។

ឥមា ខោ ភិក្ខវេ ទ្វេ បរិសា ។ ឯតទគ្គំ ភិក្ខវេ ឥមាសំ ទ្វិន្នំ បរិសានំ យទិទំ អរិយា បរិសាតិ ។

(៤៩១) ទ្វេមា ភិក្ខវេ បរិសា ។ កតមា ទ្វេ ។ បរិសកសដោ ច បរិសមណ្ឌោ ច ។ កតមោ ច ភិក្ខវេ បរិសកសដោ ។ ឥធ ភិក្ខវេ យស្សំ បរិសាយំ ភិក្ខូ ឆន្ទាគតឹ គច្ឆន្តិ ទោសាគតឹ គច្ឆន្តិ មោហាគតឹ គច្ឆន្តិ ភយាគតឹ គច្ឆន្តិ អយំ វុច្ចតិ ភិក្ខវេ បរិសកសដោ ។ កតមោ ច ភិក្ខវេ បរិសមណ្ឌោ ។ ឥធ ភិក្ខវេ យស្សំ បរិសាយំ ភិក្ខូ ន ឆន្ទាគតឹ គច្ឆន្តិ ន ទោសាគតឹ គច្ឆន្តិ ន មោហាគតឹ គច្ឆន្តិ ន ភយាគតឹ គច្ឆន្តិ អយំ វុច្ចតិ ភិក្ខវេ បរិសមណ្ឌោ ។ ឥមា ខោ ភិក្ខវេ ទ្វេ បរិសា ។ ឯតទគ្គំ ភិក្ខវេ ឥមាសំ ទ្វិន្នំ បរិសានំ យទិទំ បរិសមណ្ឌោតិ ។



ម្នាលភិក្ខុទាំងឡាយ បរិស័ទ មាន២ពួកនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាបរិស័ទទាំង២ពួកនេះ បរិស័ទប្រសើរនុ៎ះទើបប្រសើរ ។

(៤៩១) ម្នាលភិក្ខុទាំងឡាយ បរិស័ទនេះមាន២ពួក ។ បរិស័ទ ២ពួក តើដូចម្តេច ។ គឺបរិស័ទស្រោកស្រកា១ បរិស័ទផូរផង់១ ។ ម្នាលភិក្ខុទាំងឡាយ បរិស័ទស្រោកស្រកា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុក្នុងសាសនានេះ លុះក្នុងអំណាចឆន្ទាគតិ លុះក្នុងអំណាចទោសាគតិ លុះក្នុងអំណាចមោហាគតិ លុះក្នុងអំណាចភយាគតិ ក្នុងបរិស័ទណា ម្នាលភិក្ខុទាំងឡាយ បរិស័ទនេះ ហៅថា បរិស័ទស្រោកស្រកា ។ ម្នាលភិក្ខុទាំងឡាយ ចុះបរិស័ទផូរផង់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុក្នុងសាសនានេះ មិនលុះក្នុងអំណាចឆន្ទាគតិ មិនលុះក្នុងអំណាចទោសាគតិ មិនលុះក្នុងអំណាចមោហាគតិ មិនលុះក្នុងអំណាចភយាគតិ ក្នុងបរិស័ទណា ម្នាលភិក្ខុទាំងឡាយ បរិស័ទនេះហៅថា បរិស័ទផូរផង់ ។ ម្នាលភិក្ខុទាំងឡាយ បរិស័ទមាន២ពួកនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាបរិស័ទទាំង២ពួកនេះ បរិស័ទផូរផង់នុ៎ះទើបប្រសើរ ។

(២៩២) ទ្វេមា ភិក្ខវេ បរិសា ។ កតមា ទ្វេ ។ ឧក្កាចិតវិនីតា បរិសា នោ បដិបុច្ឆាវិនីតា បដិបុច្ឆាវិនីតា បរិសា នោ ឧក្កាចិតវិនីតា ។ កតមា ច ភិក្ខវេ ឧក្កាចិតវិនីតា បរិសា នោ បដិបុច្ឆាវិនីតា ។ ឥធ ភិក្ខវេ យស្សំ បរិសាយំ ភិក្ខូ យេ តេ សុត្តន្តា តថាគតភាសិតា គម្ភីរា គម្ភីរត្ថា លោកុត្តរា សុញ្ញតប្បដិសំយុត្តា តេសុ ភញ្ញមានេសុ ន សុស្សូសន្តិ ន សោតំ ឱទហន្តិ ន អញ្ញាចិត្តំ ឧបដ្ឋាបេន្តិ ន ច តេ ធម្មេ ឧគ្គហេតព្វំ បរិយាបុណិតព្វំ មញ្ញន្តិ យេ បន តេ សុត្តន្តា កវិកតា កាវេយ្យា ចិត្តក្ខរា ចិត្តព្យញ្ជនា ពាហិរកា សាវកភាសិតា តេសុ ភញ្ញមានេសុ សុស្សូសន្តិ សោតំ ឱទហន្តិ អញ្ញាចិត្តំ ឧបដ្ឋាបេន្តិ តេ ច ធម្មេ ឧគ្គហេតព្វំ បរិយាបុណិតព្វំ មញ្ញន្តិ តេ តំ ធម្មំ បរិយាបុណិត្វា ន ចេវ អញ្ញមញ្ញំ បដិបុច្ឆន្តិ ន បដិវិវរន្តិ ឥទំ កថមិទស្ស ក្វត្ថោតិ



(២៩២) ម្នាលភិក្ខុទាំងឡាយ បរិស័ទនេះមាន ២ ពួក ។ បរិស័ទ ២ ពួក តើដូចម្តេច ។ គឺបរិស័ទសិក្សាខុសទំនង មិនសិក្សាដោយការសាកសួរ ១ បរិស័ទសិក្សាដោយការសាកសួរ មិនសិក្សាខុសទំនង ១ ។ ម្នាលភិក្ខុទាំងឡាយ បរិស័ទសិក្សាខុសទំនង មិនសិក្សាដោយការសាកសួរ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពួកសូត្រណាដែលជាភាសិតរបស់តថាគត ដ៏ជ្រាលជ្រៅ មានអត្ថដ៏ជ្រាលជ្រៅ ជាលោកុត្តរៈ ប្រកបដោយសុញ្ញតធម៌ កាលបើពួកសូត្រនោះដែលគេកំពុងសំដែងក៏មិនប្រុងស្តាប់ មិនផ្ទៀងត្រចៀកស្តាប់ មិនទប់ចិត្តដែលយល់ងាយ ទាំងមិនសំគាល់ថា គួររៀនគួរសិក្សាធម៌ទាំងនោះឡើយ ពួកសូត្រណាដែលអ្នកប្រាជ្ញ ចាក់តែងទុកជាកាព្យកាព្យ មានអក្សរវិចិត្រ មានព្យញ្ជនៈវិចិត្រ ជាសូត្រខាងក្រៅ ជាសាវកភាសិត កាលបើសូត្រទាំងនោះដែលគេកំពុងសំដែង ក៏ប្រុងស្តាប់ ផ្ទៀងត្រចៀកស្តាប់ ទប់ចិត្តដែលយល់ងាយ ទាំងសំគាល់ថាគួររៀនគួរសិក្សាធម៌ទាំងនោះផង ភិក្ខុទាំងនោះ លុះសិក្សាធម៌នោះហើយ មិនបានសាកសួរគ្នាទៅវិញទៅមក មិនបើកបើកថា ព្យញ្ជនៈនេះដូចម្តេច សេចក្តីរបស់ភាសិតនេះដូចម្តេច

តេ អវិវដញ្ចេវ ន វិវរន្តិ អនុត្តានីកតញ្ច ន ឧត្តានីករោន្តិ អនេកវិហិតេសុ ច កង្ខាឋានីយេសុ ធម្មេសុ កង្ខំ ន បដិវិនោទេន្តិ អយំ វុច្ចតិ ភិក្ខវេ ឧក្កាចិតវិនីតា បរិសា នោ បដិបុច្ឆាវិនីតា ។ កតមា ច ភិក្ខវេ បដិបុច្ឆាវិនីតា បរិសា នោ ឧក្កាចិតវិនីតា ។ ឥធ ភិក្ខវេ យស្សំ បរិសាយំ ភិក្ខូ យេ តេ សុត្តន្តា កវិកតា កាវេយ្យា ចិត្តក្ខរា ចិត្តព្យញ្ជនា ពាហិរកា សាវកភាសិតា តេសុ ភញ្ញមានេសុ ន សុស្សូសន្តិ ន សោតំ ឱទហន្តិ ន អញ្ញាចិត្តំ ឧបដ្ឋាបេន្តិ ន ច តេ ធម្មេ ឧគ្គហេតព្វំ បរិយាបុណិតព្វំ មញ្ញន្តិ យេ បន តេ សុត្តន្តា តថាគតភាសិតា គម្ភីរា គម្ភីរត្ថា លោកុត្តរា សុញ្ញតប្បដិសំយុត្តា តេសុ ភញ្ញមានេសុ សុស្សូសន្តិ សោតំ ឱទហន្តិ អញ្ញាចិត្តំ ឧបដ្ឋាបេន្តិ តេ ច ធម្មេ ឧគ្គហេតព្វំ បរិយាបុណិតព្វំ មញ្ញន្តិ តេ តំ ធម្មំ បរិយាបុណិត្វា អញ្ញមញ្ញំ បដិបុច្ឆន្តិ បដិវិចរន្តិ





ភិក្ខុទាំងនោះ មិនបានបើករបស់ដែលគេបិទនៅឡើយ មិនបានធ្វើរបស់ដែលជ្រៅឲ្យរាក់ឡើង មិនបន្ទោបង់សេចក្ដីសង្ស័យ ក្នុងធម៌ទាំងឡាយដែលជាហេតុគួរឲ្យសង្ស័យជាច្រើនប្រការឡើង ក្នុងបរិស័ទណា ម្នាលភិក្ខុទាំងឡាយ បរិស័ទនេះហៅថា បរិស័ទសិក្សាដោយសង្ខេប មិនសិក្សាដោយការសាកសួរឡើយ ។ ម្នាលភិក្ខុទាំងឡាយ ចុះបរិស័ទសិក្សាដោយការសាកសួរ មិនសិក្សាដោយសង្ខេប តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុក្នុងបរិស័ទនេះ ពួកសូត្រណាដែលអ្នកប្រាជ្ញតែងជាពាក្យកាព្យ មានអក្សរវិចិត្រ មានព្យញ្ជនៈវិចិត្រ ជារបស់ខាងក្រៅ ជាសាវកភាសិត កាលបើសូត្រទាំងនោះដែលគេកំពុងសំដែង ក៏មិនប្រុងស្ដាប់ មិនផ្ទៀងត្រចៀកស្ដាប់ មិនតម្កល់ចិត្តដើម្បីដឹង ទាំងមិនសំគាល់ថា គួររៀន គួរសិក្សាធម៌ទាំងនោះដែរ ឯពួកសូត្រណាដែលជាភាសិតរបស់តថាគត ដ៏ជ្រាលជ្រៅ មានអត្ថដ៏ជ្រាលជ្រៅ ជាលោកុត្តរៈ ប្រកបដោយសុញ្ញតធម៌ កាលបើសូត្រទាំងនោះដែលគេកំពុងសំដែង ក៏ប្រុងស្ដាប់ ផ្ទៀងត្រចៀកស្ដាប់ តម្កល់ចិត្តដើម្បីដឹង ទាំងសំគាល់ថា គួររៀន គួរសិក្សាធម៌ទាំងនោះដែរ លុះភិក្ខុទាំងនោះសិក្សាធម៌នោះហើយ សាកសួរគ្នាទៅវិញទៅមក ពិចារ

ឥទំ កថមិមស្ស កោ អត្ថោតិ ។ តេ អវិវដញ្ចេវ វិវរន្តិ អនុត្តានីកតញ្ច ឧត្តានីករោន្តិ អនេកវិហិតេសុ ច កង្ខាឋានិយេសុ ធម្មេសុ កង្ខំ បដិវិនោទេន្តិ អយំ វុច្ចតិ ភិក្ខវេ បដិបុច្ឆាវិនីតា បរិសា នោ ឧក្កាចិតវិនីតា ។ ឥមា ខោ ភិក្ខវេ ទ្វេ បរិសា ។ ឯតទគ្គំ ភិក្ខវេ ឥមាសំ ទ្វិន្នំ បរិសានំ យទិទំ បដិបុច្ឆាវិនីតា បរិសា នោ ឧក្កាចិតវិនីតាតិ ។

(២៤៣) ទ្វេមា ភិក្ខវេ បរិសា ។ កតមា ទ្វេ ។ អាមិសគរុ បរិសា នោ សទ្ធម្មគរុ សទ្ធម្មគរុ បរិសា នោ អាមិសគរុ ។ កតមា ច ភិក្ខវេ អាមិសគរុ បរិសា នោ សទ្ធម្មគរុ ។ ឥធ ភិក្ខវេ យស្សំ បរិសាយំ ភិក្ខូ គិហីនំ ឱទាតវសនានំ សម្មុខា អញ្ញមញ្ញស្ស វណ្ណំ ភាសន្តិ អសុកោ ភិក្ខុ ឧភតោភាគវិមុត្តោ



ព្យញ្ជនៈនេះដូចម្តេច អត្ថរបស់ភាសិតនេះដូចម្តេច ភិក្ខុទាំងនោះបើករបស់ដែលកំបាំងផង ធ្វើរបស់ដែលជ្រៅឲ្យរាក់ផង បន្ទោបង់សេចក្តីសង្ស័យ ក្នុងធម៌ទាំងឡាយដែលជាហេតុ នាំឲ្យសង្ស័យជាច្រើនស្ថានផងដែរ ក្នុងបរិស័ទណា ម្នាលភិក្ខុទាំងឡាយ បរិស័ទនេះហៅថា បរិស័ទសិក្សាដោយការសាកសួរ មិនសិក្សាខុសចំនងឡើយ ។ ម្នាលភិក្ខុទាំងឡាយ បរិស័ទមានពីរពួកនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាបរិស័ទពីរពួកនេះ បរិស័ទដែលសិក្សាដោយការសាកសួរ មិនសិក្សាខុសចំនងនុ៎ះឯងប្រសើរ ។

[២៤៣] ម្នាលភិក្ខុទាំងឡាយ បរិស័ទនេះ មាន ២ ពួក ។ បរិស័ទ ២ ពួកតើដូចម្តេច ។ គឺបរិស័ទធ្ងន់ក្នុងអាមិសៈ មិនធ្ងន់ក្នុងព្រះសទ្ធម្ម ១ បរិស័ទធ្ងន់ក្នុងព្រះសទ្ធម្ម មិនធ្ងន់ក្នុងអាមិសៈ ១ ។ ម្នាលភិក្ខុទាំងឡាយ បរិស័ទធ្ងន់ក្នុងអាមិសៈ មិនធ្ងន់ក្នុងព្រះសទ្ធម្ម តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុក្នុងសាសនានេះ សរសើរគុណទៅវិញទៅមក ចំពោះមុខពួកគ្រហស្ថដែលស្លៀកសថា ភិក្ខុឯណោះជាឧភតោភាគវិមុត្ត (១)

---

១- បានដល់ភិក្ខុដែលបានសម្រេចវិមោក្ខទាំង ៨ គឺរូបសមាបត្តិ៤ អរូបសមាបត្តិ៤ ហើយបានសម្រេចអាសវក្ខយញ្ញាណដោយវិបស្សនា ដែលមានសមាធិជាបាទ ។

អស្សុតោ បញ្ញាវិមុត្តោ អស្សុតោ កាយសក្ខី

អស្សុតោ ទិដ្ឋិប្បត្តោ អស្សុតោ សទ្ធាវិមុត្តោ

អស្សុតោ ធម្មានុសារី អស្សុតោ សទ្ធានុសារី

អស្សុតោ សីលវា កល្យាណធម្មោ អស្សុតោ

ទុស្សីលោ បាបធម្មោតិ តេ តេន លាភំ លភន្តិ

តេ តំ លាភំ លភិត្វា គធិតា មុច្ឆិតា អជ្ឈោបន្នា

អនាទីនវទស្សាវិនោ អនិស្សរណបញ្ញា បរិភុញ្ជន្តិ

អយំ វុត្តិ ភិក្ខវេ អភិសមាគតា ឋានំ នោ សទ្ធម្មស្ស ។



ភិក្ខុឯណាជាបញ្ញាវិមុត្ត(១) ភិក្ខុឯណាជាកាយសក្ខី(២) ភិក្ខុឯណាជាទិដ្ឋិប្បត្ត ភិក្ខុឯណាជាសទ្ធាវិមុត្ត(៣) ភិក្ខុឯណាជាធម្មានុសារី(៤) ភិក្ខុឯណាជាសទ្ធានុសារី(៦) ភិក្ខុឯណាជាអ្នកមានសីល មានកល្យាណធម៌ ភិក្ខុឯណាជាអ្នកទ្រុស្តសីល មានបាបធម៌ ភិក្ខុទាំងនោះតែងបានលាភដោយសារសីលនោះ លុះភិក្ខុទាំងនោះបានលាភនោះហើយ ក៏ជ្រប់ស្រប់ងប់ (ក្នុងលាភនោះ) មិនឃើញទោស មិនមានបញ្ញាសម្រាប់រើខ្លួន ក៏បរិភោគលាភនោះ គឺថាសីលណា ម្នាលភិក្ខុទាំងឡាយ បរិយេសនេះ ពុំជាបរិយេសទុកនូវព្រះសទ្ធម្មឡើយ ។

---

១- បានដល់បុគ្គលដែលមិនបានពាល់តាមសម្រេចវិមោក្ខធម៌ទាំង ៨ ឡើយ គ្រាន់តែចំរើនវិបស្សនាតែម្ដង ក៏បានសម្រេចអរហត្តផល (ជាសុក្ខវិបស្សក:) ។

២- បានដល់បុគ្គល ដែលបានសម្រេចវិមោក្ខធម៌ទាំង៨ ហើយចំរើនវិបស្សនា តែបានសម្រេចសោតាបត្តិមគ្គ រហូតដល់អរហត្តមគ្គ ។

៣- បានដល់បុគ្គល ដែលចំរើនវិបស្សនា ហើយព្រាល់ដឹងនូវអរិយសច្ចទាំង៤ ។

៤- បានដល់បុគ្គល ដែលចំរើនវិបស្សនាហើយព្រាល់ដឹងនូវអរិយសច្ចទាំង ៤ បានសម្រេចសោតាបត្តិផល រហូតដល់អរហត្តផល ។

៥- បានដល់បុគ្គល ដែលបរិបូណ៌ដោយបញ្ញា មានបញ្ញាជាធំឡើងទៅបានសម្រេចសោតាបត្តិមគ្គ ហើយក៏ប្រតិបត្តិដើម្បីបាននូវសោតាបត្តិផល ។

៦- បានដល់បុគ្គល ដែលបរិបូណ៌ដោយសទ្ធា មានសទ្ធាជាធំឡើងទៅបានសម្រេចសោតាបត្តិមគ្គ ហើយក៏ប្រតិបត្តិដើម្បីបាននូវសោតាបត្តិផល ។

កតមា ច ភិក្ខវេ សទ្ធម្មគរុ បរិសា នោ អាមិសគរុ ។ ឥធ ភិក្ខវេ យស្សំ បរិសាយំ ភិក្ខូ ន គិហីនំ ធុតាភិសោធនំ សម្មុខា អញ្ញមញ្ញស្ស វណ្ណំ ភាសន្តិ អសុកោ ភិក្ខុ ឧភតោភាគវិមុត្តោ អសុកោ បញ្ញាវិមុត្តោ អសុកោ កាយសក្ខី អសុកោ ទិដ្ឋិប្បត្តោ អសុកោ សទ្ធាវិមុត្តោ អសុកោ ធម្មានុសារី អសុកោ សទ្ធានុសារី អសុកោ សីលវា កល្យាណធម្មោ អសុកោ ទុស្សីលោ បាបធម្មោតិ ។ តេ តេន លាភំ លភន្តិ តេ តំ លាភំ លភិត្វា អគធិតា អមុច្ឆិតា អនជ្ឈាបន្នា អាទីនវទស្សាវិនោ និស្សរណបញ្ញា បរិភុញ្ជន្តិ អយំ វុច្ចតិ ភិក្ខវេ សទ្ធម្មគរុ បរិសា នោ អាមិសគរុ ។ ឥមា ខោ ភិក្ខវេ ទ្វេ បរិសា ។ ឯតទគ្គំ ភិក្ខវេ ឥមាសំ ទ្វិន្នំ បរិសានំ យទិទំ សទ្ធម្មគរុ បរិសា នោ អាមិសគរុតិ ។



ម្នាលភិក្ខុទាំងឡាយ ចុះបរិស័ទគោរពនូវព្រះសទ្ធម្ម មិនគោរពនូវអាមិស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុក្នុងសាសនានេះ មិនសរសើរគុណគ្នាទៅវិញទៅមក ចំពោះមុខពួកគ្រហស្ថ ថ្លែងសរសើរថា ភិក្ខុឯណោះជាឧភតោភាគវិមុត្ត ភិក្ខុឯណោះជាបញ្ញាវិមុត្ត ភិក្ខុឯណោះជាកាយសក្ខី ភិក្ខុឯណោះជាទិដ្ឋិប្បត្ត ភិក្ខុឯណោះជាសទ្ធាវិមុត្ត ភិក្ខុឯណោះជាធម្មានុសារី ភិក្ខុឯណោះជាសទ្ធានុសារី ភិក្ខុឯណោះជាអ្នកមានសីល មានកល្យាណធម៌ ភិក្ខុឯណោះជាអ្នកទ្រុស្តសីល មានបាបធម៌ដូច្នេះឡើយ ភិក្ខុទាំងនោះបានដល់នូវលាភដោយមិនពោលសរសើរគ្នាទៅវិញទៅមក លុះភិក្ខុទាំងនោះបានលាភនោះហើយ មិនជ្រប់ មិនស្រវឹង មិនលង់ចុះ (ក្នុងលាភនោះ) ឃើញទោស មានបញ្ញាសម្រាប់រំដោះខ្លួន ក៏បរិភោគ (លាភនោះ) ក្នុងបរិស័ទណា ម្នាលភិក្ខុទាំងឡាយ បរិស័ទនោះហៅថា បរិស័ទគោរពនូវព្រះសទ្ធម្ម មិនគោរពនូវអាមិសៈឡើយ ។ ម្នាលភិក្ខុទាំងឡាយ បរិស័ទមាន ២ ពួកនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាបរិស័ទទាំង ២ ពួកនេះ បរិស័ទគោរពនូវព្រះសទ្ធម្ម មិនគោរពនូវអាមិសៈ ជាបរិស័ទប្រសើរ ។

(៤៨៦) ទ្វេមា ភិក្ខវេ បរិសា ។ កតមា ទ្វេ ។ វិសមា ច បរិសា សមា ច បរិសា ។ កតមា ច ភិក្ខវេ វិសមា បរិសា ។ ឥធ ភិក្ខវេ យស្សំ បរិសាយំ អធម្មកម្មានិ បវត្តន្តិ ធម្មកម្មានិ នប្បវត្តន្តិ អវិនយកម្មានិ បវត្តន្តិ វិនយកម្មានិ នប្បវត្តន្តិ អធម្មកម្មានិ ទិប្បន្តិ ធម្មកម្មានិ ន ទិប្បន្តិ អវិនយកម្មានិ ទិប្បន្តិ វិនយកម្មានិ ន ទិប្បន្តិ អយំ វុច្ចតិ ភិក្ខវេ វិសមា បរិសា ។ វិសមត្តា ភិក្ខវេ បរិសាយ អធម្មកម្មានិ បវត្តន្តិ ធម្មកម្មានិ នប្បវត្តន្តិ អវិនយកម្មានិ បវត្តន្តិ វិនយកម្មានិ នប្បវត្តន្តិ អធម្មកម្មានិ ទិប្បន្តិ ធម្មកម្មានិ ន ទិប្បន្តិ អវិនយកម្មានិ ទិប្បន្តិ វិនយកម្មានិ ន ទិប្បន្តិ ។ កតមា ច ភិក្ខវេ សមា បរិសា ។ ឥធ ភិក្ខវេ យស្សំ បរិសាយំ ធម្មកម្មានិ បវត្តន្តិ អធម្មកម្មានិ នប្បវត្តន្តិ វិនយកម្មានិ បវត្តន្តិ អវិនយកម្មានិ នប្បវត្តន្តិ ធម្មកម្មានិ ទិប្បន្តិ អធម្មកម្មានិ ន ទិប្បន្តិ វិនយកម្មានិ ទិប្បន្តិ អវិនយកម្មានិ ន ទិប្បន្តិ





(៤៨៦) ម្នាលភិក្ខុទាំងឡាយ បរិស័ទនេះមាន ២ ពួក ។ បរិស័ទ ២ ពួក តើដូចម្តេច ។ គឺបរិស័ទមិនស្មើ ១ បរិស័ទស្មើ ១ ។ ម្នាលភិក្ខុទាំងឡាយ បរិស័ទមិនស្មើ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ក្នុងបរិស័ទណានីមួយ អធម្មកម្ម (អំពើខុសធម៌) ប្រព្រឹត្តទៅបាន ធម្មកម្ម (អំពើត្រូវធម៌) ប្រព្រឹត្តទៅមិនបាន អវិនយកម្ម (អំពើខុសវិន័យ) ប្រព្រឹត្តទៅបាន វិនយកម្ម (អំពើត្រូវវិន័យ) ប្រព្រឹត្តទៅមិនបាន អធម្មកម្ម រុងរឿង ធម្មកម្មមិនរុងរឿង អវិនយកម្ម រុងរឿង វិនយកម្មមិនរុងរឿងក្នុងបរិស័ទណា ម្នាលភិក្ខុទាំងឡាយ បរិស័ទនេះហៅថា បរិស័ទមិនស្មើ ។ ម្នាលភិក្ខុទាំងឡាយ (ម្នាក់) អធម្មកម្ម ប្រព្រឹត្តទៅបាន ធម្មកម្ម ប្រព្រឹត្តទៅមិនបាន អវិនយកម្ម ប្រព្រឹត្តទៅបាន វិនយកម្មប្រព្រឹត្តទៅមិនបាន អធម្មកម្ម រុងរឿង ធម្មកម្ម មិនរុងរឿង អវិនយកម្ម រុងរឿង វិនយកម្ម មិនរុងរឿង ព្រោះបរិស័ទប្រព្រឹត្តមិនស្មើ ។ ម្នាលភិក្ខុទាំងឡាយ ចុះបរិស័ទស្មើតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ក្នុងបរិស័ទណានីមួយ ធម្មកម្ម ប្រព្រឹត្តទៅបាន អធម្មកម្ម ប្រព្រឹត្តទៅមិនបាន វិនយកម្ម ប្រព្រឹត្តទៅបាន អវិនយកម្ម ប្រព្រឹត្តទៅមិនបាន ធម្មកម្មរុងរឿង អធម្មកម្ម មិនរុងរឿង វិនយកម្ម រុងរឿង អវិនយកម្ម មិនរុងរឿងក្នុងបរិស័ទណា

អយំ វុច្ចតិ ភិក្ខវេ សមា បរិសា ។ សមាយ ភិក្ខវេ បរិសាយ ធម្មកម្មានិ បវត្តន្តិ អធម្មកម្មានិ នប្បវត្តន្តិ វិនយកម្មានិ បវត្តន្តិ អវិនយកម្មានិ នប្បវត្តន្តិ ធម្មកម្មានិ ទិប្បន្តិ អធម្មកម្មានិ ន ទិប្បន្តិ វិនយកម្មានិ ទិប្បន្តិ អវិនយកម្មានិ ន ទិប្បន្តិ ។ ឥមា ខោ ភិក្ខវេ ទ្វេ បរិសា ។ ឯតទគ្គំ ភិក្ខវេ ឥមាសំ ទ្វិន្នំ បរិសានំ យទិទំ សមា បរិសាតិ ។

[២៩០] ទ្វេមា ភិក្ខវេ បរិសា ។ កតមា ទ្វេ ។ អធម្មិកា ច បរិសា ធម្មិកា ច បរិសា ។ បេ ។ ឥមា ខោ ភិក្ខវេ ទ្វេ បរិសា ។ ឯតទគ្គំ ភិក្ខវេ ឥមាសំ ទ្វិន្នំ បរិសានំ យទិទំ ធម្មិកា បរិសាតិ ។

[២៩១] ទ្វេមា ភិក្ខវេ បរិសា ។ កតមា ទ្វេ ។ អធម្មវាទី ច បរិសា ធម្មវាទី ច បរិសា ។ កតមា ច ភិក្ខវេ អធម្មវាទី បរិសា ។



ម្នាលភិក្ខុទាំងឡាយ បរិស័ទនេះហៅថា បរិស័ទរាបស្មើ ។ ម្នាលភិក្ខុទាំងឡាយ (ក្នុងនោះ) ធម្មកម្ម ប្រព្រឹត្តទៅបាន អធម្មកម្ម ប្រព្រឹត្តទៅមិនបាន វិនយកម្ម ប្រព្រឹត្តទៅបាន អវិនយកម្ម ប្រព្រឹត្តទៅមិនបាន ធម្មកម្ម រុងរឿង អធម្មកម្ម មិនរុងរឿង វិនយកម្ម រុងរឿង អវិនយកម្ម មិនរុងរឿង ព្រោះបរិស័ទប្រព្រឹត្តរាបស្មើ ។ ម្នាលភិក្ខុទាំងឡាយ បរិស័ទមាន ២ ពួកនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាបរិស័ទទាំងពីរពួកនេះ បរិស័ទរាបស្មើនុ៎ះ ទើបប្រសើរ ។

(២៩០) ម្នាលភិក្ខុទាំងឡាយ បរិស័ទនេះមាន ២ ពួក ។ បរិស័ទ ២ ពួកតើដូចម្តេច ។ គឺបរិស័ទមិនប្រព្រឹត្តតាមធម៌ ១ បរិស័ទប្រព្រឹត្តតាមធម៌ ១ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ បរិស័ទមាន ២ ពួកនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាបរិស័ទទាំងពីរពួកនេះ បរិស័ទប្រព្រឹត្តតាមធម៌នុ៎ះ ទើបប្រសើរ ។

(២៩១) ម្នាលភិក្ខុទាំងឡាយ បរិស័ទនេះមាន ២ ពួក ។ បរិស័ទ ២ ពួកតើដូចម្តេច ។ គឺបរិស័ទមិនពោលតាមធម៌ ១ បរិស័ទពោលតាមធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះបរិស័ទមិនពោលតាមធម៌ តើដូចម្តេច

ឥធ ភិក្ខវេ យស្សំ បរិសាយំ ភិក្ខូ អធិករណំ អាបជ្ជន្តិ ធម្មិកំ វា អធម្មិកំ វា តេ តំ អធិករណំ អាបជ្ជិត្វា ន ចេវ អញ្ញមញ្ញំ សញ្ញាបេន្តិ ន ច សញ្ញត្តឹ ឧបគច្ឆន្តិ ន ច និជ្ឈាបេន្តិ ន ច និជ្ឈត្តឹ ឧបគច្ឆន្តិ តេ អសញ្ញត្តិពលា អនិជ្ឈត្តិពលា អប្បដិនិស្សគ្គមន្តិនោ តមេវ អធិករណំ ថាមសា បរាមស្ស(១) អភិនិវិស្ស វោហរន្តិ ឥទមេវ សច្ចំ មោឃមញ្ញន្តិ អយំ វុច្ចតិ ភិក្ខវេ អធម្មិកា បរិសា ។ កតមា ច ភិក្ខវេ ធម្មិកា បរិសា ។ ឥធ ភិក្ខវេ យស្សំ បរិសាយំ ភិក្ខូ អធិករណំ អាបជ្ជន្តិ ធម្មិកំ វា អធម្មិកំ វា តេ តំ អធិករណំ អាបជ្ជិត្វា អញ្ញមញ្ញំ សញ្ញាបេន្តិ ចេវ សញ្ញត្តិញ្ច ឧបគច្ឆន្តិ និជ្ឈាបេន្តិ ច និជ្ឈត្តិញ្ច ឧបគច្ឆន្តិ តេ សញ្ញត្តិពលា និជ្ឈត្តិពលា បដិនិស្សគ្គមន្តិនោ ន តមេវ អធិករណំ ថាមសា បរាមស្ស(១) អភិនិវិស្ស វោហរន្តិ ឥទមេវ សច្ចំ មោឃមញ្ញន្តិ

១ ម. បាមសា ។



ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុក្នុងសាសនានេះ កាន់យកអធិករណ៍ត្រូវតាមធម៌ក្តី មិនត្រូវតាមធម៌ក្តី លុះភិក្ខុទាំងនោះ កាន់យកអធិករណ៍នោះហើយ មិនពន្យល់គ្នាទៅវិញទៅមកផង មិនប្រជុំពន្យល់គ្នាផង មិននាំគ្នាពិនិត្យមើលផង មិនប្រជុំគ្នាពិនិត្យមើលផង ភិក្ខុទាំងនោះមានការមិនយល់ជាកំឡាំង មានសេចក្តីមិនពិនិត្យជាកំឡាំង មានគំនិតមិនប្រុងលះបង់ជាប្រក្រតី រមែងប្រកាន់មាំដោយកំឡាំងទិដ្ឋិបរាមាសៈ ហើយពោលកាន់អធិករណ៍នោះថា នេះជាពាក្យពិតមែន ពាក្យដទៃឥតអំពើទេ ដូច្នេះ ក្នុងបរិស័ទណា ម្នាលភិក្ខុទាំងឡាយ បរិស័ទនេះហៅថា បរិស័ទមិនពោលតាមធម៌ ។ ម្នាលភិក្ខុទាំងឡាយ ចុះបរិស័ទពោលតាមធម៌ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុក្នុងសាសនានេះ កាន់យកអធិករណ៍ត្រូវតាមធម៌ក្តី មិនត្រូវតាមធម៌ក្តី លុះភិក្ខុទាំងនោះ កាន់យកអធិករណ៍នោះហើយ រមែងពន្យល់គ្នាទៅវិញទៅមកផង ប្រជុំពន្យល់គ្នាផង នាំគ្នាពិនិត្យមើលផង ប្រជុំគ្នាពិនិត្យមើលផង ភិក្ខុទាំងនោះមានការយល់ជាកំឡាំង មានការពិនិត្យជាកំឡាំង មានគំនិតប្រុងនឹងលះបង់ជាប្រក្រតី មិនប្រកាន់មាំដោយកំឡាំងទិដ្ឋិបរាមាសៈ ហើយពោលកាន់អធិករណ៍នោះថា នេះជាពាក្យពិតមែន ពាក្យដទៃឥតអំពើទេ ដូច្នេះ ក្នុងបរិស័ទណា

អយំ វុច្ចតិ ភិក្ខវេ ធម្មវាទិនី បរិសា ។ ឥមា ខោ ភិក្ខវេ ទ្វេ បរិសា ។ ឯតទគ្គំ ភិក្ខវេ ឥមាសំ ទ្វិន្នំ បរិសានំ យទិទំ ធម្មវាទិនី បរិសាតិ ។

បរិសវគ្គោ បញ្ចមោ ។

បណ្ណាសកោ បឋមោ សមត្តោ ។



ម្នាលភិក្ខុទាំងឡាយ បរិស័ទនេះ ហៅថា បរិស័ទពោលតាមធម៌ ។ ម្នាលភិក្ខុទាំងឡាយ បរិស័ទមានពីរពួកនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាបរិស័ទទាំងពីរពួកនេះ បរិស័ទពោលតាមធម៌នុ៎ះឯងប្រសើរ ។

ចប់ បរិសវគ្គ ទី ៥ ។

ចប់ បឋមបណ្ណាសក ។

## ទុតិយបណ្ណាសកោ

(២៨៧) ទ្វេមេ ភិក្ខវេ បុគ្គលា លោកេ ឧប្ប-ជ្ជមានា ឧប្បជ្ជន្តិ ពហុជនហិតាយ ពហុជនសុខាយ ពហុនោ ជនស្ស អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ ។ កតមេ ទ្វេ ។ តថាគតោ ច អរហំ សម្មាសម្ពុទ្ធោ រាជា ច ចក្កវត្តិ ។ ឥមេ ខោ ភិក្ខវេ ទ្វេ បុគ្គលា លោកេ ឧប្បជ្ជមានា ឧប្បជ្ជន្តិ ពហុជនហិតាយ ពហុជនសុខាយ ពហុនោ ជនស្ស អត្ថាយ ហិតាយ សុខាយ ទេវ-មនុស្សានន្តិ ។

(២៨៨) ទ្វេមេ ភិក្ខវេ បុគ្គលា លោកេ ឧប្ប-ជ្ជមានា ឧប្បជ្ជន្តិ អច្ឆរិយមនុស្សា ។ កតមេ ទ្វេ ។ តថាគតោ ច អរហំ សម្មាសម្ពុទ្ធោ រាជា ច ចក្កវត្តិ ។ ឥមេ ខោ ភិក្ខវេ ទ្វេ បុគ្គលា លោកេ ឧប្បជ្ជមានា ឧប្បជ្ជន្តិ អច្ឆរិយមនុស្សាតិ ។

## ទុតិយបណ្ណាសក

(២៨៧) ម្នាលភិក្ខុទាំងឡាយ បុគ្គលពីរពួកនេះ កាលកើតឡើងក្នុងលោក តែងកើតឡើង ដើម្បីជាប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្ដីសុខដល់ជនច្រើន ដើម្បីសេចក្ដីចម្រើនដល់ជនច្រើន ដើម្បីជាប្រយោជន៍និងសេចក្ដីសុខដល់ទេវតានិងមនុស្សទាំងឡាយ ។ បុគ្គលពីរពួកតើដូចម្ដេច ។ គឺព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ ១ ស្ដេចចក្រពត្តិ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពីរពួកនេះ កាលកើតឡើងក្នុងលោក តែងកើតឡើង ដើម្បីជាប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្ដីសុខដល់ជនច្រើន ដើម្បីសេចក្ដីចម្រើនដល់ជនច្រើន ដើម្បីជាប្រយោជន៍និងសេចក្ដីសុខដល់ទេវតានិងមនុស្សទាំងឡាយ ។

(២៨៨) ម្នាលភិក្ខុទាំងឡាយ បុគ្គលពីរពួកនេះ កាលកើតឡើងក្នុងលោក តែងកើតឡើងជាមនុស្សអស្ចារ្យ ។ បុគ្គលទាំងពីរពួក តើដូចម្ដេច ។ គឺព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ ១ ស្ដេចចក្រពត្តិ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពីរពួកនេះ កាលកើតឡើងក្នុងលោក តែងកើតឡើងជាមនុស្សអស្ចារ្យ ។

[២៩៩] ទ្វិន្នំ ភិក្ខវេ បុគ្គលានំ កាលកិរិយា ពហុនោ ជនស្ស អនុតប្បា(១) ហោតិ ។ កតមេសំ ទ្វិន្នំ ។ តថាគតស្ស ច អរហតោ សម្មាសម្ពុទ្ធស្ស រញ្ញោ ច ចក្កវត្តិស្ស ។ ឥមេសំ ខោ ភិក្ខវេ ទ្វិន្នំ បុគ្គលានំ កាលកិរិយា ពហុនោ ជនស្ស អនុតប្បា ហោតីតិ ។

[៣០០] ទ្វេមេ ភិក្ខវេ ថូបារហា ។ កតមេ ទ្វេ ។ តថាគតោ ច អរហំ សម្មាសម្ពុទ្ធោ រាជា ច ចក្កវត្តី ។ ឥមេ ខោ ភិក្ខវេ ទ្វេ ថូបារហាតិ ។

[៣០១] ទ្វេមេ ភិក្ខវេ ពុទ្ធា ។ កតមេ ទ្វេ ។ តថាគតោ ច អរហំ សម្មាសម្ពុទ្ធោ បច្ចេកពុទ្ធោ ច ។ ឥមេ ខោ ភិក្ខវេ ទ្វេ ពុទ្ធាតិ ។

[៣០២] ទ្វេមេ ភិក្ខវេ អសនិយា ផលន្តិយា ន សន្តសន្តិ ។ កតមេ ទ្វេ ។ ភិក្ខុ ច ខីណាសវោ ហត្ថាជានីយោ ច ។ ឥមេ ខោ ភិក្ខវេ ទ្វេ អសនិយា ផលន្តិយា ន សន្តសន្តីតិ ។

១ ម. អនុតាបា ។



[២៩៩] ម្នាលភិក្ខុទាំងឡាយ កាលកិរិយារបស់បុគ្គលពីរពួក រមែងមានសេចក្ដីក្ដៅក្រហាយក្រោយដល់ជនច្រើន ។ បុគ្គលពីរពួក តើដូចម្ដេច ។ គឺព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ ១ ស្ដេចចក្រពត្តិ ១ ។ ម្នាលភិក្ខុទាំងឡាយ កាលកិរិយារបស់បុគ្គលពីរពួកនេះ រមែងមានសេចក្ដីក្ដៅក្រហាយក្រោយដល់ជនច្រើន ។

[៣០០] ម្នាលភិក្ខុទាំងឡាយ ថូបារហបុគ្គល (បុគ្គលគួរដល់ថូប) នេះមានពីរពួក ។ ថូបារហបុគ្គលពីរពួក តើដូចម្ដេច ។ គឺព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ ១ ស្ដេចចក្រពត្តិ ១ ។ ម្នាលភិក្ខុទាំងឡាយ ថូបារហបុគ្គលមានពីរពួកនេះឯង ។

[៣០១] ម្នាលភិក្ខុទាំងឡាយ ព្រះពុទ្ធនេះមានពីរពួក ។ ព្រះពុទ្ធពីរពួក តើដូចម្ដេច ។ គឺព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ ១ បច្ចេកពុទ្ធ ១ ។ ម្នាលភិក្ខុទាំងឡាយ ព្រះពុទ្ធមានពីរពួកនេះឯង ។

[៣០២] ម្នាលភិក្ខុទាំងឡាយ បុគ្គលពីរពួកនេះ រមែងមិនតក់ស្លុតក្នុងវេលាដែលរន្ទះបាញ់ ។ បុគ្គលពីរពួក តើដូចម្ដេច ។ គឺភិក្ខុជាខីណាស្រព ១ ដំរីអាជានេយ្យ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពីរពួកនេះឯង រមែងមិនតក់ស្លុត ក្នុងវេលាដែលរន្ទះបាញ់ ។

(៣០៣) ទ្វេមេ ភិក្ខវេ អសនិយា ផលន្តិយា ន សន្តសន្តិ ។ កតមេ ទ្វេ ។ ភិក្ខុ ច ខីណាសវោ អស្សាជានីយោ ច ។ ឥមេ ខោ ភិក្ខវេ ទ្វេ អសនិយា ផលន្តិយា ន សន្តសន្តីតិ ។

(៣០៤) ទ្វេមេ ភិក្ខវេ អសនិយា ផលន្តិយា ន សន្តសន្តិ ។ កតមេ ទ្វេ ។ ភិក្ខុ ច ខីណាសវោ សីហោ ច មិគរាជា ។ ឥមេ ខោ ភិក្ខវេ ទ្វេ អសនិយា ផលន្តិយា ន សន្តសន្តីតិ ។

(៣០៥) ទ្វេមេ ភិក្ខវេ អត្ថវសេ សម្បស្សមានា កិម្បុរិសា មានុសឹ វាចំ ន ភាសន្តិ ។ កតមេ ទ្វេ ។ មា ច មុសា ភណិម្ហា មា ច បរំ អភូតេន អព្ភាចិក្ខិម្ហាតិ ។ ឥមេ ខោ ភិក្ខវេ ទ្វេ អត្ថវសេ សម្បស្សមានា កិម្បុរិសា មានុសឹ វាចំ ន ភាសន្តីតិ ។

(៣០៦) ទ្វិន្នំ ភិក្ខវេ ធម្មានំ អតិត្តោ អប្បដិវានោ មាតុគាមោ កាលំ ករោតិ ។ កតមេសំ ទ្វិន្នំ ។



(៣០៣) ម្នាលភិក្ខុទាំងឡាយ បុគ្គលពីរពួកនេះ រមែងមិនតក់ស្លុត ក្នុងវេលាដែលរន្ទះបាញ់ ។ បុគ្គលពីរពួក តើដូចម្តេច ។ គឺភិក្ខុជាខីណាស្រព ១ សេះអាជានេយ្យ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពីរពួកនេះឯង រមែងមិនតក់ស្លុត ក្នុងវេលាដែលរន្ទះបាញ់ ។

(៣០៤) ម្នាលភិក្ខុទាំងឡាយ បុគ្គលពីរពួកនេះ រមែងមិនតក់ស្លុត ក្នុងវេលាដែលរន្ទះបាញ់ ។ បុគ្គលពីរពួក តើដូចម្តេច ។ គឺភិក្ខុជាខីណាស្រព ១ សីហមិគរាជ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពីរពួកនេះ រមែងមិនតក់ស្លុត ក្នុងវេលាដែលរន្ទះបាញ់ ។

(៣០៥) ម្នាលភិក្ខុទាំងឡាយ ពួកកិន្នរ កាលឃើញនូវអំណាចនៃប្រយោជន៍ពីរយ៉ាងនេះ ទើបមិនពោលពាក្យជារបស់មនុស្ស ។ ប្រយោជន៍ពីរយ៉ាង តើដូចម្តេច ។ គឺមិនពោលពាក្យមុសា ១ មិនពោលបង្កាច់អ្នកដទៃដោយពាក្យមិនពិត ១ ។ ម្នាលភិក្ខុទាំងឡាយ ពួកកិន្នរ កាលឃើញនូវអំណាចនៃប្រយោជន៍ទាំងពីរយ៉ាងនេះ ទើបមិនពោលពាក្យជារបស់មនុស្សឡើយ ។

(៣០៦) ម្នាលភិក្ខុទាំងឡាយ មាតុគ្រាម រមែងមិនឆ្អែតមិនប្រាថ្នា ចំពោះធម៌ពីរយ៉ាង ហើយធ្វើមរណកាល ។ ធម៌ពីរយ៉ាងនេះ តើដូចម្តេច ។

មេថុនធម្មសមាបត្តិយា ច វិជាយនស្ស ច ។ ឥមេសំ ខោ ភិក្ខវេ ទ្វិន្នំ ធម្មានំ អតិត្តោ អប្បដិវាណោ មាតុគ្គាមោ កាលំ ករោតីតិ ។

(៣១៧) អសន្តសន្និបាតញ្ច វោ ភិក្ខវេ ទេសេស្សាមិ សន្តសន្និបាតញ្ច តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច កតមោ ច ភិក្ខវេ អសន្តសន្និបាតោ ហោតិ កតមញ្ច អសន្តោ សន្និបតន្តិ ។ ឥធ ភិក្ខវេ ថេរស្ស ភិក្ខុនោ ឯវំ ហោតិ ថេរោបិ មំ ន វទេយ្យ មជ្ឈិមោបិ មំ ន វទេយ្យ នវោបិ មំ ន វទេយ្យ ថេរម្បាហំ ន វទេយ្យំ មជ្ឈិមម្បាហំ ន វទេយ្យំ នវម្បាហំ ន វទេយ្យំ ថេរោ ចេបិ មំ វទេយ្យ អហិតានុកម្បី មំ វទេយ្យ នោ ហិតានុកម្បី នោតិ នំ វទេយ្យំ



គឺមេថុនធម្មសមាបត្តិ(១)មួយ ១ ប្រសូតិបុត្រ ១ ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាម រមែងមិនឆ្អែត មិនគ្រាន់ចំពោះធម៌ទាំងនេះ រហូតដល់ធ្វើមរណកាល ។

(៣១៧) ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងនូវសេចក្ដីចូលចិត្តរបស់អសប្បុរសផង សេចក្ដីចូលចិត្តរបស់សប្បុរសផង ដល់អ្នកទាំងឡាយ អ្នកទាំងឡាយ ចូរស្ដាប់នូវសេចក្ដីនោះ ចូរធ្វើទុកក្នុងចិត្តឲ្យល្អចុះ តថាគតនឹងសំដែង ។ ភិក្ខុទាំងនោះទទួលព្រះពុទ្ធដីកា របស់ព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ សេចក្ដីចូលចិត្តរបស់អសប្បុរសតើដូចម្ដេច អសប្បុរសទាំងឡាយ តែងចូលចិត្តដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាថេរៈក្នុងសាសនានេះ តែងគិតយ៉ាងនេះថា ព្រះថេរៈក្ដីមិនឲ្យឱវាទយើងទេ មជ្ឈិមៈក្ដី មិនឲ្យឱវាទយើងទេ ភិក្ខុថ្មីក្ដី មិនឲ្យឱវាទយើងទេ ចំណែកយើងមិនឲ្យឱវាទព្រះថេរៈដែរ មិនឲ្យឱវាទមជ្ឈិមៈដែរ មិនឲ្យឱវាទភិក្ខុថ្មីដែរ ប្រសិនបើព្រះថេរៈគប្បីឲ្យឱវាទយើង ដោយមិនអនុគ្រោះ ដោយអំពើដែលឥតប្រយោជន៍ដល់ខ្លួនយើង មិនមែនដោយអនុគ្រោះ ដោយអំពើដែលមានប្រយោជន៍ដល់ខ្លួនយើងទេ យើងគប្បីឃាត់លោកវិញថា

១ [illegible] ។

វិហារសេយ្យំបិ ធំ ចស្សន្តិស្ស ខ បដិការេយ្យំ មជ្ឈិមោ ទេពិ ធំ វិធេយ្យ... ធាតុ ទេបិ ធំ វិធេយ្យ អហិត- ទុក្ខម្បិ ធំ វិធេយ្យ ខោ ហិតានុកម្បី ខោតិ ធំ វិធេយ្យំ វិហារសេយ្យំបិ(១) ធំ ចស្សន្តិស្ស ខ បដិការេយ្យំ មជ្ឈិមសន្តិ កិច្ចាខោ ឃំ ភោតិ ។ បេ ។ បស្សន្តិ កិច្ចាខោ ឃំ ភោតិ ចេតោបិ ធំ ធ វិធេយ្យំ មជ្ឈិមោបិ ធំ ធ វិធេយ្យ ធាតុបិ ធំ ធ វិធេយ្យ ចេវាហំ ធ វិធេយ្យំ មជ្ឈិមតាហំ ធ វិធេយ្យំ ធាតាហំ ធ វិធេយ្យំ ចេតោ ទេពិ ធំ វិធេយ្យ អហិតានុកម្បី ធំ វិធេយ្យ ខោ ហិតានុកម្បី ខោតិ ធំ វិធេយ្យំ វិហារសេយ្យំបិ ធំ ចស្សន្តិស្ស ខ បដិ- ការេយ្យំ មជ្ឈិមោ ទេបិ ធំ វិធេយ្យ... ធាតុ ទេបិ ធំ វិធេយ្យ

១ ម. វិហេឋេយ្យ ។



មិនធ្វើតាមទេ យើងគួរបៀតបៀនលោកនុះ ទុកជាយើងពិចារណា ឃើញគឺមិនគួរធ្វើតាមលោកផែរ ប្រសិនបើមជ្ឈិមគ្គលមួនាទយើង ... ប្រសិនបើកិច្ចថាខ្លួនទយើង លោកកសន្ទក្រោះដោយអំពើឥតប្រយោជន៍ ហើយខ្លួនទយើង មិនមែនសន្ទក្រោះដោយអំពើផែលឯងប្រយោជន៍ ទេ យើងគួរតបទៅលោកវិញថា មិនធ្វើតាមទេ យើងគួរបៀត បៀនលោកនុះ ទុកជាយើងពិចារណាឃើញ គឺមិនគួរធ្វើតាមលោក ផែរ ។ ឯកិច្ចជាមជ្ឈិមគ្គល ផែនឹងគយថាទីនេះជា ។ បេ ។ កិច្ចថាផែន គិតយាទីនេះជា ព្រោះថាកិច្ចមិនគួរខ្លួនទយើង មជ្ឈិមគ្គលក៏មិនគួរខ្លួនទ យើងទេ កិច្ចថាក៏ មិនគួរខ្លួនទយើងទេ យើងក៏មិនគួរខ្លួនទព្រោះផែរផែរ មិនគួរខ្លួនទមជ្ឈិមគ្គលផែរ មិនគួរខ្លួនទកិច្ចថាផែរ ប្រសិនបើត្រូវផែរ លោកគួរខ្លួនទយើង លោកផែនឹងសន្ទក្រោះ ដោយអំពើឥតប្រយោជន៍ ហើយខ្លួនទយើង មិនមែនលោកសន្ទក្រោះ ដោយអំពើឥតប្រយោជន៍ទេ យើងគួរតបទៅលោកវិញថា មិនធ្វើតាមទេ យើងគួរបៀតបៀនលោក វិញនុះ ទុកជាយើងពិចារណាឃើញ គឺមិនគួរធ្វើតាមលោកផែរ ប្រសិនបើ មជ្ឈិមគ្គលខ្លួនទយើង ... ប្រសិនបើកិច្ចថាខ្លួនទយើង

អហិតានុកម្បី មំ វទេយ្យ នោ ហិតានុកម្បី នោតិ នំ វទេយ្យំ វិហេសេយ្យំ នំ បស្សម្បិស្ស ន បដិករេយ្យំ ។ ឯវំ ខោ ភិក្ខវេ អសន្តសន្និបាតោ ហោតិ ឯវញ្ច អសន្តោ សន្និបតន្តិ ។ កតមោ ច ភិក្ខវេ សន្តសន្និបាតោ ហោតិ កថញ្ច សន្តោ សន្និបតន្តិ ។ ឥធ ភិក្ខវេ ថេរស្សបិ ភិក្ខុនោ ឯវំ ហោតិ ថេរោបិ មំ វទេយ្យ មជ្ឈិមោបិ មំ វទេយ្យ នវោបិ មំ វទេយ្យ ថេរម្បាហំ វទេយ្យំ មជ្ឈិមម្បាហំ វទេយ្យំ នវម្បាហំ វទេយ្យំ ថេរោ ចេបិ មំ វទេយ្យ ហិតានុកម្បី មំ វទេយ្យ នោ អហិតានុកម្បី សាធូតិ នំ វទេយ្យំ ន នំ វិហេសេយ្យំ បស្សម្បិស្ស បដិករេយ្យំ មជ្ឈិមោ ចេបិ មំ វទេយ្យ...នវោ ចេបិ មំ វទេយ្យ ហិតានុកម្បី មំ វទេយ្យ



លោកតែនឹកអនុគ្រោះដោយអំពើឥតប្រយោជន៍ហើយទូន្មានយើង មិនមែនលោកអនុគ្រោះដោយអំពើមានប្រយោជន៍ហើយទូន្មានទេ យើងគួរតបទៅលោកវិញថា មិនធ្វើតាមទេ យើងគួរបៀតបៀនលោកនោះ ទុកជាយើងពិចារណាឃើញក៏មិនគួរធ្វើតាមលោកដែរ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីចូលជិតគ្នារបស់អសប្បុរសយ៉ាងនេះ អសប្បុរសទាំងឡាយ តែងចូលជិតយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីចូលជិតគ្នារបស់សប្បុរស តើដូចម្តេច សប្បុរសទាំងឡាយ តែងចូលជិតគ្នាដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាថេរៈក្នុងសាសនានេះ តែងមានគំនិតយ៉ាងនេះថា ព្រះថេរៈក្តី គួរទូន្មានយើង មជ្ឈិមភិក្ខុក្តី គួរទូន្មានយើង នវកភិក្ខុក្តី គួរទូន្មានយើង យើងក៏គួរទូន្មានព្រះថេរៈដែរ គួរទូន្មានមជ្ឈិមភិក្ខុដែរ គួរទូន្មាននវកភិក្ខុដែរ ប្រសិនបើព្រះថេរៈទូន្មានយើង លោកតែនឹកអនុគ្រោះ ដោយអំពើមានប្រយោជន៍ហើយទូន្មានយើង មិនមែនលោកអនុគ្រោះ ដោយអំពើឥតប្រយោជន៍ទេ យើងគួរតបទៅលោកវិញថា ប្រពៃហើយ យើងមិនគួរបៀតបៀនលោកទេ កាលបើយើងពិចារណាឃើញ គួរតែធ្វើតាមលោកដែរ ប្រសិនបើ មជ្ឈិមភិក្ខុទូន្មានយើង ... ប្រសិនបើនវកភិក្ខុទូន្មានយើង តែនឹកអនុគ្រោះ ដោយអំពើមានប្រយោជន៍ហើយទូន្មានយើង

នោ អហិតានុកម្បី សាធូតិ នំ ភជេយ្យំ ន នំ ពហាសេយ្យំ បយិរុបាសេយ្យំ បដិការេយ្យំ ឧទ្ទិស្ស ភិក្ខុនោ ឯវំ ហោតិ ។ បេ ។ ពហុស្សុតោ ភិក្ខុនោ ឯវំ ហោតិ ចេតោបិ មំ ភជេយ្យ ឧទ្ទិស្សោបិ មំ ភជេយ្យ ធម្មោបិ មំ ភជេយ្យ ចេតោពាហំ ភជេយ្យំ ឧទ្ទិស្សបាហំ ភជេយ្យំ ធម្មាហំ ភជេយ្យំ ចេតោ ទេបិ មំ ភជេយ្យ ហិតានុកម្បី មំ ភជេយ្យ នោ អហិតានុកម្បី សាធូតិ នំ ភជេយ្យំ ន នំ ពហាសេយ្យំ បយិរុបាសេយ្យំ បដិការេយ្យំ ឧទ្ទិស្ស ទេបិ មំ ភជេយ្យ ធម្ម ទេបិ មំ ភជេយ្យ ហិតានុកម្បី មំ ភជេយ្យ នោ អហិតានុកម្បី សាធូតិ នំ ភជេយ្យំ ន នំ ពហាសេយ្យំ បយិរុបាសេយ្យំ បដិការេយ្យំ ។ ឯវំ ខោ ភិក្ខវេ សន្ទស្សនិកោ ហោតិ ឯវំ ... ។



មិនមែនលោកអនុគ្រោះ ដោយគំនិតប្រាថ្នាប្រយោជន៍ទេ យើងនឹងគប់រកលោកជាប្រាកដហើយ យើងនឹងមិនត្រូវប្រៀនប្រដៅលោកទេ កាលបើយើងពិចារណាឃើញ នូវកិច្ចធ្វើតាមលោកដែរ ។ ភិក្ខុជាមជ្ឈិមគ្រូ ដែលនឹកឃើញនេះ ។ បេ ។ ភិក្ខុដែលនឹកឃើញនេះថា ព្រោះថាភិក្ខុ នូវខ្លួនយើង មជ្ឈិមភេទក៏ នូវខ្លួនយើង ភិក្ខុជីក៏ នូវខ្លួនយើង យើងនឹងនូវខ្លួន ព្រោះថាៈដែល នូវខ្លួនមជ្ឈិមគ្រូដែល នូវខ្លួនភិក្ខុដែល ប្រសិនបើ ព្រោះថាៈលោកនូវខ្លួនយើង លោកដែលអនុគ្រោះ ដោយគំនិតប្រាថ្នាប្រយោជន៍ ហើយនូវខ្លួនយើង មិនមែនអនុគ្រោះដោយគំនិតប្រាថ្នាប្រយោជន៍ទេ យើងនឹងគប់ទៅរកលោកជាប្រាកដហើយ យើងនឹងមិនត្រូវប្រៀនប្រដៅលោកទេ កាលបើយើងពិចារណាឃើញ នូវកិច្ចធ្វើតាមលោកដែរ ប្រសិនបើ មជ្ឈិមគ្រូ នូវខ្លួនយើង... ប្រសិនបើភិក្ខុ នូវខ្លួនយើង លោកដែលអនុគ្រោះ ដោយគំនិតមានប្រយោជន៍ហើយនូវខ្លួនយើង មិនមែនលោកអនុគ្រោះ ដោយគំនិតប្រាថ្នាប្រយោជន៍ទេ យើងនឹងគប់ទៅរកលោកជាប្រាកដហើយ យើងនឹងមិនត្រូវប្រៀនប្រដៅលោកទេ កាលបើយើងពិចារណាឃើញ ត្រូវតែធ្វើតាមលោកដែរ ។ ម្នាលភិក្ខុទាំងឡាយ សេចក្ដីចូលចិត្តរបស់សប្បុរសយ៉ាងនេះ សប្បុរសទាំងឡាយ តែងចូលចិត្តយ៉ាងនេះ ។

(៣០៨) យស្មិំ ភិក្ខវេ អធិករណេ ឧភតោ វចីសំសារោ ទិដ្ឋិបលាសោ ចេតសោ អាឃាតោ អប្បច្ចយោ អនភិរទ្ធិ អជ្ឈត្តំ អវូបសន្តំ(១) ហោតិ ឯតស្មេតំ ភិក្ខវេ អធិករណេ បាដិកង្ខំ ទីឃត្តាយ ខរត្តាយ វាឡត្តាយ សំវត្តិស្សតិ ភិក្ខូ ច ន ផាសុំ វិហរិស្សន្តិ ។ យស្មិំ ច ខោ ភិក្ខវេ អធិករណេ ឧភតោ វចីសំសារោ ទិដ្ឋិបលាសោ ចេតសោ អាឃាតោ អប្បច្ចយោ អនភិរទ្ធិ អជ្ឈត្តំ សុវូបសន្តំ ហោតិ ឯតស្មេតំ ភិក្ខវេ អធិករណេ បាដិកង្ខំ ន ទីឃត្តាយ ខរត្តាយ វាឡត្តាយ សំវត្តិស្សតិ ភិក្ខូ ច ផាសុំ វិហរិស្សន្តិ ។

ចូឡវគ្គោ បឋមោ(២) ។

(៣០៩) ទ្វេមានិ ភិក្ខវេ សុខានិ ។ កតមានិ ទ្វេ ។

១ ម. អវូបសន្តំ ។ ២ ម. ចូឡវគ្គោ បឋមោ ។



(៣០៨) ម្នាលភិក្ខុទាំងឡាយ ពាក្យដែលប្រព្រឹត្តទៅដោយចំណែកពីរ (ការជេរគ្នា) ការលើកកំពស់ដោយអំណាចទិដ្ឋិ ការចងចិត្តគំនុំ សេចក្តីមិនជឿជាក់ចិត្ត សេចក្តីមិនត្រេកអរ ជាខាងក្នុងដែលមិនស្ងប់រម្ងាប់ភាគីភិក្ខុទាំងពីរ មានក្នុងអធិករណ៍ណា ម្នាលភិក្ខុទាំងឡាយ ហេតុក្នុងអធិករណ៍នោះនឹងមានប្រាកដ គឺនឹងប្រព្រឹត្តទៅដើម្បីកាលវែងឆ្ងាយ ដើម្បីសេចក្តីរឹងរូស ដើម្បីសេចក្តីកាចកាច ទាំងភិក្ខុទាំងឡាយ ក៏នៅមិនសប្បាយ ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែថា ពាក្យដែលប្រព្រឹត្តទៅដោយចំណែកពីរ (ការជេរគ្នា) ការលើកកំពស់ដោយអំណាចទិដ្ឋិ ការចងចិត្តគំនុំ សេចក្តីមិនជឿជាក់ចិត្ត សេចក្តីមិនត្រេកអរ ជាខាងក្នុងដែលស្ងប់រម្ងាប់ភាគីភិក្ខុទាំងពីរហើយ មានក្នុងអធិករណ៍ណា ម្នាលភិក្ខុទាំងឡាយ ហេតុក្នុងអធិករណ៍នោះនឹងមានប្រាកដ គឺនឹងមិនប្រព្រឹត្តទៅដើម្បីកាលវែងឆ្ងាយ ដើម្បីសេចក្តីរឹងរូស ដើម្បីសេចក្តីកាចកាច ពួកភិក្ខុក៏នឹងនៅបានសប្បាយ ។

ចប់ ចូឡវគ្គទី ១ ។

(៣០៩) ម្នាលភិក្ខុទាំងឡាយ សេចក្តីសុខទាំងឡាយនេះ មានពីរយ៉ាង ។ សេចក្តីសុខទាំងពីរយ៉ាងនេះ តើដូចម្តេច ។

គិហិសុខញ្ច បព្វជ្ជាសុខញ្ច ។ ឥមានិ ខោ ភិក្ខវេ ទ្វេ សុខានិ ។ ឯតទគ្គំ ភិក្ខវេ ឥមេសំ ទ្វិន្នំ សុខានំ យទិទំ បព្វជ្ជាសុខន្តិ ។

[៣១០] ទ្វេមានិ ភិក្ខវេ សុខានិ ។ កតមានិ ទ្វេ ។ កាមសុខញ្ច នេក្ខម្មសុខញ្ច ។ ឥមានិ ខោ ភិក្ខវេ ទ្វេ សុខានិ ។ ឯតទគ្គំ ភិក្ខវេ ឥមេសំ ទ្វិន្នំ សុខានំ យទិទំ នេក្ខម្មសុខន្តិ ។

[៣១១] ទ្វេមានិ ភិក្ខវេ សុខានិ ។ កតមានិ ទ្វេ ។ ឧបធិសុខញ្ច និរុបធិសុខញ្ច ។ ឥមានិ ខោ ភិក្ខវេ ទ្វេ សុខានិ ។ ឯតទគ្គំ ភិក្ខវេ ឥមេសំ ទ្វិន្នំ សុខានំ យទិទំ និរុបធិសុខន្តិ ។

[៣១២] ទ្វេមានិ ភិក្ខវេ សុខានិ ។ កតមានិ ទ្វេ ។ សាសវញ្ច សុខំ



ពីរ សេចក្តីសុខរបស់គ្រហស្ថ ១ សេចក្តីសុខក្នុងបព្វជ្ជា ១ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីសុខទាំងឡាយ មានពីរយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាសេចក្តីសុខទាំងពីរយ៉ាងនេះ សេចក្តីសុខក្នុងបព្វជ្ជានុះ ប្រសើរជាង ។

[៣១០] ម្នាលភិក្ខុទាំងឡាយ សេចក្តីសុខទាំងឡាយនេះមានពីរយ៉ាង ។ សេចក្តីសុខពីរយ៉ាង តើដូចម្តេច ។ សេចក្តីសុខក្នុងកាម ១ សេចក្តីសុខក្នុងនេក្ខម្ម ១ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីសុខទាំងឡាយ មានពីរយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាសេចក្តីសុខទាំងពីរយ៉ាងនេះ សេចក្តីសុខក្នុងនេក្ខម្មនុះប្រសើរជាង ។

[៣១១] ម្នាលភិក្ខុទាំងឡាយ សេចក្តីសុខទាំងឡាយនេះមានពីរយ៉ាង ។ សេចក្តីសុខពីរយ៉ាង តើដូចម្តេច ។ គឺសេចក្តីសុខប្រកបដោយឧបធិក្កិលេស សេចក្តីសុខមិនមានឧបធិក្កិលេស ១ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីសុខទាំងឡាយមានពីរយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាសេចក្តីសុខទាំងពីរយ៉ាងនេះ សេចក្តីសុខមិនមានឧបធិក្កិលេសនុះ ប្រសើរជាង ។

[៣១២] ម្នាលភិក្ខុទាំងឡាយ សេចក្តីសុខទាំងឡាយនេះមានពីរយ៉ាង ។ សេចក្តីសុខពីរយ៉ាង តើដូចម្តេច ។ គឺសេចក្តីសុខមានអាសវៈ ១

អនាសវញ្ច សុខំ ។ ឥមានិ ខោ ភិក្ខវេ ទ្វេ សុខានិ ។ ឯតទគ្គំ ភិក្ខវេ ឯតេសំ ទ្វិន្នំ សុខានំ យទិទំ អនាសវសុខន្តិ ។

(៣០៣) ទ្វេមានិ ភិក្ខវេ សុខានិ ។ កតមានិ ទ្វេ ។ សាមិសញ្ច សុខំ និរាមិសញ្ច សុខំ ។ ឥមានិ ខោ ភិក្ខវេ ទ្វេ សុខានិ ។ ឯតទគ្គំ ភិក្ខវេ ឯតេសំ ទ្វិន្នំ សុខានំ យទិទំ និរាមិសំ សុខន្តិ ។

(៣០៤) ទ្វេមានិ ភិក្ខវេ សុខានិ ។ កតមានិ ទ្វេ ។ អរិយសុខញ្ច អនរិយសុខញ្ច ។ ឥមានិ ខោ ភិក្ខវេ ទ្វេ សុខានិ ។ ឯតទគ្គំ ភិក្ខវេ ឯតេសំ ទ្វិន្នំ សុខានំ យទិទំ អរិយសុខន្តិ ។

(៣០៥) ទ្វេមានិ ភិក្ខវេ សុខានិ ។ កតមានិ ទ្វេ ។ កាយិកញ្ច សុខំ ចេតសិកញ្ច សុខំ ។ ឥមានិ ខោ ភិក្ខវេ ទ្វេ សុខានិ ។



សេចក្តីសុខមិនមានអាសវៈ ១ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីសុខទាំងឡាយ មានពីរយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាសេចក្តីសុខទាំងពីរយ៉ាងនេះ សេចក្តីសុខមិនមានអាសវៈនុ៎ះប្រសើរជាង ។

(៣០៣) ម្នាលភិក្ខុទាំងឡាយ សេចក្តីសុខទាំងឡាយនេះមានពីរយ៉ាង ។ សេចក្តីសុខពីរយ៉ាង តើដូចម្តេច ។ គឺសេចក្តីសុខប្រកបដោយអាមិសៈ ១ សេចក្តីសុខមិនប្រកបដោយអាមិសៈ ១ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីសុខទាំងឡាយ មានពីរយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាសេចក្តីសុខទាំងពីរយ៉ាងនេះ សេចក្តីសុខមិនប្រកបដោយអាមិសៈនុ៎ះប្រសើរជាង ។

(៣០៤) ម្នាលភិក្ខុទាំងឡាយ សេចក្តីសុខទាំងឡាយនេះ មានពីរយ៉ាង ។ សេចក្តីសុខពីរយ៉ាង តើដូចម្តេច ។ គឺសេចក្តីសុខរបស់ព្រះអរិយៈ ១ សេចក្តីសុខរបស់បុថុជ្ជន ១ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីសុខទាំងឡាយ មានពីរយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាសេចក្តីសុខទាំងពីរយ៉ាងនេះ សេចក្តីសុខរបស់ព្រះអរិយៈនុ៎ះប្រសើរជាង ។

(៣០៥) ម្នាលភិក្ខុទាំងឡាយ សេចក្តីសុខទាំងឡាយនេះ មានពីរយ៉ាង ។ សេចក្តីសុខពីរយ៉ាង តើដូចម្តេច ។ គឺសេចក្តីសុខប្រព្រឹត្តទៅក្នុងកាយ ១ សេចក្តីសុខប្រព្រឹត្តទៅក្នុងចិត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីសុខទាំងឡាយ មានពីរយ៉ាងនេះឯង ។

ឯតទគ្គំ ភិក្ខវេ ឥមេសំ ទ្វិន្នំ សុខានំ យទិទំ ចេតសិកំ សុខន្តិ ។

(៣១៦) ទ្វេមានិ ភិក្ខវេ សុខានិ ។ កតមានិ ទ្វេ ។ សប្បីតិកញ្ច សុខំ និប្បីតិកញ្ច សុខំ ។ ឥមានិ ខោ ភិក្ខវេ ទ្វេ សុខានិ ។ ឯតទគ្គំ ភិក្ខវេ ឥមេសំ ទ្វិន្នំ សុខានំ យទិទំ និប្បីតិកំ សុខន្តិ ។

(៣១៧) ទ្វេមានិ ភិក្ខវេ សុខានិ ។ កតមានិ ទ្វេ ។ សាតសុខញ្ច ឧបេក្ខាសុខញ្ច ។ ឥមានិ ខោ ភិក្ខវេ ទ្វេ សុខានិ ។ ឯតទគ្គំ ភិក្ខវេ ឥមេសំ ទ្វិន្នំ សុខានំ យទិទំ ឧបេក្ខាសុខន្តិ ។

(៣១៨) ទ្វេមានិ ភិក្ខវេ សុខានិ ។ កតមានិ ទ្វេ ។ សមាធិសុខញ្ច អសមាធិសុខញ្ច ។



ម្នាលភិក្ខុទាំងឡាយ បណ្ដាសេចក្ដីសុខទាំងពីរយ៉ាងនេះ សេចក្ដីសុខប្រព្រឹត្តទៅក្នុងចិត្តនុ៎ះប្រសើរជាង ។

(៣១៦) ម្នាលភិក្ខុទាំងឡាយ សេចក្ដីសុខទាំងឡាយនេះមានពីរយ៉ាង សេចក្ដីសុខពីរយ៉ាង តើដូចម្ដេច ។ គឺសេចក្ដីសុខដែលមានបីតិ (សុខក្នុងបឋមជ្ឈាននឹងទុតិយជ្ឈាន) ១ សេចក្ដីសុខដែលឥតបីតិ (សុខក្នុងតតិយជ្ឈាន នឹងចតុត្ថជ្ឈាន) ១ ។ ម្នាលភិក្ខុទាំងឡាយ សេចក្ដីសុខទាំងឡាយមានពីរយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាសេចក្ដីសុខទាំងពីរយ៉ាងនេះ សេចក្ដីសុខដែលឥតបីតិនុ៎ះប្រសើរជាង ។

(៣១៧) ម្នាលភិក្ខុទាំងឡាយ សេចក្ដីសុខទាំងឡាយនេះមានពីរយ៉ាង ។ សេចក្ដីសុខពីរយ៉ាង តើដូចម្ដេច ។ គឺសេចក្ដីសុខប្រកបដោយសេចក្ដីត្រេកអរ (សុខក្នុងឈានទាំងបី) ១ សេចក្ដីសុខប្រកបដោយឧបេក្ខា (សុខក្នុងចតុត្ថជ្ឈាន) ១ ។ ម្នាលភិក្ខុទាំងឡាយ សេចក្ដីសុខទាំងឡាយ មានពីរយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាសេចក្ដីសុខទាំងពីរយ៉ាងនេះ សេចក្ដីសុខប្រកបដោយឧបេក្ខានុ៎ះប្រសើរជាង ។

(៣១៨) ម្នាលភិក្ខុទាំងឡាយ សេចក្ដីសុខទាំងឡាយនេះមានពីរយ៉ាង ។ សេចក្ដីសុខពីរយ៉ាង តើដូចម្ដេច ។ គឺសេចក្ដីសុខមានសមាធិ (អប្បនាសមាធិនឹងឧបចារសមាធិ) ១ សេចក្ដីសុខមិនមានសមាធិ ១ ។

ឥមានិ ខោ ភិក្ខវេ ទ្វេ សុខានិ ។ ឯតទគ្គំ ភិក្ខវេ ឥមេសំ ទ្វិន្នំ សុខានំ យទិទំ សមាធិសុខន្តិ ។

(៣៥៩) ទ្វេមានិ ភិក្ខវេ សុខានិ ។ កតមានិ ទ្វេ ។ សប្បីតិការម្មណញ្ច សុខំ និប្បីតិការម្មណញ្ច សុខំ ។ ឥមានិ ខោ ភិក្ខវេ ទ្វេ សុខានិ ។ ឯតទគ្គំ ភិក្ខវេ ឥមេសំ ទ្វិន្នំ សុខានំ យទិទំ និប្បីតិការម្មណំ សុខន្តិ ។

(៣៦០) ទ្វេមានិ ភិក្ខវេ សុខានិ ។ កតមានិ ទ្វេ ។ សាតារម្មណញ្ច សុខំ ឧបេក្ខារម្មណញ្ច សុខំ ។ ឥមានិ ខោ ភិក្ខវេ ទ្វេ សុខានិ ។ ឯតទគ្គំ ភិក្ខវេ ឥមេសំ ទ្វិន្នំ សុខានំ យទិទំ ឧបេក្ខារម្មណំ សុខន្តិ ។



ម្នាលភិក្ខុទាំងឡាយ សេចក្តីសុខទាំងឡាយមាន២យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាសេចក្តីសុខទាំង២យ៉ាងនេះ សេចក្តីសុខមានសមាធិនុះប្រសើរជាង ។

(៣៥៩) ម្នាលភិក្ខុទាំងឡាយ សេចក្តីសុខទាំងឡាយនេះមាន ២យ៉ាង ។ សេចក្តីសុខទាំង២យ៉ាង តើដូចម្តេច ។ គឺសេចក្តីសុខរបស់បុគ្គលដែលមានបីតិជាអារម្មណ៍(គឺបឋមជ្ឈាននិងទុតិយជ្ឈាន)១ សេចក្តីសុខរបស់បុគ្គលឥតមានបីតិជាអារម្មណ៍ (គឺតតិយជ្ឈាននិងចតុត្ថជ្ឈាន)១ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីសុខទាំងឡាយ មាន២យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាសេចក្តីសុខទាំង២យ៉ាងនេះ សេចក្តីសុខរបស់បុគ្គលដែលឥតមានបីតិជាអារម្មណ៍នុះប្រសើរជាង ។

(៣៦០) ម្នាលភិក្ខុទាំងឡាយ សេចក្តីសុខទាំងឡាយនេះ មាន ២យ៉ាង ។ សេចក្តីសុខ២យ៉ាងតើដូចម្តេច ។ គឺសេចក្តីសុខដែលមានសេចក្តីត្រេកអរជាអារម្មណ៍១ សេចក្តីសុខដែលមានឧបេក្ខាជាអារម្មណ៍១ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីសុខទាំងឡាយមាន២យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាសេចក្តីសុខទាំង២យ៉ាងនេះ សេចក្តីសុខដែលមានឧបេក្ខាជាអារម្មណ៍នុះប្រសើរជាង ។

(៣៦១) ទ្វេមានិ ភិក្ខវេ សុខានិ ។ កតមានិ ទ្វេ ។ សារម្មណញ្ច សុខំ អនារម្មណញ្ច សុខំ ។ ឥមានិ ខោ ភិក្ខវេ ទ្វេ សុខានិ ។ ឯតទគ្គំ ភិក្ខវេ ឥមេសំ ទ្វិន្នំ សុខានំ យទិទំ អនារម្មណំ សុខន្តិ ។

សុខវគ្គោ ទុតិយោ ។

(៣៦២) សនិមិត្តា ភិក្ខវេ ឧប្បជ្ជន្តិ បាបកា អកុសលា ធម្មា នោ អនិមិត្តា ។ តស្សេវ និមិត្តស្ស បហានា ឯវន្តេ បាបកា អកុសលា ធម្មា ន ហោន្តីតិ ។

(៣៦៣) សនិទានា ភិក្ខវេ ឧប្បជ្ជន្តិ បាបកា អកុសលា ធម្មា នោ អនិទានា ។ តស្សេវ និទានស្ស បហានា ឯវន្តេ បាបកា អកុសលា ធម្មា ន ហោន្តីតិ ។





(៣៦១) ម្នាលភិក្ខុទាំងឡាយ សេចក្ដីសុខទាំងឡាយនេះមានពីរយ៉ាង ។ សេចក្ដីសុខពីរយ៉ាងតើដូចម្ដេច ។ គឺសេចក្ដីសុខដែលមានរូបជាអារម្មណ៍ ១ សេចក្ដីសុខដែលមិនមានរូបជាអារម្មណ៍ ១ ។ ម្នាលភិក្ខុទាំងឡាយ សេចក្ដីសុខទាំងឡាយមានពីរយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាសេចក្ដីសុខទាំងពីរយ៉ាងនេះ សេចក្ដីសុខដែលមិនមានរូបជាអារម្មណ៍នុះប្រសើរជាង ។

ចប់ សុខវគ្គ ទី ២ ។

(៣៦២) ម្នាលភិក្ខុទាំងឡាយ អកុសលធម៌ដ៏លាមកទាំងឡាយ ប្រកបដោយនិមិត្ត (ហេតុ) ទើបកើតឡើងបាន មិនមែនឥតនិមិត្តទេ ។ ព្រោះលះនិមិត្តនោះចេញបាន ទើបអកុសលធម៌ដ៏លាមកទាំងនោះ មិនមានដោយប្រការយ៉ាងនេះ ។

(៣៦៣) ម្នាលភិក្ខុទាំងឡាយ អកុសលធម៌ដ៏លាមកទាំងឡាយ ប្រកបដោយនិទាន(ហេតុ)ទើបកើតឡើងបាន មិនមែនឥតនិទាន(ហេតុ)ទេ ។ ព្រោះលះនិទាននោះចេញបាន ទើបអកុសលធម៌ដ៏លាមកទាំងនោះ មិនមានដោយប្រការយ៉ាងនេះ ។

(៣៤៤) សហេតុកា ភិក្ខវេ ឧប្បជ្ជន្តិ បាបកា អកុសលា ធម្មា នោ អហេតុកា ។ តស្សេវ ហេតុស្ស បហានា ឯវន្តេ បាបកា អកុសលា ធម្មា ន ហោន្តីតិ ។

(៣៤៥) សសង្ខារា ភិក្ខវេ ឧប្បជ្ជន្តិ បាបកា អកុសលា ធម្មា នោ អសង្ខារា ។ តេសំយេវ សង្ខារានំ បហានា ឯវន្តេ បាបកា អកុសលា ធម្មា ន ហោន្តីតិ ។

(៣៤៦) សប្បច្ចយា ភិក្ខវេ ឧប្បជ្ជន្តិ បាបកា អកុសលា ធម្មា នោ អប្បច្ចយា ។ តស្សេវ បច្ចយស្ស បហានា ឯវន្តេ បាបកា អកុសលា ធម្មា ន ហោន្តីតិ ។

(៣៤៧) សរូបា ភិក្ខវេ ឧប្បជ្ជន្តិ បាបកា អកុសលា ធម្មា នោ អរូបា ។ តស្សេវ រូបស្ស បហានា ឯវន្តេ បាបកា អកុសលា ធម្មា ន ហោន្តីតិ ។



(៣៤៤) ម្នាលភិក្ខុទាំងឡាយ អកុសលធម៌ដ៏លាមកទាំងឡាយ ប្រកបដោយហេតុ ទើបកើតឡើងបាន មិនមែនឥតហេតុទេ ។ ព្រោះលះហេតុនោះចេញបាន ទើបអកុសលធម៌ដ៏លាមកទាំងនោះ មិនមានដោយប្រការយ៉ាងនេះ ។

(៣៤៥) ម្នាលភិក្ខុទាំងឡាយ អកុសលធម៌ដ៏លាមកទាំងឡាយ ប្រកបដោយសង្ខារ (គ្រឿងតាក់តែង) ទើបកើតឡើងបាន មិនមែនឥតសង្ខារទេ ។ ព្រោះលះសង្ខារទាំងនោះចេញបាន ទើបអកុសលធម៌ដ៏លាមកទាំងនោះ មិនមានដោយប្រការយ៉ាងនេះ ។

(៣៤៦) ម្នាលភិក្ខុទាំងឡាយ អកុសលធម៌ដ៏លាមកទាំងឡាយ ប្រកបដោយបច្ច័យ ទើបកើតឡើងបាន មិនមែនឥតបច្ច័យទេ ។ ព្រោះលះបច្ច័យនោះចេញបាន ទើបអកុសលធម៌ដ៏លាមកទាំងនោះ មិនមានដោយប្រការយ៉ាងនេះ ។

(៣៤៧) ម្នាលភិក្ខុទាំងឡាយ អកុសលធម៌ដ៏លាមកទាំងឡាយ ប្រកបដោយរូប ទើបកើតឡើងបាន មិនមែនឥតរូបទេ ។ ព្រោះលះរូបនោះចេញបាន ទើបអកុសលធម៌ដ៏លាមកទាំងនោះ មិនមានដោយប្រការយ៉ាងនេះ ។

(៣២៨) សវេទនា ភិក្ខវេ ឧប្បជ្ជន្តិ បាបកា អកុសលា ធម្មា នោ អវេទនា ។ តស្សាយេវ វេទនាយ បហានា ឯវន្តេ បាបកា អកុសលា ធម្មា ន ហោន្តីតិ ។

(៣២៩) សសញ្ញា ភិក្ខវេ ឧប្បជ្ជន្តិ បាបកា អកុសលា ធម្មា នោ អសញ្ញា ។ តស្សាយេវ សញ្ញាយ បហានា ឯវន្តេ បាបកា អកុសលា ធម្មា ន ហោន្តីតិ ។

(៣៣០) សវិញ្ញាណា ភិក្ខវេ ឧប្បជ្ជន្តិ បាបកា អកុសលា ធម្មា នោ អវិញ្ញាណា ។ តស្សេវ វិញ្ញាណស្ស បហានា ឯវន្តេ បាបកា អកុសលា ធម្មា ន ហោន្តីតិ ។

(៣៣១) សង្ខតារម្មណា ភិក្ខវេ ឧប្បជ្ជន្តិ បាបកា អកុសលា ធម្មា នោ អសង្ខតារម្មណា ។ តស្សេវ សង្ខតស្ស បហានា ឯវន្តេ បាបកា អកុសលា ធម្មា ន ហោន្តីតិ ។

សនិមិត្តវគ្គោ អដ្ឋមោ ។



(៣២៨) ម្នាលភិក្ខុទាំងឡាយ អកុសលធម៌ដ៏លាមកទាំងឡាយ ប្រកបដោយវេទនា ទើបកើតឡើងបាន មិនមែនឥតវេទនាទេ ។ ព្រោះលះវេទនានោះចេញបាន ទើបអកុសលធម៌ដ៏លាមកទាំងនោះ មិនមានដោយប្រការយ៉ាងនេះ ។

(៣២៩) ម្នាលភិក្ខុទាំងឡាយ អកុសលធម៌ដ៏លាមកទាំងឡាយ ប្រកបដោយសញ្ញា ទើបកើតឡើងបាន មិនមែនឥតសញ្ញាទេ ។ ព្រោះលះសញ្ញានោះចេញបាន ទើបអកុសលធម៌ដ៏លាមកទាំងនោះ មិនមានដោយប្រការយ៉ាងនេះ ។

(៣៣០) ម្នាលភិក្ខុទាំងឡាយ អកុសលធម៌ដ៏លាមកទាំងឡាយ ប្រកបដោយវិញ្ញាណ ទើបកើតឡើងបាន មិនមែនឥតវិញ្ញាណទេ ។ ព្រោះលះវិញ្ញាណនោះចេញបាន ទើបអកុសលធម៌ដ៏លាមកទាំងនោះ មិនមានដោយប្រការយ៉ាងនេះ ។

(៣៣១) ម្នាលភិក្ខុទាំងឡាយ អកុសលធម៌ដ៏លាមកទាំងឡាយ មានសង្ខតធម៌ជាអារម្មណ៍ ទើបកើតឡើងបាន មិនមែនឥតសង្ខតធម៌ជាអារម្មណ៍ទេ ។ ព្រោះលះសង្ខតធម៌នោះចេញបាន ទើបអកុសលធម៌ដ៏លាមកទាំងនោះ មិនមានដោយប្រការយ៉ាងនេះ ។

ចប់ សនិមិត្តវគ្គទី ៣ ។

[៣៣២] ទ្វេមេ ភិក្ខវេ ធម្មា ។ កតមេ ទ្វេ ។ ចេតោវិមុត្តិ ច បញ្ញាវិមុត្តិ ច ។ ឥមេ ខោ ភិក្ខវេ ទ្វេ ធម្មាតិ ។

[៣៣៣] ទ្វេមេ ភិក្ខវេ ធម្មា ។ កតមេ ទ្វេ ។ បគ្គាហោ ច អវិក្ខេបោ ច ។ ឥមេ ខោ ភិក្ខវេ ទ្វេ ធម្មាតិ ។

[៣៣៤] ទ្វេមេ ភិក្ខវេ ធម្មា ។ កតមេ ទ្វេ ។ នាមញ្ច រូបញ្ច ។ ឥមេ ខោ ភិក្ខវេ ទ្វេ ធម្មាតិ ។

[៣៣៥] ទ្វេមេ ភិក្ខវេ ធម្មា ។ កតមេ ទ្វេ ។ វិជ្ជា ច វិមុត្តិ ច ។ ឥមេ ខោ ភិក្ខវេ ទ្វេ ធម្មាតិ ។

[៣៣៦] ទ្វេមេ ភិក្ខវេ ធម្មា ។ កតមេ ទ្វេ ។ ភវទិដ្ឋិ ច វិភវទិដ្ឋិ ច ។ ឥមេ ខោ ភិក្ខវេ ទ្វេ ធម្មាតិ ។



[៣៣២] ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយនេះមានពីរយ៉ាង ។ ធម៌ពីរយ៉ាងតើដូចម្តេច ។ គឺចេតោវិមុត្តិ (រួចស្រឡះចាកកិលេសដោយអំណាចផលសមាធិ) ១ បញ្ញាវិមុត្តិ (រួចស្រឡះចាកកិលេសដោយអំណាចផលបញ្ញា) ១ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយមានពីរយ៉ាងនេះឯង ។

[៣៣៣] ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយនេះមានពីរយ៉ាង ។ ធម៌ពីរយ៉ាងតើដូចម្តេច ។ គឺសេចក្តីផ្គងចិត្ត ១ សេចក្តីមិនរាយមាយ ១ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយមានពីរយ៉ាងនេះឯង ។

[៣៣៤] ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយនេះមានពីរយ៉ាង ។ ធម៌ពីរយ៉ាងតើដូចម្តេច ។ គឺនាម ១ រូប ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយមានពីរយ៉ាងនេះឯង ។

[៣៣៥] ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយនេះមានពីរយ៉ាង ។ ធម៌ពីរយ៉ាង តើដូចម្តេច ។ គឺវិជ្ជា ១ វិមុត្តិ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយមានពីរយ៉ាងនេះឯង ។

[៣៣៦] ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយនេះមានពីរយ៉ាង ។ ធម៌ពីរយ៉ាង តើដូចម្តេច ។ គឺភវទិដ្ឋិ ១ វិភវទិដ្ឋិ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយមានពីរយ៉ាងនេះឯង ។

(៣៣៧) ទ្វេមេ ភិក្ខវេ ធម្មា ។ កតមេ ទ្វេ ។ អហិរិកញ្ច អនោត្តប្បញ្ច ។ ឥមេ ខោ ភិក្ខវេ ទ្វេ ធម្មាតិ ។

(៣៣៨) ទ្វេមេ ភិក្ខវេ ធម្មា ។ កតមេ ទ្វេ ។ ហិរី (១) ច ឱត្តប្បញ្ច ។ ឥមេ ខោ ភិក្ខវេ ទ្វេ ធម្មាតិ ។

(៣៣៩) ទ្វេមេ ភិក្ខវេ ធម្មា ។ កតមេ ទ្វេ ។ ទោវចស្សតា ច បាបមិត្តតា ច ។ ឥមេ ខោ ភិក្ខវេ ទ្វេ ធម្មាតិ ។

(៣៤០) ទ្វេមេ ភិក្ខវេ ធម្មា ។ កតមេ ទ្វេ ។ សោវចស្សតា ច កល្យាណមិត្តតា ច ។ ឥមេ ខោ ភិក្ខវេ ទ្វេ ធម្មាតិ ។

(៣៤១) ទ្វេមេ ភិក្ខវេ ធម្មា ។ កតមេ ទ្វេ ។ ធាតុកុសលតា ច មនសិការកុសលតា ច ។ ឥមេ ខោ ភិក្ខវេ ទ្វេ ធម្មាតិ ។

---

១ ម. ឆ. [illegible] ហិរី ឥតិបិ បាឋោ ។





(៣៣៧) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយនេះមានពីរយ៉ាង ។ ធម៌ពីរយ៉ាង តើដូចម្តេច ។ គឺសេចក្តីមិនខ្មាស់បាប ១ សេចក្តីមិនខ្លាចបាប ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយមានពីរយ៉ាងនេះឯង ។

(៣៣៨) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយនេះមានពីរយ៉ាង ។ ធម៌ពីរយ៉ាងតើដូចម្តេច ។ គឺសេចក្តីខ្មាស់បាប ១ សេចក្តីខ្លាចបាប ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយមានពីរយ៉ាងនេះឯង ។

(៣៣៩) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយនេះមានពីរយ៉ាង ។ ធម៌ពីរយ៉ាង តើដូចម្តេច ។ គឺការធ្វើខ្លួនឲ្យគេប្រដៅបានដោយក្រ ១ ការមានមិត្តអាក្រក់ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយមានពីរយ៉ាងនេះឯង ។

(៣៤០) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយនេះមានពីរយ៉ាង ។ ធម៌ពីរយ៉ាង តើដូចម្តេច ។ គឺការធ្វើខ្លួនឲ្យគេប្រដៅបានដោយងាយ ១ ការមានមិត្តល្អ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយមានពីរយ៉ាងនេះឯង ។

(៣៤១) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយនេះមានពីរយ៉ាង ។ ធម៌ពីរយ៉ាង តើដូចម្តេច ។ គឺការឈ្លាសវៃក្នុងធាតុ ១ ការឈ្លាសវៃក្នុងមនសិការ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយមានពីរយ៉ាងនេះឯង ។

[៣៦៦] ទ្វេមេ ភិក្ខវេ ធម្មា ។ កតមេ ទ្វេ ។ អាបត្តិកុសលតា ច អាបត្តិវុដ្ឋានកុសលតា ច ។ ឥមេ ខោ ភិក្ខវេ ទ្វេ ធម្មាតិ ។

ធម្មវគ្គោ ចតុត្ថោ ។

[៣៦៧] ទ្វេមេ ភិក្ខវេ ពាលា ។ កតមេ ទ្វេ ។ យោ ច អនាគតំ ភារំ វហតិ យោ ច អាគតំ ភារំ ន វហតិ ។ ឥមេ ខោ ភិក្ខវេ ទ្វេ ពាលាតិ ។



[៣៦៦] ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយនេះមាន២យ៉ាង ។ ពីរយ៉ាង តើដូចម្តេច ។ គឺការឈ្លាសវៃក្នុងអាបត្តិ(១)១ ការឈ្លាសវៃក្នុងការចេញចាកអាបត្តិ(២)១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយមាន២យ៉ាងនេះឯង ។

ចប់ វគ្គទី៤ ។

[៣៦៧] ម្នាលភិក្ខុទាំងឡាយ ជនពាលទាំងឡាយនេះមាន២ពួក ។ ជនពាល២ពួក តើដូចម្តេច ។ គឺជនពាលនាំទទួលភារៈដែលមិនទាន់មកដល់(៣)១ ជនពាលមិនទទួលភារៈដែលមកដល់ហើយ(៤)១ ។ ម្នាលភិក្ខុទាំងឡាយ ជនពាលទាំងឡាយមាន២ពួកនេះឯង ។

---

១ ស្គាល់ច្បាស់រាល់ខ្នងនៃអាបត្តិទាំង ៥ កងឬទាំង ៧ កង ។

២ ស្គាល់ច្បាស់សេចក្តីថា អាបត្តិនេះ បរិសុទ្ធដោយទេសនាវិធី អាបត្តិនេះ បរិសុទ្ធដោយវុដ្ឋានវិធី (អដ្ឋកថា) ។

៣ បានដល់ភារៈទាំង ១០ គឺ [illegible] ១ [illegible] ១ [illegible] ១ [illegible] ១ [illegible] ១ [illegible] ១ [illegible] ១ [illegible] ១ [illegible] ១ ការភារៈរបស់ព្រះថេរៈទាំងឡាយ [illegible] ហៅថា ភារៈដែលមិនទាន់មកដល់ ។

៤ បានដល់ភារៈទាំង ១០ របស់ព្រះថេរៈ [illegible] ហៅថាមិនទទួលភារៈដែលមកដល់ហើយ ។

(៣៦៦) ទ្វេមេ ភិក្ខវេ បណ្ឌិតា ។ កតមេ ទ្វេ ។ យោ ច អាគតំ ភារំ វហតិ យោ ច អនាគតំ ភារំ ន វហតិ ។ ឥមេ ខោ ភិក្ខវេ ទ្វេ បណ្ឌិតាតិ ។

(៣៦៧) ទ្វេមេ ភិក្ខវេ ពាលា ។ កតមេ ទ្វេ ។ យោ ច អកប្បិយេ កប្បិយសញ្ញី យោ ច កប្បិយេ អកប្បិយសញ្ញី ។ ឥមេ ខោ ភិក្ខវេ ទ្វេ ពាលាតិ ។

(៣៦៨) ទ្វេមេ ភិក្ខវេ បណ្ឌិតា ។ កតមេ ទ្វេ ។ យោ ច អកប្បិយេ អកប្បិយសញ្ញី យោ ច កប្បិយេ កប្បិយសញ្ញី ។ ឥមេ ខោ ភិក្ខវេ ទ្វេ បណ្ឌិតាតិ ។

(៣៦៩) ទ្វេមេ ភិក្ខវេ ពាលា ។ កតមេ ទ្វេ ។ យោ ច អនាបត្តិយា អាបត្តិសញ្ញី



(៣៦៦) ម្នាលភិក្ខុទាំងឡាយ បណ្ឌិតទាំងឡាយនេះមាន ២ ពួក ។ បណ្ឌិត ២ ពួក តើដូចម្ដេច ។ គឺបណ្ឌិតដែលទទួលភារៈដែលមកដល់ហើយ(១) ១ បណ្ឌិតមិនទទួលភារៈដែលមិនទាន់មក(២)ដល់ ១ ។ ម្នាលភិក្ខុទាំងឡាយ បណ្ឌិតទាំងឡាយមាន ២ ពួកនេះឯង ។

(៣៦៧) ម្នាលភិក្ខុទាំងឡាយ ជនពាលនេះមាន ២ ពួក ជនពាល ២ ពួក តើដូចម្ដេច ។ គឺជនពាលមានសេចក្ដីសំគាល់ថាគួរក្នុងរបស់ដែលមិន(៣)គួរ ១ ជនពាលមានសេចក្ដីសំគាល់ថាមិនគួរក្នុងរបស់ដែល(៤)គួរ ១ ។ ម្នាលភិក្ខុទាំងឡាយ ជនពាលទាំងឡាយមាន ២ ពួកនេះឯង ។

(៣៦៨) ម្នាលភិក្ខុទាំងឡាយ បណ្ឌិតទាំងឡាយនេះមាន ២ ពួក ។ បណ្ឌិត ២ ពួក តើដូចម្ដេច ។ គឺបណ្ឌិតមានសេចក្ដីសំគាល់ថា មិនគួរក្នុងរបស់ដែលមិនគួរ ១ បណ្ឌិតមានសេចក្ដីសំគាល់ថាគួរក្នុងរបស់ដែលគួរ ១ ។ ម្នាលភិក្ខុទាំងឡាយ បណ្ឌិតទាំងឡាយមាន ២ ពួកនេះឯង ។

(៣៦៩) ម្នាលភិក្ខុទាំងឡាយ ជនពាលទាំងឡាយនេះមាន ២ ពួក ។ ជនពាល ២ ពួក តើដូចម្ដេច ។ គឺជនពាលមានសេចក្ដីសំគាល់ថាមានអាបត្តិ

---

១-២ ព្រោះតែធ្វើយុត្តិនឹងកិច្ចការនៃខ្លួនប៉ុណ្ណោះ (ឧបោសថវគ្គដីកា) ។

៣ សំគាល់ក្នុងសាច់ទាំង ១០ យ៉ាងមានសាច់ដំរីជាដើម ដែលមិនគួរឆាន់ថាសាច់គួរឆាន់វិញ ។

៤ សំគាល់ក្រៅពីសាច់ទាំង ១០ យ៉ាង មានសាច់ត្រីជាដើម សាច់ឈ្មោះដទៃដែលគួរឆាន់ថា មិនគួរឆាន់វិញ ។ (មើលសមន្តបាសាទិកា បរិវារ ពិស្តារដោយ) ។

យោ ច អាបត្តិយា អនាបត្តិសញ្ញី ។ ឥមេ ខោ ភិក្ខវេ ទ្វេ ពាលាតិ ។

(៣៨៨) ទ្វេមេ ភិក្ខវេ បណ្ឌិតា ។ កតមេ ទ្វេ ។ យោ ច អនាបត្តិយា អនាបត្តិសញ្ញី យោ ច អាបត្តិយា អាបត្តិសញ្ញី ។ ឥមេ ខោ ភិក្ខវេ ទ្វេ បណ្ឌិតាតិ ។

(៣៨៩) ទ្វេមេ ភិក្ខវេ ពាលា ។ កតមេ ទ្វេ ។ យោ ច អធម្មេ ធម្មសញ្ញី យោ ច ធម្មេ អធម្មសញ្ញី ។ ឥមេ ខោ ភិក្ខវេ ទ្វេ ពាលាតិ ។

(៣៩០) ទ្វេមេ ភិក្ខវេ បណ្ឌិតា ។ កតមេ ទ្វេ ។ យោ ច អធម្មេ អធម្មសញ្ញី យោ ច ធម្មេ ធម្មសញ្ញី ។ ឥមេ ខោ ភិក្ខវេ ទ្វេ បណ្ឌិតាតិ ។

(៣៩១) ទ្វេមេ ភិក្ខវេ ពាលា ។ កតមេ ទ្វេ ។ យោ ច អវិនយេ វិនយសញ្ញី



ក្នុងអនាបត្តិ ១ ជនពាលមានសេចក្តីសំគាល់ថាឥតមានអាបត្តិក្នុងអាបត្តិ ១ ។ ម្នាលភិក្ខុទាំងឡាយ ជនពាលទាំងឡាយ មានពីរពួកនេះឯង ។

(៣៨៨) ម្នាលភិក្ខុទាំងឡាយ បណ្ឌិតទាំងឡាយនេះមានពីរពួក ។ បណ្ឌិតពីរពួក តើដូចម្តេច ។ គឺបណ្ឌិតសំគាល់ថាឥតមានអាបត្តិក្នុងអនាបត្តិ ១ បណ្ឌិតដែលសំគាល់ថាមានអាបត្តិក្នុងអាបត្តិ ១ ។ ម្នាលភិក្ខុទាំងឡាយ បណ្ឌិតទាំងឡាយ មានពីរពួកនេះឯង ។

(៣៨៩) ម្នាលភិក្ខុទាំងឡាយ ជនពាលទាំងឡាយនេះមានពីរពួក ។ ជនពាលពីរពួក តើដូចម្តេច ។ ជនពាលមានសេចក្តីសំគាល់ថាធម៌ក្នុងអធម៌ ១ ជនពាលមានសេចក្តីសំគាល់ថាអធម៌ក្នុងធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ ជនពាលទាំងឡាយ មានពីរពួកនេះឯង ។

(៣៩០) ម្នាលភិក្ខុទាំងឡាយ បណ្ឌិតទាំងឡាយនេះមានពីរពួក ។ បណ្ឌិតពីរពួក តើដូចម្តេច ។ គឺបណ្ឌិតមានសេចក្តីសំគាល់ថាអធម៌ក្នុងអធម៌ ១ បណ្ឌិតមានសេចក្តីសំគាល់ថាធម៌ក្នុងធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ បណ្ឌិតទាំងឡាយ មានពីរពួកនេះឯង ។

(៣៩១) ម្នាលភិក្ខុទាំងឡាយ ជនពាលទាំងឡាយនេះមានពីរពួក ។ ជនពាលពីរពួក តើដូចម្តេច ។ គឺជនពាលមានសេចក្តីសំគាល់ថាវិន័យក្នុង

យោ ច វិនយេ អវិនយសញ្ញី ។ ឥមេ ខោ ភិក្ខវេ ទ្វេ ពាលាតិ ។

(៣៩៦) ទ្វេមេ ភិក្ខវេ បណ្ឌិតា ។ កតមេ ទ្វេ ។ យោ ច អវិនយេ អវិនយសញ្ញី យោ ច វិនយេ វិនយសញ្ញី ។ ឥមេ ខោ ភិក្ខវេ ទ្វេ បណ្ឌិតាតិ ។

(៣៩៧) ទ្វិន្នំ ភិក្ខវេ អាសវា វឌ្ឍន្តិ ។ កតមេសំ ទ្វិន្នំ ។ យោ ច ន កុក្កុច្ចាយិតព្ពំ កុក្កុច្ចាយតិ យោ ច កុក្កុច្ចាយិតព្ពំ ន កុក្កុច្ចាយតិ ។ ឥមេសំ ខោ ភិក្ខវេ ទ្វិន្នំ អាសវា វឌ្ឍន្តីតិ ។

(៣៩៨) ទ្វិន្នំ ភិក្ខវេ អាសវា ន វឌ្ឍន្តិ ។ កតមេសំ ទ្វិន្នំ ។ យោ ច ន កុក្កុច្ចាយិតព្ពំ ន កុក្កុច្ចាយតិ យោ ច កុក្កុច្ចាយិតព្ពំ កុក្កុច្ចាយតិ ។ ឥមេសំ ខោ ភិក្ខវេ ទ្វិន្នំ អាសវា ន វឌ្ឍន្តីតិ ។



អវិន័យ ១ ជនពាលបានសេចក្តីសំគាល់ថាអវិន័យក្នុងវិន័យ ១ ។ ម្នាលភិក្ខុទាំងឡាយ ជនពាលទាំងឡាយ មានពីរពួកនេះឯង ។

(៣៩៦) ម្នាលភិក្ខុទាំងឡាយ បណ្ឌិតទាំងឡាយនេះមានពីរពួក ។ បណ្ឌិតពីរពួក តើដូចម្តេច ។ គឺបណ្ឌិតបានសេចក្តីសំគាល់ថាអវិន័យក្នុងអវិន័យ ១ បណ្ឌិតបានសេចក្តីសំគាល់ថា វិន័យ ក្នុងវិន័យ ១ ។ ម្នាលភិក្ខុទាំងឡាយ បណ្ឌិតទាំងឡាយ មានពីរពួកនេះឯង ។

(៣៩៧) ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងឡាយ តែងចំរើនដល់បុគ្គលពីរពួក ។ បុគ្គលពីរពួក តើដូចម្តេច ។ គឺបុគ្គលសង្ស័យក្នុងរបស់ដែលមិនគួរសង្ស័យ ១ បុគ្គលដែលមិនសង្ស័យនឹងរបស់ដែលគួរសង្ស័យ ១ ។ ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងឡាយ តែងចំរើនដល់បុគ្គលពីរពួកនេះឯង ។

(៣៩៨) ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងឡាយ តែងមិនចំរើនដល់បុគ្គលពីរពួក ។ បុគ្គលពីរពួក តើដូចម្តេច ។ គឺបុគ្គលមិនសង្ស័យក្នុងរបស់ដែលមិនគួរសង្ស័យ ១ បុគ្គលសង្ស័យនឹងរបស់ដែលគួរសង្ស័យ ១ ។ ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងឡាយ តែងមិនចំរើនដល់បុគ្គលពីរពួកនេះឯង ។

(៣៥៥) ទ្វិន្នំ ភិក្ខវេ អាសវា វឌ្ឍន្តិ ។ កតមេសំ ទ្វិន្នំ ។ យោ ច អកប្បិយេ កប្បិយសញ្ញី យោ ច កប្បិយេ អកប្បិយសញ្ញី ។ ឥមេសំ ខោ ភិក្ខវេ ទ្វិន្នំ អាសវា វឌ្ឍន្តីតិ ។

(៣៥៦) ទ្វិន្នំ ភិក្ខវេ អាសវា ន វឌ្ឍន្តិ ។ កតមេសំ ទ្វិន្នំ ។ យោ ច អកប្បិយេ អកប្បិយសញ្ញី យោ ច កប្បិយេ កប្បិយសញ្ញី ។ ឥមេសំ ខោ ភិក្ខវេ ទ្វិន្នំ អាសវា ន វឌ្ឍន្តីតិ ។

(៣៥៧) ទ្វិន្នំ ភិក្ខវេ អាសវា វឌ្ឍន្តិ ។ កតមេសំ ទ្វិន្នំ ។ យោ ច អនាបត្តិយា អាបត្តិសញ្ញី យោ ច អាបត្តិយា អនាបត្តិសញ្ញី ។ ឥមេសំ ខោ ភិក្ខវេ ទ្វិន្នំ អាសវា វឌ្ឍន្តីតិ ។



(៣៥៥) ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងឡាយ តែងចំរើនដល់បុគ្គលពីរពួក ។ បុគ្គលពីរពួក តើដូចម្តេច ។ គឺបុគ្គលមានសេចក្តីសំគាល់ថាគួរក្នុងរបស់ដែលមិនគួរ ១ បុគ្គលមានសេចក្តីសំគាល់ថាមិនគួរក្នុងរបស់ដែលគួរ ១ ។ ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងឡាយ តែងចំរើនដល់បុគ្គលពីរពួកនេះឯង ។

(៣៥៦) ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងឡាយ តែងមិនចំរើនដល់បុគ្គលពីរពួក ។ បុគ្គលពីរពួក តើដូចម្តេច ។ គឺបុគ្គលមានសេចក្តីសំគាល់ថាមិនគួរក្នុងរបស់ដែលមិនគួរ ១ បុគ្គលមានសេចក្តីសំគាល់ថាគួរក្នុងរបស់ដែលគួរ ១ ។ ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងឡាយ តែងមិនចំរើនដល់បុគ្គលពីរពួកនេះឯង ។

(៣៥៧) ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងឡាយ តែងចំរើនដល់បុគ្គលពីរពួក ។ បុគ្គលពីរពួក តើដូចម្តេច ។ គឺបុគ្គលមានសេចក្តីសំគាល់ថាអាបត្តិក្នុងអនាបត្តិ ១ បុគ្គលមានសេចក្តីសំគាល់ថាអនាបត្តិ ក្នុងអាបត្តិ ១ ។ ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងឡាយ តែងចំរើនដល់បុគ្គលពីរពួកនេះឯង ។

(៣៥៨) ទ្វិន្នំ ភិក្ខវេ អាសវា ន វឌ្ឍន្តិ ។ កតមេសំ ទ្វិន្នំ ។ យោ ច អនាបត្តិយា អនាបត្តិសញ្ញី យោ ច អាបត្តិយា អាបត្តិសញ្ញី ។ ឥមេសំ ខោ ភិក្ខវេ ទ្វិន្នំ ន វឌ្ឍន្តីតិ ។

(៣៥៩) ទ្វិន្នំ ភិក្ខវេ អាសវា វឌ្ឍន្តិ ។ កតមេសំ ទ្វិន្នំ ។ យោ ច អធម្មេ ធម្មសញ្ញី យោ ច ធម្មេ អធម្មសញ្ញី ។ ឥមេសំ ខោ ភិក្ខវេ ទ្វិន្នំ អាសវា វឌ្ឍន្តីតិ ។

(៣៦០) ទ្វិន្នំ ភិក្ខវេ អាសវា ន វឌ្ឍន្តិ ។ កតមេសំ ទ្វិន្នំ ។ យោ ច អធម្មេ អធម្មសញ្ញី យោ ច ធម្មេ ធម្មសញ្ញី ។ ឥមេសំ ខោ ភិក្ខវេ ទ្វិន្នំ អាសវា ន វឌ្ឍន្តីតិ ។



(៣៥៨) ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងឡាយ តែងមិនចំរើនដល់បុគ្គលពីរពួក ។ បុគ្គលពីរពួក តើដូចម្តេច ។ គឺបុគ្គលមានសេចក្តីសំគាល់ថាអនាបត្តិក្នុងអនាបត្តិ ១ បុគ្គលមានសេចក្តីសំគាល់ថាអាបត្តិក្នុងអាបត្តិ ១ ។ ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងឡាយ តែងមិនចំរើនដល់បុគ្គលពីរពួកនេះឯង ។

(៣៥៩) ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងឡាយ តែងចំរើនដល់បុគ្គលពីរពួក ។ បុគ្គលពីរពួក តើដូចម្តេច ។ គឺបុគ្គលមានសេចក្តីសំគាល់ថាធម៌ក្នុងអធម៌ ១ បុគ្គលមានសេចក្តីសំគាល់ថាអធម៌ក្នុងធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងឡាយ តែងចំរើនដល់បុគ្គលពីរពួកនេះឯង ។

(៣៦០) ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងឡាយ តែងមិនចំរើនដល់បុគ្គលពីរពួក ។ បុគ្គលពីរពួក តើដូចម្តេច ។ គឺបុគ្គលមានសេចក្តីសំគាល់ថាអធម៌ក្នុងអធម៌ ១ បុគ្គលមានសេចក្តីសំគាល់ថាធម៌ក្នុងធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងឡាយ តែងមិនចំរើនដល់បុគ្គលពីរពួកនេះឯង ។

(៣៦០) ទ្វិន្នំ ភិក្ខវេ អាសវា វឌ្ឍន្តិ ។ កតមេសំ ទ្វិន្នំ ។ យោ ច អវិនយេ វិនយសញ្ញី យោ ច វិនយេ អវិនយសញ្ញី ។ ឥមេសំ ខោ ភិក្ខវេ ទ្វិន្នំ អាសវា វឌ្ឍន្តីតិ ។

(៣៦១) ទ្វិន្នំ ភិក្ខវេ អាសវា ន វឌ្ឍន្តិ ។ កតមេសំ ទ្វិន្នំ ។ យោ ច អវិនយេ អវិនយសញ្ញី យោ ច វិនយេ វិនយសញ្ញី ។ ឥមេសំ ខោ ភិក្ខវេ ទ្វិន្នំ អាសវា ន វឌ្ឍន្តីតិ ។

ពាលវគ្គោ បញ្ចមោ ។

ទុតិយោ បណ្ណាសកោ សមត្តោ ។



(៣៦០) ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងឡាយ រមែងចំរើនដល់បុគ្គលពីរពួក ។ បុគ្គលពីរពួក តើដូចម្តេច ។ គឺបុគ្គលមានសេចក្តីសំគាល់ថាវិន័យ ក្នុងអវិន័យ ១ បុគ្គលមានសេចក្តីសំគាល់ថាអវិន័យ ក្នុងវិន័យ ១ ។ ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងឡាយ រមែងចំរើនដល់បុគ្គលពីរពួកនេះឯង ។

(៣៦១) ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងឡាយ រមែងមិនចំរើនដល់បុគ្គលពីរពួក ។ បុគ្គលពីរពួក តើដូចម្តេច ។ គឺបុគ្គលមានសេចក្តីសំគាល់ថាអវិន័យ ក្នុងអវិន័យ ១ បុគ្គលមានសេចក្តីសំគាល់ថាវិន័យ ក្នុងវិន័យ ១ ។ ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងឡាយ រមែងមិនចំរើនដល់បុគ្គលពីរពួកនេះឯង ។

ចប់ ពាលវគ្គទី ៥ ។

ចប់ ទុតិយបណ្ណាសក ។

# តតិយបណ្ណាសកោ

(៣៦៣) ទ្វេមា ភិក្ខវេ អាសា ទុប្បជហា ។ កតមា ទ្វេ ។ លាភាសា ច ជីវិតាសា ច ។ ឥមា ខោ ភិក្ខវេ ទ្វេ អាសា ទុប្បជហាតិ ។

(៣៦៤) ទ្វេមេ ភិក្ខវេ បុគ្គលា ទុល្លភា លោកស្មឹ ។ កតមេ ទ្វេ ។ យោ ច បុព្វការី យោ ច កតញ្ញូ កតវេទី ។ ឥមេ ខោ ភិក្ខវេ ទ្វេ បុគ្គលា ទុល្លភា លោកស្មិន្តិ ។

(៣៦៥) ទ្វេមេ ភិក្ខវេ បុគ្គលា ទុល្លភា លោកស្មឹ ។ កតមេ ទ្វេ ។ តិត្តោ ច តប្បេតា ច ។ ឥមេ ខោ ភិក្ខវេ ទ្វេ បុគ្គលា ទុល្លភា លោកស្មិន្តិ ។

(៣៦៦) ទ្វេមេ ភិក្ខវេ បុគ្គលា ទុត្តប្បយា ។ កតមេ ទ្វេ ។ យោ ច លទ្ធំ លទ្ធំ និក្ខិបតិ យោ ច លទ្ធំ លទ្ធំ វិស្សជ្ជេតិ ។

# តតិយបណ្ណាសក

(៣៦៣) ម្នាលភិក្ខុទាំងឡាយ សេចក្តីប្រាថ្នាពីរយ៉ាងនេះ ដែលបុគ្គលលះបង់បានដោយកម្រ ។ សេចក្តីប្រាថ្នាពីរយ៉ាង តើដូចម្តេច ។ គឺប្រាថ្នាលាភ ១ ប្រាថ្នាជីវិត ១ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីប្រាថ្នាពីរយ៉ាងនេះ បុគ្គលលះបង់បានដោយកម្រ ។

(៣៦៤) ម្នាលភិក្ខុទាំងឡាយ បុគ្គលពីរពួកនេះ រកបានដោយកម្រក្នុងលោក ។ បុគ្គលពីរពួក តើដូចម្តេច ។ គឺបុគ្គលដែលធ្វើឧបការៈក្នុងមុន ១ បុគ្គលដឹងឧបការៈដែលគេធ្វើហើយធ្វើតបវិញ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពីរពួកនេះ រកបានដោយកម្រក្នុងលោក ។

(៣៦៥) ម្នាលភិក្ខុទាំងឡាយ បុគ្គលពីរពួកនេះរកបានដោយកម្រក្នុងលោក ។ បុគ្គលពីរពួក តើដូចម្តេច ។ គឺបុគ្គលឆ្អែតឆ្អន់ (ព្រោះតួប្រាថ្នាក្នុងចិត្តត្រូវរលាស់ស្រេច)១ បុគ្គលអ្នកធ្វើអ្នកដទៃឲ្យឆ្អែត (ព្រោះអាចធ្វើសត្វឲ្យស្ងប់ )១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពីរពួកនេះ រកបានដោយកម្រក្នុងលោក ។

(៣៦៦) ម្នាលភិក្ខុទាំងឡាយ បុគ្គលពីរពួកនេះគេឲ្យឆ្អែតបានដោយកម្រ ។ បុគ្គលពីរពួក តើដូចម្តេច ។ គឺបុគ្គលទុកដាក់របស់ដែលបានមក ១ បុគ្គលដែលកញ្ចះកញ្ចាយរបស់ដែលបានៗមក ១ ។

ឥមេ ខោ ភិក្ខវេ ទ្វេ បុគ្គលា ទុត្តប្បយាតិ ។

(៣៦៣) ទ្វេមេ ភិក្ខវេ បុគ្គលា សុតប្បយា ។ កតមេ ទ្វេ ។ យោ ច លទ្ធំ លទ្ធំ ន និក្ខិបតិ យោ ច លទ្ធំ លទ្ធំ ន វិស្សជ្ជេតិ ។ ឥមេ ខោ ភិក្ខវេ ទ្វេ បុគ្គលា សុតប្បយាតិ ។

(៣៦៤) ទ្វេមេ ភិក្ខវេ បច្ចយា រាគស្ស ឧប្បា-ទាយ ។ កតមេ ទ្វេ ។ សុភនិមិត្តញ្ច អយោ-និសោ ច មនសិការោ ។ ឥមេ ខោ ភិក្ខវេ ទ្វេ បច្ចយា រាគស្ស ឧប្បាទាយាតិ ។

(៣៦៥) ទ្វេមេ ភិក្ខវេ បច្ចយា ទោសស្ស ឧប្បាទាយ ។ កតមេ ទ្វេ ។ បដិឃនិមិត្តញ្ច អយោនិសោ ច មនសិការោ ។ ឥមេ ខោ ភិក្ខវេ ទ្វេ បច្ចយា ទោសស្ស ឧប្បាទាយាតិ ។



ម្នាលភិក្ខុទាំងឡាយ បុគ្គលពីរពួកនេះ គេឲ្យផ្គត់បានដោយក្រ ។

(៣៦៣) ម្នាលភិក្ខុទាំងឡាយ បុគ្គលពីរពួកនេះ គេឲ្យផ្គត់បានដោយងាយ ។ បុគ្គលពីរពួក តើដូចម្តេច ។ គឺបុគ្គលមិនលាក់ទុករបស់ដែលគេបានមក ១ បុគ្គលមិនខ្ជះខ្ជាយរបស់ដែលគេបានមក ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពីរពួកនេះ គេឲ្យផ្គត់បានដោយងាយ ។

(៣៦៤) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយពីរយ៉ាងនេះ ជាបច្ច័យដើម្បីនាំឲ្យរាគៈកើតឡើង ។ ធម៌ពីរយ៉ាង តើដូចម្តេច ។ គឺសុភ-និមិត្ត ១ អយោនិសោមនសិការ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ពីរយ៉ាងនេះ ជាបច្ច័យដើម្បីនាំឲ្យរាគៈកើតឡើង ។

(៣៦៥) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ ពីរយ៉ាងនេះ ជាបច្ច័យដើម្បីនាំឲ្យទោសៈកើតឡើង ។ ធម៌ពីរយ៉ាង តើដូចម្តេច ។ គឺបដិឃនិមិត្ត ១ អយោនិសោមនសិការ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ពីរយ៉ាងនេះ ជាបច្ច័យដើម្បីនាំឲ្យទោសៈកើតឡើង ។

(៣៧០) ទ្វេមេ ភិក្ខវេ បច្ចយា មិច្ឆាទិដ្ឋិយា ឧប្បាទាយ ។ កតមេ ទ្វេ ។ បរតោ ច ឃោសោ អយោនិសោ ច មនសិការោ ។ ឥមេ ខោ ភិក្ខវេ ទ្វេ បច្ចយា មិច្ឆាទិដ្ឋិយា ឧប្បាទាយាតិ ។

(៣៧១) ទ្វេមេ ភិក្ខវេ បច្ចយា សម្មាទិដ្ឋិយា ឧប្បាទាយ ។ កតមេ ទ្វេ ។ បរតោ ច ឃោសោ យោនិសោ ច មនសិការោ ។ ឥមេ ខោ ភិក្ខវេ ទ្វេ បច្ចយា សម្មាទិដ្ឋិយា ឧប្បាទាយាតិ ។

(៣៧២) ទ្វេមា ភិក្ខវេ អាបត្តិយោ ។ កតមា ទ្វេ ។ លហុកា ច អាបត្តិ គរុកា ច អាបត្តិ ។ ឥមា ខោ ភិក្ខវេ ទ្វេ អាបត្តិយោតិ ។

(៣៧៣) ទ្វេមា ភិក្ខវេ អាបត្តិយោ ។ កតមា ទ្វេ ។ ទុដ្ឋុល្លា ច អាបត្តិ អទុដ្ឋុល្លា ច អាបត្តិ ។ ឥមា ខោ ភិក្ខវេ ទ្វេ អាបត្តិយោតិ ។



(៣៧០) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយពីរយ៉ាងនេះ ជាបច្ច័យដើម្បីនាំឲ្យមិច្ឆាទិដ្ឋិកើតឡើង ។ ធម៌ពីរយ៉ាង តើដូចម្តេច ។ គឺសូរសំឡេងដ៏ចេញពីសំណាក់អ្នកដទៃ (ការស្តាប់អសទ្ធម្ម)១ អយោ-និសោមនសិការ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ពីរយ៉ាងនេះ ជាបច្ច័យដើម្បីនាំឲ្យមិច្ឆាទិដ្ឋិកើតឡើង ។

(៣៧១) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយពីរយ៉ាងនេះ ជាបច្ច័យដើម្បីនាំឲ្យសម្មាទិដ្ឋិកើតឡើង ។ ធម៌ពីរយ៉ាង តើដូចម្តេច គឺសូរសំឡេងដ៏ចេញពីសំណាក់អ្នកដទៃ (ការស្តាប់ព្រះសទ្ធម្ម)១ យោនិសោមន-សិការ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ពីរយ៉ាងនេះ ជាបច្ច័យដើម្បីនាំឲ្យសម្មាទិដ្ឋិកើតឡើង ។

(៣៧២) ម្នាលភិក្ខុទាំងឡាយ អាបត្តិទាំងឡាយនេះមានពីរយ៉ាង ។ អាបត្តិពីរយ៉ាង តើដូចម្តេច ។ គឺលហុកាបត្តិ១ គរុកាបត្តិ១ ។ ម្នាលភិក្ខុទាំងឡាយ អាបត្តិទាំងឡាយ មានពីរយ៉ាងនេះឯង ។

(៣៧៣) ម្នាលភិក្ខុទាំងឡាយ អាបត្តិទាំងឡាយនេះមានពីរយ៉ាង ។ អាបត្តិពីរយ៉ាង តើដូចម្តេច ។ គឺទុដ្ឋុល្លាបត្តិ (អាបត្តិធ្ងន់គឺបារាជិកសង្ឃាទិសេស)១ អទុដ្ឋុល្លាបត្តិ (អាបត្តិមិនធ្ងន់គឺអាបត្តិទាំង ៥ ក្រៅនេះ)១ ។ ម្នាលភិក្ខុទាំងឡាយ អាបត្តិទាំងឡាយ មានពីរយ៉ាងនេះ ។

[៣៧៤] ទ្វេមា ភិក្ខវេ អាបត្តិយោ ។ កតមា ទ្វេ ។ សាវសេសា ច អាបត្តិ អនវសេសា ច អាបត្តិ ។ ឥមា ខោ ភិក្ខវេ ទ្វេ អាបត្តិយោតិ ។

អាសាវគ្គោ បឋមោ ។

(៣៧៥) សទ្ធោ ភិក្ខវេ ភិក្ខុ ឯវំ សម្មា អាយាចមានោ អាយាចេយ្យ តាទិសោ ហោមិ យាទិសា សារីបុត្តមោគ្គល្លានាតិ ។ ឯសា ភិក្ខវេ តុលា ឯតំ បមាណំ មមំ សាវកានំ ភិក្ខូនំ យទិទំ សារីបុត្តមោគ្គល្លានាតិ ។

(៣៧៦) សទ្ធា ភិក្ខវេ ភិក្ខុនី ឯវំ សម្មា អាយាចមានា អាយាចេយ្យ តាទិសា ហោមិ យាទិសា ខេមា ច ភិក្ខុនី ឧប្បលវណ្ណា ចាតិ ។ ឯសា ភិក្ខវេ តុលា ឯតំ បមាណំ មមំ សាវិកានំ ភិក្ខុនីនំ យទិទំ ខេមា ច ភិក្ខុនី ឧប្បលវណ្ណា ចាតិ ។



(៣៧៤) ម្នាលភិក្ខុទាំងឡាយ អាបត្តិទាំងឡាយនេះមានពីរយ៉ាង ។ អាបត្តិពីរយ៉ាង តើដូចម្តេច ។ គឺសាវសេសាបត្តិ (អាបត្តិទាំង ៥ កង) ១ អនវសេសាបត្តិ (អាបត្តិបារាជិក) ១ ។ ម្នាលភិក្ខុទាំងឡាយ អាបត្តិទាំងឡាយ មានពីរយ៉ាងនេះឯង ។

ចប់ អាសាវគ្គទី ១ ។

(៣៧៥) ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានសទ្ធា កាលបើបន់ស្រន់ដោយប្រពៃ គប្បីបន់ស្រន់យ៉ាងនេះថា ព្រះសារីបុត្តនិងព្រះមោគ្គល្លានមានសភាពយ៉ាងណា អាត្មាអញ សូមឲ្យមានសភាពដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ សារីបុត្តនិងមោគ្គល្លាននេះ ជាថ្លឹងជាខ្នាតនៃពួកភិក្ខុ ជាសាវ័ករបស់តថាគត ។

(៣៧៦) ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីជាអ្នកមានសទ្ធា កាលបើបន់ស្រន់ដោយប្រពៃ គប្បីបន់ស្រន់យ៉ាងនេះថា ខេមាភិក្ខុនី និងឧប្បលវណ្ណាភិក្ខុនីមានសភាពយ៉ាងណា អាត្មាអញ សូមឲ្យមានសភាពដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ខេមាភិក្ខុនីនេះ និងឧប្បលវណ្ណាភិក្ខុនីនេះ ជាថ្លឹង ជាខ្នាតនៃពួកភិក្ខុនី ជាសាវិការបស់តថាគត ។

(៣៧៧) សទ្ធោ ភិក្ខវេ ឧបាសកោ ឯវំ សម្មា អាយាចមានោ អាយាចេយ្យ តាទិសោ ហោមិ យាទិសោ ចិត្តោ ច គហបតិ ហត្ថកោ ច អាឡវកោតិ ។ ឯសា ភិក្ខវេ តុលា ឯតំ បមាណំ មម សាវកានំ ឧបាសកានំ យទិទំ ចិត្តោ ច គហបតិ ហត្ថកោ ច អាឡវកោតិ ។

(៣៧៨) សទ្ធា ភិក្ខវេ ឧបាសិកា ឯវំ សម្មា អាយាចមានា អាយាចេយ្យ តាទិសី ហោមិ យាទិសី ខុជ្ជុត្តរា ច ឧបាសិកា វេឡុកណ្ដកិយា ច នន្ទមាតាតិ ។ ឯសា ភិក្ខវេ តុលា ឯតំ បមាណំ មម សាវិកានំ ឧបាសិកានំ យទិទំ ខុជ្ជុត្តរា ច ឧបាសិកា វេឡុកណ្ដកិយា ច នន្ទមាតាតិ ។

(៣៧៩) ទ្វីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ពាលោ អព្យត្តោ អសប្បុរិសោ ខតំ ឧបហតំ អត្តានំ បរិហរតិ សាវជ្ជោ ហោតិ សានុវជ្ជោ វិញ្ញូនំ ពហុញ្ច អបុញ្ញំ បសវតិ ។ កតមេហិ ទ្វីហិ ។



(៣៧៧) ម្នាលភិក្ខុទាំងឡាយ ឧបាសកជាអ្នកមានសទ្ធា កាលបើបន់ស្រន់ដោយប្រពៃ គប្បីបន់ស្រន់យ៉ាងនេះថា ចិត្តគហបតីក្តី ហត្ថកអាឡវកឧបាសកក្តី មានសភាពយ៉ាងណា អាត្មាអញ សូមឲ្យមានសភាពដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ចិត្តគហបតីនេះក្តី ហត្ថកអាឡវកឧបាសកនេះក្តី ជាជញ្ជីងជាខ្នាតនៃពួកឧបាសក ជាសាវករបស់តថាគត ។

(៣៧៨) ម្នាលភិក្ខុទាំងឡាយ ឧបាសិកាជាអ្នកមានសទ្ធា កាលបើបន់ស្រន់ដោយប្រពៃ គប្បីបន់ស្រន់យ៉ាងនេះថា ខុជ្ជុត្តរាឧបាសិកាក្តី វេឡុកណ្ដកិយានន្ទមាតាក្តី មានសភាពយ៉ាងណា អាត្មាអញ សូមឲ្យមានសភាពដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ខុជ្ជុត្តរាឧបាសិកានេះក្តី វេឡុកណ្ដកិយានន្ទមាតានេះក្តី ជាជញ្ជីង ជាខ្នាតនៃពួកឧបាសិកា ជាសាវិការបស់តថាគត ។

(៣៧៩) ម្នាលភិក្ខុទាំងឡាយ បុគ្គលពាល មិនឈ្លាសវៃ ជាអសប្បុរស ប្រកបដោយធម៌ពីរ យ៉ាងនេះ រមែងរក្សាខ្លួន ដែលខូចខាតរំលើង កំចាត់គុណលោះលះចេញ ជាអ្នកប្រកបដោយទោស ប្រកបដោយពាក្យតិះដៀលនៃអ្នកប្រាជ្ញទាំងឡាយផង រមែងបាននូវបាបច្រើនផង ។ ធម៌ពីរ តើដូចម្តេច ។

អននុវិច្ច អបរិយោគាហេត្វា អវណ្ណារហស្ស វណ្ណំ ភាសតិ អននុវិច្ច អបរិយោគាហេត្វា វណ្ណារហស្ស អវណ្ណំ ភាសតិ ។ ឥមេហិ ខោ ភិក្ខវេ ទ្វីហិ ធម្មេហិ សមន្នាគតោ ពាលោ អព្យត្តោ អសប្បុរិសោ ខតំ ឧបហតំ អត្តានំ បរិហរតិ សាវជ្ជោ ច ហោតិ សានុវជ្ជោ វិញ្ញូនំ ពហុញ្ច អបុញ្ញំ បសវតិ ។ ទ្វីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ បណ្ឌិតោ ព្យត្តោ សប្បុរិសោ អក្ខតំ អនុបហតំ អត្តានំ បរិហរតិ អនវជ្ជោ ច ហោតិ អននុវជ្ជោ វិញ្ញូនំ ពហុញ្ច បុញ្ញំ បសវតិ ។ កតមេហិ ទ្វីហិ ។ អនុវិច្ច បរិយោគាហេត្វា អវណ្ណារហស្ស អវណ្ណំ ភាសតិ អនុវិច្ច បរិយោគាហេត្វា វណ្ណារហស្ស វណ្ណំ ភាសតិ ។ ឥមេហិ ខោ ភិក្ខវេ ទ្វីហិ ធម្មេហិ សមន្នាគតោ បណ្ឌិតោ ព្យត្តោ សប្បុរិសោ អក្ខតំ អនុបហតំ អត្តានំ បរិហរតិ អនវជ្ជោ ច ហោតិ អននុវជ្ជោ វិញ្ញូនំ ពហុញ្ច បុញ្ញំ បសវតីតិ ។



គឺមិនពិចារណា មិនពិនិត្យស្រាវជ្រាវ ស្រាប់តែសរសើរគុណរបស់បុគ្គលមិនគួរសរសើរ ១ មិនពិចារណា មិនពិនិត្យស្រាវជ្រាវ ស្រាប់តែពោលទោសរបស់បុគ្គលគួរសរសើរ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលមិនឈ្លាសវៃជាអសប្បុរស ប្រកបដោយធម៌ពីរយ៉ាងនេះ តែងរក្សាខ្លួនដែលខ្លួនជីកគាស់រំលើងកំចាត់គុណពោលចេញ ជាអ្នកប្រកបដោយទោសផង ប្រកបដោយដំណៀលនៃអ្នកប្រាជ្ញទាំងឡាយផង តែងបានបាបច្រើនផង ។ ម្នាលភិក្ខុទាំងឡាយ បណ្ឌិតជាអ្នកឈ្លាសវៃ ជាសប្បុរសប្រកបដោយធម៌ពីរយ៉ាង តែងរក្សាខ្លួនដែលខ្លួនមិនបានជីកគាស់កំចាត់គុណពោលចេញ ជាអ្នកមិនប្រកបដោយទោសផង មិនមានដំណៀលនៃអ្នកប្រាជ្ញទាំងឡាយផង តែងបាននូវបុណ្យដ៏ច្រើនផង ។ ធម៌ពីរយ៉ាង តើដូចម្តេច ។ គឺពិចារណា ពិនិត្យស្រាវជ្រាវ ទើបពោលទោសរបស់បុគ្គលគួរពោលទោស ១ ពិចារណា ពិនិត្យស្រាវជ្រាវ ទើបសរសើរគុណរបស់បុគ្គលគួរសរសើរ ១ ។ ម្នាលភិក្ខុទាំងឡាយ បណ្ឌិតជាអ្នកឈ្លាសវៃ ជាសប្បុរសប្រកបដោយធម៌ពីរយ៉ាងនេះ តែងរក្សាខ្លួនដែលខ្លួនមិនបានជីកគាស់ កំចាត់គុណពោលចេញ ជាអ្នកមិនប្រកបដោយទោសផង មិនមានដំណៀលនៃអ្នកប្រាជ្ញទាំងឡាយផង តែងបាននូវបុណ្យដ៏ច្រើនផង ។

(៣៨០) ទ្វីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ពាលោ អព្យត្តោ អសប្បុរិសោ ខតំ ឧបហតំ អត្តានំ បរិហរតិ សាវជ្ជោ ច ហោតិ សានុវជ្ជោ វិញ្ញូនំ ពហុញ្ច អបុញ្ញំ បសវតិ ។ កតមេហិ ទ្វីហិ ។ អននុវិច្ច អបរិយោគាហេត្វា អប្បសាទនីយេ ឋានេ បសាទំ ឧបទំសេតិ អននុវិច្ច អបរិយោគាហេត្វា បសាទនីយេ ឋានេ អប្បសាទំ ឧបទំសេតិ ។ ឥមេហិ ខោ ភិក្ខវេ ទ្វីហិ ធម្មេហិ សមន្នាគតោ ពាលោ អព្យត្តោ អសប្បុរិសោ ខតំ ឧបហតំ អត្តានំ បរិហរតិ សាវជ្ជោ ច ហោតិ សានុវជ្ជោ វិញ្ញូនំ ពហុញ្ច អបុញ្ញំ បសវតិ ។ ទ្វីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ បណ្ឌិតោ ព្យត្តោ(១) សប្បុរិសោ អក្ខតំ អនុបហតំ អត្តានំ បរិហរតិ អនវជ្ជោ ច ហោតិ អននុវជ្ជោ វិញ្ញូនំ ពហុញ្ច បុញ្ញំ បសវតិ ។ កតមេហិ ទ្វីហិ ។

១ ម. វិយត្តោ ។



(៣៨០) ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលមិនឈ្លាសវៃ ជាអសប្បុរស ប្រកបដោយធម៌ទាំងពីរយ៉ាង តែងរក្សាខ្លួន ដែលខូចបាក់ ជីកគាស់ កំចាត់គុណចោលចេញ ជាអ្នកប្រកបដោយទោសផង ប្រកបដោយដំណៀលនៃអ្នកប្រាជ្ញទាំងឡាយផង តែងបានបាបដ៏ច្រើនផង ។ ធម៌ពីរយ៉ាង តើដូចម្តេច ។ គឺមិនពិចារណា មិនពិនិត្យមើល ស្រាប់តែបណ្ដុះសេចក្ដីជ្រះថ្លា ក្នុងហេតុដែលមិនគួរជ្រះថ្លា ១ មិនពិចារណា មិនពិនិត្យមើល ស្រាប់តែបណ្ដុះសេចក្ដីមិនជ្រះថ្លា ក្នុងហេតុដែលគួរជ្រះថ្លា ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលមិនឈ្លាសវៃ ជាអសប្បុរស ប្រកបដោយធម៌ពីរយ៉ាងនេះ តែងរក្សាខ្លួនដែលខូចជីកគាស់ កំចាត់គុណចោលចេញ ជាអ្នកប្រកបដោយទោសផង ប្រកបដោយដំណៀលនៃអ្នកប្រាជ្ញទាំងឡាយផង តែងបានបាបដ៏ច្រើនផង ។ ម្នាលភិក្ខុទាំងឡាយ បណ្ឌិតជាអ្នកឈ្លាសវៃ ជាសប្បុរស ប្រកបដោយធម៌ទាំងពីរយ៉ាង តែងរក្សាខ្លួនដែលខ្លួនមិនបានជីកគាស់ កំចាត់គុណចោលចេញ ជាអ្នកមិនមានទោសផង មិនមានដំណៀលនៃអ្នកប្រាជ្ញទាំងឡាយផង តែងបានបុណ្យដ៏ច្រើនផង ។ ធម៌ពីរយ៉ាង តើដូចម្តេច ។

អនុវិច្ច បរិយោគាហេត្វា អប្បសាទនីយេ ឋានេ អប្បសាទំ ឧបទំសេតិ អនុវិច្ច បរិយោគាហេត្វា បសាទនីយេ ឋានេ បសាទំ ឧបទំសេតិ ។ ឥមេហិ ខោ ភិក្ខវេ ទ្វីហិ ធម្មេហិ សមន្នាគតោ បណ្ឌិតោ ព្យត្តោ សប្បុរិសោ អក្ខតំ អនុបហតំ អត្តានំ បរិហរតិ អនវជ្ជោ ច ហោតិ អននុវជ្ជោ ច វិញ្ញូនំ ពហុញ្ច បុញ្ញំ បសវតិ ។

[៣៨១] ទ្វីសុ ភិក្ខវេ មិច្ឆាបដិបជ្ជមានោ ពាលោ អព្យត្តោ អសប្បុរិសោ ខតំ ឧបហតំ អត្តានំ បរិហរតិ សាវជ្ជោ ច ហោតិ សានុវជ្ជោ ច វិញ្ញូនំ ពហុញ្ច អបុញ្ញំ បសវតិ ។ កតមេសុ ទ្វីសុ ។ មាតរិ ច បិតរិ ច ។ ឥមេសុ ខោ ភិក្ខវេ ទ្វីសុ មិច្ឆាបដិបជ្ជមានោ ពាលោ អព្យត្តោ អសប្បុរិសោ ខតំ ឧបហតំ អត្តានំ បរិហរតិ សាវជ្ជោ ច ហោតិ សានុវជ្ជោ ច វិញ្ញូនំ ពហុញ្ច អបុញ្ញំ បសវតិ ។



គឺពិចារណា ពិនិត្យស្រាវជ្រាវ ហើយបណ្ដាលសេចក្ដីមិនជ្រះថ្លា ក្នុងហេតុដែលមិនគួរជ្រះថ្លា ១ ពិចារណាពិនិត្យស្រាវជ្រាវ ហើយបណ្ដាលសេចក្ដីជ្រះថ្លា ក្នុងហេតុដែលគួរជ្រះថ្លា ១ ។ ម្នាលភិក្ខុទាំងឡាយ បណ្ឌិតជាអ្នកឈ្លាសវៃ ជាសប្បុរស ប្រកបដោយធម៌ពីរយ៉ាងនេះ តែងរក្សាខ្លួនដែលខ្លួនមិនបានជីកកាស់កំចាត់គុណចោលចេញ ជាអ្នកមិនមានទោស មិនមានគេតិះដៀលនៃអ្នកប្រាជ្ញទាំងឡាយផង តែងបានបុណ្យដ៏ច្រើនផង ។

(៣៨១) ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលមិនឈ្លាសវៃ ជាអសប្បុរស កាលប្រតិបត្តិខុស ក្នុងបុគ្គលពីរពួក តែងរក្សាខ្លួនដែលខ្លួនបានជីកកាស់ កំចាត់គុណចោលចេញ ជាអ្នកប្រកបដោយទោសផង ប្រកបដោយពាក្យតិះដៀលនៃអ្នកប្រាជ្ញទាំងឡាយផង តែងបានបាបដ៏ច្រើនផង ។ បុគ្គលពីរពួក តើដូចម្ដេច ។ គឺមាតា ១ បិតា ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលមិនឈ្លាសវៃ ជាអសប្បុរស កាលប្រតិបត្តិខុស ក្នុងបុគ្គលពីរពួកនេះ តែងរក្សាខ្លួនដែលខ្លួនជីកកាស់ កំចាត់គុណចោលចេញ ជាអ្នកប្រកបដោយទោសផង ជាអ្នកប្រកបដោយពាក្យតិះដៀលនៃអ្នកប្រាជ្ញទាំងឡាយផង តែងបានបាបដ៏ច្រើនផង ។

ទ្វីសុ ភិក្ខវេ សម្មាបដិបជ្ជមានោ បណ្ឌិតោ ព្យត្តោ សប្បុរិសោ អក្ខតំ អនុបហតំ អត្តានំ បរិហរតិ អនវជ្ជោ ច ហោតិ អននុវជ្ជោ វិញ្ញូនំ ពហុញ្ច បុញ្ញំ បសវតិ ។ កតមេសុ ទ្វីសុ ។ មាតរិ ច បិតរិ ច ។ ឥមេសុ ខោ ភិក្ខវេ ទ្វីសុ សម្មាបដិបជ្ជមានោ បណ្ឌិតោ ព្យត្តោ សប្បុរិសោ អក្ខតំ អនុបហតំ អត្តានំ បរិហរតិ អនវជ្ជោ ច ហោតិ អននុវជ្ជោ វិញ្ញូនំ ពហុញ្ច បុញ្ញំ បសវតីតិ ។

(៣៩២) ទ្វីសុ ភិក្ខវេ មិច្ឆាបដិបជ្ជមានោ ពាលោ អព្យត្តោ អសប្បុរិសោ ខតំ ឧបហតំ អត្តានំ បរិហរតិ សាវជ្ជោ ច ហោតិ សានុវជ្ជោ វិញ្ញូនំ ពហុញ្ច អបុញ្ញំ បសវតិ ។ កតមេសុ ទ្វីសុ ។ តថាគតេ ច តថាគតសាវកេ ច ។ ឥមេសុ ខោ ភិក្ខវេ ទ្វីសុ មិច្ឆាបដិបជ្ជមានោ ពាលោ អព្យត្តោ អសប្បុរិសោ ខតំ ឧបហតំ អត្តានំ បរិហរតិ



ម្នាលភិក្ខុទាំងឡាយ បណ្ឌិតជាអ្នកឈ្លាសវៃ ជាសប្បុរសប្រតិបត្តិត្រូវក្នុងបុគ្គលពីរពួក រមែងរក្សាខ្លួនដែលខ្លួនមិនបានជីកកាស់ កំចាត់គុណចោលចេញ ជាអ្នកមិនមានទោសផង ជាអ្នកមិនមានដំណៀលនៃអ្នកប្រាជ្ញទាំងឡាយផង រមែងបាននូវបុណ្យដ៏ច្រើនផង ។ បុគ្គលពីរពួក តើដូចម្តេច ។ គឺមាតា ១ បិតា ១ ។ ម្នាលភិក្ខុទាំងឡាយ បណ្ឌិតជាអ្នកឈ្លាសវៃ ជាសប្បុរសប្រតិបត្តិត្រូវ ក្នុងបុគ្គលពីរពួកនេះ រមែងរក្សាខ្លួនដែលខ្លួនមិនបានជីកកាស់កំចាត់គុណចោលចេញ ជាអ្នកមិនមានទោសផង ជាអ្នកមិនមានដំណៀលនៃអ្នកប្រាជ្ញទាំងឡាយផង រមែងបាននូវបុណ្យដ៏ច្រើនផង ។

(៣៩២) ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលមិនឈ្លាសវៃ ជាអសប្បុរស ប្រតិបត្តិខុស ក្នុងបុគ្គលពីរពួក រមែងរក្សាខ្លួនដែលខ្លួនជីកកាស់ កំចាត់គុណចោលចេញ ជាអ្នកប្រកបដោយទោសផង ប្រកបដោយដំណៀលនៃអ្នកប្រាជ្ញទាំងឡាយផង រមែងបាននូវបាបដ៏ច្រើនផង ។ បុគ្គលពីរពួក តើដូចម្តេច ។ គឺព្រះតថាគត ១ សាវករបស់ព្រះតថាគត ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលមិនឈ្លាសវៃ ជាអសប្បុរសប្រតិបត្តិខុស ក្នុងបុគ្គលពីរពួកនេះរមែងរក្សាខ្លួនដែលខ្លួនជីកកាស់កំចាត់គុណចោលចេញ

សាវជ្ជោ ច ហោតិ សានុវជ្ជោ វិញ្ញូនំ ពហុញ្ច អបុញ្ញំ បសវតិ ។ ទ្វីសុ ភិក្ខវេ សម្មាបដិបជ្ជមានោ បណ្ឌិតោ ព្យត្តោ សប្បុរិសោ អក្ខតំ អនុបហតំ អត្តានំ បរិហរតិ អនវជ្ជោ ហោតិ អននុវជ្ជោ វិញ្ញូនំ ពហុញ្ច បុញ្ញំ បសវតិ ។ កតមេសុ ទ្វីសុ ។ តថាគតេ ច តថាគតសាវកេ ច ។ ឥមេសុ ខោ ភិក្ខវេ ទ្វីសុ សម្មាបដិបជ្ជមានោ បណ្ឌិតោ ព្យត្តោ សប្បុរិសោ អក្ខតំ អនុបហតំ អត្តានំ បរិហរតិ អនវជ្ជោ ច ហោតិ អននុវជ្ជោ វិញ្ញូនំ ពហុញ្ច បុញ្ញំ បសវតីតិ ។

(៣៨៣) ទ្វេមេ ភិក្ខវេ ធម្មា ។ កតមេ ទ្វេ ។ សចិត្តវោទានញ្ច ន ច កិញ្ចិ លោកេ ឧបាទិយតិ ។ ឥមេ ខោ ភិក្ខវេ ទ្វេ ធម្មាតិ ។



ជាអ្នកប្រកបដោយទោសផង ព្រោះជាទីតិះដៀលនៃអ្នកប្រាជ្ញទាំងឡាយផង តែងបាននូវបាបដ៏ច្រើនផង ។ ម្នាលភិក្ខុទាំងឡាយ បណ្ឌិតជាអ្នកឈ្លាសវៃ ជាសប្បុរសប្រតិបត្តិត្រូវ ក្នុងបុគ្គលពីរពួកតែងគ្រប់គ្រងខ្លួនដែលខ្លួនមិនបានជីកគាស់ កំចាត់គុណចោលចេញ ជាអ្នកមិនមានទោសផង មិនមានដំណៀលនៃអ្នកប្រាជ្ញទាំងឡាយផង តែងបាននូវបុណ្យដ៏ច្រើនផង ។ បុគ្គលពីរពួក តើដូចម្ដេច ។ គឺព្រះតថាគត ១ សាវករបស់ព្រះតថាគត ១ ។ ម្នាលភិក្ខុទាំងឡាយ បណ្ឌិតជាអ្នកឈ្លាសវៃ ជាសប្បុរសប្រតិបត្តិត្រូវ ក្នុងបុគ្គលពីរពួកនេះ តែងគ្រប់គ្រងខ្លួនដែលខ្លួនមិនបានជីកគាស់ កំចាត់គុណចោលចេញ ជាអ្នកមិនមានទោសផង មិនមានដំណៀលនៃអ្នកប្រាជ្ញទាំងឡាយផង តែងបាននូវបុណ្យដ៏ច្រើនផង ។

(៣៨៣) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយនេះមានពីរយ៉ាង ។ ធម៌ពីរយ៉ាង តើដូចម្ដេច ។ គឺការជំរះចិត្តរបស់ខ្លួនឲ្យផូរផង់ ១ មិនប្រកាន់មាំនូវវត្ថុណាមួយក្នុងលោក[១] ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយមានពីរយ៉ាងនេះឯង ។

---

១ បណ្ឌិតខ្លះពន្យល់ថា ៦ … ណាមួយ រៀង ៥ (បញ្ចក្ខន្ធ) ។

(៣៥៤) ទ្វេមេ ភិក្ខវេ ធម្មា ។ កតមេ ទ្វេ ។ កោធោ ច ឧបនាហោ ច ។ ឥមេ ខោ ភិក្ខវេ ទ្វេ ធម្មាតិ ។

(៣៥៥) ទ្វេមេ ភិក្ខវេ ធម្មា ។ កតមេ ទ្វេ ។ កោធវិនយោ ច ឧបនាហវិនយោ ច ។ ឥមេ ខោ ភិក្ខវេ ទ្វេ ធម្មាតិ ។

អាយាចនវគ្គោ ទុតិយោ ។

(៣៥៦) ទ្វេមានិ ភិក្ខវេ ទានានិ ។ កតមានិ ទ្វេ ។ អាមិសទានញ្ច ធម្មទានញ្ច ។ ឥមានិ ខោ ភិក្ខវេ ទ្វេ ទានានិ ។ ឯតទគ្គំ ភិក្ខវេ ឥមេសំ ទ្វិន្នំ ទានានំ យទិទំ ធម្មទានន្តិ ។

(៣៥៧) ទ្វេមេ ភិក្ខវេ យាគា ។ កតមេ ទ្វេ ។ អាមិសយាគោ ច ធម្មយាគោ ច ។ ឥមេ ខោ ភិក្ខវេ ទ្វេ យាគា ។ ឯតទគ្គំ ភិក្ខវេ ឥមេសំ ទ្វិន្នំ យាគានំ យទិទំ ធម្មយាគោតិ ។



(៣៥៤) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយនេះមានពីរយ៉ាង ។ ធម៌ពីរយ៉ាង តើដូចម្តេច ។ គឺសេចក្តីក្រោធ ១ ចងគំនុំ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយមានពីរយ៉ាងនេះឯង ។

(៣៥៥) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយនេះមានពីរយ៉ាង ។ ធម៌ពីរយ៉ាង តើដូចម្តេច ។ គឺការកំចាត់សេចក្តីក្រោធ ១ កំចាត់ចងគំនុំ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយមានពីរយ៉ាងនេះឯង ។

ចប់ អាយាចនវគ្គទី ២ ។

(៣៥៦) ម្នាលភិក្ខុទាំងឡាយ ទានទាំងឡាយនេះមានពីរយ៉ាង ។ ទានពីរយ៉ាង តើដូចម្តេច ។ គឺអាមិសទាន ១ ធម្មទាន ១ ។ ម្នាលភិក្ខុទាំងឡាយ ទានទាំងឡាយមានពីរយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាទានពីរយ៉ាងនេះ ធម្មទានដ៏ប្រសើរជាង ។

(៣៥៧) ម្នាលភិក្ខុទាំងឡាយ ការបូជាទាំងឡាយនេះ មានពីរយ៉ាង ។ ការបូជាពីរយ៉ាង តើដូចម្តេច ។ គឺការបូជាដោយអាមិសៈ ១ ការបូជាដោយធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ ការបូជាទាំងឡាយមានពីរយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាការបូជាទាំងពីរយ៉ាងនេះ ។ ការបូជាដោយធម៌ដ៏ប្រសើរជាង ។

(៣៨៨) ទ្វេមេ ភិក្ខវេ ចាគា ។ កតមេ ទ្វេ ។ អាមិសចាគោ ច ធម្មចាគោ ច ។ ឥមេ ខោ ភិក្ខវេ ទ្វេ ចាគា ។ ឯតទគ្គំ ភិក្ខវេ ឥមេសំ ទ្វិន្នំ ចាគានំ យទិទំ ធម្មចាគោតិ ។

(៣៨៩) ទ្វេមេ ភិក្ខវេ បរិច្ចាគា ។ កតមេ ទ្វេ ។ អាមិសបរិច្ចាគោ ច ធម្មបរិច្ចាគោ ច ។ ឥមេ ខោ ភិក្ខវេ ទ្វេ បរិច្ចាគា ។ ឯតទគ្គំ ភិក្ខវេ ឥមេសំ ទ្វិន្នំ បរិច្ចាគានំ យទិទំ ធម្មបរិច្ចាគោតិ ។

(៣៩០) ទ្វេមេ ភិក្ខវេ ភោគា ។ កតមេ ទ្វេ ។ អាមិសភោគោ ច ធម្មភោគោ ច ។ ឥមេ ខោ ភិក្ខវេ ទ្វេ ភោគា ។ ឯតទគ្គំ ភិក្ខវេ ឥមេសំ ទ្វិន្នំ ភោគានំ យទិទំ ធម្មភោគោតិ ។

(៣៩១) ទ្វេមេ ភិក្ខវេ សម្ភោគា ។ កតមេ ទ្វេ ។ អាមិសសម្ភោគោ ច ធម្មសម្ភោគោ ច ។ ឥមេ ខោ ភិក្ខវេ ទ្វេ សម្ភោគា ។ ឯតទគ្គំ ភិក្ខវេ ឥមេសំ ទ្វិន្នំ សម្ភោគានំ យទិទំ ធម្មសម្ភោគោតិ ។



(៣៨៨) ម្នាលភិក្ខុទាំងឡាយ ចាគៈទាំងឡាយនេះមានពីរយ៉ាង ចាគៈពីរយ៉ាង តើដូចម្តេច ។ គឺអាមិសចាគៈ ១ ធម្មចាគៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ចាគៈទាំងឡាយមានពីរយ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ បណ្តាចាគៈទាំងពីរយ៉ាងនេះ ធម្មចាគៈនុ៎ះប្រសើរជាង ។

(៣៨៩) ម្នាលភិក្ខុទាំងឡាយ ការបរិច្ចាគទាំងឡាយនេះមានពីរយ៉ាង ។ ការបរិច្ចាគពីរយ៉ាង តើដូចម្តេច ។ គឺអាមិសបរិច្ចាគ ១ ធម្មបរិច្ចាគ ១ ។ ម្នាលភិក្ខុទាំងឡាយ ការបរិច្ចាគមានពីរយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាបរិច្ចាគពីរយ៉ាងនេះ ធម្មបរិច្ចាគនុ៎ះប្រសើរជាង

(៣៩០) ម្នាលភិក្ខុទាំងឡាយ ភោគៈទាំងឡាយនេះមានពីរយ៉ាង ។ ភោគៈពីរយ៉ាង តើដូចម្តេច ។ គឺអាមិសភោគៈ ១ ធម្មភោគៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ភោគៈទាំងឡាយមានពីរយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាភោគៈពីរយ៉ាងនេះ ធម្មភោគៈនុ៎ះប្រសើរជាង ។

(៣៩១) ម្នាលភិក្ខុទាំងឡាយ ការប្រើប្រាស់ទាំងឡាយនេះមានពីរយ៉ាង ។ ការប្រើប្រាស់ពីរយ៉ាង តើដូចម្តេច ។ គឺប្រើប្រាស់អាមិសៈ ១ ប្រើប្រាស់ធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ ការប្រើប្រាស់ទាំងឡាយ មានពីរយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាការប្រើប្រាស់ពីរយ៉ាងនេះ ការប្រើប្រាស់ធម៌នុ៎ះប្រសើរជាង ។

(៣៩៦) ទ្វេមេ ភិក្ខវេ សំវិភាគា ។ កតមេ ទ្វេ ។ អាមិសសំវិភាគោ ច ធម្មសំវិភាគោ ច ។ ឥមេ ខោ ភិក្ខវេ ទ្វេ សំវិភាគា ។ ឯតទគ្គំ ភិក្ខវេ ឥមេសំ ទ្វិន្នំ សំវិភាគានំ យទិទំ ធម្មសំវិភាគោតិ ។

(៣៩៧) ទ្វេមេ ភិក្ខវេ សង្គហា ។ កតមេ ទ្វេ ។ អាមិសសង្គហោ ច ធម្មសង្គហោ ច ។ ឥមេ ខោ ភិក្ខវេ ទ្វេ សង្គហា ។ ឯតទគ្គំ ភិក្ខវេ ឥមេសំ ទ្វិន្នំ សង្គហានំ យទិទំ ធម្មសង្គហោតិ ។

(៣៩៨) ទ្វេមេ ភិក្ខវេ អនុគ្គហា ។ កតមេ ទ្វេ ។ អាមិសានុគ្គហោ ច ធម្មានុគ្គហោ ច ។ ឥមេ ខោ ភិក្ខវេ ទ្វេ អនុគ្គហា ។ ឯតទគ្គំ ភិក្ខវេ ឥមេសំ ទ្វិន្នំ អនុគ្គហានំ យទិទំ ធម្មានុគ្គហោតិ ។



(៣៩៦) ម្នាលភិក្ខុទាំងឡាយ ការចែករំលែកទាំងឡាយនេះ មានពីរយ៉ាង ។ ការចែករំលែកពីរយ៉ាង តើដូចម្តេច ។ គឺការចែករំលែកអាមិសៈ ១ ការចែករំលែកធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ ការចែករំលែកទាំងឡាយមានពីរយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាការចែករំលែកពីរយ៉ាងនេះ ការចែករំលែកធម៌ជាប្រសើរជាង ។

(៣៩៧) ម្នាលភិក្ខុទាំងឡាយ ការសង្គ្រោះទាំងឡាយនេះ មានពីរយ៉ាង ។ ការសង្គ្រោះពីរយ៉ាង តើដូចម្តេច ។ គឺសង្គ្រោះដោយអាមិសៈ ១ សង្គ្រោះដោយធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ ការសង្គ្រោះទាំងឡាយមានពីរយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាការសង្គ្រោះពីរយ៉ាងនេះ ការសង្គ្រោះដោយធម៌ជាប្រសើរជាង ។

(៣៩៨) ម្នាលភិក្ខុទាំងឡាយ សេចក្តីអនុគ្រោះទាំងឡាយនេះ មានពីរយ៉ាង ។ សេចក្តីអនុគ្រោះពីរយ៉ាង តើដូចម្តេច ។ គឺអនុគ្រោះដោយអាមិសៈ ១ អនុគ្រោះដោយធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីអនុគ្រោះទាំងឡាយ មានពីរយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាសេចក្តីអនុគ្រោះពីរយ៉ាងនេះ អនុគ្រោះដោយធម៌ជាប្រសើរជាង ។

(៣៩៥) ទ្វេមា ភិក្ខវេ អនុកម្បា ។ កតមា ទ្វេ ។ អាមិសានុកម្បា ច ធម្មានុកម្បា ច ។ ឥមា ខោ ភិក្ខវេ ទ្វេ អនុកម្បា ។ ឯតទគ្គំ ភិក្ខវេ ឥមាសំ ទ្វិន្នំ អនុកម្បានំ យទិទំ ធម្មានុកម្បាតិ ។

ទានវគ្គោ តតិយោ ។

(៣៩៦) ទ្វេមេ ភិក្ខវេ សន្ថារា ។ កតមេ ទ្វេ ។ អាមិសសន្ថារោ ច ធម្មសន្ថារោ ច ។ ឥមេ ខោ ភិក្ខវេ ទ្វេ សន្ថារា ។ ឯតទគ្គំ ភិក្ខវេ ឥមេសំ ទ្វិន្នំ សន្ថារានំ យទិទំ ធម្មសន្ថារោតិ ។

(៣៩៧) ទ្វេមេ ភិក្ខវេ បដិសន្ថារា ។ កតមេ ទ្វេ ។ អាមិសប្បដិសន្ថារោ ច ធម្មប្បដិសន្ថារោ ច ។ ឥមេ ខោ ភិក្ខវេ ទ្វេ បដិសន្ថារា ។ ឯតទគ្គំ ភិក្ខវេ ឥមេសំ ទ្វិន្នំ បដិសន្ថារានំ យទិទំ ធម្មប្បដិសន្ថារោតិ ។



(៣៩៥) ម្នាលភិក្ខុទាំងឡាយ សេចក្តីអាសូរទាំងឡាយនេះមានពីរយ៉ាង ។ សេចក្តីអាសូរពីរយ៉ាង តើដូចម្តេច ។ គឺអាសូរដោយអាមិសៈ១ អាសូរដោយធម៌១ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីអាសូរទាំងឡាយមានពីរយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាសេចក្តីអាសូរទាំងពីរយ៉ាងនេះ សេចក្តីអាសូរដោយធម៌នុ៎ះប្រសើរជាង ។

ចប់ ទានវគ្គទី ៣ ។

(៣៩៦) ម្នាលភិក្ខុទាំងឡាយ ការរាក់ទាក់ទាំងឡាយនេះ មានពីរយ៉ាង ។ ការរាក់ទាក់ពីរយ៉ាង តើដូចម្តេច ។ គឺការរាក់ទាក់ដោយអាមិសៈ១ ការរាក់ទាក់ដោយធម៌១ ។ ម្នាលភិក្ខុទាំងឡាយ ការរាក់ទាក់មានពីរយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាការរាក់ទាក់ពីរយ៉ាងនេះ ការរាក់ទាក់ដោយធម៌នុ៎ះប្រសើរជាង ។

(៣៩៧) ម្នាលភិក្ខុទាំងឡាយ បដិសន្ថារៈទាំងឡាយនេះ មានពីរយ៉ាង ។ បដិសន្ថារៈពីរយ៉ាង តើដូចម្តេច ។ គឺបដិសន្ថារៈដោយអាមិសៈ១ បដិសន្ថារៈដោយធម៌១ ។ ម្នាលភិក្ខុទាំងឡាយ បដិសន្ថារៈមានពីរយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាបដិសន្ថារៈទាំងពីរយ៉ាងនេះ បដិសន្ថារៈដោយធម៌នុ៎ះប្រសើរជាង ។

(៣៩៨) ទ្វេមា ភិក្ខវេ ឯសនា ។ កតមា ទ្វេ ។ អាមិសេសនា ច ធម្មេសនា ច ។ ឥមា ខោ ភិក្ខវេ ទ្វេ ឯសនា ។ ឯតទគ្គំ ភិក្ខវេ ឥមាសំ ទ្វិន្នំ ឯសនានំ យទិទំ ធម្មេសនាតិ ។

(៣៩៩) ទ្វេមា ភិក្ខវេ បរិយេសនា ។ កតមា ទ្វេ ។ អាមិសបរិយេសនា ច ធម្មបរិយេសនា ច ។ ឥមា ខោ ភិក្ខវេ ទ្វេ បរិយេសនា ។ ឯតទគ្គំ ភិក្ខវេ ឥមាសំ ទ្វិន្នំ បរិយេសនានំ យទិទំ ធម្មបរិយេសនាតិ ។

(៤០០) ទ្វេមា ភិក្ខវេ បរិយេដ្ឋិយោ ។ កតមា ទ្វេ ។ អាមិសបរិយេដ្ឋិ ច ធម្មបរិយេដ្ឋិ ច ។ ឥមា ខោ ភិក្ខវេ ទ្វេ បរិយេដ្ឋិយោ ។ ឯតទគ្គំ ភិក្ខវេ ឥមាសំ ទ្វិន្នំ បរិយេដ្ឋីនំ យទិទំ ធម្មបរិយេដ្ឋីតិ ។



(៣៩៨) ម្នាលភិក្ខុទាំងឡាយ ការស្វែងរកនេះ មានពីរយ៉ាង ។ ការស្វែងរកពីរយ៉ាង តើដូចម្តេច ។ គឺការស្វែងរកអាមិសៈ ១ ការស្វែងរកធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ ការស្វែងរក មានពីរយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាការស្វែងរកទាំងពីរយ៉ាងនេះ ការស្វែងរកធម៌នុ៎ះប្រសើរជាង ។

(៣៩៩) ម្នាលភិក្ខុទាំងឡាយ ការស្វះស្វែងទាំងឡាយនេះ មានពីរយ៉ាង ។ ការស្វះស្វែងពីរយ៉ាង តើដូចម្តេច ។ គឺការស្វះស្វែងអាមិសៈ ១ ការស្វះស្វែងធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ ការស្វះស្វែងទាំងឡាយមានពីរយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាការស្វះស្វែងពីរយ៉ាងនេះ ការស្វះស្វែងធម៌នុ៎ះប្រសើរជាង ។

(៤០០) ម្នាលភិក្ខុទាំងឡាយ ការត្រាច់រកទាំងឡាយនេះ មានពីរយ៉ាង ។ ការត្រាច់រកពីរយ៉ាង តើដូចម្តេច ។ គឺការត្រាច់រកអាមិសៈ ១ ការត្រាច់រកធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ ការត្រាច់រកទាំងឡាយមានពីរយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាការត្រាច់រកពីរយ៉ាងនេះ ការត្រាច់រកធម៌នុ៎ះប្រសើរជាង ។

(៦០១) ទ្វេមា ភិក្ខវេ បូជា ។ កតមា ទ្វេ ។ អាមិសបូជា ច ធម្មបូជា ច ។ ឥមា ខោ ភិក្ខវេ ទ្វេ បូជា ។ ឯតទគ្គំ ភិក្ខវេ ឥមាសំ ទ្វិន្នំ បូជានំ យទិទំ ធម្មបូជាតិ ។

(៦០២) ទ្វេមានិ ភិក្ខវេ អតិថេយ្យានិ ។ កតមានិ ទ្វេ ។ អាមិសាតិថេយ្យញ្ច ធម្មាតិថេយ្យញ្ច ។ ឥមានិ ខោ ភិក្ខវេ ទ្វេ អតិថេយ្យានិ ។ ឯតទគ្គំ ភិក្ខវេ ឥមេសំ ទ្វិន្នំ អតិថេយ្យានំ យទិទំ ធម្មាតិថេយ្យន្តិ ។

(៦០៣) ទ្វេមា ភិក្ខវេ ឥទ្ធិយោ ។ កតមា ទ្វេ ។ អាមិសិទ្ធិ ច ធម្មិទ្ធិ ច ។ ឥមា ខោ ភិក្ខវេ ទ្វេ ឥទ្ធិយោ ។ ឯតទគ្គំ ភិក្ខវេ ឥមាសំ ទ្វិន្នំ ឥទ្ធីនំ យទិទំ ធម្មិទ្ធីតិ ។



(៦០១) ម្នាលភិក្ខុទាំងឡាយ បូជាទាំងឡាយនេះមានពីរយ៉ាង ។ បូជាពីរយ៉ាង តើដូចម្តេច ។ គឺអាមិសបូជា ១ ធម្មបូជា ១ ។ ម្នាលភិក្ខុទាំងឡាយ បូជាទាំងឡាយមានពីរយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាបូជាពីរយ៉ាងនេះ ធម្មបូជានុ៎ះប្រសើរជាង ។

(៦០២) ម្នាលភិក្ខុទាំងឡាយ ការដើម្បីភ្ញៀវទាំងឡាយនេះមានពីរយ៉ាង ។ ការដើម្បីភ្ញៀវពីរយ៉ាង តើដូចម្តេច ។ គឺការដើម្បីភ្ញៀវដោយអាមិសៈ ១ ការដើម្បីភ្ញៀវដោយធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ ការដើម្បីភ្ញៀវទាំងឡាយ មានពីរយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាការដើម្បីភ្ញៀវពីរយ៉ាងនេះ ការដើម្បីភ្ញៀវ ដោយធម៌នុ៎ះប្រសើរជាង ។

(៦០៣) ម្នាលភិក្ខុទាំងឡាយ សេចក្តីសម្រេចទាំងឡាយនេះមានពីរយ៉ាង ។ សេចក្តីសម្រេចពីរយ៉ាង តើដូចម្តេច ។ គឺសេចក្តីសម្រេចដោយអាមិសៈ ១ សេចក្តីសម្រេចដោយធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីសម្រេចទាំងឡាយ មានពីរយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាសេចក្តីសម្រេចពីរយ៉ាងនេះ សេចក្តីសម្រេចដោយធម៌នុ៎ះប្រសើរជាង ។

(៦០៤) ទ្វេមា ភិក្ខវេ វុឌ្ឍិយោ ។ កតមា ទ្វេ ។ អាមិសវុឌ្ឍិ ច ធម្មវុឌ្ឍិ ច ។ ឥមា ខោ ភិក្ខវេ ទ្វេ វុឌ្ឍិយោ ។ ឯតទគ្គំ ភិក្ខវេ ឥមាសំ ទ្វិន្នំ វុឌ្ឍីនំ យទិទំ ធម្មវុឌ្ឍីតិ ។

(៦០៥) ទ្វេមានិ ភិក្ខវេ រតនានិ ។ កតមានិ ទ្វេ ។ អាមិសរតនញ្ច ធម្មរតនញ្ច ។ ឥមានិ ខោ ភិក្ខវេ ទ្វេ រតនានិ ។ ឯតទគ្គំ ភិក្ខវេ ឥមេសំ ទ្វិន្នំ រតនានំ យទិទំ ធម្មរតនន្តិ ។

(៦០៦) ទ្វេមេ ភិក្ខវេ សន្និចយា ។ កតមេ ទ្វេ ។ អាមិសសន្និចយោ ច ធម្មសន្និចយោ ច ។ ឥមេ ខោ ភិក្ខវេ ទ្វេ សន្និចយា ។ ឯតទគ្គំ ភិក្ខវេ ឥមេសំ ទ្វិន្នំ សន្និចយានំ យទិទំ ធម្មសន្និចយោតិ ។

(៦០៧) ទ្វេមានិ ភិក្ខវេ វេបុល្លានិ ។ កតមានិ ទ្វេ ។ អាមិសវេបុល្លញ្ច ធម្មវេបុល្លញ្ច ។



(៦០៤) ម្នាលភិក្ខុទាំងឡាយ សេចក្តីចំរើនទាំងឡាយនេះមានពីរយ៉ាង ។ សេចក្តីចំរើនពីរយ៉ាង តើដូចម្តេច ។ គឺសេចក្តីចំរើនដោយអាមិសៈ១ សេចក្តីចំរើនដោយធម៌១ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីចំរើនទាំងឡាយមានពីរយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាសេចក្តីចំរើនពីរយ៉ាងនេះ សេចក្តីចំរើនដោយធម៌នុ៎ះប្រសើរជាង ។

(៦០៥) ម្នាលភិក្ខុទាំងឡាយ រតនៈទាំងឡាយនេះ មានពីរយ៉ាង ។ រតនៈពីរយ៉ាង តើដូចម្តេច ។ គឺអាមិសរតនៈ១ ធម្មរតនៈ១ ។ ម្នាលភិក្ខុទាំងឡាយ រតនៈទាំងឡាយ មានពីរយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តារតនៈពីរយ៉ាងនេះ ធម្មរតនៈនុ៎ះប្រសើរជាង ។

(៦០៦) ម្នាលភិក្ខុទាំងឡាយ ការសន្សំទាំងឡាយនេះ មានពីរយ៉ាង ។ ការសន្សំពីរយ៉ាង តើដូចម្តេច ។ គឺការសន្សំអាមិសៈ១ ការសន្សំធម៌១ ។ ម្នាលភិក្ខុទាំងឡាយ ការសន្សំទាំងឡាយ មានពីរយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាការសន្សំពីរយ៉ាងនេះ ការសន្សំធម៌នុ៎ះប្រសើរជាង ។

(៦០៧) ម្នាលភិក្ខុទាំងឡាយ សេចក្តីសម្បូណ៌នេះមានពីរយ៉ាង ។ សេចក្តីសម្បូណ៌ពីរយ៉ាង តើដូចម្តេច ។ គឺសម្បូណ៌អាមិសៈ១ សម្បូណ៌ធម៌១ ។

ឥមានិ ខោ ភិក្ខវេ ទ្វេ វេបុល្លានិ ។ ឯតទគ្គំ ភិក្ខវេ ឥមេសំ ទ្វិន្នំ វេបុល្លានំ យទិទំ ធម្មវេបុល្លន្តិ ។

សមាបត្តិវគ្គោ ចតុត្ថោ ។

(៦០៨) ទ្វេមេ ភិក្ខវេ ធម្មា ។ កតមេ ទ្វេ ។ សមាបត្តិកុសលតា ច សមាបត្តិវុដ្ឋានកុសលតា ច ។ ឥមេ ខោ ភិក្ខវេ ទ្វេ ធម្មាតិ ។

(៦០៩) ទ្វេមេ ភិក្ខវេ ធម្មា ។ កតមេ ទ្វេ ។ អជ្ជវញ្ច មទ្ទវញ្ច ។ ឥមេ ខោ ភិក្ខវេ ទ្វេ ធម្មាតិ ។

(៦១០) ទ្វេមេ ភិក្ខវេ ធម្មា ។ កតមេ ទ្វេ ។ ខន្តិ ច សោរច្ចំ ច ។ ឥមេ ខោ ភិក្ខវេ ទ្វេ ធម្មាតិ ។

(៦១១) ទ្វេមេ ភិក្ខវេ ធម្មា ។ កតមេ ទ្វេ ។ សាខល្យញ្ច បដិសន្ថារោ ច ។ ឥមេ ខោ ភិក្ខវេ ទ្វេ ធម្មាតិ ។



ម្នាលភិក្ខុទាំងឡាយ សេចក្តីសម្បូរណ៍ មានពីរយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាសេចក្តីសម្បូរណ៍ពីរយ៉ាងនេះ សេចក្តីសម្បូរណ៍ដោយធម៌ប្រសើរជាង ។

ចប់ សមាបត្តិវគ្គទី ៤ ។

(៦០៨) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយនេះមានពីរយ៉ាង ។ ធម៌ពីរយ៉ាង តើដូចម្តេច ។ គឺការឈ្លាសវៃក្នុងសមាបត្តិ ១ ការឈ្លាសវៃក្នុងការចេញចាកសមាបត្តិ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ មានពីរយ៉ាងនេះឯង ។

(៦០៩) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយនេះមានពីរយ៉ាង ។ ធម៌ពីរយ៉ាង តើដូចម្តេច ។ គឺភាពនៃចិត្តត្រង់ ១ ភាពនៃចិត្តទន់ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ មានពីរយ៉ាងនេះឯង ។

(៦១០) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយនេះមានពីរយ៉ាង ។ ធម៌ពីរយ៉ាង តើដូចម្តេច ។ គឺខន្តិ ១ សោរច្ចៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ មានពីរយ៉ាងនេះឯង ។

(៦១១) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយនេះមានពីរយ៉ាង ។ ធម៌ពីរយ៉ាង តើដូចម្តេច ។ គឺសខិលៈ ១ ការទទួលរាក់ទាក់ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ មានពីរយ៉ាងនេះឯង ។

(៤១៦) ទ្វេមេ ភិក្ខវេ ធម្មា ។ កតមេ ទ្វេ ។ អហិរិកំ ច អនោត្តប្បញ្ច ។ ឥមេ ខោ ភិក្ខវេ ទ្វេ ធម្មាតិ ។

(៤១៧) ទ្វេមេ ភិក្ខវេ ធម្មា ។ កតមេ ទ្វេ ។ ឥន្ទ្រិយេសុ អគុត្តទ្វារតា ច ភោជនេ អមត្តញ្ញុតា ច ។ ឥមេ ខោ ភិក្ខវេ ទ្វេ ធម្មាតិ ។

(៤១៨) ទ្វេមេ ភិក្ខវេ ធម្មា ។ កតមេ ទ្វេ ។ ឥន្ទ្រិយេសុ គុត្តទ្វារតា ច ភោជនេ មត្តញ្ញុតា ច ។ ឥមេ ខោ ភិក្ខវេ ទ្វេ ធម្មាតិ ។

(៤១៩) ទ្វេមេ ភិក្ខវេ ធម្មា ។ កតមេ ទ្វេ ។ បដិសង្ខានពលញ្ច ភាវនាពលញ្ច ។ ឥមេ ខោ ភិក្ខវេ ទ្វេ ធម្មាតិ ។

(៤២០) ទ្វេមេ ភិក្ខវេ ធម្មា ។ កតមេ ទ្វេ ។ សតិពលញ្ច សមាធិពលញ្ច(១) ។ ឥមេ ខោ ភិក្ខវេ ទ្វេ ធម្មាតិ ។

---

១ ម. ការណពលញ្ច ។



(៤១៦) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយនេះមានពីរយ៉ាង ។ ធម៌ពីរយ៉ាង តើដូចម្តេច ។ គឺសេចក្តីមិនខ្មាសបាប ១ សេចក្តីមិនខ្លាចបាប ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ មានពីរយ៉ាងនេះឯង ។

(៤១៧) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយនេះមានពីរយ៉ាង ។ ធម៌ពីរយ៉ាង តើដូចម្តេច ។ គឺការមិនរក្សាទ្វារក្នុងឥន្ទ្រិយ ១ ការមិនស្គាល់ប្រមាណក្នុងភោជន ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ មានពីរយ៉ាងនេះឯង ។

(៤១៨) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយនេះមានពីរយ៉ាង ។ ធម៌ពីរយ៉ាង តើដូចម្តេច ។ គឺការរក្សាទ្វារក្នុងឥន្ទ្រិយ ១ ការស្គាល់ប្រមាណក្នុងភោជន ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយមានពីរយ៉ាងនេះឯង ។

(៤១៩) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយនេះមានពីរយ៉ាង ។ ធម៌ពីរយ៉ាង តើដូចម្តេច ។ គឺកម្លាំងពិចារណា ១ កម្លាំងភាវនា ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ មានពីរយ៉ាងនេះឯង ។

(៤២០) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយនេះ មានពីរយ៉ាង ។ ធម៌ទាំងពីរ តើដូចម្តេច ។ គឺកម្លាំងស្មារតី ១ កម្លាំងសមាធិ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ មានពីរយ៉ាងនេះឯង ។

(៤០៧) ទ្វេមេ ភិក្ខវេ ធម្មា ។ កតមេ ទ្វេ ។ សមថោ ច វិបស្សនា ច ។ ឥមេ ខោ ភិក្ខវេ ទ្វេ ធម្មាតិ ។

(៤០៨) ទ្វេមេ ភិក្ខវេ ធម្មា ។ កតមេ ទ្វេ ។ សីលវិបត្តិ ច ទិដ្ឋិវិបត្តិ ច ។ ឥមេ ខោ ភិក្ខវេ ទ្វេ ធម្មាតិ ។

(៤០៩) ទ្វេមេ ភិក្ខវេ ធម្មា ។ កតមេ ទ្វេ ។ សីលសម្បទា ច ទិដ្ឋិសម្បទា ច ។ ឥមេ ខោ ភិក្ខវេ ទ្វេ ធម្មាតិ ។

(៤១០) ទ្វេមេ ភិក្ខវេ ធម្មា ។ កតមេ ទ្វេ ។ សីលវិសុទ្ធិ ច ទិដ្ឋិវិសុទ្ធិ ច ។ ឥមេ ខោ ភិក្ខវេ ទ្វេ ធម្មាតិ ។

(៤១១) ទ្វេមេ ភិក្ខវេ ធម្មា ។ កតមេ ទ្វេ ។ ទិដ្ឋិវិសុទ្ធិ ច យថា ទិដ្ឋិស្ស ច បធានំ ។ ឥមេ ខោ ភិក្ខវេ ទ្វេ ធម្មាតិ ។



(៤០៧) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយនេះ មានពីរយ៉ាង ។ ធម៌ពីរយ៉ាង តើដូចម្តេច ។ គឺសមថៈ ១ វិបស្សនា ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ មានពីរយ៉ាងនេះឯង ។

(៤០៨) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយនេះមានពីរយ៉ាង ។ ធម៌ពីរយ៉ាង តើដូចម្តេច ។ គឺសីលវិបត្តិ ១ ទិដ្ឋិវិបត្តិ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ មានពីរយ៉ាងនេះឯង ។

(៤០៩) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយនេះមានពីរយ៉ាង ។ ធម៌ពីរយ៉ាង តើដូចម្តេច ។ គឺសីលសម្បទា ១ ទិដ្ឋិសម្បទា ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ មានពីរយ៉ាងនេះឯង ។

(៤១០) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយនេះមានពីរយ៉ាង ។ ធម៌ពីរយ៉ាង តើដូចម្តេច ។ គឺសីលវិសុទ្ធិ ១ ទិដ្ឋិវិសុទ្ធិ ១ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ មានពីរយ៉ាងនេះឯង ។

(៤១១) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយនេះមានពីរយ៉ាង ។ ធម៌ពីរយ៉ាង តើដូចម្តេច ។ គឺសេចក្តីបរិសុទ្ធិនៃទិដ្ឋិ ១ សេចក្តីព្យាយាមរបស់បុគ្គលដែលមានទិដ្ឋិដ៏សមគួរ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ មានពីរយ៉ាងនេះឯង ។

(៤២២) ទ្វេមេ ភិក្ខវេ ធម្មា ។ កតមេ ទ្វេ ។ អសន្តុដ្ឋិតា ច កុសលេសុ ធម្មេសុ អប្បដិវាណិតា ច បធានស្មឹ ។ ឥមេ ខោ ភិក្ខវេ ទ្វេ ធម្មាតិ ។

(៤២៣) ទ្វេមេ ភិក្ខវេ ធម្មា ។ កតមេ ទ្វេ ។ មុដ្ឋស្សច្ចញ្ច អសម្បជញ្ញញ្ច ។ ឥមេ ខោ ភិក្ខវេ ទ្វេ ធម្មាតិ ។

(៤២៤) ទ្វេមេ ភិក្ខវេ ធម្មា ។ កតមេ ទ្វេ ។ សតិ ច សម្បជញ្ញញ្ច ។ ឥមេ ខោ ភិក្ខវេ ទ្វេ ធម្មាតិ ។

សមាបត្តិវគ្គោ បញ្ចមោ ។

តតិយោ បណ្ណាសកោ សមត្តោ ។





(៤២២) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយនេះមានពីរយ៉ាង ។ ធម៌ពីរយ៉ាង តើដូចម្តេច ។ គឺសេចក្តីមិនសន្តោសក្នុងកុសលធម៌ ១ មិនរួញរាក្នុងការព្យាយាម ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ មានពីរយ៉ាងនេះឯង ។

(៤២៣) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយនេះមានពីរយ៉ាង ។ ធម៌ពីរយ៉ាង តើដូចម្តេច ។ គឺការភ្លេចស្មារតី ១ សេចក្តីមិនដឹងខ្លួន ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ មានពីរយ៉ាងនេះឯង ។

(៤២៤) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយនេះមានពីរយ៉ាង ។ ធម៌ពីរយ៉ាង តើដូចម្តេច ។ គឺសតិ ១ សម្បជញ្ញៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ មានពីរយ៉ាងនេះឯង ។

ចប់ សមាបត្តិវគ្គ ទី ៥ ។

ចប់ តតិយបណ្ណាសក ។

## បណ្ណាសកាសង្គហិតា សុត្តា

(៤៤៥) ទ្វេមេ ភិក្ខវេ ធម្មា ។ កតមេ ទ្វេ ។ កោធោ ច ឧបនាហោ ច... មក្ខោ ច បឡាសោ ច... ឥស្សា ច មច្ឆរិយញ្ច... មាយា ច សាឋេយ្យញ្ច... អហិរិកញ្ច អនោត្តប្បញ្ច ។ ឥមេ ខោ ភិក្ខវេ ទ្វេ ធម្មាតិ ។

(៤៤៦) ទ្វេមេ ភិក្ខវេ ធម្មា ។ កតមេ ទ្វេ ។ អកោធោ ច អនុបនាហោ ច... អមក្ខោ ច អបឡាសោ ច... អនិស្សា ច អមច្ឆរិយញ្ច... អមាយា ច អសាឋេយ្យញ្ច... ហិរី ច ឱត្តប្បញ្ច ។ ឥមេ ខោ ភិក្ខវេ ទ្វេ ធម្មាតិ ។

(៤៤៧) ទ្វីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ទុក្ខំ វិហរតិ ។ កតមេហិ ទ្វីហិ ។ កោធេន ច ឧបនាហេន ច... មក្ខេន ច បឡាសេន ច... ឥស្សាយ ច មច្ឆរិយេន ច... មាយាយ ច សាឋេយ្យេន ច... អហិរិកេន ច អនោត្តប្បេន ច ។ ឥមេហិ ខោ ភិក្ខវេ ទ្វីហិ ធម្មេហិ សមន្នាគតោ ទុក្ខំ វិហរតីតិ ។

## ពួកសូត្រដែលមិនបានសង្រ្គោះក្នុងបណ្ណាសក

(៤៤៥) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយនេះមានពីរយ៉ាង ។ ធម៌ពីរយ៉ាង តើដូចម្តេច ។ គឺសេចក្តីក្រោធ ១ ចងគំនុំ ១... លុបគុណ ១ លើកកំពស់ ១... ឫស្យា ១ កំណាញ់ ១... លាក់ពុត ១ អួតអាង ១... មិនមានសេចក្តីខ្មាសបាប ១ មិនមានសេចក្តីខ្លាចបាប ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ មានពីរយ៉ាងនេះឯង ។

(៤៤៦) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយនេះមានពីរយ៉ាង ។ ធម៌ពីរយ៉ាង តើដូចម្តេច ។ គឺសេចក្តីមិនក្រោធ ១ មិនចងគំនុំ ១... មិនលុបគុណ ១ មិនលើកកំពស់ ១... មិនឫស្យា ១ មិនកំណាញ់ ១... មិនលាក់ពុត ១ មិនអួតអាង ១... សេចក្តីខ្មាសបាប ១ សេចក្តីខ្លាចបាប ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ មានពីរយ៉ាងនេះឯង ។

(៤៤៧) ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ពីរយ៉ាង តែងនៅជាទុក្ខ ។ ធម៌ពីរយ៉ាង តើដូចម្តេច ។ គឺសេចក្តីក្រោធ ១ ចងគំនុំ ១... លុបគុណ ១ លើកកំពស់ ១... ឫស្យា ១ កំណាញ់ ១... លាក់ពុត ១ អួតអាង ១... មិនមានសេចក្តីខ្មាសបាប ១ មិនមានសេចក្តីខ្លាចបាប ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ពីរយ៉ាងនេះ តែងនៅជាទុក្ខ ។

(៤៦៨) ទ្វីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ សុខំ វិហរតិ ។ កតមេហិ ទ្វីហិ ។ អក្កោធេន ច អនុបនាហេន ច... អមក្ខេន ច អបឡាសេន ច... អនិស្សាយ ច អមច្ឆរិយេន ច... អមាយាយ ច អសាឋេយ្យេន ច... ហិរិយា ច ឱត្តប្បេន ច ។ ឥមេហិ ខោ ភិក្ខវេ ទ្វីហិ ធម្មេហិ សមន្នាគតោ សុខំ វិហរតីតិ ។

(៤៦៩) ទ្វេមេ ភិក្ខវេ ធម្មា សេក្ខស្ស ភិក្ខុនោ បរិហានាយ សំវត្តន្តិ ។ កតមេ ទ្វេ ។ កោធោ ច ឧបនាហោ ច... មក្ខោ ច បឡាសោ ច... ឥស្សា ច មច្ឆរិយញ្ច... មាយា ច សាឋេយ្យញ្ច... អហិរិកញ្ច អនោត្តប្បញ្ច ។ ឥមេ ខោ ភិក្ខវេ ទ្វេ ធម្មា សេក្ខស្ស ភិក្ខុនោ បរិហានាយ សំវត្តន្តីតិ ។

(៤៧០) ទ្វេមេ ភិក្ខវេ ធម្មា សេក្ខស្ស ភិក្ខុនោ អបរិហានាយ សំវត្តន្តិ ។ កតមេ ទ្វេ ។ អក្កោធោ ច អនុបនាហោ ច... អមក្ខោ ច អបឡាសោ ច...



(៤៦៨) ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ពីរយ៉ាង រមែងនៅជាសុខ ។ ធម៌ទាំងពីរយ៉ាង តើដូចម្តេច ។ គឺសេចក្តីមិនក្រោធ ១ មិនចងគំនុំ ១... មិនលុបគុណ ១ មិនលើកកំពស់ ១... មិនឫស្យា ១ មិនកំណាញ់ ១... មិនលាក់ពុត ១ មិនអួតអាង ១... សេចក្តីខ្មាសបាប ១ សេចក្តីខ្លាចបាប ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ពីរយ៉ាងនេះ រមែងនៅជាសុខ ។

(៤៦៩) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយពីរយ៉ាងនេះ រមែងប្រព្រឹត្តទៅ ដើម្បីសាបសូន្យនៃសេក្ខភិក្ខុ ។ ធម៌ទាំងពីរយ៉ាង តើដូចម្តេច ។ គឺសេចក្តីក្រោធ ១ ចងគំនុំ ១... លុបគុណ ១ លើកកំពស់ ១... ឫស្យា ១ កំណាញ់ ១... លាក់ពុត ១ អួតអាង ១... មិនមានសេចក្តីខ្មាសបាប ១ មិនមានសេចក្តីខ្លាចបាប ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងពីរយ៉ាងនេះ រមែងប្រព្រឹត្តទៅ ដើម្បីសាបសូន្យនៃសេក្ខភិក្ខុ ។

(៤៧០) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយពីរយ៉ាងនេះ រមែងប្រព្រឹត្តទៅដើម្បីមិនសាបសូន្យនៃសេក្ខភិក្ខុ ។ ធម៌ទាំងពីរយ៉ាង តើដូចម្តេច ។ គឺសេចក្តីមិនក្រោធ ១ មិនចងគំនុំ ១... មិនលុបគុណ ១ មិនលើកកំពស់ ១...

អនិស្សា ច អមច្ឆរិយញ្ច... អមាយា ច អសាឋេយ្យញ្ច... ហិរិ ច ឱត្តប្បញ្ច ។ ឥមេ ខោ ភិក្ខវេ ទស ធម្មា សេក្ខស្ស ភិក្ខុនោ អបរិហានាយ សំវត្តន្តីតិ ។

(២៣១) ទសហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ កតមេហិ ទសហិ ។ កោធេន ច ឧបនាហេន ច... មក្ខេន ច បឡាសេន ច... ឥស្សាយ ច មច្ឆរិយេន ច... មាយាយ ច សាឋេយ្យេន ច... អហិរិកេន ច អនោត្តប្បេន ច ។ ឥមេហិ ខោ ភិក្ខវេ ទសហិ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ និរយេតិ ។

(២៣២) ទសហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ សគ្គេ ។ កតមេហិ ទសហិ ។ អកោធេន ច អនុបនាហេន ច... អមក្ខេន ច អបឡាសេន ច... អនិស្សាយ ច អមច្ឆរិយេន ច... អមាយាយ ច អសាឋេយ្យេន ច... ហិរិយា ច ឱត្តប្បេន ច ។ ឥមេហិ ខោ ភិក្ខវេ ទសហិ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ សគ្គេតិ ។



មិនឫស្យា ១ មិនកំណាញ់ ១... មិនលាក់ពុត ១ មិនអួតអាង ១... សេចក្តីខ្មាសបាប ១ សេចក្តីខ្លាចបាប ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ១០ យ៉ាងនេះ តែងប្រព្រឹត្តទៅ ដើម្បីមិនសាបសូន្យនៃសេក្ខភិក្ខុ ។

(២៣១) ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ១០ យ៉ាង ទើបធ្លាក់ទៅក្នុងនរក ដូចគេយកទៅទំលាក់ចោល ។ ធម៌ ១០ យ៉ាង តើដូចម្តេច ។ គឺសេចក្តីក្រោធ ១ ចងគំនុំ ១... លុបគុណ ១ លើកកំពស់ ១... ឫស្យា ១ កំណាញ់ ១... លាក់ពុត ១ អួតអាង ១... មិនមានសេចក្តីខ្មាសបាប ១ មិនមានសេចក្តីខ្លាចបាប ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ១០ យ៉ាងនេះ ទើបធ្លាក់ទៅក្នុងនរក ដូចគេយកទៅទំលាក់ចោល ។

(២៣២) ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ១០ យ៉ាង ទើបទៅកើតក្នុងឋានសួគ៌ ដូចជាគេនាំយកទៅដាក់ទុក ។ ធម៌ ១០ យ៉ាង តើដូចម្តេច ។ គឺសេចក្តីមិនក្រោធ ១ មិនចងគំនុំ ១... មិនលុបគុណ ១ មិនលើកកំពស់ ១... មិនឫស្យា ១ មិនកំណាញ់ ១... មិនលាក់ពុត ១ មិនអួតអាង ១... សេចក្តីខ្មាសបាប ១ សេចក្តីខ្លាចបាប ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ១០ យ៉ាងនេះ ទើបទៅកើតក្នុងឋានសួគ៌ ដូចជាគេនាំយកទៅដាក់ទុក ។

(៤៣៣) ទ្វីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ឥធេកច្ចោ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ ។ កតមេហិ ទ្វីហិ ។ កោធេន ច ឧបនាហេន ច... មក្ខេន ច បឡាសេន ច... ឥស្សាយ ច មច្ឆរិយេន ច... មាយាយ ច សាឋេយ្យេន ច... អហិរិកេន ច អនោត្តប្បេន ច ។ ឥមេហិ ខោ ភិក្ខវេ ទ្វីហិ ធម្មេហិ សមន្នាគតោ ឥធេកច្ចោ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ ។

(៤៣៤) ទ្វីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ឥធេកច្ចោ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ ។ កតមេហិ ទ្វីហិ ។ អក្កោធេន ច អនុបនាហេន ច... អមក្ខេន ច អបឡាសេន ច... អនិស្សាយ ច អមច្ឆរិយេន ច... អមាយាយ ច អសាឋេយ្យេន ច... ហិរិយា ច ឱត្តប្បេន ច ។ ឥមេហិ ខោ ភិក្ខវេ ទ្វីហិ ធម្មេហិ សមន្នាគតោ ឥធេកច្ចោ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ ។



(៤៣៣) ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ ប្រកបដោយធម៌ពីរយ៉ាង លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ។ ធម៌ពីរយ៉ាង តើដូចម្តេច ។ គឺសេចក្តីក្រោធ ១ ចងគំនុំ ១... លុបគុណ ១ រលើសរលាស់ ១... ច្រណែន ១ កំណាញ់ ១... ល្បិចកល ១ អួតអាង ១... មិនមានសេចក្តីខ្មាសបាប ១ មិនមានសេចក្តីខ្លាចបាប ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ ប្រកបដោយធម៌ទាំងពីរយ៉ាងនេះ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ។

(៤៣៤) ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ ប្រកបដោយធម៌ពីរយ៉ាង លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក ។ ធម៌ពីរយ៉ាង តើដូចម្តេច ។ គឺសេចក្តីមិនក្រោធ ១ មិនចងគំនុំ ១... មិនលុបគុណ ១ មិនរលើសរលាស់ ១... មិនច្រណែន ១ មិនកំណាញ់ ១... មិនល្បិចកល ១ មិនអួតអាង ១... សេចក្តីខ្មាសបាប ១ សេចក្តីខ្លាចបាប ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ប្រកបដោយធម៌ពីរយ៉ាងនេះ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក ។

[២៣៥] ទ្វេមេ ភិក្ខវេ ធម្មា អកុសលា ... ទ្វេមេ ភិក្ខវេ ធម្មា កុសលា ... ទ្វេមេ ភិក្ខវេ ធម្មា សាវជ្ជា ... ទ្វេមេ ភិក្ខវេ ធម្មា អនវជ្ជា ... ទ្វេមេ ភិក្ខវេ ធម្មា ទុក្ខុទ្រយា ... ទ្វេមេ ភិក្ខវេ ធម្មា សុខុទ្រយា ... ទ្វេមេ ភិក្ខវេ ធម្មា ទុក្ខវិបាកា ... ទ្វេមេ ភិក្ខវេ ធម្មា សុខវិបាកា ... ទ្វេមេ ភិក្ខវេ ធម្មា សព្យាបជ្ឈា ... ទ្វេមេ ភិក្ខវេ ធម្មា អព្យាបជ្ឈា ។ កតមេ ទ្វេ ។ អក្កោធោ ច អនុបនាហោ ច ... អមក្ខោ ច អបឡាសោ ច ... អនិស្សា ច អមច្ឆរិយញ្ច ... អមាយា ច អសាឋេយ្យញ្ច ... ហិរី ច ឱត្តប្បញ្ច ។ ឥមេ ខោ ភិក្ខវេ ទ្វេ ធម្មា អព្យាបជ្ឈាតិ(១) ។

[២៣៦] ទ្វេមេ ភិក្ខវេ អត្ថវសេ បដិច្ច តថាគតេន សាវកានំ សិក្ខាបទំ បញ្ញត្តំ ។ កតមេ ទ្វេ ។ សង្ឃសុដ្ឋុតាយ សង្ឃផាសុតាយ ... ទុម្មង្កូនំ បុគ្គលានំ និគ្គហាយ

---

១ ម. [illegible] បាលី [illegible] ។



(២៣៥) ម្នាលភិក្ខុទាំងឡាយ ធម៌ពីរយ៉ាងនេះជាអកុសល។–ម្នាលភិក្ខុទាំងឡាយ ធម៌ពីរយ៉ាងនេះជាកុសល... ម្នាលភិក្ខុទាំងឡាយ ធម៌ពីរយ៉ាងនេះ ប្រកបដោយទោស... ម្នាលភិក្ខុទាំងឡាយ ធម៌ពីរយ៉ាងនេះមិនមានទោស... ម្នាលភិក្ខុទាំងឡាយ ធម៌ពីរយ៉ាងនេះជាគ្រឿងចំរើនសេចក្តីទុក្ខ... ម្នាលភិក្ខុទាំងឡាយ ធម៌ពីរយ៉ាងនេះជាគ្រឿងចំរើនសេចក្តីសុខ... ម្នាលភិក្ខុទាំងឡាយ ធម៌ពីរយ៉ាងនេះមានផលជាទុក្ខ... ម្នាលភិក្ខុទាំងឡាយ ធម៌ពីរយ៉ាងនេះមានផលជាសុខ... ម្នាលភិក្ខុទាំងឡាយ ធម៌ពីរយ៉ាងនេះ ប្រកបដោយព្យាបាទ... ម្នាលភិក្ខុទាំងឡាយ ធម៌ពីរយ៉ាងនេះមិនប្រកបដោយព្យាបាទ ។ ធម៌ពីរយ៉ាង តើដូចម្តេច ។ គឺសេចក្តីមិនក្រោធ មិនចងគំនុំ... មិនលុបគុណគេ មិនលើកកំពស់ ១... មិនច្រណែន មិនកំណាញ់ ១... មិនបោកពុត មិនអួតអាង ១... សេចក្តីខ្មាសបាប ១ សេចក្តីខ្លាចបាប ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ពីរយ៉ាងនេះ មិនប្រកបដោយព្យាបាទឡើយ ។

(២៣៦) ម្នាលភិក្ខុទាំងឡាយ ព្រះតថាគត បញ្ញត្តសិក្ខាបទដល់សាវកទាំងឡាយ ព្រោះអាស្រ័យអំណាចប្រយោជន៍ពីរយ៉ាងនេះ ។ អំណាចប្រយោជន៍ពីរយ៉ាង តើដូចម្តេច ។ គឺដើម្បីសេចក្តីល្អដល់សង្ឃ ១ ដើម្បីសេចក្តីស្រួលដល់សង្ឃ ១ ... ដើម្បីសង្កត់សង្កិនបុគ្គលទាំងឡាយ ដែលមិនមានសេចក្តីអៀនខ្មាស ១

បេសលានំ ភិក្ខូនំ ផាសុវិហារាយ... ទិដ្ឋធម្មិកានំ អាសវានំ សំវរាយ សម្បរាយិកានំ អាសវានំ បដិឃាតាយ... ទិដ្ឋធម្មិកានំ វេរានំ សំវរាយ សម្បរាយិកានំ វេរានំ បដិឃាតាយ... ទិដ្ឋធម្មិកានំ វជ្ជានំ សំវរាយ សម្បរាយិកានំ វជ្ជានំ បដិឃាតាយ... ទិដ្ឋធម្មិកានំ ភយានំ សំវរាយ សម្បរាយិកានំ ភយានំ បដិឃាតាយ... ទិដ្ឋធម្មិកានំ អកុសលានំ ធម្មានំ សំវរាយ សម្បរាយិកានំ អកុសលានំ ធម្មានំ បដិឃាតាយ... គិហីនំ អនុកម្បាយ បាបិច្ឆានំ(១) បក្ខុបច្ឆេទាយ... អប្បសន្នានំ បសាទាយ បសន្នានំ ភិយ្យោភាវាយ... សទ្ធម្មដ្ឋិតិយា វិនយានុគ្គហាយ ។ ឥមេ ខោ ភិក្ខវេ ទ្វេ អត្ថវសេ បដិច្ច តថាគតេន សាវកានំ សិក្ខាបទំ បញ្ញត្តំ ។

---

១ ម. [illegible] ។



ដើម្បីនៅជាសុខស្រួលនៃភិក្ខុទាំងឡាយដែលមានសីលជាទីស្រឡាញ់១... ដើម្បីរក្សានូវអាសវៈទាំងឡាយក្នុងបច្ចុប្បន្ន១ ដើម្បីកំចាត់បង់នូវអាសវៈទាំងឡាយ ក្នុងខាងមុខ១... ដើម្បីរក្សានូវពៀរទាំងឡាយក្នុងបច្ចុប្បន្ន១ ដើម្បីកំចាត់បង់នូវពៀរទាំងឡាយក្នុងខាងមុខ១ ... ដើម្បីរក្សានូវទោសទាំងឡាយ ក្នុងបច្ចុប្បន្ន១ ដើម្បីកំចាត់បង់នូវទោសទាំងឡាយ ក្នុងខាងមុខ១ ... ដើម្បីរក្សានូវភ័យទាំងឡាយ ក្នុងបច្ចុប្បន្ន ១ ដើម្បីកំចាត់បង់នូវភ័យទាំងឡាយក្នុងខាងមុខ១... ដើម្បីរក្សានូវអកុសលធម៌ទាំងឡាយ ក្នុងបច្ចុប្បន្ន១ ដើម្បីកំចាត់បង់នូវអកុសលធម៌ទាំងឡាយ ក្នុងខាងមុខ១...ដើម្បីអនុគ្រោះដល់គ្រហស្ថទាំងឡាយ១ ដើម្បីផ្តាច់បង់នូវពួកនៃភិក្ខុមានសេចក្តីប្រាថ្នាលាមក១ ដើម្បីដឹកនាំជនទាំងឡាយ ដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើង១ ដើម្បីដឹកនាំជនទាំងឡាយ ដែលជ្រះថ្លាស្រាប់ហើយ ឲ្យរឹតតែជ្រះថ្លាឡើង ១ ដើម្បីដំកល់ខាន់នៃព្រះសទ្ធម្ម(១)១ ដើម្បីអនុគ្រោះដល់វិន័យ(២)១ ។ ម្នាលភិក្ខុទាំងឡាយ តថាគត បញ្ញត្តសិក្ខាបទដល់សាវកទាំងឡាយ ព្រោះអាស្រ័យអំណាចប្រយោជន៍ទាំងពីរយ៉ាងនេះ ។

---

១ បានដល់ព្រះសទ្ធម្ម៣ យ៉ាង គឺបរិយត្តិសទ្ធម្ម១ បដិបត្តិសទ្ធម្ម១ អធិគមសទ្ធម្ម ឬបដិវេធសទ្ធម្ម១ ។

២ ដើម្បីទំនុកបំរុងនូវគម្ពីរវិន័យ ៤ យ៉ាង គឺសំវរវិន័យ បានដល់ការសង្រួមឥន្ទ្រិយ...១ បហានវិន័យ បានដល់ការលះបង់ លះធម៌ដែលគួរលះ...១ សមថវិន័យ បានដល់សមថៈទាំង៧ យ៉ាង១ បញ្ញត្តិវិន័យ បានដល់សិក្ខាបទដែលជាអាណា ត្រូវបញ្ញត្តិមិនឲ្យខ្វះទៅដល់ភិក្ខុទាំងឡាយ១ ។ បរមត្ថ ។

[២៣៧] ទ្វេមេ ភិក្ខវេ អត្ថវសេ បដិច្ច តថាគតេន សាវកានំ បាតិមោក្ខំ បញ្ញត្តំ... បាតិមោក្ខុទ្ទេសោ បញ្ញត្តោ... បាតិមោក្ខដ្ឋបនំ បញ្ញត្តំ... បវារណា បញ្ញត្តា... បវារណាដ្ឋបនំ បញ្ញត្តំ... តជ្ជនីយកម្មំ បញ្ញត្តំ... និយស្សកម្មំ បញ្ញត្តំ... បព្វាជនីយកម្មំ បញ្ញត្តំ... បដិសារណីយកម្មំ បញ្ញត្តំ... ឧក្ខេបនីយកម្មំ បញ្ញត្តំ... បរិវាសទានំ បញ្ញត្តំ... មូលាយបដិកស្សនំ បញ្ញត្តំ... មានត្តទានំ បញ្ញត្តំ... អព្ភានំ បញ្ញត្តំ... ឱសារណំ(១) បញ្ញត្តំ... និស្សារណំ(២) បញ្ញត្តំ... ឧបសម្បទា បញ្ញត្តា... ញត្តិកម្មំ បញ្ញត្តំ... ញត្តិទុតិយកម្មំ បញ្ញត្តំ... ញត្តិចតុត្ថកម្មំ បញ្ញត្តំ... អបញ្ញត្តេ បញ្ញត្តំ... បញ្ញត្តេ អនុប្បញ្ញត្តំ... សម្មុខាវិនយោ បញ្ញត្តោ... សតិវិនយោ បញ្ញត្តោ... អមូឡ្ហវិនយោ បញ្ញត្តោ... បដិញ្ញាតករណំ បញ្ញត្តំ... យេភុយ្យសិកា បញ្ញត្តា... តស្សបាបិយសិកា បញ្ញត្តា... តិណវត្ថារកោ បញ្ញត្តោ ។ កតមេ ទ្វេ ។ សង្ឃសុដ្ឋុតាយ សង្ឃផាសុតាយ... ទុម្មង្កូនំ បុគ្គលានំ និគ្គហាយ

១ ឱ. ម. ឱសារណីយំ ។ ២ និស្សារណីយំ ។



(២៣៧) ម្នាលភិក្ខុទាំងឡាយ តថាគត បញ្ញត្តបាតិមោក្ខដល់សាវកទាំងឡាយ...បញ្ញត្តបាតិមោក្ខុទ្ទេស ... បញ្ញត្តការបញ្ឈប់បាតិមោក្ខ ... បញ្ញត្តបវារណា ... បញ្ញត្តការបញ្ឈប់បវារណា ... បញ្ញត្តតជ្ជនីយកម្ម... បញ្ញត្តនិយស្សកម្ម...បញ្ញត្តបព្វាជនីយកម្ម...បញ្ញត្តបដិសារណីយកម្ម ... បញ្ញត្តឧក្ខេបនីយកម្ម...បញ្ញត្តការឲ្យបរិវាស...បញ្ញត្តការទាញអាបត្តិមកដាក់ក្នុងមូលាបត្តិ...បញ្ញត្តការឲ្យមានត្ត...បញ្ញត្តអព្ភាន ... បញ្ញត្តឱសារណកម្ម...បញ្ញត្តនិស្សារណកម្ម...បញ្ញត្តឧបសម្បទា...បញ្ញត្តញត្តិកម្ម... បញ្ញត្តញត្តិទុតិយកម្ម... បញ្ញត្តញត្តិចតុត្ថកម្ម... បញ្ញត្តសិក្ខាបទដែលមិនទាន់បញ្ញត្ត ... បញ្ញត្តថែមក្នុងសិក្ខាបទដែលទ្រង់បញ្ញត្តរួចហើយ ... បញ្ញត្តសម្មុខាវិន័យ... បញ្ញត្តសតិវិន័យ... បញ្ញត្តអមូឡ្ហវិន័យ ... បញ្ញត្តបដិញ្ញាតករណៈ... បញ្ញត្តយេភុយ្យសិកា... បញ្ញត្តតស្សបាបិយសិកា... បញ្ញត្តតិណវត្ថារកៈ ព្រោះអាស្រ័យអំណាចប្រយោជន៍ពីរយ៉ាងនេះ ។ អំណាចប្រយោជន៍ទាំងពីរយ៉ាងនោះ តើដូចម្តេច ។ គឺ ដើម្បីសេចក្តីល្អដល់សង្ឃ ១ ដើម្បីនៅសប្បាយនៃសង្ឃ ១ ... ដើម្បីសង្កត់សង្កិនបុគ្គលទាំងឡាយ ដែលមិនអៀនខ្មាស ១

បេសលានំ ភិក្ខូនំ ផាសុវិហារាយ... ទិដ្ឋធម្មិកានំ អាសវានំ សំវរាយ សម្បរាយិកានំ អាសវានំ បដិឃាតាយ... ទិដ្ឋធម្មិកានំ វេរានំ សំវរាយ សម្បរាយិកានំ វេរានំ បដិឃាតាយ... ទិដ្ឋធម្មិកានំ វជ្ជានំ សំវរាយ សម្បរាយិកានំ វជ្ជានំ បដិឃាតាយ... ទិដ្ឋធម្មិកានំ ភយានំ សំវរាយ សម្បរាយិកានំ ភយានំ បដិឃាតាយ... ទិដ្ឋធម្មិកានំ អកុសលានំ ធម្មានំ សំវរាយ សម្បរាយិកានំ អកុសលានំ ធម្មានំ បដិឃាតាយ... គិហីនំ អនុកម្បាយ បាបិច្ឆានំ បក្ខុបច្ឆេទាយ... អប្បសន្នានំ បសាទាយ បសន្នានំ ភិយ្យោភាវាយ... សទ្ធម្មដ្ឋិតិយា វិនយានុគ្គហាយ ។ ឥមេ ខោ ភិក្ខវេ ទ្វេ អត្ថវសេ បដិច្ច តថាគតេន សាវកានំ សិក្ខាបទំ បញ្ញត្តំ ។



ដើម្បីនៅជាសុខស្រួលនៃភិក្ខុទាំងឡាយដែលមានសីលជាទីស្រឡាញ់ ១ ដើម្បីកំចាត់នូវអាសវៈទាំងឡាយក្នុងបច្ចុប្បន្ន ១ ដើម្បីកំចាត់បង់នូវអាសវៈទាំងឡាយក្នុងអនាគត ១ ... ដើម្បីកំចាត់នូវពៀរទាំងឡាយក្នុងបច្ចុប្បន្ន ១ ដើម្បីកំចាត់បង់នូវពៀរទាំងឡាយក្នុងអនាគត ១ ... ដើម្បីកំចាត់នូវទោសទាំងឡាយក្នុងបច្ចុប្បន្ន ១ ដើម្បីកំចាត់បង់នូវទោសទាំងឡាយ ក្នុងអនាគត ១ ដើម្បីកំចាត់នូវភ័យទាំងឡាយក្នុងបច្ចុប្បន្ន ១ ដើម្បីកំចាត់បង់នូវភ័យទាំងឡាយ ក្នុងអនាគត ១ ... ដើម្បីកំចាត់នូវអកុសលធម៌ទាំងឡាយក្នុងបច្ចុប្បន្ន ១ ដើម្បីកំចាត់បង់នូវអកុសលធម៌ទាំងឡាយក្នុងអនាគត ១ ... ដើម្បីអនុគ្រោះដល់គ្រហស្ថទាំងឡាយ ១ ដើម្បីផ្តាច់បង់នូវពួកនៃភិក្ខុមានសេចក្តីប្រាថ្នាលាមក ១ ... ដើម្បីនឹកនាំជនទាំងឡាយ ដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើង ១ ដើម្បីនឹកនាំជនទាំងឡាយ ដែលជ្រះថ្លាស្រាប់ហើយ ឲ្យរឹតតែជ្រះថ្លាឡើង ១ ... ដើម្បីដំកល់នៅនៃព្រះសទ្ធម្ម ១ ដើម្បីអនុគ្រោះដល់វិន័យ ១ ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគត បញ្ញត្តសិក្ខាបទដល់សាវកទាំងឡាយ ព្រោះអាស្រ័យអំណាចប្រយោជន៍ទាំងពីរនេះ ។

(៦៣៨) រាគស្ស ភិក្ខវេ អភិញ្ញាយ ទ្វេ ធម្មា ភាវេតព្វា ។ កតមេ ទ្វេ ។ សមថោ ច វិបស្សនា ច ។ រាគស្ស ភិក្ខវេ អភិញ្ញាយ ឥមេ ទ្វេ ធម្មា ភាវេតព្វាតិ ។ រាគស្ស ភិក្ខវេ បរិញ្ញាយ... បរិក្ខយាយ... បហានាយ... ខយាយ... វយាយ... វិរាគាយ... និរោធាយ... ចាគាយ... បដិនិស្សគ្គាយ ។ ឥមេ ទ្វេ ធម្មា ភាវេតព្វាតិ ។

(៦៣៩) ទោសស្ស... មោហស្ស... កោធស្ស... ឧបនាហស្ស... មក្ខស្ស... បឡាសស្ស... ឥស្សាយ... មច្ឆរិយស្ស... មាយាយ... សាឋេយ្យស្ស... ថម្ភស្ស... សារម្ភស្ស... មានស្ស... អតិមានស្ស... មទស្ស... បមាទស្ស... អភិញ្ញាយ... បរិញ្ញាយ... បរិក្ខយាយ... បហានាយ... ខយាយ... វយាយ... វិរាគាយ... និរោធាយ... ចាគាយ... បដិនិស្សគ្គាយ... ឥមេ ទ្វេ ធម្មា ភាវេតព្វាតិ ។

ទុកនិបាតោ សមត្តោ ។



(៦៣៨) ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយពីរយ៉ាង ដែលបុគ្គលគប្បីចំរើន ដើម្បីដឹងច្បាស់នូវរាគៈ ។ ធម៌ទាំងពីរយ៉ាង តើដូចម្តេច គឺសមថៈ ១ វិបស្សនា ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ពីរយ៉ាងនេះ ដែលបុគ្គលគប្បីចំរើន ដើម្បីដឹងច្បាស់នូវរាគៈ ។ ម្នាលភិក្ខុទាំងឡាយ ដើម្បីកំណត់ដឹងនូវរាគៈ... ដើម្បីធ្វើឲ្យអស់ទៅ... ដើម្បីលះបង់... ដើម្បីធ្វើឲ្យសាបសូន្យ... ដើម្បីធ្វើឲ្យវិនាស... ដើម្បីនឿយណាយ... ដើម្បីរលត់ទៅ... ដើម្បីបញ្ចុះបង់... ដើម្បីរលាស់ចោល (នូវរាគៈ) ។ ធម៌ពីរយ៉ាងនេះ ដែលបុគ្គលគប្បីចំរើន ។

(៦៣៩) ធម៌ពីរយ៉ាងនេះ បុគ្គលគប្បីចំរើន ដើម្បីដឹងច្បាស់... ដើម្បីកំណត់ដឹង... ដើម្បីអស់ទៅ... ដើម្បីលះបង់... ដើម្បីសាបសូន្យ... ដើម្បីវិនាស... ដើម្បីនឿយណាយ... ដើម្បីរលត់ទៅ... ដើម្បីបញ្ចុះបង់... ដើម្បីរលាស់ចោលនូវទោសៈ... នូវមោហៈ... នូវសេចក្តីក្រោធ... នូវគំនុំ... នូវសេចក្តីលុបគុណ... នូវការលើកកំពស់... នូវឫស្យា... នូវកំណាញ់... នូវការពុតត្បុត... នូវសេចក្តីអួតអាង... នូវសេចក្តីរឹងត្អឹង... នូវការប្រណាំងប្រជែង... នូវមានះ... នូវសេចក្តីមើលងាយ... នូវសេចក្តីស្រវឹង... នូវសេចក្តីប្រមាទ... ។

ចប់ ទុកនិបាត ។

# វិរុទ្ធាវិរុទ្ធបទ

| វិរុទ្ធគាថា | អវិរុទ្ធគាថា | អង្គ | វគ្គលេខគាថា |
|---|---|---|---|
| លលិត | លុលិត | ១៧ | ៣ |
| សិង្ឃសម្មគម្បី | សិង្ឃីសម្មុគម្បី | ,, | ១៤ |
| ដំ | យំ ដំ | ១៤ | ,, |
| ឯកជម្ពូ | ឯកជម្ពូបិ | ២៤ | ៨ |
| ខរោ | ខសោ | ៣៨ | ១ |
| មេត្តាវិហារិន | មេត្តាវិហារីនិ | ៨៧ | ១៨ |
| ឈាយីន | ឈាយីនិ | ,, | ១២ |
| វិស្សាសកន្ធ | វិស្សាសិកន្ធ | ៨៨ | ២ |
| ឋបមោ វគ្គោ | ទុតិយោ វគ្គោ | ២៨ | ០ |
| ,, | ,, | ៧០ | ,, |
| ,, | ,, | ៧៣ | ,, |
| ,, | តតិយោ វគ្គោ | ៧៨ | ,, |
| មោឃបុរិសោ | មត្តេយ្យ មោឃបុរិសោ | ៧២ | ១២ |
| បឋមោ វគ្គោ | តតិយោ វគ្គោ | ៧៧ | ១ |
| ,, | ,, | ៧៩ | ,, |

# វិរុទ្ធាវិរុទ្ធបត្ត

| វិរុទ្ធបាឋ | អវិរុទ្ធបាឋ | អង្គ | បន្ទាត់លេខ |
|---|---|---|---|
| បញ្ញាតលំ កាលេ... | បញ្ញាតលំ កាលេ | ៩៤ | ៤ |
| អនុបុព្វាបរិក្ខាយ | អនុបុព្វាបរិក្ខាយ | ៩៨ | ៣ |
| គហបតកំបំ | គហបតណកំបំ | ១០៨ | ៧ |
| ទុក្ខេកិ បទ | ទុក្ខេកិ បទំ | ១០៩ | ១៨ |
| ទើទុក្ខាវេស្ស | ទើទុក្ខាវិគស្ស | ១០៧ | ១៦ |
| គន្ធមគោ | អនន្ធមគោ | ១៥៥ | ៦ |
| ឯមន្ទ | ឯកមន្ទំ | ១៥៣ | ៨ |
| អញ្ញក | អញ្ញតក | ១៣៤ | ៧ |
| អត្ថិក្ខាកាយស្ស | អត្ថិក្ខាមិកាយស្ស | ១៤៥ | ១ |
| សមត្ថកក្ដា | សមត្ថកក្ដាតិ | ១៤៨ | ១៤ |
| វេស្សសតិ គោ | វេស្សសតិគោ | ១៥១ | ១៣ |
| ខ ដេរ ភ្ញៃ | ខ ដេរ ភ្ញៃ | ១៥៦ | ១៧ |
| យស៍ | យស្សំ | ១៩១ | ៩ |
| វេយ៉ោបុណ្ណកា | បរិយោបុណ្ណកា | ១៩៣ | ១៩ |
| ភិត | ភិត | ១៩៤ | ១៣ |



# វិរុទ្ធាវិរុទ្ធបត្ត

| វិរុទ្ធបាឋ | អវិរុទ្ធបាឋ | អង្គ | បន្ទាត់លេខ |
|---|---|---|---|
| កាយសក្ខី | កាយសក្ខី | ១៦៨ | ៦ |
| " | " | ១៦៩ | ៩ |
| ភិក្ខុ | ភិក្ខុ | ១៧៦ | ១៩ |
| សន្តិកសន្តិ | សន្តិកេសន្តិ | ១៧៤ | ១០ |
| វិហារេសយ ំបិ | វិហារេសយ្យំបិ | ១៧៨ | ៨ |
| បរស្សមស្ស | បរស្សមិស្ស | " | " |
| វិហារេសយ្យបិ | វិហារេសយ្យំបិ | " | ១៦ |
| សន្តិកសន្តិ | សន្តិកេសន្តិ | ១៧៩ | ៨ |
| " | " | " | ៩ |
| វរយស្ស | វរយស្សំ | " | ១០ |
| ចំ វរយស្ស | ចំ វរយស្ស... | ១៧៧ | ១០ |
| សន្តិកសន្តិ | សន្តិកេសន្តិ | " | ១៨ |
| អបរទ្ធយោ | អប្បរទ្ធយោ | ១៧៨ | ៤ |
| សព្វិតិការម្មណាញ្ញ | សព្វិតិការម្មណាញ្ញ សុទ្ធ | ១៨៦ | ៤ |
| ឧត្ត គោ | ឧត្ត ន | ១៨៤ | ១៩ |

## វិគ្គាវិគ្គបត្ត

| វិគ្គហាហ៍ | អវិគ្គហាហ៍ | អង្កេត | ខ្សែលេខាយ៉ំ |
|---|---|---|---|
| ទំនំ | ទំនំ គាសប់ | ១៨៧ | ៨ |
| គត្ថវិជ្ជា | គតន្ទវិជ្ជា | ៦០១ | ១៧ |
| គនវិជ្ជា | គនវិជ្ជា ២ | ៦០៤ | ៨ |
| គត្តិតវិតកាយស្ស | គត្ថិតវិតកាយស្ស | ៦០៦ | ១ |
| គត្តិវិតកាយស្ស | " | ៦៦០ | " |



## សន្លឹកប្រាប់ពាក្យខុស-ត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| ស្ទូរ្យ | ស្ទូរ្យ៉ | ១៨ | ១៦ |
| សោរស្បូយ | សោរស្បើយ | ៤៦ | ៧ |
| ព្រះវេទ្ធម្មស្បូយ | ព្រះវេទ្ធម្មស្បើយ | ៣៨ | ១៦ |
| ៗ ១ ៗ | ៗ ២ ៗ | ៤១ | ៣ |
| បរិស័ទធ្យោយ | បរិស័ទយើយ | ៨៧ | ៦ |
| អដ្ឋខាលី | អដ្ឋខាលិ | ៤០ | ៤ |
| ត្រួតរឹង | ត្រួតរឹង | " | ១៦ |
| នីយ៉ាយ៉ាលោកុទ្ទ | នីយ៉ាលោកុទ្ទ | ៦៣ | ១៦ |
| វគ្គទី ១ | វគ្គទី ៤ | ៦៨ | ១ |
| " | " | ៧១ | " |
| " | " | ៧៣ | " |
| " | វគ្គទី ៣ | ៧៨ | " |
| " | " | ៧៧ | " |
| " | " | ៧៨ | " |

## សន្លឹកប្រាប់ពាក្យខុស-ត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| បុគ្គលទាំ មាន | បុគ្គលមិនមាន | ៤១ | ១០ |
| ថ្ងុះ | ផ្ទុះ ១ | ១០៦ | ៧ |
| កយាបនកម្ម | ករោបណកម្ម | ១០៨ | ១៤ |
| ប៉ុនគបកបនៈ | ប៉ុនគបោះបណៈ | " | ១៣ |
| ក័ម្ពុះ | គីអ្នុះ | ១១៦ | ៨ |
| ព្រោះកិច្ច | ព្រោះកិច្ច | ១៦១ | ១២ |
| ដឹក | ដឹក | ១៦៦ | ១១ |
| អស់ទៅ | អស់ទៅ | ១៦៣ | ៧ |
| គ្នាក | គ្មានខ | ១៩០ | ១៦ |
| ខ្លីក្លិប | ខ្លីក្លិម | ១៩០ | ១៤ |
| ដើម្ប | ដើម្បី | ១៩៩ | ១៣ |
| ប្រូប | សម្រេច | " | ១៥ |
| កាយសក្ដិ | កាយសក្ដិ | ១៦៩ | ៤ |
| " | " | ១៦៦ | ៨ |



## សន្លឹកប្រាប់ពាក្យខុស-ត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| ចរម្រិតល់ | ចម្រើនផល់ | ១៧១ | ៦ |
| តាន់ឡាយ | តាំងឡាយ | " | ១០ |
| កិច្ចរ | កិច្ចរ | ១៧៣ | ១៦ |
| ក្រោតគរ | ក្រោកគរ | ១៨៦ | ១៦ |
| ទាំការៈ | ទទួលការៈ | ១៩៩ | ១៧ |
| មិនទាំការៈ | មិនទទួលការៈ | " | ១៧ |
| ពម្មរគនៈ | ធម្មគុណៈ ១ | ២០១ | ៨ |
| ម្ចាត | ម្ចាស | ២០៦ | ៩ |

# សុត្តន្តបិដកេ

## អង្គុត្តរនិកាយស្ស ឯកនិបាតោ

### បឋមោ ភាគោ

មាតិកា | អង្កេ

#### ឯកធម្មាទិបាឡិ


ឯកធម្មាទិបាឡិយំ បឋមោ វគ្គោ ........................ ១
ទុតិយោ វគ្គោ ........................ ៦
តតិយោ វគ្គោ ........................ ៨
ចតុត្ថោ វគ្គោ ........................ ១២
បញ្ចមោ វគ្គោ ........................ ១៤
ឆដ្ឋោ វគ្គោ ........................ ១៩
សត្តមោ វគ្គោ ........................ ២២
អដ្ឋមោ វគ្គោ ........................ ២៦
នវមោ វគ្គោ ........................ ៣០
ទសមោ វគ្គោ ........................ ៣៤
ឯកាទសមោ វគ្គោ ........................ ៤៣


# សុត្តន្តបិដក

## អង្គុត្តរនិកាយ ឯកនិបាត

### បឋមភាគ

មាតិកា | លេខទំព័រ

#### បាលីសំដែងនូវធម៌ក្នុងមួយៗជាដើម


បាលីពួកធម៌មួយៗជាដើម វគ្គទី ១ ........................ ១
វគ្គទី ២ ........................ ៦
វគ្គទី ៣ ........................ ៨
វគ្គទី ៤ ........................ ១២
វគ្គទី ៥ ........................ ១៤
វគ្គទី ៦ ........................ ១៩
វគ្គទី ៧ ........................ ២២
វគ្គទី ៨ ........................ ២៦
វគ្គទី ៩ ........................ ៣០
វគ្គទី ១០ ........................ ៣៤
វគ្គទី ១១ ........................ ៤៣

# សន្លឹកបង្គុលប្រាប់មាតិកា


| មាតិកា | | លេខទំព័រ |
|---|---|---|
| បាលិត្តកនិមួយៗ ជាដើម វគ្គទី១៦ | | ៦៦ |


## ឯកបុគ្គលបាលិ


| | | |
|---|---|---|
| ឯកបុគ្គលបាលិ | បុគ្គលវគ្គ | ៨៤ |


## ឯតទគ្គបាលិ


| | | |
|---|---|---|
| ឯតទគ្គបាលិ | វគ្គទី១ | ៨៣ |
| | វគ្គទី២ | " |
| | វគ្គទី៣ | ៨៥ |
| | វគ្គទី៤ | ៨៨ |
| | វគ្គទី៥ | " |
| | វគ្គទី៦ | ៨៦ |
| | វគ្គទី៧ | ៨៧ |


## អដ្ឋានបាលិ


| | | |
|---|---|---|
| អដ្ឋានបាលិ | វគ្គទី១ | ៨៨ |
| | វគ្គទី២ | ៦៦ |
| | វគ្គទី៣ | ៦៨ |




# មាតិកាបត្តាទី


| មាតិកា | | អង្ក |
|---|---|---|
| ឯកធម្មាទិបាលិយំ | ចុទ្ទសមោ វគ្គោ | ៦៦ |


## ឯកបុគ្គលបាលិ


| | | |
|---|---|---|
| ឯកបុគ្គលបាលិយំ | បុគ្គលវគ្គោ | ៦៤ |


## ឯតទគ្គបាលិ


| | | |
|---|---|---|
| ឯតទគ្គបាលិយំ | បឋមោ វគ្គោ | ៨៣ |
| | ទុតិយោ វគ្គោ | " |
| | តតិយោ វគ្គោ | ៨៥ |
| | ចតុត្ថោ វគ្គោ | ៨៨ |
| | បញ្ចមោ វគ្គោ | " |
| | ឆដ្ឋោ វគ្គោ | ៨៦ |
| | សត្តមោ វគ្គោ | ៨៧ |


## អដ្ឋានបាលិ


| | | |
|---|---|---|
| អដ្ឋានបាលិយំ | បឋមោ វគ្គោ | ៨៨ |
| | ទុតិយោ វគ្គោ | ៦៦ |
| | តតិយោ វគ្គោ | ៦៨ |

## សន្លឹកបង្ហាញប្រាប់មាតិកា


មាតិកា — លេខទំព័រ

### ឯកធម្មាទិបាលិ តទៅទៀត

ឯកធម្មាទិបាលិ តទៅទៀត វគ្គ ទី១ .............. ៦៨

វគ្គ ទី២ .............. ៦៩

វគ្គ ទី៣ .............. ៧៥

វគ្គ ទី៤ .............. ៨០

### បសាទករធម្មាទិបាលិ

បសាទករធម្មាទិបាលិ .............................. ៨៧




## មាតិកាបទានិ


មាតិកា — អង្កេ

### អបរា ឯកធម្មាទិបាលិ

អបរស្មឹ ឯកធម្មាទិបាលិយំ បឋមោ វគ្គោ .............. ៦៨

ទុតិយោ វគ្គោ .............. ៦៩

តតិយោ វគ្គោ .............. ៧៥

ចតុត្ថោ វគ្គោ .............. ៨០

### បសាទករធម្មាទិបាលិ

បសាទករធម្មាទិបាលិយំ .............................. ៨៧

# សុត្តន្តបិដក

## អង្គុត្តរនិកាយ ទុកនិបាត

## បឋមបណ្ណាសក

មាតិកា ... លេខទំព័រ


បឋមបណ្ណាសក កម្មករណវគ្គ ទី១ .............. ១០៤

អធិករណវគ្គ ទី២ .............. ១១៤

ពាលវគ្គ ទី៣ .............. ១៣១

សមចិត្តវគ្គ ទី៤ .............. ១៣៦

បរិសវគ្គ ទី៥ .............. ១៤៦


## ទុតិយបណ្ណាសក


ទុតិយបណ្ណាសក បុគ្គលវគ្គ ទី១ .............. ១៧០

សុខវគ្គ ទី២ .............. ១៧៨

សនិមិត្តវគ្គ ទី៣ .............. ១៨៣

ធម្មវគ្គ ទី៤ .............. ១៨៦

ពាលវគ្គ ទី៥ .............. ១៨៨


## តតិយបណ្ណាសក


តតិយបណ្ណាសក អាសាវគ្គ ទី១ .............. ១៩៤

អាយាចនវគ្គ ទី២ .............. ១៩៨


# សុត្តន្តបិដកេ

## អង្គុត្តរនិកាយស្ស ទុកនិបាតោ

## បឋមបណ្ណាសកោ

មាតិកា ... អង្កេ


បឋមបណ្ណាសកេ បឋមោ កម្មករណវគ្គោ.............. ១០៤

ទុតិយោ អធិករណវគ្គោ.............. ១១៤

តតិយោ ពាលវគ្គោ.............. ១៣១

ចតុត្ថោ សមចិត្តវគ្គោ.............. ១៣៦

បញ្ចមោ បរិសវគ្គោ.............. ១៤៦


## ទុតិយបណ្ណាសកោ


ទុតិយបណ្ណាសកេ បឋមោ បុគ្គលវគ្គោ.............. ១៧០

ទុតិយោ សុខវគ្គោ.............. ១៧៨

តតិយោ សនិមិត្តវគ្គោ.............. ១៨៣

ចតុត្ថោ ធម្មវគ្គោ.............. ១៨៦

បញ្ចមោ ពាលវគ្គោ.............. ១៨៨


## តតិយបណ្ណាសកោ


តតិយបណ្ណាសកេ បឋមោ អាសាវគ្គោ.............. ១៩៤

ទុតិយោ អាយាចនវគ្គោ.............. ១៩៨

## សន្លឹកបង្គុលប្រាប់មាតិកា

មាតិកា លេខទំព័រ

តតិយបណ្ណាសក ធាតុវគ្គ ទី ៣ .................... ៦០៨

សច្ចវគ្គ ទី ៤ .................... ៦០៨

សមាបត្តិវគ្គទី ៥ .................... ៦១៦

សូត្រដែលមិនបានសង្គ្រោះក្នុងបណ្ណាសក

ពួកសូត្រមិនបានសង្គ្រោះក្នុងបណ្ណាសក .............. ៦១៦



## មាតិកាបត្តានិ

មាតិកា អង្កេ

តតិយបណ្ណាសកេ តតិយោ ធាតុវគ្គោ................ ៦០៨

ចតុត្ថោ សច្ចវគ្គោ................ ៦០៨

បញ្ចមោ សមាបត្តិវគ្គោ................ ៦១៦

បណ្ណាសកាសង្គហិតា សុត្តា

បណ្ណាសកាសង្គហិតា សុត្តា..................... ៦១៦

សុត្តន្តបិដក

អង្គុត្តរនិកាយ ឯក·ទុកនិបាត

បឋមភាគ

៤០

ព.ស ២៤៩៦

# 「トリピタカ」復刻進呈にあたって

親愛なるカンボジアの皆さん！
敬愛するカンボジアの仏教徒の皆さん！

カンボジア版『トリピタカ』は、プノンペンの仏教研究所が、仏教界の英知を集め、1930年から1968年まで、39年の歳月をかけて翻訳し、分類し、集大成して完成されました。まさにカンボジア仏教の宝であると共に、カンボジア出版文化の至宝です。日本仏教徒の有志は、カンボジア仏教の復興再生を願いつつ、これを復刻し、贈らせていただきます。

これはカンボジア仏教徒のみならず、カンボジア全国民、否、平和を愛する地球上のすべての人々への、心からの贈り物です。

カンボジアは、古今未曾有の悲劇を体験しました。カンボジア仏教もこの受難の時代に壊滅的な打撃を受けました。しかし、今はその悲しみを乗りこえ、憤りを鎮め、怨みを赦し、ブッダの教えに従い、世界平和の実現に努力するときです。

この本の贈呈は、日本の仏教徒も共々に、世界平和のために努力することを誓うしるしであり、相互の連帯と友情の証なのです。

合掌

1994年7月吉日

カンボジア版トリピタカ（南伝大蔵経）復刻救援委員会

| | | | | | | |
|---|---|---|---|---|---|---|
| 世話人代表 | 無着 | 成恭 | 世話人 | 松永 然道 | 有馬 実成 |
| 事務局長 | 篠原 | 鋭一 | | 伊藤 佳通 | 渡井 圭一 |
| | | | | 杉谷 義純 | 茂田 真澄 |
| | | | | 前田 利勝 | 中島 教之 |
| | | | | 永 六輔 | |

# Acknowledgment

Dear Cambodian friends and respected members of the Cambodian Buddhist community,

It is a matter of great joy that the translation into Cambodian of the Pali Tripitaka has been completed and published. The Tripitaka Commission of the Buddhist Institute, Phnom Penh, launched the translation project in 1930 and completed the translation, after 39 years of effort, in 1968.

The Cambodian translation of this great work will not only become a cherished treasure of the Cambodian Buddhist community but will also be an important milestone in the history of publication in Cambodia.

The revival and prosperity of Buddhism in Cambodia are the ardent wish of the Japanese Buddhist community. It is in this spirit that we have completed this important project and now present the entire work to the Cambodian Buddhist community. It is a gift not only to the Buddhist community in Cambodia but also to all Cambodian people and all peace loving people in the world.

Cambodia experienced great tragedies in modern times, and the Cambodian Buddhist community also underwent severe trials and suffered crushing blows during this period. But now a time has come to surmount grief and anger, to forgive, and to start working again for world peace.

This great work is a symbol of the Japanese Buddhist community's resolve to work with our Cambodian brothers and sisters toward world peace and is a testimony to the friendship between our people.

With hands joined in reverence.
July 1994

**TRIPITAKA PUBLISHING SUPPORT COMMITTEE**
Project Manager : The Rev. Seikyo Muchaku
Secretary General : The Rev. Eiitsu Shinohara
Management Team :
The Rev. Zendo Matsunaga The Rev. Jitsujo Arima The Rev. Yoshimichi Ito
The Rev. Keiichi Watai The Rev. Gijun Sugitani The Rev. Shincho Shigeta
The Rev. Risho Maeda The Rev. Kyoshi Nakajima Mr. Rokusuke Ei

សៀវភៅនេះ ត្រូវបានបោះពុម្ពឡើងវិញ ដោយការឧបត្ថម្ភពី
អ្នកមានព្រះនាមនេះ :

Printing costs were met through the gift of

Wat. Sotoshu Ryutokuji Temple
The Rev. Wajou Shouji
96 Azakawaminamimachiura, Wakayanagicho, Kurihara-gun, Miyagi-ken
989-55 Japan
Wat. Sotoshu Enpukuji Temple
The Rev. Houyuu Mitamura
61 Ishiharaka, Wakabayashi ku, Sendai-shi, Miyagi-ken 980 Japan

この本は次の方によって後見されました。

曹洞宗 龍徳寺 住職 荘司和成
〒989-55 宮城県栗原郡若柳町字川南町浦96
☎0228-32-2171
曹洞宗 円福寺 住職 三田村鳳雄
〒980 宮城県仙台市若林区石名坂61
☎022-222-91[illegible]

ព្រះត្រៃបិដក ភាគទី ១១០ " អភិធម្មបិដក "
ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ
ការបោះពុម្ពជាថ្មីឡើងវិញ របស់សមាគមជំនួយដល់ការបោះពុម្ពព្រះត្រៃបិដកឡើងវិញ
បោះពុម្ព ថ្ងៃទី ០៨ កក្កដា ឆ្នាំ ១៩៩៤
សហប្រតិបត្តិការរៀបរៀង និងបោះពុម្ពនៅប្រទេសជប៉ុន

TRIPITAKA VOL. 40 (of 110 volumes total)
"SUTTANTA PITAKA"
Published by the Buddhist Institute, Phnom Penh
Reproduced with the kind cooperation of the
TRIPITAKA PUBLISHING COMMITTEE
First edition December 8, 1994
Printed in Japan by Hirosaki Sogo Printing Ltd.

トリピタカ（南伝大蔵経）全110巻・第40巻スッタンタピタカ（経部）
発　行：プノンペン仏教研究所
復刻発行：カンボジア版トリピタカ（南伝大蔵経）復刻発行委員会
発　行：1994年12月8日
印刷・製本／弘前相互印刷株式会社
製作にあたり弘前相互印刷株式会社の多大な協力を得ました。